# ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧

# ទូតកូរ៉េថា នឹងខិតខំជំរុញរដ្ឋាភិបាលកូរ៉េ បង្កើនចំនួនកូតាពលករខ្មែរ ឲ្យបានកាន់តែច្រើនថែមទៀត

http://www.cen.com.kh/archives/ December 1, 2017

ភ្នំពេញ៖ ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េ បាន អះអាងថា នឹងខិតខំជំរុញរដ្ឋាភិបាលកូរ៉េ បង្កើនចំនួនកូតាពលករខ្មែរ ឲ្យបានកាន់តែច្រើនថែមទៀត ខណៈពេលនេះ មានពលរដ្ឋខ្មែរជាង ៤៥០០០នាក់ កំពុងធ្វើការនៅសាធារណរដ្ឋកូរ៉េ។

នៅព្រឹកថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានអនុញ្ញាតឲ្យលោក គីម វុនជិន ( Kim Weon-Jin) ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េ ដែលនឹងត្រូវចប់ អាណត្តិការទូតនៅកម្ពុជាចូលជួបសម្តែងការគួរសមនិងជំរាបលារនៅវិមានរដ្ឋសភា។ លោក គីម វុនជិន បាន លើកឡើងថា ការបង្កើតវិទ្យាស្ថានចលនាភូមិថ្មី បណ្តុះបណ្តាលកសិកម្ម នៅក្នុងខេត្តកំពង់ស្ពឺ ជាផ្នែកសំខាន់ដែលនិងអាចជំរុញប្រាក់ចំណូលរបស់កសិករ ពីព្រោះការបណ្តុះបណ្តាលនៅទីនោះ នឹងធ្វើឲ្យវិស័យកសិកម្មមានការរីកចម្រើន។

ជាមួយគ្នានេះ លោកទូត ក៏បានលើកឡើងថា ពលរដ្ឋខ្មែរ ដែលបានចេញទៅធ្វើការនៅប្រទេសកូរ៉េ បានផ្តល់ប្រាក់ចំណូលមកកម្ពុជាផងដែរ។ រហូតមកដល់ពេលនេះ មានពលរដ្ឋខ្មែរប្រមាណជាង ៤៥ ០០០នាក់ កំពុងធ្វើការនៅសាធារណរដ្ឋកូរ៉េ។ លោក ឯកអគ្គរដ្ឋទូត អះអាងថា "នឹងខិតខំជំរុញរដ្ឋាភិបាលកូរ៉េ ក្នុងការបង្កើនចំនួនកូតាពលករខ្មែរ ឲ្យបានកាន់តែច្រើនថែមទៀត"។

ចំពោះ វិស័យទេសចរណ៍វិញ លោក គីម វុនជិន បានលើកឡើងថា កម្ពុជាមិនមែនមានតែប្រាសាទអង្គរវត្តនោះទេ កម្ពុជាមានប្រាសាទរាប់រយ នៅទូទាំងប្រទេស ដូចជា ប្រាសាទសំបូរព្រៃគុក នៅខេត្តកំពង់ធំ ដែលទើបត្រូវបានការអង្គការយូណេស្កូ ដាក់បញ្ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោក កាលពីពេលថ្មីៗនេះសុទ្ធសឹងជាសក្តានុពលក្នុងការទាក់ទាញភ្ញៀវទេសចរ។ ប្រជាជនកូរ៉េ បានស្ថិតនៅក្នុងចំនួនច្រើន នៃអ្នកទេសចរបរទេស ដែលបានមកទស្សនាកម្ពុជា ហើយកូរ៉េបានបង្កើតអគ្គកុងស៊ុលរបស់ខ្លួន នៅទីក្រុងសៀមរាបរួចហើយ។

ក្នុងនាមរដ្ឋសភាកម្ពុជា សម្តេចអគ្គមហាពញាចក្រី ហេង សំរិន បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែង ក្នុងអាណត្តិការទូតរបស់ លោក គីម វុនជិន ថាពិតជាបានរួមចំណែកដ៏ធំធេង សំដៅបន្តពូនជ្រុំលើកកម្ពស់ទំនាក់ទំនង មិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រជាជនយើងទាំងពីរ កម្ពុជា-កូរ៉េ មានការរីកចម្រើនជាបន្តបន្ទាប់ ។

សម្តេចប្រធានរដ្ឋសភា បានលើកឡើងថា រដ្ឋសភាកម្ពុជា បានសង្កេតឃើញ ដោយពេញចិត្ត ក្នុងរយៈពេល ២០ឆ្នាំ នៃការភ្ជាប់ទំនាក់ទំនងការទូតឡើងវិញ រវាងប្រទេសយើងទាំងពីរ កម្ពុជា-កូរ៉េ ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគី មានការវិវឌ្ឍន៍ រីកចម្រើនយ៉ាងឆាប់រហ័ស ទាំងវិស័យនយោបាយការទូត សេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ អប់រំ វប្បធម៌ និងទេសចរណ៍ បានប្រែក្លាយទៅជាទំនាក់ទំនង "ភាពជាដៃគូយុទ្ធសាស្ត្រ" ដែលបង្កើតបានជាសមិទ្ធិផលជាក់ស្តែងយ៉ាងច្រើន ដើម្បីឧត្តមប្រយោជន៍ជាតិទាំងសងខាង ជាពិសេសបានរួមចំណែកដល់ការអភិវឌ្ឍរបស់កម្ពុជា។

ទោះជាត្រូវទៅបំពេញបេសកកម្មនៅប្រទេសផ្សេងពីកម្ពុជា ក៏ លោក គីម វុនដិន បានជម្រាប សម្តេចប្រធានរដ្ឋសភាថា នឹងខិតខំជំរុញ កិច្ចសហប្រតិបត្តិរវាងសភាកម្ពុជានិងកូរ៉េ ឲ្យរឹងមាំឡើង ពិសេសឲ្យមានការផ្លាស់ប្តូរដំណើរទេស្សនកិច្ចគ្នាបានច្រើនថែមទៀត៕ ដោយៈបញ្ញាស័ក្តិ

## ខ្មែររបួស 10នាក់ ថៃស្លាប់1នាក់ ក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចររថយន្តបុកគ្នា

http://www.pheaktraprak.com/ December 1, 2017

កាលពីថ្ងៃព្រហស្បតិ៍ ទី30 ខែវិច្ឆិកា ឆ្នាំ2017 ម្សិលមិញនេះមានករណីគ្រោះថ្នាក់ចរាចររវាងរថយន្តដឹកកម្មករខ្មែរបុកនិងរថយន្តបើកបញ្ច្រាសទិសគ្នាគ្រឿងទៀតបណ្តាលឲ្យកម្មករខ្មែរប្រមាណជាង10 នាក់រងរបួសនិងតៃកុងរថយន្តម្នាក់បានស្លាប់។ ហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍រថយន្តបុកគ្នានេះបានកើតឡើងនៅវេលាម៉ោង11:10 នាទីស្ថិតនៅត្រង់ចំណុចផ្លូវកោង ក្បែរចំការក្រូច មុនដល់កុងត្រូលត្រួតពិនិត្យ ស្រុកសយដាវ ខេត្តចាន់បុរី។ ប្រភពពីកន្លែងកើតហេតុបានឲ្យដឹងថារថយន្តម៉ាកToyota vigos ពណ៌ខ្មៅមួយគ្រឿង បានជ្រុលទៅបុកជាមួយរថយន្តម៉ាកToyota vigos ពណ៌ទឹកប្រាក់ មួយគ្រឿងទៀតយ៉ាងពេញទំហឹងបណ្តាលឲ្យ អ្នករថយន្តvigos ពណ៌ខ្មៅស្លាប់ភ្លាមៗនៅនិងកន្លែងហេតុ និងកម្មករខ្មែរប្រមាណជាង10 នាក់ដែលជិះលើរថយន្តទាំងពីរទៅធ្វើការបេះផ្លែឈើបានរងរបួសធ្ងន់និងស្រាល។

## អាជ្ញាធរថៃ បង្ក្រាបពលករចំណាកស្រុកខុសច្បាប់ចំនួន 42នាក់

http://www.pheaktraprak.com/ December 1, 2017

កាលពីថ្ងៃព្រហស្បតិ៍ ទី30 ខែវិច្ឆិកា ឆ្នាំ2017 កម្លាំងអាជ្ញាធរថៃប្រចាំខេត្តសង់ក្លា ប្រទេសថៃបានធ្វើការចុះឃាត់ខ្លួនពលករចំណាកខុសច្បាប់ចំនួន42នាក់ នៅក្នុងព្រៃកៅស៊ូមួយកន្លែងស្ថិតនៅខេត្តសង់ក្លា។ ហេតុការណ៍ឃាត់ពលករចំណាកខុសច្បាប់នេះបានកើតឡើងនៅភូមិ9 ឃុំណំម៉ៃថៃ ស្រុកចាក់ណាក់ ខេត្តសង់ក្លា ក្នុងកិច្ចព្រឹត្តិបត្រការណ៍នេះសមត្ថកិច្ចថៃឃាត់ខ្លួនបានពលករខុសច្បាប់ប្រុសស្រីសញ្ជាតិមីយ៉ាន់ម៉ាចំនួន42នាក់ ខណៈពេលកំពុងលាក់ខ្លួននៅក្នុងចំការកៅស៊ូរបស់ពលរដ្ឋថៃ។ ប្រភពពីពលករភូមាម្នាក់ក្នុងចំណោម42នាក់ បានសារភាពប្រាប់សមត្ថកិច្ចថៃបានឲ្យដឹងថាពួកគេទាំងគ្នា បានធ្វើដំណើរឆ្លងដែនខុសច្បាប់ចូលប្រទេសថៃតាមរយៈខេត្តរ៉ាក់ណងដើម្បីស្វែងរកការងារតាមរោងចក្រធ្វើ តែក៏ត្រូវសម្ថកិច្ចថៃចុះមកចាប់ខ្លួនមុន បច្ចុប្បន្នពលករភូមាខុសច្បាប់ទាំងអស់ត្រូវសមត្ថកិច្ចថៃធ្វើការចោទប្រកាន់ពីបទឆ្លងដែនខុសច្បាប់ដោយគ្មានលិខិតអនុញ្ញាត និងកសាងសំណុំរឿងបញ្ជូនទៅតុលាការដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## ចាប់ផ្តើមហើយ យុទ្ធនាការចុះត្រួតពិនិត្យឯកសារពលករចំណាកស្រុកខុសច្បាប់

http://www.pheaktraprak.com/ November 30, 2017

កាលពីថ្ងៃព្រហស្បតិ៍ ទី30 ខែវិច្ឆិកា ឆ្នាំ2017នេះ កម្លាំងអាជ្ញាធរមូលដ្ឋានស្រុកបានផែវ ខេត្តណាខនប៉ាធុមប្រទេសថៃ បានដឹកនាំកម្លាំងអាជ្ញាធមូលដ្ឋានប្រមាណ50នាក់ ចុះត្រួតពិនិត្យឯកសារធ្វើការរបស់ពលករបរទេសដែលកំពុងធ្វើការនៅ តាមរោងចក្រ សហគ្រាសនាក្នុងខេត្តណាខនប៉ាធុមប្រទេសថៃ ដើម្បីទប់ស្កាត់ពលករចំណាកស្រុកខុសច្បាប់។ ប្រភពពីលោកអភិបាលស្រុកបានផែវ បានមានប្រសាសន៍ថា កិច្ចព្រឹត្តិបត្រការណ៍ចុះត្រួតពិនិត្យឯកសារ

ពលករបរទេសលើកនេះ គឺដើម្បីស្រង់ស្ថិតិរបស់ពលករដែលមិនបានត្រួតសញ្ជាតិ និងទប់ស្កាត់ពលករខុសច្បាប់ ដែលគ្មានលិខិតអនុញ្ញាតធ្វើការ ដែលកំពុងលាក់ខ្លួនធ្វើការនៅតាមរោងចក្រសហគ្រាសចំនួន ដើម្បីជំរុញឲ្យពួកគេវិលត្រឡប់ទៅស្រុកកំណើតវិញ និងចូលមកធ្វើការវិញតាមរយៈMOUដែលរាជរដ្ឋាភិបាលថៃនិងកម្ពុជាចុះកិច្ចព្រមព្រៀងជាមួយគ្នានាពេលកន្លងមក។

## អតីតមេតម្រួតថៃ ឡើងកាន់តំណែងជារដ្ឋមន្ត្រីក្រសួងការងារថ្មី

http://www.pheaktraprak.com November 30, 2017

កាលពីវេលាម៉ោង06:25នាទី ព្រលប់ថ្ងៃព្រហស្បតិ៍ទី30 ខែវិច្ឆិកា ឆ្នាំ2017នេះ លោកAdul Saengsingkaew រដ្ឋមន្ត្រីក្រសួងការងារថៃថ្មី ប្រារព្ធពិធីថ្វាយកម្រងផ្កា ដល់ព្រះពុទ្ធរូបនៅមុខក្រសួងការងារ បន្ទាប់ពីបានឡើងកាន់តំណែងជារដ្ឋមន្ត្រីក្រសួងការងារថ្មី ជំនួសលោកSirichai Duttakul រដ្ឋមន្ត្រីក្រសួងការងារចាស់។ អតីតលោកAdul Saengsingkaew លោកជាអគ្គស្នងការតម្រួតថៃនាសម័យរាជរដ្ឋាភិបាលលោកស្រីយីងឡាក់ តែបច្ចុប្បន្ននេះលោកបានទទួលតំណែងជារដ្ឋមន្ត្រីក្រសួងការងារថ្មី ហើយលោកបានសន្យាថានិងខិតខំប្រឹងប្រែងបំពេញការងារដោះស្រាយបញ្ហាពលករចំណាកស្រុកខុសច្បាប់។

## អឺរ៉ុប និងអាហ្វ្រិកសម្រេចបានកិច្ចព្រមព្រៀងដើម្បី បំបាត់ទាសភាពនៅលីប៊ី

http://km.rfi.fr/europe/ ដោយ ឈាង បុប្ផា 30/11/2017

ថ្នាក់ដឹកនាំរបស់ប្រទេសអឺរ៉ុប និងអាហ្វ្រិកចំនួន ៩ បានរកឃើញកិច្ចព្រមព្រៀងអន្តរជាតិមួយ ដើម្បីដោះស្រាយវិបត្តិទាសភាព នៅប្រទេសលីប៊ី។ យោងតាមប្រសាសន៍របស់ប្រធានាធិបតី បារាំង លោកអេម៉ានុយអែល ម៉ាក្រុង ដែលបានចូលរួម នៅក្នុងជំនួបកំពូលអឺរ៉ុប និងអាហ្វ្រិក លើកទី ៥ នៅទីក្រុងអាប៊ីហ្សង់ សហភាពអឺរ៉ុប សហភាពអាហ្វ្រិក និងអង្គការសហប្រជាជាតិ បានសម្រេចព្រមព្រៀងគ្នាថា នឹងរៀបចំបេសកកម្ម មួយ នៅប៉ុន្មានថ្ងៃខាងមុខ ដើម្បី រំដោះ ជម្លៀស ជនអន្តោប្រវេសន៍ ដែលកំពុងធ្លាក់ខ្លួន ធ្វើជាទាសករ នៅក្នុងប្រទេសលីប៊ី។

បិទបញ្ចប់ការជួញដូរទាសករ នៅលីប៊ី នេះជាវិធានការបន្ទាន់ ដែលសហភាពអឺរ៉ុប និងសហភាពអាហ្វ្រិក បានយល់ព្រមព្រៀង ធ្វើរួមគ្នា នៅប៉ុន្មានថ្ងៃខាងមុខ។ នៅក្នុងសន្និសីទកាសែត នៅថ្ងៃម្សិលមិញ ប្រធានាធិបតី បារាំង ដែលជាអ្នកផ្តួចផ្តើមគំនិតឲ្យមានកិច្ចប្រជុំពិសេសស្តីពីទាសភាព នៅលីប៊ី បានលើកឡើងថា ប្រទេសនៅអឺរ៉ុប និងអាហ្វ្រិកចំនួន ៩ បានសម្រេចថា នឹងបើកប្រតិបត្តិការបន្ទាន់មួយ នៅប៉ុន្មានថ្ងៃខាងមុខ ដើម្បី ជម្លៀសចេញ ជនអន្តោប្រវេសន៍ ដែលកំពុងជាប់អន្ទាក់ ធ្លាក់ខ្លួនធ្វើជាទាសករ នៅក្នុងទឹកដីលីប៊ី។

យោងតាមប្រធានាធិបតីបារាំង រដ្ឋាភិបាលលីប៊ីបានយល់ព្រមសហការ ដើម្បី កំណត់ឈ្មោះ ជំរំ ជាទី ដែលជនអន្តោប្រវេសន៍ ត្រូវបានឈ្មួញទុច្ចរិត បោកបញ្ឆោត និងលក់ដូរ ក្នុងទីផ្សារទាសករ។ រូបភាពវីដេអូដែលបង្ហាញពីផ្សារទិញលក់ ទាសករ នាសតវត្សរ៍ ទី ២១ នៅក្នុងទឹកដីលីប៊ី បានបង្កឲ្យមានរលករិះគន់ខ្លាំង ពីសហគមអន្តរជាតិ។ តាមលោកប្រធានាធិបតី បារាំង សហភាពអឺរ៉ុប និងអាហ្វ្រិក នឹងពង្រឹងការសហការ ក្នុងផ្នែកសន្តិសុខ និងព័ត៌មានសម្ងាត់ ដើម្បី គាស់រំលើងបណ្តាញជួញដូរទាសករ នៅលីប៊ី។ ក្រៅតែពីចាប់ខ្លួន និងរឹបអូសទ្រព្យសម្បត្តិរបស់ឈ្មួញជួញដូរមនុស្ស វិធានការបន្ទាប់មកទៀត គឺធ្វើយុទ្ធនាការឃោសនាផ្សព្វផ្សាយ ដើម្បី កុំឲ្យយុវជនអាហ្វ្រិក អាចធ្លាក់ខ្លួន ក្នុងអន្ទាក់ទាសភាពរបស់ឈ្មួញទុច្ចរិត។

មួយវិញទៀត ទៅតាមកិច្ចព្រមព្រៀង នៅថ្ងៃម្សិលមិញ នៅក្រុងអាប៊ីហ្សង់ ប្រទេសកូតឌីវ័រ សហភាពអឺរ៉ុប អាហ្វ្រិក និងអង្គការសហប្រជាជាតិ នឹងគាំទ្រ សកម្មភាពរបស់អង្គការអន្តោប្រវេសន៍អន្តរជាតិ IOMដែលធ្វើការទៅលើការវិលត្រឡប់របស់ជនអន្តោប្រវេសន៍ អាហ្វ្រិក ទៅក្នុងប្រទេសកំណើត។ នៅក្នុងពិធីបើកសម្ពោធជំនួបកំពូល អឺរ៉ុប អាហ្វ្រិក ប្រធានាធិបតីម្ចាស់ផ្ទះរបស់ប្រទេសកូតឌីវ័រ បានអំពាវនាវកុំឲ្យយុវជនអាហ្វ្រិក ចាញ់ពាក្យឃោសនា និងផ្សងព្រេងប្រថុយជីវិត ដើម្បី ធ្វើដំណើរមកអឺរ៉ុប។ គេវាយតម្លៃថា ៦០ភាគរយនៃប្រជាជនអាហ្វ្រិក មានអាយុក្រោម ២៥ឆ្នាំ។ ដោយសារតែភាពក្រីក្រ គ្មានការងារធ្វើ ពួកគេជាច្រើនសែននាក់ បានប្រថុយគ្រោះថ្នាក់ ឆ្លងកាត់ប្រទេសលីប៊ី ដើម្បី ចង់ធ្វើអន្តោប្រវេសន៍ ចូលទឹកដីអឺរ៉ុប៕

## ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧

## នាយឧត្តមសេនីយ៍ ថោង លីម ៖ ឆ្នាំ២០១៧ បង្ក្រាបករណី ជួញដូរមនុស្ស និងផ្លូវភេទ ១៥១ករណី ឃាត់ខ្លួនមនុស្ស ១៨៧នាក់

https://www.dap-news.com/kh/ ថ្ងៃច័ន្ទ, 04 ធ្នូ ២០១៧ 11:35 ដោយ: ឫទ្ធិ ជ័យ ID:012

ភ្នំពេញ ៖ លោកឧត្តមសេនីយ៍ ថោង លីម អគ្គស្នងការរងនគរបាលជាតិ បានលើកឡើងថា គិតត្រឹម ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៧នេះ កម្លាំងសមត្ថកិច្ចនៅទូទាំងប្រទេស បានបង្ក្រាប បទល្មើស ជួញដូរ មនុស្ស និងអាជីវកម្មផ្លូវភេទ បានចំនួន ១៥១ករណី និងឃាត់ខ្លួន ជនសង្ស័យបាន ១៨៧នាក់ (ស្រី ៥៧នាក់) ដោយជួយ សង្គ្រោះបានជនរងគ្រោះ ២៩៦នាក់ ។

ក្នុងពិធីបំពាក់គ្រឿងឥស្សរិយសជូនអង្គការក្រៅរដ្ឋាភិបាល ដែលបានសហការល្អ ជាមួយ កម្លាំងនគរបាលជាតិ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នាយឧត្តមសេនីយ៍ ថោង លីម បានមានប្រសាសន៍ថា បទល្មើសអំពើជួញដូរទាំង ១៥១ករណីនេះ ក្នុងនោះបង្ក្រាប បទល្មើស អំពើជួញដូរមនុស្ស ៤៣ករណី ឃាត់ខ្លួន ៦៥នាក់ (ស្រី៣៣នាក់) សង្គ្រោះជនរង គ្រោះបាន ៨៥នាក់ និងអំពើធ្វើអាជីវកម្មផ្លូវភេទ ១០៨ករណី ឃាត់ខ្លួន ១២២នាក់ (ស្រី២៤នាក់) សង្គ្រោះជនរងគ្រោះបាន ២១១នាក់ ៕

## អគ្គស្នងការរងនគរបាលជាតិ បំពាក់គ្រឿងឥស្សរិយយស ជូនអង្គការក្រៅរដ្ឋាភិបាល ដែលបានសហការល្អជាមួយកងកម្លាំងនគរបាលជាតិក្នុងការប្រយុទ្ធប្រឆាំងអំពើរជួញដូរមនុស្ស

http://cambodiapolice.com/ 11:01 am 4 ធ្នូ 2017 121

**ភ្នំពេញ ៖** ឯកឧត្តម នាយឧត្តមសេនីយ៍ ថោង លីម អគ្គស្នងការរងនគរបាលជាតិ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ នៅព្រឹកថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៧នេះ បានអញ្ជើញបំពាក់គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ធិបឌិន្ទ, គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ធិបឌិន្ទ និងគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់អស្សឫទ្ធិ ជូនបណ្តាអង្គការក្រៅរដ្ឋាភិបាល ដែលបានសហការល្អជាមួយកងកម្លាំងនគរបាលជាតិក្នុងការប្រយុទ្ធប្រឆាំងអំពើរជួញដូរមនុស្ស នាពេលកន្លងមក។

ឯកឧត្តម នាយឧត្តមសេនីយ៍ ថោង លីម អគ្គស្នងការរងនគរបាលជាតិ ក្នុងនាម ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អង្គការដៃគូរទាំងអស់ដែលជានិច្ចកាលតែងតែមានកិច្ចសហប្រតិបត្តិការល្អ ជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ជាពិសេសនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីកម្មផ្លូវភេទលើស្ត្រី និងកុមារ ទាំងការងារស៊ើបអង្កេត និងជួយសង្គ្រោះជនរងគ្រោះ ក៏ដូចជាការងារពង្រឹងសមត្ថភាពដល់មន្ត្រីនគរបាល

យុត្តិធម៌នៅនាយកដ្ឋាន និងតាមបណ្តារាជធានី-ខេត្ត។ ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការរងនគរបាលជាតិ បានបញ្ជាក់ថា បទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ជាបទល្មើសសកលមានលក្ខណៈស្មុគស្មាញ ដែលចាំបាច់រួមគ្នាប្រយុទ្ធ និងបទល្មើសទាំងនេះ ជាក់ស្តែងក្នុងឆ្នាំ២០១៧នេះ សមត្ថកិច្ចបង្ក្រាបបានចំនួន ១៥១/៧៦ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ១៨៧នាក់ (ស្រី៥៧នាក់) សង្គ្រោះជនរងគ្រោះបាន ២៩៦នាក់ ក្នុងនោះ អំពើជួញដូរមនុស្ស ៤៣/២៤ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ៦៥នាក់ (ស្រី៣៣នាក់) សង្គ្រោះជនរងគ្រោះបាន ៨៥នាក់ និងអំពើធ្វើអាជីវកម្មផ្លូវភេទ ១០៨/៥២នាក់ ឃាត់ខ្លួនជនសង្ស័យចំនួន ១២២នាក់ (ស្រី២៤នាក់) សង្គ្រោះជនរងគ្រោះបាន ២១១នាក់។ ផ្អែកលើលទ្ធផលនៃការខិតខំប្រឹងប្រែងទាំងអស់នេះធ្វើឲ្យប្រទេសកម្ពុជាបានទទួលស្គាល់ជាអន្តរជាតិលើចំណាត់ថ្នាក់លេខ២ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

ក្នុងឱកាសនោះដែរ ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការរងនគរបាលជាតិ ក៏បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អង្គការទាំងអស់ដែលមានវត្តមាននៅពេលនេះ ដែលកន្លងមកបានសហការល្អក្នុងការស្រាវជ្រាវស៊ើមអង្កេតបទល្មើសពាក់ព័ន្ធ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដែលទទួលបានលទ្ធផលល្អប្រសើរ។ ទន្ទឹមនឹងមានការខិតខំប្រឹងប្រែងរបស់សមត្ថកិច្ច ក៏ដូចជាសហការល្អជាមួយអង្គការដៃគូរយើងក៏ត្រូវមានបញ្ហាជាច្រើនទៀតដែលត្រូវរួមគ្នាប្រយុទ្ធប្រឆាំងបន្ថែមទៀត ដូចជា បទល្មើសជួញដូរមនុស្សឆ្លងដែន អាជីវកម្មផ្លូវភេទលើអនីតិជន និងការបំពានផ្លូវភេទលើកុមារជាដើម ៕

## កាត់ទោសបុរសជនជាតិជប៉ុនម្នាក់ និងខ្មែរ២នាក់ រឿងនាំស្ត្រីខ្មែរទៅលក់នៅប្រទេសជប៉ុន

http://ann.com.kh/site/news/ ថ្ងៃចន្ទ, 4 ខែធ្នូ 2017 1:55 ល្ងាច

រាជធានីភ្នំពេញ៖ នៅព្រឹកថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៧នេះ លោក វេង ហាត់ ប្រធានក្រុមប្រឹក្សាចៅក្រមជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ បានបើកសវនាការជាអសាធារណៈ កាត់ទោសបុរសជនជាតិជប៉ុនម្នាក់ និងជនជាតិខ្មែរប្រុសស្រី ២នាក់ រឿងនាំស្ត្រីខ្មែរទៅលក់ ឱ្យផ្ទះបននៅប្រទេសជប៉ុន ដើម្បីបម្រើសវាផ្លូវភេទ។

លោក គុជ គឹមឡុង ជាតំណាងអយ្យការបានចោទប្រកាន់ ពីបទការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់ការកេងប្រវ័ញ្ច ប្រព្រឹត្តកាលពីអំឡុងខែសីហា ឆ្នាំ២០១៦ យោងតាមមាត្រា១២ នៃច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ លើជនជាប់ចោទ ទី១.ឈ្មោះ FUKUI SUSUMU ភេទប្រុសអាយុ ៥២ឆ្នាំ ជាជនជាតិជប៉ុន, ទី២.ឈ្មោះ លឹម លក្ខិណា ហៅអាណែត ភេទស្រី អាយុ ២៨ឆ្នាំ ជាជនជាតិខ្មែរ និងទី៣.ឈ្មោះ សេង ចាន់ឌី ហៅខេនឌី ភេទប្រុស អាយុ ៣០ឆ្នាំ ជាជនជាតិខ្មែរ (ត្រូវបានអនុញ្ញាតឱ្យនៅក្រៅឃុំ ក្រោយពេលតុលាការសម្រេចឃុំខ្លួនបានមួយរយៈ)។

នៅក្នុងសវនាការនាព្រឹកនេះ គឺមានវត្តមានដើមបណ្តឹងដែលជាជនរងគ្រោះ ចំនួន៥នាក់ និងជនជាប់ចោទជនជាតិជប៉ុន និងស្ត្រីខ្មែរចំនួន ២នាក់ប៉ុណ្ណោះ ដោយជនជាប់ចោទឈ្មោះ សេង ចាន់ឌី ហៅខេនឌី មិនចូលរួមឡើយដោយឱ្យមេធាវីមកជាតំណាងនៅក្នុងសំណុំរឿង ឧក្រិដ្ឋមួយនេះ។

យោងតាមសមត្ថកិច្ចនៃមន្ទីរប្រឆាំងការជួញដូរមនុស្សបានឱ្យដឹងថា ជនជាប់ចោទទាំង២នាក់បាន សារភាពនៅក្នុងសវនាការថា ពួកគេពិតជាបាន ប្រកាសជ្រើសរើស និងបញ្ជូននារីរងគ្រោះ ចំនួន ១០នាក់ទៅប្រទេសជប៉ុនមែន ប៉ុន្តែរឿងលក់ស្ត្រីរងគ្រោះឱ្យផ្ទះបន ពួកគេមិនបានដឹងនោះទេ គឺខាងចៅកែនៅប្រទេសជប៉ុនជាអ្នកធ្វើ។ យោង

តាមរបាយការណ៍របស់សមត្ថកិច្ចកាលពីពេលចាប់ខ្លួនជនជាប់ចោទ បានបញ្ជាក់ថា ក្រុមជនជាប់ចោទបានរួមគំនិតគ្នា លួងលោម និងបោកបញ្ឆោតនាំនារីខ្មែរ ចំនួន ១០នាក់ឱ្យទៅធ្វើការនៅប្រទេសជប៉ុន ដោយឱ្យប្រាក់ខ្ចីមុនក្នុងម្នាក់ៗ ៥០០ដុល្លារ។

ក្រុមជនជាប់ចោទ បានសន្យាផ្តល់ការងារដល់ជនរងគ្រោះនៅប្រទេសជប៉ុន ដែលមានប្រាក់ខែចាប់ពី ៣៥០០ដុល្លារ ទៅដល់៥០០០ដុល្លារ ក្នុង១ខែ។ មិនដូចអ្វីដែលបានសន្យាឡើយ ក្រុមជនជាប់ចោទទាំង៣នាក់ បាននាំនារីរងគ្រោះយកទៅលក់ឱ្យផ្ទះបន ដើម្បីបម្រើផ្លូវភេទទៅវិញ។ ក្រោយមកក្រុមនារីរងគ្រោះបាននាំគ្នាទៅប្តឹងសមត្ថកិច្ចឱ្យជួយរំដោះចេញពីបននោះបាន និងត្រូវបានអាជ្ញាធរកម្ពុជាជួយនាំមកប្រទេសកំណើតវិញ។

គួររំលឹកថា លោក លាង សំណាត់ ក្រុមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចឃុំខ្លួនជនជាប់ចោទទាំង ៣នាក់ខាងលើកាលពី រសៀលថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៧។ ទោះជាយ៉ាងណា ដោយសារពេលវេលាមិនគ្រប់គ្រាន់ សំណុំរឿងនេះត្រូវតុលាការសម្រេចលើកពេលទៅបន្តសវនាការនៅពេលក្រោយទៀត៕ ដោយៈ ឡុក សំរិត

## ទប់ស្កាត់ពលរដ្ឋឆ្លងដែនចូលប្រទេសថៃខុសច្បាប់១១៤នាក់នៅស្រុកសំពៅលូន

http://cambodiapolice.com/ 10:36 am 3 ធ្នូ 2017 33

បាត់ដំបង ៖ នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង ១១និង២០នាទី នៅចំណុចភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង កម្លាំងការិយាល័យប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្ត បានសហការជាមួយកម្លាំងអធិកាដ្ឋាននគរបាលស្រុកសំពៅលូន បានចុះទប់ស្កាត់និងបង្ក្រាបប្រជាពលរដ្ឋឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ ១ករណី ឃាត់ខ្លួនមនុស្សចំនួន ១១៤នាក់ ស្រី ៤៨នាក់ (ក្មេង ៣៤នាក់) រស់នៅភូមិព្រៃកឈើត្រាវ ឃុំអន្លង់វិល ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ។ ករណីនេះ សមត្ថកិច្ចជំនាញបានធ្វើការណែនាំអប់រំចុះកិច្ចសន្យា និងឲ្យវិលត្រឡប់ទៅមូលដ្ឋានវិញ ៕

## កិច្ចព្រមព្រៀងថ្មី ត្រូវបានចុះដើម្បីបញ្ជូនស្ត្រីខ្មែរទៅធ្វើការនៅម៉ាឡេស៊ី

http://www.postkhmer.com/ Fri, 1 December 2017 យន់ ស៊ីនាត and Daphne Chen

**ភ្នំពេញៈ** ស្ត្រីបម្រើការងារតាមផ្ទះ ជនជាតិកម្ពុជាដែលធ្វើការនៅក្នុងប្រទេសម៉ាឡេស៊ីនឹងត្រូវផ្តល់ឲ្យនូវទូរស័ព្ទស្មាតហ្វូន គណនីធនាគារ និងការប្រឹក្សាយោបល់ក្រោមកិច្ចព្រមព្រៀងថ្មីមួយដែលចុះហត្ថលេខាដោយប្រទេសទាំង ២ កាលពីម្សិលមិញដែលនេះជាវិធានការក្នុងគោលបំណងការពារមិនឲ្យមានការរំលោភបំពានដែលធ្លាប់កើតមានជាច្រើន ហើយបណ្តាលឲ្យមានការហាមប្រាមការបញ្ជូនស្ត្រីបម្រើការងារតាមផ្ទះទៅប្រទេសម៉ាឡេស៊ីកាលពី ៦ ឆ្នាំមុន។ នេះបើតាមតំណាងទីភ្នាក់ងារជ្រើសរើសពលករម្នាក់ដែលបានថ្លែង។ ប៉ុន្តែព័ត៌មានដែលត្រូវបានប្រកាសនៅក្នុងសារព័ត៌មានម៉ាឡេស៊ី កាលពីម្សិលមិញ បានធ្វើឲ្យមានការភ្ញាក់ផ្អើលដល់ក្រុមការពារសិទ្ធិការងារនៅក្នុងប្រទេសទាំង ២ ដែលបានថ្លែងថាពួកគេមិនទាន់ទទួលបានការពិគ្រោះយោបល់អំពីអនុស្សរណៈនៃការយោគយល់ (MoU) ដែលទន្ទឹងរង់ចាំជាយូរមកហើយនេះ និងដែលនៅតែមិនទាន់បង្ហាញជាសាធារណៈនៅឡើយទេ។

កម្ពុជាមិនបានប្រកាសជាសាធារណៈអំពីពិធីចុះហត្ថលេខានេះនៅទីក្រុងគូឡាឡាំពួនោះទេដែលត្រូវបានចូលរួមដោយលោក សេង សក្កដា អគ្គនាយកនៃអគ្គនាយកដ្ឋានការងារនៃក្រសួងការងារ និងលោក Jeffrey Foo ប្រធានសមាគមទីភ្នាក់ងារជ្រើសរើសស្ត្រីបម្រើការងារតាមផ្ទះពីបរទេសរបស់ម៉ាឡេស៊ី។

ទាំងលោក សេង សក្កដា និងអ្នកនាំពាក្យក្រសួងការងារ លោក ហេង សួគ៌ មិនបានឆ្លើយតបនឹងសំណើសុំអត្ថាធិប្បាយកាលពីម្សិលមិញទេ។

លោក Foo នៅពេលទាក់ទងកាលពីម្សិលមិញបានថ្លែងថាកិច្ចព្រមព្រៀងនេះបង្កើតឲ្យមានការការពារជាច្រើនសម្រាប់ពលករបម្រើការងារតាមផ្ទះ ជនជាតិកម្ពុជាដែលត្រូវការដើម្បីបំពេញភាពខ្វះខាតពលករបម្រើការងារតាមផ្ទះក្នុងប្រទេសម៉ាឡេស៊ី។ ក្នុងចំណោមរឿងដទៃៗទៀត សមាគមនឹងផ្តល់ឲ្យពលករម្នាក់ៗនូវទូរស័ព្ទស្មាតហ្វូនមួយដោយមិនគិតថ្លៃដើម្បីតាមដានការបើកប្រាក់ខែរបស់ពួកគេ និងធ្វើឲ្យទីភ្នាក់ងារជ្រើសរើសពលករចុះកិច្ចសន្យាដែលមានគូសបង្ហាញអំពីកាតព្វកិច្ច និងការទទួលខុសត្រូវរបស់ពលករបម្រើការងារតាមផ្ទះ។ លោក Foo បានថ្លែងបន្តថា៖ «យើងត្រូវខិតខំប្រឹងប្រែងធ្វើការដើម្បីបណ្តុះបណ្តាល និងផ្តល់ទំនុកចិត្តដល់ប្រជាជនក្នុងប្រទេសកម្ពុជាថាប្រទេសម៉ាឡេស៊ីគឺជាកន្លែងល្អមួយសម្រាប់ធ្វើការ»។ «យើងនឹងត្រូវតែធ្វើវាដោយប្រុងប្រយ័ត្នណាស់ ហើយធ្វើឲ្យប្រាកដថាអត្ថប្រយោជន៍របស់ភាគីទាំងអស់ត្រូវបានការពារ»។

កម្ពុជាបានហាមប្រាមការបញ្ជូនស្ត្រីបម្រើការងារតាមផ្ទះទៅប្រទេសម៉ាឡេស៊ីក្នុងឆ្នាំ ២០១១ បន្ទាប់ពីមានការរាយការណ៍ថាមានករណីរំលោភបំពានយ៉ាងធ្ងន់ធ្ងរជាច្រើនទៅលើស្ត្រីបម្រើការងារតាមផ្ទះទាំងនោះរួមមានដូចជាការធ្វើការងារច្រើនជ្រុល បញ្ហាមិនបើកប្រាក់ និងការរំលោភបំពានលើរាងកាយ និងផ្លូវភេទ។ ប្រទេសទាំង ២ បានព្រមព្រៀងគ្នាបើកការបញ្ជូនពលករឡើងវិញក្នុងឆ្នាំ ២០១៥ ប៉ុន្តែការចាប់ផ្តើមដំណើរការឡើងវិញនេះបានជួបបញ្ហាដោយសារនីតិវិធីមានលក្ខណៈភាន់ច្រឡំ។

ក្រុមអង្គការការពារសិទ្ធិការងារបានសម្តែងការខកចិត្តកាលពីម្សិលមិញថា ពួកគេមិនត្រូវបានបញ្ចូលនៅក្នុងដំណើរការបង្កើត MoU នេះ ឬកិច្ចព្រមព្រៀងក្នុងឆ្នាំ ២០១៥ ដែលបានលុបចោលការហាមប្រាមជាលក្ខណៈក្រៅផ្លូវការនោះទេ។ លោក កែវ ពឿន អ្នកសម្របសម្រួលនៅសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) បានថ្លែងថាលោកមិនទាន់បានឃើញកិច្ចព្រមព្រៀងនេះនៅឡើយទេ ប៉ុន្តែសង្ឃឹមថាវាតម្រូវឲ្យមានការពិនិត្យទៀងទាត់ទៅលើលក្ខខណ្ឌការងារ និងពេលឈប់សម្រាកសម្រាប់ពលករ។ «ប្រសិនបើពួកគេមិនផ្តល់ការការពារដូចនោះទេ ខ្ញុំមិនគិតថាស្ត្រីបម្រើការងារតាមផ្ទះនៅប្រទេសម៉ាឡេស៊ីមានសុវត្ថិភាពនោះទេ»។

Adrian Pereira នាយកប្រតិបត្តិនៃអង្គការ North-South Initiative ដែលជាអង្គការការពារសិទ្ធិមនុស្សម៉ាឡេស៊ីបានចោទសួរថា តើកិច្ចព្រមព្រៀងនេះនឹងមានការអនុវត្តមានប្រសិទ្ធភាពឬអត់? «[សមាគមទីភ្នាក់ងារជ្រើសរើសស្ត្រីបម្រើការងារតាមផ្ទះពីបរទេសរបស់ម៉ាឡេស៊ី] ត្រូវសួរខ្លួនឯងថា តើសមាជិកផ្ទាល់របស់ខ្លួនចំនួនប៉ុន្មានបានធ្វើតាមគោលការណ៍ណែនាំនេះ»។

តំណាងនៅអង្គការចាប់ដៃដែលជាអង្គការក្រៅរដ្ឋាភិបាលប្រឆាំងការជួញដូរមនុស្ស និងអង្គការសិទ្ធិមនុស្សអាដហុកបានថ្លែងថាពួកគេក៏មិនបានដឹងផងដែរអំពីកិច្ចព្រមព្រៀងថ្មីនេះ។ តំណាងម្នាក់នៅក្រុមហ៊ុន Elite Manpower Agency ដែលជាទីភ្នាក់ងារជ្រើសរើសពលករមានមូលដ្ឋាននៅភ្នំពេញដែលបដិសេធបញ្ចេញឈ្មោះបានថ្លែងថាក្រុមហ៊ុនមិនទាន់បានឃើញអនុស្សរណៈនៃការយោគយល់ (MoU) ថ្មីនេះជាមួយប្រទេសម៉ាឡេស៊ីនៅឡើយទេ៕ PS

## លោក ហេង សួរ៖ ពលករចំណាកស្រុកច្រើន បង្កើនប្រាក់ចំណូលដល់កម្លាំងពលកម្មក្នុងស្រុក

https://thmeythmey.com/ 03, Dec 2017 , 9:19 pm

ភ្នំពេញ៖ បច្ចុប្បន្នកម្ពុជា ត្រូវបានគេមើលឃើញថា ជាប្រទេសដែលបញ្ជូនពលករចំណាកស្រុកច្រើន នៅក្នុងតំបន់អាស៊ាន។ បើតាមតួលេខក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពលករខ្មែរនៅប្រទេសថៃ មានចំនួន១ លាន ៥សែននាក់ ខណៈនៅប្រទេសកូរ៉េខាងត្បូងមានពលករច្រើនលំដាប់ទី២ និងម៉ាឡេស៊ី លំដាប់ទី៣។

អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក ហេង សួរ បាននិយាយថា លំហូរចំណាកស្រុករបស់ពលករខ្មែរនេះ គឺវាស្របទៅនឹងគោលការណ៍សកល នៃលក្ខណៈសេដ្ឋកិច្ច។ ត្រង់ចំណុចនេះ លោក ហេង សួរ ពន្យល់ថា ការបញ្ជូនពលករទៅក្រៅប្រទេស នឹងជួយលើកកម្ពស់សេដ្ឋកិច្ចក្នុងស្រុក ជាពិសេសការទាញយកជំនាញពីប្រទេសសេដ្ឋកិច្ចជឿនលឿន មកអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា នាពេលអនាគត។ លោក ហេង សួរ បញ្ជាក់ថា ពលករចំណាកស្រុកច្រើន បានបង្កើនប្រាក់ចំណូលដល់កម្លាំងពលកម្មក្នុងស្រុក។

## មន្ទីរការងារខេត្តណាខនរាចស៊ីម៉ា ប្រកាសចែកលេខរៀងធ្វើប៉ាស្ព័រ

http://www.pheaktraprak.com December 3, 2017

នៅថ្ងៃអាទិត្យទី03 ខែធ្នូ ឆ្នាំ2017នេះ គេហទំព័រហ្វេសប៊ុករបស់ ศูนย์บริการช่วยเหลือแรงงานต่างด้าวจังหวัดนครราชสีมา បានចេញសេចក្តីប្រកាសជូនដំណឹងដល់បងប្អូនពលករកម្ពុជាដែលកំពុងរង់ចាំលេខរៀង ដើម្បីទៅត្រួតសញ្ជាតិធ្វើប៉ាស្ព័រ អោយបានជ្រៀបថា ចាប់តាំងពីថ្ងៃច័ន្ទទី04 ខែធ្នូ ឆ្នាំ2017នេះ មន្ទីរការងារខេត្តណាខនរាចស៊ីម៉ា ប្រទេសថៃ នឹងចាប់ផ្តើមផ្តល់លេខរៀងទៅត្រួតសញ្ជាតិធ្វើប៉ាស្ព័រ ដល់បងប្អូនពលករខ្មែរក្នុងមួយថ្ងៃចំនួន100នាក់ ការផ្តល់លេខរៀងខាងលើនេះចំពោះតែពលករដែលលុងបៀនថ្មីប៉ុណ្ណោះ ហើយការផ្តល់លេខរៀងជូននេះគឺមានរយៈពេលរហូតដល់ថ្ងៃទី29 ខែធ្នូ ឆ្នាំ2017។ ដូច្នេះចំពោះបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅធ្វើការក្នុងខេត្តណាខនរាចស៊ីម៉ា សូមប្រញាប់រួសរាន់ដើម្បីទៅសុំលេខរៀងធ្វើប៉ាស្ព័រនៅមន្ទីរការងារខេត្តអោយបានទាន់ពេលវេលា និងរៀងរាល់ម៉ោធ្វើការ។

បញ្ជាក់ការផ្តល់លេខរៀងរបស់មន្ទីរការងារខេត្តណាខនរាចស៊ីម៉ានេះ ចំពោះបងប្អូនពលកដែលបានលុងបៀនថ្មីតែប៉ុណ្ណោះ សូមអរគុណ។

## បញ្ហាលក់ដូរលេខរៀងធ្វើប៉ាស្ព័រ កើតឡើងដោយសារត្រួតសញ្ជាតិមិនទាន់.!

http://www.pheaktraprak.com December 2, 2017

បញ្ហាលក់ដូរលេខរៀងធ្វើប៉ាស្ព័ររបស់ពលករបរទេស កើតឡើងដោយសារតែ ត្រួតសញ្ជាតិជូនពលករមានភាពយឺតយ៉ាវ ទើបធ្វើកើតបញ្ហារឿងលក់ដូរលេខរៀង ក្នុងពិធីចុះត្រួតពិនិត្យការិយាល័យត្រួតសញ្ជាតិជូនពលករភូមានៅក្នុងខេត្តសាមុតប្រាកាន កាលពីថ្ងៃទី01 ខែធ្នូ ឆ្នាំ2017កន្លងទៅថ្មីៗនេះ លោក អាប់ដុល សែងសិងកែវ រដ្ឋមន្រ្តីក្រសួងការងារថៃថ្មី បានមានប្រសាសន៍ថា បញ្ហាដែលធ្វើអោយកើតរឿងលក់ដូរលេខរៀងចូលធ្វើប៉ាស្ព័ររបស់ពលករបរទេស គឺកើតឡើងដោយសារតែ ដំណើរការត្រួតសញ្ជាតិជូនពលករមានភាពយឺតយ៉ាវ ទើបធ្វើឱ្យមានជនឆ្លៀតឱកាសលក់ដូរលេខរៀង។ ពីព្រោះមានពលករមួយចំនួនពួកគេព្រួយបារម្ភខ្លាចធ្វើប៉ាស្ព័រមិនទាន់ពេលកំណត់ទើបបង្ខំចិត្តទិញលេខរៀង ដើម្បីធ្វើប៉ាស្ព័រអោយបានមុនគេ ព្រោះខ្លាចធ្វើមិនទាន់ពេលកំណត់។

## រដ្ឋមន្រ្តីក្រសួងការងារថ្មី ប្រកាសចាត់វិធានការ រឿងលក់លេខរៀងធ្វើប៉ាស្ព័រ

http://www.pheaktraprak.com December 2, 2017

កាលពីថ្ងៃសៅរ៍ ទី02 ខែធ្នូ ឆ្នាំ2017ព្រឹកមិញនេះ លោករដ្ឋមន្រ្តីក្រសួងការងារថៃ បានមានប្រសាសន៍ប្រាប់អ្នកយកព័ត៌មានក្នុងស្រុកថៃ ក្នុងកិច្ចប្រជុំទទួលផែនការថ្មីរបស់ក្រសួងការងារថៃ កាលពីព្រឹកមិញនេះថា រឿងបញ្ហាអំពើពុករលួយរបស់ក្រុមអ្នករកស៊ីលក់លេខរៀងត្រួតសញ្ជាតិរបស់ពលករបរទេស នៅក្នុងការិយាល័យត្រួតសញ្ជាតិ

ពលករបរទេស លោកនឹងអោយសមត្ថកិច្ចចាត់វិធានការយ៉ាងដាច់ខាតចំពោះក្រុមបុគ្គលអស់ទាំងនេះ។ ដើម្បីកែបញ្ហាជូនពលករបរទេសដែលកំពុងវេការលំបាកអំពីបញ្ហាទាំងនេះ ក្នុងនោះដែរលោករដ្ឋមន្ត្រីបានលើកឡើងផងដែរថា បញ្ហាលេខរៀងត្រួតសញ្ជាតិរបស់ពលករបរទេស លោកនឹងរៀបចំយុទ្ធសាស្ត្រថ្មីក្នុងការផ្តល់លេខរៀងជូនពលករនៅក្នុងតំបន់នីមួយៗបានទាន់ពេលវេលា និងដើម្បីឲ្យងាយស្រួលក្នុងការគ្រប់គ្រងបញ្ហាទាំងអស់នេះដែលកើតឡើងមិនចេះចប់មិនចេះហើយ។

## មូលហេតុដែលរាជរដ្ឋាភិបាលថៃបើកធ្វើប័ណ្ណស៊ីជម្ពូថ្មី ជូនពលករ

http://www.pheaktraprak.com December 3, 2017

បន្ទាប់ពីលេចធ្លាយដំណឹងថា រាជរដ្ឋាភិបាលថៃនឹងប្រកាសបើកអោយធ្វើប័ណ្ណស៊ីជម្ពូសារថ្មីម្តងទៀតជូនដល់ពលករខ្មែរ,ភូមា,ឡាវ នៅពេលឆាប់ៗខាងមុខនេះ ហើយដំណឹងនេះបានធ្វើឲ្យបងប្អូនពលករខ្មែរមួយចំនួនមានការងឿងឆ្ងល់យ៉ាងខ្លាំងអំពីមូលហេតុទាំងអស់នេះ។ ហើយនៅថ្ងៃនេះដើម្បីអោយបងប្អូនពលករខ្មែរយើងទាំងអស់គ្នាបានយល់អំពីមូលហេតុទាំងអស់នេះខ្ញុំសូមរៀបរាប់និងអធិបាយអំពីមូលហេតុខ្លះៗ ដែលខ្ញុំបានដឹងដូចតទៅ៖

ដោយសារតែបញ្ហាត្រួតសញ្ជាតិធ្វើប៉ាស្ព័រជូនពលករបរទេសនៅក្នុងប្រទេសថៃ មានភាពអាក់រអួល ហើយពេលវេលាដែលរាជរដ្ឋាភិបាលថៃបានកំណត់កាន់តែខិតជិតមកដល់ដល់ទៀតនោះ វិធីសាស្ត្រដែលអាចពន្យារពេលអោយពលករទាំងអស់នោះបានត្រួតសញ្ជាតិធ្វើប៉ាស្ព័ររួចរាល់ តាមនយោបាយរបស់អគ្គនាយកដ្ឋានក្រសួងការងារថៃបានកំណត់កាលពីកន្លងមកនោះ គឺមានតែធ្វើប័ណ្ណស៊ីជម្ពូថ្មីបណ្តោះអាសន្នមួយ ដើម្បីកុំឲ្យពលករដែលមិនទាន់បានត្រួតសញ្ជាតិទាំងអស់នោះ ត្រូវច្បាប់ថ្មីដែលត្រៀមនឹងអនុវត្តនៅដើម ឆ្នាំ2018 ខាងមុខនេះ រងផលប៉ះពាល់ដូច្នេះប័ណ្ណស៊ីជម្ពូថ្មីនេះ អ្នកធ្វើអោយពលករដែលត្រួតសញ្ជាតិមិនទាន់មានដង្ហើមតទៅមុខទៀត។ ហើយដូច្នេះមានតែវិធីនេះទេដែលអាចធ្វើអ្វីៗមើលទៅល្អប្រសើរឡើងវិញ ហើយឥឡូវបងប្អូនចូលទៅមើលចំណុចទាំងបួនដូចខាងក្រោម៖

1-ចំពោះពលករខ្មែរដែលលុងបៀនថ្មី ហើយមានលិខិតបញ្ជាក់ចេញពីក្រសួងការងារថៃ ហើយនេះគឺមានសុពលភាពធ្វើការស្នាក់នៅក្នុងប្រទេសថៃត្រឹមតែ 31.12.2017 នេះតែប៉ុណ្ណោះ ដើម្បីឲ្យពួកគាត់អាចត្រួតសញ្ជាតិធ្វើប៉ាស្ព័របានទាន់ពេលកំណត់នោះ។ ដូច្នេះរាជរដ្ឋាភិបាលថៃបានសម្រេចអោយពលករលុងបៀនថ្មី ទាំងនោះត្រូវតែធ្វើប័ណ្ណស៊ីជម្ពូបណ្តោះអាសន្នមួយ ដើម្បីឲ្យពួកគាត់អាចធ្វើការស្នាក់នៅបន្តដើម្បីបានត្រួតសញ្ជាតិធ្វើប៉ាស្ព័ររួចរាល់តាមកិច្ចសន្យារបស់រាជរដ្ឋាភិបាលថៃ។

2-ចំពោះពលករដែលមានប័ណ្ណស៊ីជម្ពូផុតកំណត់ 31.03.2018 តែមិនទាន់បានត្រួតសញ្ជាតិ ដើម្បីឲ្យពួកគាត់អាចធ្វើការស្នាក់នៅបន្តនិងបានត្រួតសញ្ជាតិធ្វើប៉ាស្ព័រនោះរាជរដ្ឋាភិបាលថៃ បានកំណត់អោយពលករទាំងអស់នោះត្រូវប្តូរប័ណ្ណស៊ីជម្ពូចាស់ធ្វើប័ណ្ណស៊ីជម្ពូថ្មី ពីព្រោះដោយសារតែបញ្ហាលេខរៀងមានការអាក់រអួលអាចធ្វើឲ្យអ្នកមានប័ណ្ណស៊ីជម្ពូទាំងអស់នោះមិនអាចត្រួតសញ្ជាតិទាន់រយះពេល ដែលរាជរដ្ឋាភិបាលថៃកំណត់។ ដូច្នេះប័ណ្ណស៊ីជម្ពូថ្មីនេះ ហើយដែលអាចជួយបន្តអាយុការស្នាក់នៅរបស់ពួកគាត់ ដើម្បីឲ្យពួកគាត់អាចត្រួតសញ្ជាតិធ្វើប៉ាស្ព័រស្របច្បាប់តាមរយះពេលដែលរាជរដ្ឋាភិបាលថៃបានសន្យានាពេលកន្លងមក។

3-ចំពោះពលករដែលបានត្រួតសញ្ជាតិរួចរាល់ហើយ ហើយបានទទួលលិខិតឆ្លងដែនធ្វើការត្រឹមត្រូវរួចហើយនោះ នៅមិនទាន់ដឹងច្បាស់ថា តើពួកគាត់នឹងត្រូវធ្វើប័ណ្ណស៊ីជម្ពូថ្មីទៀតឬអត់.? ពីព្រោះសេចក្តីប្រកាសជាផ្លូវការនៅ

មិនទាន់បានប្រកាស ដូច្នេះបងប្អូនពលករដែលបានទទួលលិខិតឆ្លងដែនធ្វើការរួចហើយត្រូវដំណើរការរើសារ និងស្នើសុំច្បាប់អនុញ្ញាតធ្វើការអោយបានត្រឹមត្រូវដើម្បីកុំឲ្យខុសច្បាប់។

4-ចំពោះពលករធ្វើការនេសាទ(ផ្នែកការងារសមុទ្រ) ដែលបានទទួលលិខិតឆ្លងដែនធ្វើការរួចរាល់ហើយ និងមិនទាន់បានត្រួតសញ្ជាតិឬប័ត្រស៊ីជម្ពូផុតកំណត់ មិនអាចសុំរើសារធ្វើការបាននោះត្រូវរង់ចាំមើលសេចក្តីប្រកាសចេញជាផ្លូវការនៅពេលឆាប់ៗខាងមុខនេះ។

សរុបទៅប័ត្រស៊ីជម្ពូថ្មីនេះ ដែលរាជរដ្ឋាភិបាលថៃត្រៀមប្រកាសឲ្យធ្វើនៅពេលឆាប់ៗខាងមុខនេះ គឺដើម្បីបន្តសុពលភាពដល់ពលករលុងបៀនថ្មី ដែលមិនទាន់បានត្រួតសញ្ជាតិធ្វើប៉ាស្ព័រ និងពលករមានប័ត្រស៊ីជម្ពូហើយ មិនទាន់បានត្រួតសញ្ជាតិ ដើម្បីអោយពួកគាត់អាចត្រួតសញ្ជាតិធ្វើប៉ាស្ព័រអោយចប់សព្វគ្រប់ទៅតាមការសន្យារបស់រាជរដ្ឋាភិបាលថៃ ហើយដំណើរការធ្វើប័ត្រស៊ីជម្ពូថ្មីនេះនឹងផ្តើមធ្វើនៅក្នុង .12.2017 នេះ ដោយមានរយៈត្រឹមតែមួយខែប៉ុណ្ណោះ។ ហើយចំពោះពលករខុសច្បាប់គឺត្រូវវិលត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនវិញ ហើយអាចវិលត្រឡប់ឡើងមកធ្វើការនៅក្នុងប្រទេសថៃវិញបាន ដោយត្រូវធ្វើប៉ាស្ព័រការងារតាមរយៈ MOU ដែលមានទីតាំងធ្វើនៅតាមច្រកព្រំដែនអន្តរជាតិនីមួយៗរវាងកម្ពុជា-ថៃ។ រៀបរៀងដោយ:PrakPheakTra

## ពលករខ្មែរម្នាក់ កើតខ្យល់គរស្លាប់យ៉ាងអាណោចអាធ័ម

http://www.pheaktraprak.com December 3, 2017

កាលពីវេលាម៉ោង06:00ល្ងាច ថ្ងៃសៅរ៍ទី02 ខែធ្នូ ឆ្នាំ2017 នេះ មានករណីប្រទះឃើញសាកសពបុរសកម្មករសំណង់ខ្មែរម្នាក់ បានដេកស្លាប់នៅក្នុងបន្ទប់ស្នាក់នៅក្បែរស្តង់ដាក់ទំនិញមួយកន្លែង ស្ថិតនៅក្នុងឃុំបាងប្លា ស្រុកបាងភ្លី ខេត្តសាមុតប្រាកាន ប្រទេសថៃ។ ប្រភពពីកន្លែងកើតហេតុបានឲ្យដឹងថា ជនរងគ្រោះដែលដេកស្លាប់មានឈ្មោះ គុណ វិចិត្រ ភេទប្រុសអាយុ 25ឆ្នាំសញ្ជាតិខ្មែរ ធ្វើការសំណង់នៅក្បែរកន្លែងកើតហេតុ យោងតាមការត្រួតពិនិត្យរបស់សមត្ថកិច្ចថៃនៅកន្លែងកើតហេតុបានប្រាប់ថា ជនរងគ្រោះបានដេកស្លាប់អស់រយៈពេលជាង8ម៉ោងមកហើយ តាមការសន្និដ្ឋានរបស់សមត្ថកិច្ច អ្នកស្លាប់ប្រហែលជាកើតខ្យល់គរស្លាប់។ បច្ចុប្បន្នសាកសពពលករខ្មែរខាងលើត្រូវបានសមត្ថកិច្ច បញ្ជូនទៅរក្សាទុកនៅមន្ទីរពេទ្យខេត្តសាមុតប្រាកាន ដើម្បីរង់ចាំឲ្យស្ថានទូតកម្ពុជា ទាក់ទងទៅសាច់ញាតិយកទៅធ្វើបុណ្យតាមប្រពៃណី។

## ថៃត្រៀមធ្វើប័ណ្ណស៊ីជម្ពូថ្មី ជូនពលករបរទេសទាំងបីសញ្ជាតិ

http://www.pheaktraprak.com December 2, 2017

រាជរដ្ឋាភិបាលថៃ ត្រៀមប្រកាសធ្វើប័ណ្ណស៊ីជម្ពូសាជាថ្មីជូនពលករទាំងបីសញ្ជាតិនៅពេលឆាប់ៗខាងមុខនេះ នេះយោងតាមទំព័រហ្វេសប៊ុកផេកធំៗដែលទទួលធ្វើប៉ាស្ព័រជូនពលករបរទេសក្នុងប្រទេសថៃ ដោយតំរូវអោយពលករដែលស្របច្បាប់មានលក្ខណៈដូចខាងក្រោម៖

ពលករដែលបានលុងបៀនថ្មី តែបានត្រួតសញ្ជាតិរួចរាល់ហើយ ត្រូវទៅដំណើរធ្វើប័ណ្ណស៊ីជម្ពូថ្មី តាមនយោបាយរបស់អគ្គនាយកដ្ឋានក្រសួងការងារថ្មី នៅពេលឆាប់ៗខាងមុខនេះ។ ពលករធ្វើការនេសាទ(ផ្នែកការងារសមុទ្រ) មានប័ណ្ណស៊ីជម្ពូផុតកំណត់ 01.11.2017 តែបានត្រួតសញ្ជាតិរួចរាល់ហើយ ត្រូវទៅដំណើរការធ្វើប័ណ្ណស៊ី

ជម្ពូថ្មី តាមនយោបាយរបស់អគ្គនាយកដ្ឋានក្រសួងការងារថ្មីនៅពេលឆាប់ៗខាងមុខនេះ។ ពលករធ្វើការនេសាទ(ផ្នែកការងារសមុទ្រ) មានប័ណ្ណស៊ីជម្ពូផុតកំណត់ 01.11.2017 តែមិនទាន់បានទៅត្រួតសញ្ជាតិ ត្រូវទៅដំណើរការធ្វើប័ណ្ណស៊ីជម្ពូ តាមនយោបាយរបស់អគ្គនាយកដ្ឋានក្រសួងការងារថ្មីនៅពេលឆាប់ៗខាងមុខនេះ។

ពលករដែលមានប័ណ្ណស៊ីជម្ពូផុតកំណត់ 31.03.2018 តែបានត្រួតសញ្ជាតិរួចរាល់ហើយ ត្រូវទៅដំណើរការធ្វើប័ណ្ណស៊ីជម្ពូថ្មី តាមនយោបាយរបស់អគ្គនាយកដ្ឋានក្រសួងការងារថ្មីនៅពេលឆាប់ៗខាងមុខនេះ។ ពលករដែលមានប័ណ្ណស៊ីជម្ពូផុតកំណត់ 31.03.2018 តែមិនទាន់បានត្រួតសញ្ជាតិត្រូវទៅដំណើរការធ្វើប័ណ្ណស៊ីជម្ពូថ្មី តាមនយោបាយរបស់អគ្គនាយកដ្ឋានក្រសួងការងារថ្មី នៅពេលឆាប់ៗខាងមុខនេះ។

## ឃាត់ខ្លួនពលករខុសច្បាប់ 11នាក់ ដាក់ឈ្មោះក្នុងបញ្ជីខ្មៅ

http://www.pheaktraprak.com December 2, 2017

ពលករចំណាកស្រុកខុសច្បាប់ចំនួន11នាក់ ទៀតហើយត្រូវកម្លាំងទាហានថៃតាមច្រកព្រំដែនឃាត់ខ្លួន ករណីនេះបានកើតឡើងកាលពីថ្ងៃសុក្រ ទី01 ខែធ្នូ ឆ្នាំ2017 ស្ថិតត្រង់ចំណុចតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ នៅក្រោយផ្សារលុងក្លឿស្រុកអារញ្ញប្រមាណជាង200ម៉ែត។ យោងតាមប្រភពព័ត៌មានរបស់ថៃបានឱ្យដឹងថា ពលករខ្មែរចំណាកស្រុកខុសច្បាប់ដែលត្រូវបានកម្លាំងទាហានឈុតខ្មៅថៃចាប់នោះមានបុរស 6នាក់ នារី 5នាក់ ។ តាមចម្លើយសារភាពរបស់ពលករចំណាកស្រុកទាំងនោះបាននិយាយថា គេបានធ្វើដំណើរមកពីខេត្តផ្សេងក្នុងប្រទេសកម្ពុជា ហើយបានជួលមេខ្យល់អោយនាំឆ្លងដែនចូលមកស្វែងរកការងារនៅក្នុងប្រទេសថៃ ដោយចាយលុយថ្លៃផ្លូវក្នុងមនុស្សម្នាក់2.000 បាត ។

បច្ចុប្បន្នពលករខុសច្បាប់ទាំងអស់ត្រូវបានទាហានឈុតខ្មៅថៃប្រគល់ខ្លួនឱ្យតម្រួតអន្តោប្រវេសន៍ស្រុកអារញ្ញយកទៅធ្វើប្រវត្តិរូប និងដាក់បញ្ចូលក្នុងបញ្ជីខ្មៅ រួចបញ្ជូនខ្លួនអោយវិលត្រឡប់ទៅប្រទេសកម្ពុជាវិញតាមរយៈច្រកអន្តរជាតិប៉ោយប៉ែត។

## រដ្ឋមន្ត្រីក្រសួងការងារថ្មីចុះត្រួតពិនិត្យទីតាំងធ្វើប៉ាស្ព័រ

http://www.pheaktraprak.com December 1, 2017

រដ្ឋមន្ត្រីក្រសួងការងារថ្មីចុះត្រួតពិនិត្យទីតាំងត្រួតសញ្ជាតិជូនពលករបរទេសក្នុងខេត្តសាមុតប្រាកាន កាលពីថ្ងៃសុក្រទី01 ខែធ្នូ ឆ្នាំ2017 នេះលោក អាដុល សែងសិងកែវ រដ្ឋមន្ត្រីក្រសួងការងារថ្មីបានចុះត្រួតពិនិត្យទីតាំងត្រួតសញ្ជាតិជូនពលករភូមាក្នុងខេត្តសាមុតប្រាកាន ដើម្បីកែបញ្ហារឿងក្រុមអ្នករកស៊ីរត់លេខរៀងនិងអំពើពុករលួយផ្សេងដែលធ្វើឲ្យបញ្ហាត្រួតសញ្ជាតិមានភាពយឺតយ៉ាវ។ ក្នុងនោះដែរលោករដ្ឋមន្ត្រីក្រសួងការងារបានសន្យាថាលោកនឹងចាត់វិធានការយ៉ាងដាច់ខាត ចំពោះមន្ត្រីក្រសួងការងាររូបណា ដែលជាប់ពាក់ព័ន្ធនឹងករណីរត់លក់លេខរៀង ឬអំពើពុករលុយនៅក្នុងការិយាល័យត្រួតសញ្ជាតិជូនពលករបរទេសក្នុងប្រទេសថៃ។

## ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧

## "មជ្ឈមណ្ឌលឱកាសការងារខ្ញុំ" ដកអត្តសញ្ញាណប័ណ្ណពលករទុក

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៧ ម៉ោង ២០:៥២ យន់ ស៊ីថា

រាជធានីភ្នំពេញ ៖ យុវជនចំនួន៤នាក់បានធ្វើដំណើរទៅកាន់ប៉ុស្តិ៍ចោមចៅ១ ខណ្ឌពោធិ៍សែនជ័យ កាលពីវេលាម៉ោង៥ល្ងាច ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៧ ដើម្បីឲ្យសមត្ថកិច្ចជួយដកយកអត្តសញ្ញាណប័ណ្ណរបស់ពួកគេដែលត្រូវបានក្រុមហ៊ុនមួយឈ្មោះថា "មជ្ឈមណ្ឌលឱកាសការងារខ្ញុំ" ដកទុក ហើយពេលពួកគេទាមទារយកវិញមិនព្រមប្រគល់ឲ្យវិញសោះ។ ប៉ុន្តែអ្វីដែលជារឿងហួសចិត្តនោះ គឺនៅពេលដែលពួកគេទៅពឹងពាក់នគរបាលប៉ុស្តិ៍ចោមចៅ១ម្នាក់ឈ្មោះ កែម ភក្តី តែដូចជាទៅពឹង"ផ្កាយនៅលើមេឃ" ។ ទីបំផុតពួកគេមិនអាចយកអត្តសញ្ញាណប័ណ្ណពីក្រុមហ៊ុនបានឡើយ ដោយមិនដឹងថា មន្ត្រីនគរបាលខាងលើនោះរាយការណ៍សុំយោបល់ពីលោកនាយប៉ុស្តិ៍ឬអត់នោះទេ? ប៉ុន្តែពេលបានជួបមន្ត្រីនគរបាលម្នាក់នោះ មិនបាននាំពួកគេទៅជួបក្រុមហ៊ុននោះដើម្បីសុំយកអត្តសញ្ញាណប័ណ្ណវិញសាកមើលសិនទេ បែរជាហៅពួកគេទៅអង្គុយលើបង់ក្រោមដើមស្វាយ រួចទាញក្រដាសកិច្ចសន្យារវាងក្រុមហ៊ុន និងយុវជនទាំងនោះអានម្តង១ចំណុចៗ ឲ្យពួកគេស្តាប់រហូតដល់ចប់។

ហើយនៅចុងក្រោយនគរបាលម្នាក់នេះបាននិយាយប្រាប់យុវជនទាំង៤នាក់ខាងលើថា " បងមិនអាចជួយប្អូនទាំអស់គ្នាបានទេ" ចំណែកយុវជនទាំងអស់គ្នាក្រោយទទួលបានចម្លើយនោះភ្លាមបានត្រឹមតែចាកចេញទៅវិញទាំងអស់សង្ឃឹមតែប៉ុណ្ណោះ។ យុវជនទាំង៤នាក់ខាងលើនោះ១,ឈ្មោះ នាក់ ឌី អាយុ២៣ឆ្នាំ ២,ឈ្មោះ ប៉ាក ពុំ អាយុ២៤ឆ្នាំ ៣,ឈ្មោះ ទាម ទី អាយុ២០ឆ្នាំ និង៤,ឈ្មោះ លាង មករា អាយុ២០ឆ្នាំ អ្នកទាំងបីនាក់មានទីលំនៅក្នុងភូមិត្រពាំងបី ឃុំត្រពាំងបី ស្រុកឈូក ខេត្តកំពត។ អ្នកទាំង៤នាក់បាននិយាយថា ពួកគេសុទ្ធតែមានជីវភាពទីទ័លក្រមិនមានមុខរបរ ឬការងារអ្វីនោះធ្វើដើម្បីបានលុយទេ ក្រោយមកបានស្តាប់វិទ្យុមួយហើយបានឮ "មជ្ឈមណ្ឌលឱកាសការងារខ្ញុំ" ប្រកាសស្វែងរកបុគ្គលិកចូលបម្រើការងារ។ ក៏បាននាំគ្នាធ្វើដំណើរចាកចេញពីស្រុកកំណើតនៅឯខេត្តកំពតទៅកាន់ភ្នំពេញ ដើម្បីរកការងារធ្វើនៅ "មជ្ឈមណ្ឌលឱកាសការងារខ្ញុំ"នោះ។ ប៉ុន្តែមិនទាន់បានឃើញកន្លែងធ្វើការផងខាងក្រុមហ៊ុនបានឲ្យធ្វើកិច្ចសន្យា និងយកអត្តសញ្ញាណប័ណ្ណមុន ចំណែកពួកគេក៏មិនបានដឹងថា ក្រុមហ៊ុនមួយនោះមានលក្ខណៈបែបណាឡើយ ប៉ុន្តែនឹកឃើញថាក្រុមហ៊ុននោះធំ និងប្រកាសតាមវិទ្យុត្រឹមត្រូវទើបព្រមធ្វើកិច្ចសន្យាជាមុន។

លុះក្រោយពេលទៅដល់ក្រុមហ៊ុនស្ថិតនៅក្នុងភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ១ ខណ្ឌពោធិ៍សែនជ័យ ដោយមើលទៅមិនអាចធ្វើការបានព្រោះជាការងារលើសែងលើកដាក់ធ្ងន់ៗពេកពួកខ្លួនបានសម្រេចចិត្តថាមិនធ្វើវិញ និងបានសុំយកអត្តសញ្ញាណប័ណ្ណមកវិញ។ ប៉ុន្តែខាងក្រុមហ៊ុនមួយនេះមិនព្រមឲ្យវិញទេ ទើបនាំគ្នារត់រកនគរបាលឲ្យជួយតែបែរជាដូចពឹងផ្កាយលើមេឃទៅវិញពិតជាអស់សង្ឃឹមខ្លាំងណាស់។ ប្រភពដដែលបានបន្តទៀតថា នគរបាលឈ្មោះ កែម ភក្តី មិនបាននាំពួកគេទៅកាន់ក្រុមហ៊ុនមួយនោះ ដើម្បីជួយទំនាក់ទំនងសុំអត្តសញ្ញាណប័ណ្ណវិញទេ។ បែរជានាំពួកគេទៅអង្គុយលើបង់ក្រោមដើមស្វាយ រួចអានកិច្ចសន្យាដែលពួកគេធ្វើជាមួយក្រុមហ៊ុនតាំងពីដើមដល់ចប់។ បន្ទាប់មកបានប្រាប់ឲ្យពួកគេធ្វើការឲ្យចប់កុងត្រា៣ខែសិនទៅចាំយកអត្តសញ្ញាណប័ណ្ណនោះវិញ ហើយចុងក្រោយបានប្រាប់ពួកគេថា" បងមិនអាចជួយប្អូនទាំអស់គ្នាបានទេ"។

ដោយអស់សង្ឃឹមមិនដឹងថា ទៅរកនរណាជួយពួកគេបាននាំគ្នាចាកចេញពីប៉ុស្តិ៍នគរបាលទាំងហួសចិត្ត ហើយមិនដឹងធ្វើយ៉ាងដូចម្តេចឡើយ ព្រោះអត្តសញ្ញាប័ណ្ណសំខាន់ខ្លាំងណាស់សម្រាប់ពួកគេដើម្បីស្វែងរកការងារធ្វើ។ មតិជាច្រើនបានលើកឡើងថា ក្រុមហ៊ុន "មជ្ឈមណ្ឌលឱកាសការងារខ្ញុំ" នោះគ្មានសិទ្ធិក្នុងការយកអត្តសញ្ញាណប័ណ្ណ

របស់គេទៅទុកបែបនេះទេ ហើយក៏គ្មានសិទ្ធិបង្ខិតបង្ខំឲ្យគេធ្វើការដោយមិនពេញចិត្តបែបនេះដែរ។ ចំណែកមន្ត្រីនគរបាលប៉ុស្តិ៍ចោមចៅ១ ឈ្មោះ កែម ភក្តី គួរតែនាំពួកគេទៅជួបតំណាងក្រុមហ៊ុន សុំយកអត្តសញ្ញាណប័ណ្ណមកវិញសាកមើល ប្រសិនបើបានឲ្យដឹងថាបាន ហើយបើមិនបានក៏ឲ្យដឹងថាមិនបានទៅចុះ មិនគួរលើកហេតុផលច្រើន ហើយមិនជួយគ្នាបែបនេះឡើយ ហើយរឿងនេះប្រហែលជាលោកនាយប៉ុស្តិ៍ចោមចៅមិនបានដឹងឡើយ៕

## កិច្ចប្រជុំត្រួតពិនិត្យការអនុវត្តន៍គោលការណ៍ របស់អគ្គស្នងការនគបាលជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៧

http://cambodiapolice.com/blog/archives/ 10:36 am 5 ធ្នូ 2017 16

ត្បូងឃ្មុំ៖ កិច្ចប្រជុំត្រួតពិនិត្យការអនុវត្តន៍គោលការណ៍ របស់អគ្គស្នងការនគបាលជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញការដូរមនុស្សឆ្នាំ២០១៧ ថ្ងៃអង្គារ៍០២រោច-ថ្ងៃពុធ០៣រោច ខែមិគសិរ ឆ្នាំរកា នព្វស័កព.ស២៥៦១ លោកជំទាវឧត្តមសេនីយ៍ឯក យក់ សុខា អគ្គស្នងការរងនគរបាលជាតិ ទទួលបន្ទុកផែននគរបាលយុត្តិធម៌ ឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងលោកឧត្តមសេនីយ៍ទោ បែន រ័ត្ន ស្នងការនគបាលខេត្តត្បូងឃ្មុំ លោក លោកស្រីស្នងការង នាយ នារងការិយាល័យ ទាំង៤ខេត្តរួមមាន ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តស្វាយរៀង និងសមាសភាពពាក់ព័ន្ធជាច្រើនរូបទៀត ។

## រយៈពេល១សប្តាហ៍ចុងក្រោយយ៉ាងហោចណាស់មានពលករខ្មែរជិត១០០នាក់ត្រូវទាហានថៃបង្ក្រាបចាប់ខ្លួនពួកគេឆ្លងដែនចូលទៅកាប់ឈើគ្រញូងក្នុងប្រទេសថៃ

http://nokorwatnews.com/ ថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០១៧

ខេត្តបន្ទាយមានជ័យ៖ បើយោងតាមការដកស្រង់ចេញពីកាសែតក្នុងថៃឱ្យដឹងថា យ៉ាងហោចណាស់មានពលករខ្មែរជិត១០០នាក់នោះហើយ បានរងការង្ក្រាប ចាប់ឃាត់ខ្លួនជាបន្តបន្ទាប់ ក្នុងរយៈពេលមួយសប្តាហ៍ចុងក្រោយនេះ ពីសំណាក់ក្រុមទាហានថៃសហការ និងតម្រួតថៃ ខណៈដែលពួកគេ ត្រូវបានមេក្លោងរកស៊ីធ្វើជំនួញឈើគ្រញូងជនជាតិខ្មែរ និងមេខ្លោងជនជាតិថៃ សហការគ្នាដឹកនាំឆ្លងដែន និងលបលួចចូលទៅកាន់ឈើគ្រញូងតំបន់ឧទ្យានជាតិហាមឃាត់ខុសច្បាប់ក្នុងប្រទេសថៃ។ ការបង្ក្រាបពលករខ្មែរចូលទៅកាប់ឈើគ្រញូងក្នុងដីថៃត្រូវបានសមត្ថកិច្ចថៃចេញប្រតិបត្តិការបង្ក្រាបចំនួន៣ករណីផ្សេងគ្នាឃាត់ខ្លួនពលករខ្មែរសរុប៩៥នាក់។

បើតាមប្រភពព័ត៌មានពីកាសែតថៃឱ្យដឹងទៀតថា ករណីទី១,ពលករខ្មែរ១១នាក់រងការបង្ក្រាបកាលពីយប់ថ្ងៃទី ៣ ខែធ្នូ ឆ្នាំ២០១៧ ត្រង់ចំណុចក្នុងឧទ្យានជាតិ ថាប់ឡាន ស្ថិតក្នុងស្រុកខនបុរី ខេត្តនគររាជសីម៉ាប្រទេសថៃ។ កម្លាំងចម្រុះបានដកហូតនូវវត្ថុតាងមួយចំនួនដូចជារណោយន្ត១គ្រឿង និងឈើគ្រញូងចំនួន ១៤ ដុំ ដែលមានតម្លៃសរុបប្រមាណ ជាង១សែនបាតពលករខ្មែរទាំង១១នាក់កំពុងត្រូវបាននាំខ្លួនយកទៅកាន់ រដ្ឋបាលព្រៃឈើ នៅក្នុងស្រុកខនបុរី ដើម្បីសាកសួរបន្ត និងចាត់ការតាមនីតិវិធីច្បាប់ព្រៃឈើរបស់ប្រទេសថៃ។នៅចំពោះមុខសមត្ថកិច្ចថៃពលករខ្មែរទាំងនោះបានសារភាពថា ពួកគេទាំងអស់គ្នាមានចំនួនប្រមាណជិត ៩០ នាក់ ត្រូវបានជនជាតិខ្មែរ និងថៃនាំឆ្លងដែន និងធ្វើដំណើរចូលទៅក្នុងតំបន់ឧទ្យានជាតិនេះប្រហែល ជាង១សប្តាហ៍ មកហើយ ដើម្បីធ្វើសកម្មភាពកាប់ឈើគ្រញូងនាំយកមកលក់ឱ្យឈ្មួញរកស៊ីឈើគ្រញូងជាជនជាតិខ្មែរ។

ករណីទី២,កាលពីសៀលថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ មានការស្ទាក់ចាប់ពលករខ្មែរដែលបានលបលួចចូលទៅកាប់ឈើគ្រញូងក្នុងតំបន់ឧទ្យានជាតិថាប់ឡានស្ថិតក្នុង ស្រុកខនបុរី ខេត្តនគររាជសីមានោះផងដែរ។ ក្នុងកិច្ចប្រតិបត្តិការនោះសមត្ថកិច្ចថៃបាន ឃាត់ខ្លួនជនជាតិខ្មែរបានចំនួន៣៩នាក់ ព្រមទាំងបានដកហូតឈើគ្រញូងជាច្រើនដុំ។

ករណីទី៣,នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧កម្លាំងចម្រុះថៃ បានរុករក និងឈានដល់ការចាប់ខ្លួនជនជាតិខ្មែរ និងថៃ បន្ថែមទៀត៤៥នាក់ នៅក្នុងតំបន់ឧទ្យានជាតិថាប់ឡាននោះផងដែរ ។ ជនសង្ស័យទាំងអស់បានសារភាពថា ពួកគេសរុបប្រមាណជាង ១០០នាក់ ត្រូវបានមេក្លោងខ្មែរ និង ថៃ បាននាំលួចឆ្លងដែរតាមខ្សែបន្ទាត់ព្រំដែនក្នុងខេត្ត ស្រះកែវ ឈម និងខេត្តបន្ទាយមានជ័យដោយបានបន្តដំណើរលបចូលទៅកាប់ឈើគ្រញូងក្នុងតំបន់ហាមឃាត់ខាងលើ និងជញ្ជូនឈើទាំងនេះចេញមកខាងក្រៅ ដោយទទួលបានកម្រៃក្នុងឈើមួយគីឡូក្រាមចំនួនពី២ម៉ឺនរៀលទៅ៣ម៉ឺនរៀល។

សូមបញ្ជាក់ថា បញ្ហាធ្វើជំនួញឈើគ្រញូងឆ្លងដែនខុសច្បាប់ពីដីថៃចូលមកកម្ពុជាឆ្លងកាត់បន្ទាត់ព្រំដែនត្រូវគេមើលឃើញថាពលករខ្មែរកំពុងមានបញ្ហាប្រឈមគ្រោះថ្នាក់អាចរហូតបាត់បង់ជីវិត និងអាបណ្តាលឱ្យរងរបួសដោយរងការបាញ់ប្រហារពីទាហានថៃជាដើម។

សេចក្តីរាយការណ៍ឱ្យដឹងថា កាលពីប៉ុន្មានខែកន្លងមុននេះមានពលករខ្មែរម្នាក់បានរងការបាញ់ប្រហារបង្កឱ្យរងរបួសនៅក្នុងដីថៃស្ថិតនៅក្នុងស្រុកបរ៉ាយខេត្តត្រាត ប្រទេសថៃ ឈម និងស្រុកសំឡូតខេត្តបាត់ដំបង មិនតែប៉ុណ្ណោះនៅក្នុងតំបន់ឧទ្យានជាតិអភិរក្សខេត្តច័ន្ទបុរី ប្រទេសថៃឈម និងខេត្តប៉ៃលិនក៏ធ្លាប់កើតឡើងពលករខ្មែរមួយចំនួនចូលកាប់ឈើគ្រញូងនៅទីនោះ បានរងការបង្ក្រាបចាប់ខ្លួនផងដែរ។

បញ្ហាការឆ្លងដែនខុសច្បាប់របស់ពលករខ្មែរចូលកាប់ឈើគ្រញូងក្នុងដីថៃត្រូវគេមើលឃើញថា មិនអាចដោះស្រាយបាននោះឡើយគ្រាដែលមានសេចក្តីរាយការណ៍ឱ្យដឹងថា មានសមត្ថកិច្ចមួយចំនួនទាំងសមត្ថកិច្ចកម្ពុជា និងសមត្ថកិច្ចថៃឈរជើងតាមបន្ទាត់ព្រំដែនត្រូវគេដាក់ការសង្ស័យជាប់ព័ន្ធ និងការរកស៊ីឈើគ្រញូងខុសច្បាប និងបើកផ្លូវឱ្យពលករទាំងនោះឆ្លងដែនចូលប្រទេសថៃ ៕ សំវិច្ឆិកា

## រាជរដ្ឋាភិបាលថៃសម្រេចកែសម្រួលច្បាប់ ពលករបរទេសចំនួនពីរច្បាប់

http://www.pheaktraprak.com December 4, 2017

កាលពីថ្ងៃច័ន្ទទី 04 ខែ ធ្នូ ឆ្នាំ2017ព្រឹកនេះ រដ្ឋាភិបាលថៃបានបើកកិច្ចប្រជុំផ្លូវការជាផ្លូវការលើកដំបូងរបស់គណៈរដ្ឋមន្ត្រី 5 ដឹកនាំដោយលោកនាយករដ្ឋមន្ត្រី ប្រយុទ្ធ ចាន់អូចា និង លោក វិស្នូក គ្រឿរងាម ឧបនាយករដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ ក្នុងកិច្ចប្រជុំពិភាក្សាលោកនាយករដ្ឋប្រយុទ្ធចាន់អូចា បានលើកឡើងអំពីបញ្ហាធំៗ មួយចំនួនយកមកពិចារណា ក្នុងនោះមានច្បាប់គ្រប់គ្រងពលករបរទេសបរទេសក្នុងប្រទេសថៃ ចំនួន3ចំណុចត្រូវបានលើកឡើងយកមកពិភាក្សាដោះស្រាយមានដូចខាងក្រោម ។

1- បញ្ហាច្បាប់ស្នាក់អាស្រ័យធ្វើការរបស់ពលករបរទេស នៅអាស័យដ្ឋានថៅកែបន្ទាប់ពីច្បាប់នេះនៅមិនស្របគ្នាជាមួយច្បាប់គ្រប់គ្រងពលករថ្មី ដែលអាចធ្វើឲ្យប៉ះពាល់ដល់ពលករ។ ហើយចំណុចនេះលោកនាយករដ្ឋមន្ត្រី បញ្ជាឲ្យគណៈរដ្ឋមន្ត្រីពាក់ព័ន្ធយកច្បាប់នេះទៅពិចារណាសារឡើងវិញដើម្បីអោយស្របតាមច្បាប់គ្រប់គ្រងថ្មី។

2- បញ្ហាច្បាប់ធ្វើការខុសលក្ខខ័ណ្ឌការងារឬ(ខុសប្រភេទការងារ) ដែលមានអត្រាទោសទណ្ឌខ្ពស់ស្មើនិងទោសជួញដូរមនុស្សខុសច្បាប់ នៅត្រង់ចំណុចនេះលោកនាយករដ្ឋមន្ត្រីប្រយុទ្ធចាន់អូចា បានបញ្ជាអោយគណៈកម្មការរៀបចំច្បាប់យកច្បាប់នេះទៅកែសម្រួលឡើងវិញដើម្បីឲ្យស្របទៅតាមគោលការណ៍នៃច្បាប់អន្តរជាតិ។

3- គណៈរដ្ឋមន្ត្រីថៃក្នុងកិច្ចប្រជុំបានយល់ស្របលើវិសោធនកម្មច្បាប់ ស្តីពីក្រុមហ៊ុននាំចូលពលករ MOU ដែលចូលមកធ្វើការនៅប្រទេសថៃតាមរយៈ MOU ដោយច្បាប់នេះគណៈរដ្ឋមន្ត្រីបានសម្រេចបន្ថែមទិដ្ឋការធ្វើការពីរយៈ2 ឆ្នាំទៅ 5ឆ្នាំ ដោយកំណត់ឲ្យពលករជាអ្នកបង់ថ្លៃច្បាប់អនុញ្ញាតធ្វើការប្រចាំឆ្នាំ។

## រាជរដ្ឋាភិបាលថៃ សម្រេចបន្ថែមរយៈពេលធ្វើការដល់ពលករ MOU

http://www.pheaktraprak.com December 4, 2017

នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីនៅថ្ងៃទី 4 ខែធ្នូ ឆ្នាំ2017នេះ កិច្ចប្រជុំផ្លូវការជាផ្លូវការលើកដំបូងរបស់គណៈរដ្ឋមន្ត្រី 5 ដឹកនាំដោយលោកនាយករដ្ឋមន្ត្រី ប្រយុទ្ធ ចាន់អូចា និង លោក Wissanu Krea Ngam ឧបនាយករដ្ឋមន្ត្រីបានស្នើឡើងថា កិច្ចប្រជុំនេះនឹងអនុម័តសេចក្តីព្រាងច្បាប់មួយចំនួន ដូចជាការសើសុំអនុញ្ញាតជួលពលករបរទេសឲ្យធ្វើការ ឬសុំផ្លាស់ប្តូរប្រភេទការងារ និងស្នើសុំការអនុញ្ញាតការងារ ដល់មន្ត្រីអគ្រានុកូលដ្ឋាន។ ចំពោះក្រុមហ៊ុននាំចូលពលករបរទេស តាមរយៈ MOU គណៈរដ្ឋមន្ត្រីសម្រេចបន្ថែមវិសោធនកម្មនៃអាយុលិខិតឆ្លងដែនរបស់ពលករបរទេសដែលមានអាយុវីសារការងារពី 2 ឆ្នាំដល់ 5 ឆ្នាំ ប៉ុន្តែអ្នកដែលនាំចូលពលករបរទេសត្រូវតែបង់ថ្លៃច្បាប់អនុញ្ញាតធ្វើការបែបប្រចាំឆ្នាំ។

## អាជ្ញាធរថៃចាប់ខ្លួនពលករខ្មែរ១១នាក់ដែលលបលួចនាំឈើគ្រញូង

http://www.rasmeinews.com/ December 5, 2017

(ប្រទេសថៃ)៖អាជ្ញាធរថៃបានឃាត់ខ្លួនពលករខ្មែរចំនួន១១នាក់នៅក្នុងទឹកដីខេត្តនគររាជសីមាក្រោយពីពួកគេទាំងអស់គ្នាលបលួចស្លាយឈើគ្រញូងចេញពីក្នុងតំបន់ឧទ្យានជាតិដែលជាតំបន់ហាមឃាត់របស់ប្រទេសថៃ។ ការឃាត់ខ្លួននេះ ត្រូវបានភាគីថៃ ដែលមានកម្លាំងតម្រួត និងក្រុមអភិរក្សព្រៃឈើថៃ ធ្វើឡើងកាលពីយប់ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៧ ត្រង់ចំណុចក្នុងឧទ្យានជាតិ ថាប់ឡាន ស្ថិតក្នុងស្រុកខនបុរីខេត្តនគររាជសីមា។

ប្រភពព័ត៌មានបានឱ្យដឹងថាប្រតិបត្តិការឃាត់ខ្លួនពលករខ្មែរចំនួន១១នាក់ នៅក្នុងទឹកដីខេត្តនគររាជសីមាប្រទេសថៃនោះ គឺកម្លាំងចម្រុះបានដកហូតនូវវត្ថុតាងមួយចំនួន ដូចជា រណាយន្ត ១គ្រឿង និងឈើគ្រញូងចំនួន ១៤ ផ្ទាំង ដែលមានតម្លៃសរុបប្រមាណជាង ១សែនបាត។ក្នុងនោះ ព្រមទាំងបាននាំខ្លួនយកទៅកាន់រដ្ឋបាលព្រៃឈើ នៅក្នុងស្រុកខនបុរី ដើម្បីធ្វើការសាកសួរបន្ត។

នៅចំពោះមុខសមត្ថកិច្ច ពួកគេបានសារភាពថា ពួកគេទាំងអស់គ្នាមានចំនួនប្រមាណជិត ៩០នាក់ ត្រូវបានជនជាតិខ្មែរ និងថៃ នាំឆ្លងដែន និងធ្វើដំណើរចូលទៅក្នុងតំបន់ឧទ្យានជាតិនេះ ប្រហែលជាង ១សប្តាហ៍ មកហើយ។ ដើម្បីធ្វើសកម្មភាពកាត់ឈើគ្រញូង និងទទួលបានប្រាក់កម្រៃមកវិញ ប៉ុន្តែក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនបានជាបន្តបន្ទាប់។

បច្ចុប្បន្ន សមត្ថកិច្ចជំនាញថៃ កំពុងធ្វើការស៊ើបរកមេខ្លោងដែលនៅពីក្រោយខ្នងពួកគេ ហើយគេក៏ចង់ដឹងដែរថា តើក្រុមនេះ មានការពាក់ព័ន្ធជាមួយនឹងក្រុមជាង ៧០នាក់ ដែលទើបនឹងចាប់ខ្លួនបាន កាលពីពេលថ្មីៗ កន្លងទៅនោះដែរឬទេ?។S/

## អ្នកទោសជនជាតិអាមេរិកកាំងម្នាក់សុំតុលាការកំពូលបន្ថយទោស

http://www.postkhmer.com/ Tue, 5 December 2017 គីម សារុំ

**ភ្នំពេញៈ** បុរសជនជាតិអាមេរិកកាំងម្នាក់កាលពីម្សិលមិញបានស្នើសុំតុលាការកំពូលឲ្យបន្ថយទោសដល់ខ្លួនក្នុងបណ្តឹងសុំស្រួបទោសពាក់ព័ន្ធបទចោទទិញពេស្យាចារកុមារ, រួមភេទជាមួយអនីតិជនក្រោមអាយុ ១៥ ឆ្នាំ និងរក្សាទុកគ្រឿងញៀនកាលពីឆ្នាំ ២០១១ ដែលត្រូវបានតុលាការថ្នាក់ក្រោមផ្តន្ទាទោសដាក់គុក ១០ ឆ្នាំ។ នៅក្នុងអង្គសវនាការដែលមានសមាសភាពចៅក្រម ៥ រូបនោះលោកចៅក្រម ឃឹម ប៉ុណ្ណ ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះបានថ្លែងថាសំណុំរឿងនេះមានជនជាប់ចោទឈ្មោះ James Allan-Morrow ហើយជនជាប់ចោទប្តឹងសារទុក្ខមកតុលាការកំពូលគឺសុំស្រួបទោស។ ទោះយ៉ាងណាលោកថ្លែងប្រាប់មេធាវីរបស់ជនជាប់ចោទថា៖ «សំណុំរឿងនេះតុលាការមិនអាចជំនុំ

ជម្រះបានទេព្រោះជាគោលការណ៍កាលណាជនជាប់ចោទប្ដឹងសុំស្រួបទោសបានលុះណាជនជាប់ចោទមានសាលដីកាស្ដាពរលើសពីមួយហើយច្បាប់កំណត់យកទោសណាខ្ពស់ជាងគេ។ ប៉ុន្តែតុលាការពិនិត្យទៅឃើញថាជនជាប់ចោទមានសាលដីកាតែមួយប៉ុណ្ណោះដូច្នេះមិនអាចជំនុំជម្រះតាមនីតិវិធីបានទេ»។

លោកស្រី ពឹង យុហៀប មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានប្រាប់ចៅក្រមថាកូនក្ដីលោកស្រីត្រូវតុលាការថ្នាក់ក្រោមចោទក្នុង ៣ បទចោទគឺ «ទិញពេស្យាចារកុមារ, រួមភេទជាមួយអនីតិជនក្រោមអាយុ ១៥ ឆ្នាំ និងរក្សាទុកគ្រឿងញៀនខុសច្បាប់»។ ក្នុងបទចោទនេះតុលាការថ្នាក់ក្រោមផ្ដន្ទាទោសកូនក្ដីលោកស្រីចំនួន ១០ ឆ្នាំ។ លោកស្រីថាៈ «ខ្ញុំធ្វើតាមការស្នើរបស់គាត់ទៅព្រោះគាត់អង្វរខ្ញុំដោយសារគាត់ចង់ចេញទៅជួបជុំម្ដាយចាស់ជរារបស់គាត់ និងប្រពន្ធកូនគាត់ហើយគាត់ជាប់គុកបាន ៧ ឆ្នាំហើយ»។ ក្រោយពីការជជែកពិភាក្សាគ្នាមកលោកចៅក្រម ឃឹម ប៉ុណ្ណថ្លែងថាសាលដីកាដែលនឹងសម្រេចថាយ៉ាងណានោះនឹងប្រកាសនៅថ្ងៃទី ១១ ខែធ្នូខាងមុខ។

តាមអង្គហេតុលោក JamesAllanMorrow ត្រូវនគរបាលប្រឆាំងការជួញដូរមនុស្សឃាត់ខ្លួនកាលពីថ្ងៃទី ១១ ខែមិថុនាឆ្នាំ ២០១១ នៅសង្កាត់ផ្សារថ្មីទី ៣ ខណ្ឌដូនពេញដោយជនជាប់ចោទបានទាក់ទងនារីម្នាក់ឲ្យនាំក្មេងស្រីម្នាក់អាយុ ១២ ឆ្នាំមកឱ្យខ្លួន។ សំណុំរឿងនេះត្រូវសាលាដំបូងរាជធានីភ្នំពេញផ្ដន្ទាទោសដាក់គុក ១០ ឆ្នាំចោទពីបទ «ទិញពេស្យាចារកុមារ,រួមភេទជាមួយអនីតិជនក្រោមអាយុ ១៥ ឆ្នាំនិងរក្សាទុកគ្រឿងញៀនខុសច្បាប់» និងបង្គាប់ឲ្យសងជំងឺចិត្តទៅកុមារីរងគ្រោះ ១០ លានរៀលរួមពិន័យប្រាក់ ៥ លានរៀលចូលថវិការដ្ឋផង៕

## កម្ពុជា-ម៉ាឡេស៊ី ចុះ MOU លើការងារសហប្រតិបត្តិការផ្នែកគ្រប់គ្រងកម្លាំងពលកម្ម

http://bayontv.com.kh/ 05/12/2017

ភ្នំពេញ៖ លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឱ្យដឹងថា កម្ពុជា-ម៉ាឡេស៊ី បានចុះ MOU លើការងារសហប្រតិបត្តិការផ្នែកគ្រប់គ្រងកម្លាំងពលកម្មនៅឆ្នាំ២០១៥ ប៉ុន្តែដើម្បីអនុវត្ត MoU នោះ ភាគីទាំងពីរត្រូវមានកិច្ចព្រមព្រៀងជាលក្ខណៈបច្ចេកទេសមួយចំនួនបន្ថែមទៀតដើម្បីការពារ និងគាំពារសិទ្ធិ និងផលប្រយោជន៍របស់ពលករពលការិនីយើង។ លោកបន្តថា អនុស្សារណៈនៃកិច្ចព្រមព្រៀង ដែលអគ្គនាយកដ្ឋានការងារកម្ពុជា បានចុះជាមួយសមាគមទីភ្នាក់ងារពលករម៉ាឡេស៊ីនេះ គឺបានកំណត់យន្តការលម្អិតសម្រាប់ការពារ និងគាំពារដល់ពលករយើង។ អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជាក់ថា ម៉ាឡេស៊ីមិនមានកំណត់កូតានោះទេ គឺអាស្រ័យលើតម្រូវការរបស់និយោជកម៉ាឡេស៊ី និងការស្ម័គ្រចិត្តទទួលយកលក្ខខណ្ឌការងាររបស់ពលករ ពលការិនីកម្ពុជា។ យើងរំពឹងថា នឹងមានការជ្រើសរើស និងចេញដំណើរក្នុងពេលឆាប់ៗខាងមុខនេះ៕

## និយោជកកំពុងភ័យខ្លួន រឿងប្រាក់ពិន័យ ក្រោយពីពលករខុសច្បាប់ជាង ១៣.០០០នាក់ ត្រូវកូរ៉េខាងត្បូងចាប់ខ្លួន

https://www.dap-news.com/kh/ អង្គារ, 05 ធ្នូ ២០១៧ 10:21 ប្រែសម្រួល: ណៃ តុលា ID:014

បរទេស៖ ក្រសួងយុត្តិធម៌របស់កូរ៉េខាងត្បូង បានចាប់ខ្លួនកម្មករបរទេសចំនួន ១៣.២៥៥នាក់ដែលគ្មានឯកសារ និងជនជាតិកូរ៉េខាងត្បូង ២.៥៤៩នាក់ ដែលបានជួលពួកគេនៅឆ្នាំនេះ។

យោងតាមសារព័ត៌មាន Korean Times ចេញផ្សាយនៅថ្ងៃទី០៤ ខែធ្នូ បានឲ្យដឹងថាពលករបរទេសទាំងនោះត្រូវបានចាប់ខ្លួន ក្នុងការបង្ក្រាបយ៉ាងសកម្មពីរលើក។ ការបង្ក្រាបនេះត្រូវបានធ្វើឡើង ដោយមន្ត្រីចំនួន ៦៥៨នាក់មកពីស្ថាប័នរដ្ឋាភិបាលចំនួនបួន គឺក្រសួងយុត្តិធម៌,ក្រសួងការងារ,ទីភ្នាក់ងារនគរបាលជាតិ និងឆ្មាំឆ្នេរសមុទ្រកូរ៉េ។

យោងតាមក្រសួងយុត្តិធម៌ បានឲ្យដឹងថា ជនបរទេសដែលត្រូវបានចាប់ខ្លួន ត្រូវបានគេនិរទេសចេញ ឬត្រូវបានបញ្ជាឱ្យចាកចេញពីប្រទេស ខណៈនិយោជកកូរ៉េ ត្រូវពិន័យជាប្រាក់ចំនួន ២០លានវ៉ុន ស្មើនឹង ១៨.៣៧០ដុល្លារអាមេរិក។ ពាក់ព័ន្ធនឹងបញ្ហានេះដែរ ឧស្សាហកម្មខាងផលិតកម្ម គឺមានភាពងាយរងគ្រោះបំផុត ក្នុងការជួលជនបរទេសខុសច្បាប់ទាំងនោះ ដែលមានចំនួន ៣.២៩១នាក់ នៅក្នុងការបង្ក្រាបចំនួន២ ហើយបន្ទាប់មកឧស្សាហកម្មសំណង់ មានចំនួន ១.៨៦១នាក់ និងឧស្សាហកម្មកម្សាន្ត មានចំនួន ១.០៩៣នាក់៕

## ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៧

## ប្រសាសន៍សំខាន់ៗ សម្តេចតេជោ ហ៊ុន សែន ក្នុងឱកាសជួបសំណេះសំណាល ជាមួយកម្មករ នៅរោងចក្រតំបន់ អូរដឹម

https://www.dap-news.com/kh/ ថ្ងៃពុធ, 06 ធ្នូ ២០១៧ 09:00 ដោយ: ដើមអម្ពិល ID:004

**ភ្នំពេញ៖** ប្រសាសន៍សំខាន់ៗ សម្តេចតេជោ ហ៊ុន សែន ក្នុងឱកាសជួបសំណេះសំណាល ជាមួយកម្មករ នៅរោងចក្រតំបន់ អូរដឹម :

- នៅសល់២៥ថ្ងៃទៀតប៉ុណ្ណោះ យើងចាប់ផ្តើមការអនុវត្តបៀវត្សរ៍ សម្រាប់ឆ្នាំ២០១៨តទៅ ។

- អរគុណក្មួយៗ ដែលគោរពនិងស្រឡាញ់រាប់អានពូ ហើយរាប់អានតាំងពី ជំនាន់ឪពុកម្តាយក្មួយៗ មកម្ល៉េះ។

- ក្នុងខែធ្នូ នេះ មានព្រឹត្តិការណ៍សំខាន់ៗច្រើនណាស់ សម្រាប់ប្រវត្តិសាស្រ្តកម្ពុជា។ ថ្ងៃទី២ធ្នូ ឆ្នាំ១៩៧៨ ជាថ្ងៃបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលគេអាចមើលឃើញ តាមរយៈវីដេអូដែលបន្សល់ទុក រហូតដល់សព្វមានរូបសម្តេច ជា ស៊ីម សម្តេច ហេង សំរិន និងរូបពូផ្ទាល់។ ២ធ្នូ ឆ្នាំ១៩៨៧ ជំនួបចរចា សីហនុ- ហ៊ុន សែន នៅបារាំង ដើម្បីស្វែងរកសន្តិភាព ឆ្ពោះទៅរកការបញ្ចប់ចំបាំង រាំងជល់នៅកម្ពុជា។ ២ធ្នូ ១៩៩៨ ជាការដាក់ចេញនូវគោលនយោបាយត្រីកោណ ដែលគណបក្សប្រជាជនកម្ពុជាឈ្នះឆ្នោត ។ មុំទី១ ការធ្វើសមាហរណកម្មផ្ទៃក្នុង មុំទី២ ការធ្វើសមាហរណកម្មអន្តរជាតិ ឲ្យបានកាន់តែឆាប់ (ទៅយកអសនៈនៅអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិធំៗ រាប់ទាំងអង្គការពាណិជ្ជកម្មពិភពលោក) មុំទី៣ បញ្ហាផ្ទៃក្នុងនិងអន្តរជាតិ ។

- ទាំងអស់នេះ បានក្លាយជាទ្រព្យសំណាង សម្រាប់ក្មួយៗ ដែលបានមកពីសុខសន្តិភាព និងការអភិវឌ្ឍ។ ពូមិនឲ្យក្មួយជឿទេ តែសូមឲ្យក្មួយៗសួរចាស់ៗ ដែលធ្លាប់បានឆ្លងកាត់។

- មុននេះ ខ្ញុំបានទាក់ទងជាមួយសម្តេចក្រឡាហោម លើបញ្ហាប្រជាពលរដ្ឋខ្មែរ នៅសហរដ្ឋអាមេរិក។ ខ្ញុំបានជួបជាមួយឯកអគ្គរដ្ឋទូតកូរ៉េខាងត្បូង ហើយគេ បានកោតសរសើរពលកររបស់យើង ដែលស្តង់ដាខ្ពស់ ហើយនៅប្រទេសថៃ ក៏ដូចគ្នាដែរ ដើម្បីធ្វើឲ្យពលករខ្មែរធ្វើការស្របច្បាប់ ទទួលបានអត្ថប្រយោជន៍ ដូចពលករថៃ ហើយពលករមិនស្របច្បាប់ ឲ្យទៅជាស្របច្បាប់។ កម្ពុជា អាមេរិក យើងមានកិច្ចព្រមព្រៀងស្តីពីការបញ្ជូនពលរដ្ឋកម្ពុជា ដែលមានទោស ត្រឡប់មកកម្ពុជា វិញ។ ហើយថ្មីៗចុងក្រោយនេះ មានការចង់បញ្ជូនពលរដ្ឋកម្ពុជា ដែលមានទោសត្រឡប់មកវិញ ប៉ុន្តែយើងបានគិតពីសុខទុក្ខ របស់អ្នកទាំងនោះ ដោយស្នើឲ្យអាមេរិក ពិនិត្យនិងព្យាបាលអ្នកទាំងឡាយ ដែលមានជំងឺ ជាមុនសិន។ ក្រសួងការបរទេស និង ក្រសួងមហាផ្ទៃ ធ្វើការចរចាជាមួយអាមេរិក លើបញ្ហានេះឡើងវិញ។ ឥឡូវនេះ អាមេរិកដល់ខ្លួនចេញពីអង្គការអន្តោប្រវេសន៍អន្តរជាតិ ទៅទៀត។ តាមរយៈនេះ ស្នើឲ្យអគ្គរដ្ឋទូត អាមេរិកប្រចាំកម្ពុជា បញ្ជូនសារនេះ ទៅរដ្ឋធានីវ៉ាស៊ីនតោន ថា សូមឲ្យអនុវត្តកិច្ចព្រមព្រៀងដែលមានស្រាប់ រវាងប្រទេសទាំងពីរ កម្ពុជា អាមេរិក និងសូមឲ្យអាមេរិក ផ្តល់ការផ្គត់ផ្គង់និងការឧបត្ថម្ភខ្លះ ដល់អ្នកទាំងនោះ។

- អ្វីដែលក្មួយ មាននៅដៃ ត្រូវរក្សាឲ្យបាន ។

- ម្សិលមិញនេះ ជនក្បត់ជាតិ ប្រកាសធ្វើសង្គ្រាម ជាមួយកម្ពុជា ក្បត់ជាតិ តពូជ ដែលបានអំពាវនាវឲ្យកងទ័ពបែរកាណុងប្រឆាំងរាជរដ្ឋាភិបាល។ ជនក្បត់ជាតិ មិនស្គាល់ច្បាស់ពីស្ថានភាពពិតនៅកម្ពុជាទេ ជនក្បត់ជាតិឯងមិនស្គាល់ កងទ័ពនៅកម្ពុជាទេ។

- នៅថ្ងៃនេះ ខ្ញុំដឹងថា អគ្គមេបញ្ជាការកងទ័ពកម្ពុជា ព្រមទាំងកងទ័ពកម្ពុជា នឹងពាក្យបណ្ដឹងទៅតុលាការ លើបញ្ហានេះដែរ។

- គេបានប្រកាសតាំងពីឆ្នាំ២០១១ ពីការអំពាវនាវឲ្យកងទ័ព ប្រឆាំរាជរដ្ឋាភិបាល ហើយម្សិលមិញនេះ គេបានធ្វើម្តងទៀត។ មកៗ ខ្លួនឯងតែម្តងមក ហើយបញ្ចេញទាហានមក ទាហានណាបះបោរ ហើយមានជំនួយពីបរទេសទៀត ក៏សូមអញ្ជើញមក តែខ្ញុំសូមប្រាប់ទៅវិញ ហ៊ុន សែន ម្នាក់នេះ នឹងមិនអនុញ្ញាតិ ឲ្យមានសង្គ្រាមកើតឡើង នៅកម្ពុជា ជាដាច់ខាត។ ហ៊ុន សែន បានធ្វើការប្រឆាំងនឹងរបបប៉ុលពត ទប់ស្កាត់ការវិលត្រឡប់នៃរបបប៉ុល ពត ស្វែងរកសន្តិភាព និងការអភិវឌ្ឍ។ យើងបានអនុវត្តច្បាប់ ដើម្បីទប់ស្កាត់និងបញ្ចៀសនូវសង្គ្រាម។

-យើងក៏ត្រូវទិញទំនិញពីបង់ក្លាដែស ហើយបង់ក្លាដែសក៏ទិញទំនិញពីកម្ពុជាដែរ។ ត្រូវបង្កើនប្រាក់ចំណូលរបស់កម្មករ។

-សម្តេចតេជោ បានផ្តាំទៅក្រុមយុវជនកម្ពុជាត្រូវកសាងខ្លួនឲ្យល្អ កុំសេពគ្រឿងញៀន ល្បែងស៊ីសង។ សម្តេចបញ្ចប់កិច្ចសំណេះសំណាល នៅម៉ោង៩និង៥៩នាទី៕

## ថៃបញ្ជូនសពមកខ្មែរវិញ ដោយម្នាក់ស្លាប់ដោយសារកែវទឹកនិងម្នាក់ទៀតខ្យល់គ

ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៧ ម៉ោង ១៧:០៦ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ សព២នាក់ត្រូវបានភាគីថៃធ្វើការបញ្ជូនប្រគល់ឱ្យសាច់ញាតិក្នុងពេលតែមួយតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ម្នាក់ដេកស្លាប់សង្ស័យខ្យល់គ និងម្នាក់លង់ទឹកព្រោះតែកែវទឹក១ ។ ជនរងគ្រោះដេកស្លាប់ជាកម្មករសំណង់នៅក្រុងបាងកកប្រទេសថៃគឺឈ្មោះ ត្រួត ប្រុសតូច ភេទប្រុស អាយុ២០ឆ្នាំ ខេត្តក្រចេះ ។ តាមសាច់ញាតិសពប្រាប់ថា ជនរងគ្រោះបានដេកស្លាប់កាលពីយប់ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៧ សង្ស័យខ្យល់គ ។ ដោយឡែកជនរងគ្រោះលង់ទឹកជាកុមារា អាយុ៦ឆ្នាំ ឈ្មោះ ស៊ីក វ៉ាន់វ៉ាំ បានស្លាប់ដោយលង់ទឹកនៅខេត្តសាក៉ាប់ប៉ូរី និងមានទីលំនៅភូមិពង្រ ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។ ក្មេងរងគ្រោះលង់ទឹកស្លាប់កាលពីព្រឹកថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧ ។ តាមសាច់ញាតិសពប្រាប់ថា ឪពុកម្តាយក្មេងរងគ្រោះជាអាជីវករលក់បន្លែក្នុងខេត្តកើតហេតុខាងលើ ។

ពួកគាត់បន្តទៀតថា ស្ត្រីជាម្តាយលក់យប់អត់ងងុយក៏ដេកថ្ងៃ ឯឪពុករវល់ទៅលើកដាក់បន្លែពីរថយន្តដោយឡែកក្មេងរងគ្រោះទៅរៀនសាលារដ្ឋរបស់ថៃ ។ ពេលក្មេងរងគ្រោះចេញពីសាលាដល់បន្ទប់ជួលក៏មានក្មេងៗជិតខាងបបួលទៅលេងទឹកបន្តដោយមិនទាន់ទាំងដោះខោអាវជាសិស្សទុកផង ។ ពួកគាត់ថាសិស្សតូចៗនៅស្រុកថៃគ្រូៗចែកកែវទឹកជ័រម្នាក់១សម្រាប់ផឹកនៅសាលាហើយដោយសារពេលទៅលេងមាត់ទឹកក្មេងរងគ្រោះជ្រុះកែវជ័រនោះចូលក្នុងស្រះសង្ស័យគេភ័យខ្លាចបាត់កែវពេលទៅរៀនគ្រូវាយក៏ចុះតាមយកកែវទឹកវិញទើបបណ្តាលឲ្យលង់ស្លាប់តែម្តង ៕

## លក្ខខ័ណ្ឌ 5ចំណុច ដែលពលករ MOU គួរស្វែងយល់

http://www.pheaktraprak.com December 6, 2017

ចំពោះពលករបរទេសភាគច្រើន ដែលចំណាក់ស្រុកមកធ្វើការនៅប្រទេសថៃ មិនបានយល់ដឹងអំពីច្បាប់ទំលាប់របស់ប្រទេសគេឡើយ។ នៅថ្ងៃនេះខ្ញុំសូមលើកយកករណីមួយដែលបានកើតឡើងកាលពីពេលថ្មីកន្លងទៅនេះ បន្ទាប់ពីទំព័រហ្វេសប៊ុកឈ្មោះ ต่างด้าว បានចែករំលែកអំពីករណីកម្មករធ្វើការនៅរោងចក្រមួយកន្លែងនៅក្នុងប្រទេសថៃ បានធ្វើកូដកម្មទាមទារពីក្រុមហ៊ុន ដែលពួកគេកំពុងធ្វើការដោយមិនបានយល់ដឹងអំពីសភាពការណ៍នៅក្នុងពេល

បច្ចុប្បន្នរបស់ប្រទេសថៃ។ ដោយទំព័រហ្វេសប៊ុកខាងលើបានរៀបរាប់អធិប្បាយអំពីលក្ខខណ្ឌចំនួន 5 ចំណុចអោយពលករបរទេស ដែលជួបករណីបែបនេះបានយល់ដឹងខ្លឹមសារនៃលក្ខខ័ណ្ឌទាំង5 ចំណុចមានដូចខាងក្រោម៖

១-ហាមកម្មករធ្វើការប្រមូលផ្តុំគ្នាឬធ្វើកូដកម្មតវ៉ាដោយមានមនុស្សលើសពី 5នាក់ គណៈពេលកំពុងស្ថិតនៅក្រោមច្បាប់ការគ្រប់គ្រងរបស់(គសខ)។

២-ការទាមទារតវ៉ាសូមកុំធ្វើ-តែត្រូវទំនាក់នងទៅក្រុមហ៊ុនដែលនាំពលករចូល ហើយរាយការណ៍អំពីករណីកើតឡើង។

៣-ករណីមានរឿងអយុត្តិធម៌នៅក្នុងរោងចក្រត្រូវរាយការណ៍ទៅក្រសួងការងារតាមរយៈលេខទូរស័ព្ទ 1694 ឬ 1111 ក្រសួងសង្គមកិច្ចការងារ។

៤-ត្រូវដឹងថា ក្នុងរយៈពេល15ថ្ងៃ ពលករអាចធ្វើការសុំប្តូរថៅកែថ្មីបាន តែត្រូវទំនាក់ទំនងក្រុមហ៊ុនដែលនាំយើងចូលមកធ្វើការ។

៥-លក្ខខ័ណ្ឌក្នុងការជួលពលករមកធ្វើការបានកំណត់យ៉ាងច្បាស់លាស់ ក្នុងរយៈពេល15ថ្ងៃករណីរកថៅកែថ្មីមិនបាន ក្រុមហ៊ុនត្រូវបញ្ជូនពលករអោយវិលត្រឡប់ទៅស្រុកកំណើតវិញតាមសភាពធម្មតា។

## **វិធីស្នើរសុំទិដ្ឋាការវីសារការងារឆ្នាំ2020**

http://www.pheaktraprak.com December 6, 2017

បាទនៅថ្ងៃនេះខ្ញុំសូមប្រែសម្រួលអត្ថបមួយដែលខ្ញុំបានដកស្រង់ចេញពីទំព័រហ្វេសប៊ុក(ผู้ประกอบการใช้แรงงานต่างด้าว អត្ថបទខាងលើនេះទាក់ទងនឹងវិធីសាស្រ្តក្នុងការស្នើសុំទិដ្ឋាការវីសារការងារឆ្នាំ2020 របស់បងប្អូនពលករធ្វើការនៅក្នុងប្រទេសថៃ ។វិធីសាស្រ្តក្នុងការស្នើសុំមានដូចខាងក្រោម៖

ជំហានដំបូងបងប្អូនត្រូវពិនិត្យមើលលិខិតឆ្លងដែនធ្វើការរបស់បងប្អូនជាមុនសិនតើផុតកំណត់នៅថ្ងៃ 31.12.2018 ដែរឬទេ ? បើផុតសូមចាប់ដំណើរការដូចខាងក្រោម៖

បញ្ជាក់:ទីតាំងដែលអាចដំណើរការស្នើសុំទិដ្ឋាការីសា ឆ្នាំ2020 បានមានតែពីន្លែងប៉ុណ្ណោះទី1 (តម៉)ខេតជនមឿង ទី2 (តម៉)ខេតវ៉ាតប៉ូរណៈ។

១-រៀបចំឯកសារសម្រាប់ដំណើរការស្នើសុំទិដ្ឋការវីសាការងារ ឆ្នាំ2020

២-ឯកសារទាំងអស់នេះបងប្អូនចូលទៅទាញយកបានតាមរយ: internet ឬវេបសាយក្រសួងការងារថៃ
៣-តំលៃសេវាកម្មចំនួន500฿

៤-ថៅកែថៃអាចផ្ទេរសិទ្ធិអោយអ្នកដ៏ទៃទៅស្នើសុំជំនួសបាន(ចំពោះបុគ្គលមានសញ្ជាតិថៃប៉ុណ្ណោះ) ត្រូវប្រើសំណុំបែបបទរបស់(ตม) ប៉ុណ្ណោះ (តាមការបញ្ជាក់នៅក្នុងឯកសារ)

៥-លិខិតឆ្លងដែនដែលត្រូវយកស្នើសុំvisa ត្រូវមានសុពលភាពលើស 31.12.2020 ទើបអាចស្នើសុំវីសាឆ្នាំ 2020 បាន។ ក្នុងករណីអ្នកមានលិខិតឆ្លងដែនធ្វើការទិដ្ឋាការវីសារការងារផុតកំណត់ថ្ងៃ 31.03.2018 ភាគច្រើនជាអ្នកចូលមកធ្វើការនៅប្រទេសថៃយូរមកហើយ ដូច្នេះត្រូវទៅទំនាក់ទំនងមន្ទីរការងារថៃធ្វើឯកសារបញ្ជាក់ដើម្បីប្តូរលិខិតឆ្លងដែនថ្មីទើបអាចតទិដ្ឋការវីសារការងារ ឆ្នាំ2020បាន។

ក្នុងការប្រែសម្រួលអត្ថបទខាងលើនេះបើសិនជាមានកំហុសខុសឆ្គង អក្សរត្រង់ចំណុចណា សូមប្រិយមិត្តអ្នកអានមេត្តាអធ្យាស្រ័យ។ ហើយការប្រែសម្រួលអត្ថបទទាំងអស់នេះ ដើម្បីជាប្រយោជន៍ដល់បងប្អូនពលករខ្មែរដែលកំពុងធ្វើការក្នុងប្រទេសថៃ។ អ្នកប្រែសម្រួល: PrakPheakTra

## រដ្ឋមន្ត្រីក្រសួងការងារថៃថ្មី ជួបសំណេះសំណាលជាមួយពលករភូមា

http://www.pheaktraprak.com December 6, 2017

លោករដ្ឋមន្ត្រីក្រសួងការងារថៃថ្មី ជួបសំណេះសំណាលជាមួយបងប្អូនពលករភូមា ដែលមកបញ្ជាក់អត្តសញ្ញាណនៅក្នុងខេត្តសាមុតសាខនប្រទេសថៃ។ ក្នុងឱកាសចុះត្រួតពិនិត្យការិយាល័យបញ្ជាក់អត្តសញ្ញាណជូនពលករភូមានៅក្នុងខេត្តសាមុតសាខនប្រទេសថៃកាលពីពេលថ្មីកន្លងទៅនេះ លោក អាប់ឌុន សែងសិងកែវ រដ្ឋមន្ត្រីក្រសួងការងារថៃថ្មី បានជួបសំណេះសំណាលជាមួយបងប្អូនពលករភូមា ដែលមកត្រួតសញ្ជាតិធ្វើប៉ាស្ព័រនៅការិយាល័យបញ្ជាក់អត្តសញ្ញាណយ៉ាងជិតស្និទ្ធបំផុត។ ហើយមិនត្រឹមតែប៉ុណ្ណោះទេលោករដ្ឋមន្ត្រីព្រមទាំងបានសន្យាចំពោះពលករភូមា ដែលមានកូនក្មេងតូចៗតាមឪពុកម្តាយមកធ្វើការនៅប្រទេសថៃថា លោកនិងមើលថៃកូនរបស់របស់ពលករទាំងនោះយ៉ាងយកចិត្តទុកដាក់បំផុត។ ខបគុណខ្ញុំមូលពីក:ThairathNews

## ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៧

## មេបញ្ជាការរងៈការពារព្រំដែនលេខ ៤០៥ ល្បីខាងកាងពលករឆ្លងដែនកាប់ឈើក្រញូង យកម្នាក់២២ម៉ឺនរៀល

http://ann.com.kh/site/news/ ថ្ងៃព្រហស្បតិ៍, 7 ខែធ្នូ 2017 10:49 ព្រឹក

**ខេត្តព្រះវិហារ៖** លោកវរសេនីឯក រាម ខេត មេបញ្ជាការរងការពារព្រំដែន៤០៥ នៅតំបន់សមរភូមិមុខទិសទី០១ ស្រុកជាំក្សាន្ត កំពុងតែល្បីឈ្មោះបោះសំឡេងក្នុងមុខជំនួញចរាចរឈើក្រញូង និងកាងពលករឆ្លងដែនចូលទៅក្នុងទឹកដីថៃ តាមច្រករបៀងចំនួន៣ គឺច្រករបៀងដំណាក់ទឹក ច្រកកណ្តាល និងច្រករបៀងឈើទាលគង ក្នុងឃុំជាំក្សាន្ត។ ជាក់ស្តែង កាលពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧ មានសេចក្តីរាយការមកថា មានពលករប្រមាណជាង៦០នាក់បាននាំគ្នាឆ្លងដែនទៅកាប់ឈើក្រញូងក្នុងទឹកដីថៃ តាមច្រកទាំងបីខាងលើ ដោយមេការបានឆ្លើយថា ក្នុងម្នាក់បានបង់ប្រាក់អោយទៅលោកមេបញ្ជាការរងៈការពារព្រំដែន405ចំនួន 220.000រៀល។ ក្នុងនោះមានមេការចំនួនពីនាក់ប្តីប្រពន្ធជាអ្នកនាំផ្លូវយកក្នុងមួយគីឡូ មួយពាន់រៀលផ្សេងទៀត។ មេខ្យល់ទាំង២នាក់នោះ ត្រូវបានគេស្គាល់ឈ្មោះ ម៉ឺន ភេទប្រុស និងប្រពន្ធឈ្មោះ អូន ឌីណា។ ពីរនាក់នេះត្រូវបានគេដឹងថា ជាសេនាវីយោប្រម៉ូលពលករឆ្លងដែនជំនួសមុខអោយលោកមេបញ្ជាការ រាម ខេត។

ពាក់ព័ន្ធករណីនេះអភិបាលស្រុកជាំក្សាន្ត លោក ជាគឹម សេង បានអោយដឹងថា លោកទទួលស្គាល់ចំពោះពលករឆ្លងដែនយ៉ាងគគ្រឹកគគ្រេងបែបអនាធិបតេយ្យពិតប្រាកដមែន ប៉ុន្តែលោកមិនអាចមានសមត្ថភាពទប់ស្កាត់

បានទេពីព្រោះតំបន់ព្រំដែននោះគ្រប់គ្រងដោយកងកំលាំងយោធា។ លោកបានបន្តថា សូម្បីតែរូបលោកចង់ចូលទៅមើលសកម្មភាពនោះក៏មិនបានផង ព្រោះត្រូវរារាំងដោយកងកំលាំងយោធាវរៈការពារព្រំដែន405របស់លោក រាម ខេត។ លោកថា លោកក៏ធ្លាប់ប្រាប់ទៅកាន់យោធាឈរជើងនៅតំបន់ខាងលើថា លោកជាចៅហ្វាយស្រុក តែមន្ត្រីយោធារបស់លោករាមខេត ឆ្លើយតបមកលោកវិញថា ទោះជាចៅហ្វាយស្រុក ឬអ្នកណាក៏ដោយ បើគ្មានបទបញ្ជាពីលោករាមខេតទេ គឺមិនអោយចូលទៅក្នុងតំបន់បទល្មើសជាច់ខាត។ ជុំវិញករណីខាងលើក្រុមការងារយើងមិនអាចសុំការបំភ្លឺពីលោក រាម ខេត បានទេ ព្រោះទូរសព្ទ័ចុចទៅជាប់រវល់៕ **អត្ថបទដោយ៖** *សួន ក្រែង*

## ពលរដ្ឋប្រុស ស្រីចូលទៅធ្វើការផ្នែកកាប់អំពៅនៅប្រទេសថៃរយៈពេល៤ថ្ងៃមាន៤០៦៩នាក់ តាមច្រកភ្នំដី ស្រុកសំពៅលូន

http://nokorwatnews.com/ ថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០១៧

ខេត្តបាត់ដំបង៖ ប្រជាពលរដ្ឋខ្មែរប្រុស ស្រីក្មេងចាស់ជាច្រើនរយនាក់នៅតាមបណ្តា ស្រុកក្រុងខេត្តបាត់ដំបង បាននាំគ្នាចាកចេញពីភូមិកំណើតរបស់ខ្លួនចូលទៅប្រកបការងារនៅប្រទេសថៃ តាមច្រកទ្វារព្រំដែនគីឡូម៉ែត្រ១៣ (ហៅច្រកភ្នំដី )បិតក្នុង ស្រុកសំពៅលូន ចាប់តាំងពីថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៧ រហូតមកដល់ថ្ងៃទី០៥ ខែ ធ្នូ ឆ្នាំ២០១៧ មានចំនួនសរុប៤០៦៩នាក់ ក្នុងនោះ ស្រីចំនួន១២៣៦នាក់ ចំណែកកុមារចំនួន៩៩៥នាក់។

នេះបើតាមសម្តីលោក អនុសេនីយ៍ កែវ ឌឿន មេប៉ុស្តិ៍គីឡូម៉ែត្រលេខ១៣ បានបញ្ជាក់ប្រាប់អ្នកយកព័ត៌មាននៅរសៀលថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៧នេះតាមទូរស័ព្ទថា ពលរដ្ឋខ្មែរជាច្រើនរយពាន់នាក់ កំពុងឈរតម្រង់ជួរដើម្បីឲ្យកម្លាំងនគរបាល បំពេញបែបបទ បានចូលធ្វើការ(កាប់អំពៅ) របស់សហគមន៍ថៃចំនួន៤ខេត្ត មានខេត្តស្រះកែវ ខេត្តឈុនបុរី ខេត្តចន្ទ័បុរី និងខេត្តសាក់សើងសៅ (ប្រទេសថៃ) ក្នុងការបើកឲ្យចូលនេះផងដែរ គឺមិនត្រូវបានបង់ប្រាក់ឲ្យកម្លាំងសមត្ថកិច្ចនោះទេ។ លោកថា ពលរដ្ឋខ្មែរដែលចូលទៅបម្រើការនៅប្រទេសថៃនោះ គឺពួកគាត់បានទៅបំពេញបែបបទ នៅសមាគម កន្លែងការងារក្នុងស្រុកខ្លងហាត ប្រទេសថៃរួចរាល់ ខាងសមាគម ឲ្យប្រជាពលរដ្ឋកាន់កាតវិលមកតាមច្រកភ្នំដីវិញ រួចហើយឲ្យចូលតាមច្រកទ្វារអន្តរាជាតិប៉ោយប៉ែត ក្នុងទឹកដីខេត្តបន្ទាយមានជ័យឆ្លងកាត់ខេត្តស្រះកែវ(ប្រទេសថៃ) ទើបខាងថៅកែថៃមកទទួល ដើម្បីចូលទៅស្របច្បាប់ ។

ប៉ុន្តែពេលនេះ ប្រជាពលរដ្ឋខ្មែរដែលចូលទៅធ្វើការនៅប្រទេសថៃ ពួកគាត់កំពុងតែបោះជំរុំនៅតាមចំការអំពៅរបស់ថៅកែថៃ ដើម្បីរង់ចាំបំពេញបែបបទ ប៉ុន្តែវគ្គទី១ គាត់នឹងវិលត្រឡប់ពីស្រុកក្លងហាត (ប្រទេសថៃ) មកវិញ តាមច្រកភ្នំដីចាប់ពី៨០០នាក់ទៅ១០០០នាក់ នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៧ ដើម្បីចូលទៅថៃ តាមច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែតវិញ។

ការធ្វើដំណើររបស់ប្រជាពលរដ្ឋទៅស៊ីឈ្នួលកាប់អំពៅនៅប្រទេសថៃនោះមានរយៈពេលពី៣ទៅ៤ខែ អស់រដូវកាលកាប់អំពៅ ទើបត្រឡប់មកស្រុកកំណើតវិញ ម្យ៉ាងវិញទៀតពលរដ្ឋខ្មែរដែលចូលទៅកាប់អំពៅនៅសហគមន៍ថៃមានចំនួន៤ខេត្តនោះ ចំពោះបញ្ហាសុខភាព ខាងថៅកែថៃគាត់ជាអ្នករ៉ាប់រងព្យាបាលមកលើពលរដ្ឋផងដែរ ៕ វណ្ណា

## រដ្ឋាភិបាលជំរុញឲ្យបង្កើនកូតានាំពលករទៅកូរ៉េខណៈឡាវមានកិច្ចព្រមព្រៀងថ្មី

http://www.postkhmer.com/ Wed, 6 December 2017 បែន សុខហ៊ាន

**ភ្នំពេញ៖** រដ្ឋាភិបាលកម្ពុជាកំពុងជំរុញឱ្យបង្កើនកូតានាំពលករទៅកូរ៉េខាងត្បូង ខណៈមានការបារម្ភពីការថយចុះកូតានេះដោយសារមានកិច្ចព្រមព្រៀងថ្មីមួយជាមួយឡាវ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីថ្ងៃ៦ ធ្នូនេះបានថ្លែងថា លោកបានជួបជាមួយឯកអគ្គរដ្ឋទូតថ្មីរបស់កូរ៉េកាលពីថ្ងៃអង្គារ។

លោកបានប្រាប់កម្មកររោងចក្រថា៖«ពួកគេបានចាត់ទុកពលករកម្ពុជាថាមានស្តង់ដារ ការគោរពវិន័យនិងមានវិជ្ជាជីវៈខ្ពស់ ឯកឧត្តម អ៊ិត សំហេង ត្រូវពិភាក្សាជាមួយភាគីកូរ៉េ ដើម្បីបង្កើនកូតាសម្រាប់នាំពលករខ្មែរទៅនៅកូរ៉េ»។

លោកឡុង ឌីម៉ង់ ឯកអគ្គរាជទូតកម្ពុជាប្រចាំកូរ៉េខាងត្បូង បានថ្លែងកាលពីថ្ងៃអង្គារថា លោកបារម្ភថាកូតាអាចនឹងកាត់បន្ថយពេលកូរ៉េទើបចុះកិច្ចព្រមព្រៀងមួយជាមួយឡាវ ខណៈពេលនេះលោកថា មានពលរដ្ឋកម្ពុជាប្រមាណ៦០.០០០នាក់កំពុងរស់នៅ និងធ្វើការនៅប្រទេសនេះ ហើយលោកសូមរក្សាកូតានៅចន្លោះពី៨០០០ទៅ៩០០០នាក់។

ប៉ុន្តែអ្នកនាំពាក្យក្រសួងការងារលោក ហេង សួរ បានថ្លែងថា មិនចាំបាច់បារម្ភទេដោយលោកបានបញ្ជាក់តាមរយៈសារមួយថា៖«[សាធារណរដ្ឋកូរ៉េ]តែងរក្សាទុកកូតាមួយសិតសម្រាប់ហេតុផលពិសេសនិងសំណូមពររបស់មិត្តភក្តិជិតស្និទ្ធ។ ដូច្នេះហើយដោយមានសំណូមពរជាពិសេសរបស់សម្តេចនាយករដ្ឋមន្ត្រីហ៊ុនសែននោះចំនួនកូតាសរុបសម្រាប់ពលករកម្ពុជានៅឆ្នាំ២០១៨នឹងមិនត្រូវបានបដិសេធនោះទេប៉ុន្តែនឹងកើនឡើង»។ ស្ថានទូតកូរ៉េខាងត្បូងមិនអាចទាក់ទងបានទេ៕ NS/រាយការណ៍បន្ថែមដោយ Leonie Kijewski

## កូរ៉េចាត់ទុកពលករខ្មែរ មានស្តង់ដារខ្ពស់

https://www.dap-news.com/kh/ ថ្ងៃពុធ, 06 ធ្នូ ២០១៧ 15:50 ដោយ: ដើមអម្ពិល ID:012

ភ្នំពេញ ៖ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា បានថ្លែងថា ប្រទេសកូរ៉េបានចាត់ទុកពលករខ្មែរ មានស្តង់ដារស្តស់ និងចេះគោរពវិន័យត្រឹមត្រូវ។

សម្តេចតេជោ បានថ្លែងក្នុងពិធីជួបសំណេះសំណាល ជាមួយកម្មករជាង១ម៉ឺននាក់ នៅព្រឹក ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៧ថា នៅកូរ៉េមានព័ត៌មានល្អ គឺកូរ៉េចាត់ទុកថា កម្មករ កម្មការិនីកម្ពុជា មានស្តង់ដារ ការគោរពវិន័យ និងមានវិជ្ជាជីវៈ ខ្ពស់ណាស់ ។ សម្តេចបន្តថា ឆ្នាំក្រោយ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ ត្រូវពិភាក្សាជាមួយ ភាគីកូរ៉េ ដើម្បីបង្កើនកូតា សម្រាប់នាំ ពលករខ្មែរទៅធ្វើការនៅកូរ៉េ ។ សម្តេចថា នៅថៃក៏ រាជរដ្ឋាភិបាលកម្ពុជា បានខិតខំធ្វើការ ជាមួយភាគីថៃ ដើម្បីឲ្យកម្មករស្របច្បាប់ ទទួលបាន អត្ថប្រយោជន៍ផ្សេងៗបន្ថែម និងកម្មករមិនស្របច្បាប់ ឲ្យទទួលបានភាពស្របច្បាប់ ធ្វើការនៅ ថៃផងដែរ ៕

## ពលករខ្មែរចំនួន16នាក់បានរងរបួសធ្ងន់ នៅក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរឡានបុកគ្នាកាលពីយប់មិញ

http://www.pheaktraprak.com December 7, 2017

កាលពីវេលាម៉ោង08:40នាទីយប់ថ្ងៃពុធទី06 ខែធ្នូ ឆ្នាំ2017 មានករណីរថយន្តដឹកពលករខ្មែរវិលត្រឡប់មកពីធ្វើការជួបគ្រោះថ្នាក់ចរាចរបុកជាមួយរថយន្តដឹកកុងតឺន័រ នៅក្នុងខេត្តឈុនបុរី បណ្តាលឲ្យពលករខ្មែរចំនួន16នាក់និងថៃ2 នាក់បានរងរបួសធ្ងន់។ ករណីគ្រោះថ្នាក់ចរាចរដ៏រន្ធត់នេះបានកើតឡើងនៅវេលាម៉ោង08:40នាទីយប់ ស្ថិតនៅត្រង់ចំណុចក្បែរផ្លូវរថភ្លើង ជាប់និងផ្លូវជាតិ(បានកោ) ក្នុងស្រុកផាន់ថង ខេត្តឈុនបុរី ប្រទេសថៃ ប្រភពពីកន្លែងកើតហេតុបានឲ្យដឹងថារថយន្តម៉ាកអ៊ីស៊ុយស៊ុយ ពណ៌ខ្មៅ ពាក់ស្លាកលេខ 1756 ឈុនបុរី ជ្រុលចង្កូតបុកបុកគូទរថយន្តដឹកកុងតឺន័រយ៉ាងពេញ នៅលើផ្លូវជាតិ ផាន់ថង-ឈុនបុរី បណ្តាលឲ្យកម្មករខ្មែរដែលជិះនៅលើរថយន្តអ៊ីស៊ុយស៊ុយចំនួន16នាក់រងរបួសធ្ងន់។ បញ្ជីឈ្មោះពលករខ្មែររងគ្រោះនៅក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរនេះ។

១.ឈ្មោះ នី (ប្រុស) អាយុ30ឆ្នាំ សញ្ជាតិខ្មែរ
២.ឈ្មោះ សៀវ មឿន (ប្រុស) អាយុ40ឆ្នាំ សញ្ជាតិខ្មែរ
៣.ឈ្មោះ ហេង (ប្រុស) អាយុ 32ឆ្នាំ សញ្ជាតិខ្មែរ
៤.ឈ្មោះ រ៉ន ឆាង (ប្រុស) អាយុ43ឆ្នាំ សញ្ជាតិខ្មែរ
៥.ឈ្មោះ មួនលឿន (ស្រី) អាយុ 33ឆ្នាំ សញ្ជាតិខ្មែរ
៦.ឈ្មោះ ដន (ស្រី) អាយុ 30ឆ្នាំ សញ្ជាតិខ្មែរ
៧.ឈ្មោះ ភាព (ស្រី) អាយុ 27ឆ្នាំ សញ្ជាតិខ្មែរ
៨.ឈ្មោះ សន ធុង (ប្រុស) អាយុ22ឆ្នាំ សញ្ជាតិខ្មែរ

៩.ឈ្មោះ តើយ (ប្រុស) អាយុ36ឆ្នាំ សញ្ជាតិខ្មែរ
១០.ឈ្មោះ ហួយ (ប្រុស) អាយុ18ឆ្នាំ សញ្ជាតិខ្មែរ
១១.ឈ្មោះ ថម ជីន (ប្រុស) អាយុ42ឆ្នាំ សញ្ជាតិខ្មែរ
១២.ឈ្មោះ សាន់ (ប្រុស) អាយុ43ឆ្នាំ សញ្ជាតិខ្មែរ
១៣.ឈ្មោះ មុន (ស្រី) អាយុ 37ឆ្នាំ សញ្ជាតិខ្មែរ
១៤.ឈ្មោះ svay Nhoem (ស្រី) អាយុ37ឆ្នាំ សញ្ជាតិខ្មែរ
១៥.ឈ្មោះ Sophy soeurn (ប្រុស) អាយុ37ឆ្នាំ (ខ្មែរ)
១៦.ឈ្មោះ Noey sien (ស្រី) អាយុ24ឆ្នាំ សញ្ជាតិខ្មែរ
១៧.ឈ្មោះ ភិស្នុក សុថានី (ប្រុស) អាយុ38ឆ្នាំ (ថៃ)
១៨.ឈ្មោះ ថងថង អែងវ៉ែសិម (ប្រុស) អាយុ32ឆ្នាំ (ថៃ)

បច្ចុប្បន្នពលករខ្មែររងគ្រោះទាំងអស់ ត្រូវបានភ្នាក់ងារសង្គ្រោះស្រុកផាន់ថង ខេត្តឈុនបុរីបានបញ្ជូនជនរងគ្រោះយកទៅសង្គ្រោះនៅមន្ទីរពេទ្យផាន់ថងខេត្តឈុនបុរី។

## ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧

## MOU មួយដើម្បីបង្កើនការការពារដល់ពលករខ្មែរនៅម៉ាឡេស៊ី ត្រូវបានផ្អឹបទុកសិន

http://www.postkhmer.com/ 8 December 2017 យន់ ស៊ីនាត and Daphne Chen

**ភ្នំពេញៈ** យោងតាមប្រព័ន្ធផ្សព្វផ្សាយ របស់ម៉ាឡេស៊ីបានឲ្យដឹងថា អនុស្សរណៈនៃការយោគយល់គ្នាដើម្បីបង្កើនការការពារដល់ពលករខ្មែរបម្រើការងារតាមផ្ទះនៅប្រទេសម៉ាឡេស៊ី គឺត្រូវបានផ្អឹបទុកសិន បន្ទាប់ពីរដ្ឋមន្ត្រីធនធានមនុស្សរបស់ម៉ាឡេស៊ី បានអះអាងថា លោកមិនបានដឹងអំពីកិច្ចព្រមព្រៀងនេះទេ។ អនុស្សរណៈនៃកិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខាដោយក្រសួងការងារកម្ពុជានិងសមាគមទីភ្នាក់ងារពលករបរទេសនៅម៉ាឡេស៊ីកាលពីសប្តាហ៍មុន ដោយមានរួមបញ្ចូលទាំងការសន្យាផ្តល់ជូនពលករបម្រើការងារតាមផ្ទះជនជាតិខ្មែរនូវទូរសព្ទស្មាតហ្វូន និងមានធានារ៉ាប់រងសុខភាព ជាដើម រួមទាំងចំណុចផ្សេងៗជាច្រើនទៀត។

យោងតាមសារព័ត៌មានម៉ាឡេស៊ី The Sun Daily បានឱ្យដឹងថាសមាគមនេះកំពុងដាក់កិច្ចព្រមព្រៀងនេះផ្អឹបទុកមួយឡែកសិន បន្ទាប់ពីរដ្ឋមន្ត្រីក្រសួងធនធានមនុស្សរបស់ម៉ាឡេស៊ីលោក Richard Riot Jaem បានថ្លែងថាលោកមិនបានដឹងអំពីកិច្ចព្រមព្រៀងនោះទេ គឺចាំរហូតទាល់តែទទួលបានភ្លើងខៀវផ្លូវការពីរដ្ឋាភិបាលសិន។ កាលពីម្សិលមិញលោក Jeffrey Foo ប្រធានសមាគមទីភ្នាក់ងារពលករបរទេសបម្រើការងារតាមផ្ទះនៅម៉ាឡេស៊ីមិនបានឆ្លើយតបទៅនឹងសំណើជាច្រើនលើកច្រើនសារដើម្បីសុំអត្ថាធិប្បាយទេ។

អ្នកនាំពាក្យក្រសួងការងារ លោក ហេង សួរ ដែលបានចូលរួមក្នុងពិធីចុះហត្ថលេខាកាលពីសប្តាហ៍មុននៅទីក្រុងគូឡាឡាំពួរ ជាមួយរដ្ឋមន្ត្រីក្រសួងការងារ លោក អ៊ិត សំហេង បានបដិសេធមិនធ្វើអត្ថាធិប្បាយអំពីករណីនេះទេ ដោយលោកបានហៅថាវាជា «បញ្ហាផ្ទៃក្នុងរបស់ប្រទេសដទៃ»។

លោក Adrian Pereira នាយកប្រតិបត្តិអង្គការក្រុមសិទ្ធិការងារម៉ាឡេស៊ី North-South Initiative បានថ្លែងថា អនុស្សរណៈនៃកិច្ចព្រមព្រៀងនេះបានធ្វើតិចតួចណាស់ដើម្បីការពារដល់ពលករទាំងនោះពីព្រោះពួកគេមិនត្រូវបានចងក្រងឲ្យស្របច្បាប់នោះទេ។ លោក Pereira បញ្ជាក់ថាៈ« អ្វីដែលប្រទេសម៉ាឡេស៊ីគួរតែមានគឺច្បាប់ដ៏ទូលំទូលាយមួយសម្រាប់ពលករបម្រើការងារតាមផ្ទះដែលការពារដល់ពលករទាំងអស់នោះគឺមិនមែនគ្រាន់តែសម្រាប់ប្រទេសជាក់លាក់ណាមួយនោះទេ»។ អនុស្សរណៈនៃកិច្ចព្រមព្រៀងនេះមិនទាន់ត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅឡើយទេ។

លោក អន ប៊ុនហាក់ ប្រធានសមាគមជ្រើសរើសពលករកម្ពុជា Top Manpower Co. Ltd បានថ្លែងថាលោកនៅតែសង្ឃឹមថា រដ្ឋាភិបាលម៉ាឡេស៊ីនឹងគាំទ្រដល់កិច្ចព្រមព្រៀងនេះ។ លោក ប៊ុនហាក់ ដែលបានចូលរួមក្នុងពិធីចុះហត្ថលេខានេះផងដែរនោះបានបញ្ជាក់ថា ភ្នាក់ងាររបស់លោកគ្រោងនឹងចាប់ផ្តើមបញ្ជូនពលករបម្រើការងារតាមផ្ទះទៅធ្វើការនៅម៉ាឡេស៊ីនៅខែមីនាឆ្នាំក្រោយ៕ NS

## ពលករខ្មែរម្នាក់បាត់ ខ្លួនជាង1ម៉ោងត្រូវគេរកឃើញនៅកណ្តាលសមុទ្រ

http://www.pheaktraprak.com December 8, 2017

ករណីបាត់ខ្លួនពលករខ្មែរធ្វើការនៅលើទូកនេសាទត្រីមួយគ្រឿងធ្វើឲ្យមានការផ្អើលឆោឡោដល់មន្ត្រីតម្រួតថៃ និងភ្នាក់ងារសង្គ្រោះក្នុងត្រាតប្រទេសថៃ។ ករណីនេះបានកើតឡើងកាលពីថ្ងៃព្រហស្បតិ៍ទី07 ខែធ្នូ ឆ្នាំ2017 បន្ទាប់ពីបុរសពលករខ្មែរម្នាក់ឈ្មោះលឿត ភេទប្រុសអាយុ 27ឆ្នាំ សញ្ជាតិខ្មែរ ជាកម្មករធ្វើការនៅលើទូកនេសាទត្រី ស្ថិតនៅក្នុងភូមិឡែមអួន ឃុំខ្លងយ៉ៃ ស្រុកឡែមង៉ុប ខេត្តត្រាត ប្រទេសថៃ។ យោងតាមប្រភពពីបណ្តាញសារព័ត៌មានថៃបានចុះផ្សាយឲ្យដឹងថា ករណីបាត់ខ្លួនពលករខ្មែរខាងលើបានកើតឡើងបន្ទាប់ពីពលកររូបនោះបានឡូតពីលើទូកចូលទឹកសមុទ្ររួចបាត់ខ្លួនឈឹង ធ្វើឱ្យមានការភ្ញាក់ផ្អើលដល់មិត្តភក្តិរួមការងារព្រមទាំងថៅកែទូក រហូតដល់សុំកម្លាំងភ្នាក់ងារសង្គ្រោះប្រចាំខេត្តត្រាតឲ្យជួយអន្តរាគមន៍មុជទឹកតាមស្វែងរករូបពលករខ្មែរខាងលើ ប្រតិបត្តិការមុជទឹកស្វែងរកបានប្រព្រឹត្តទៅអស់រយៈពេលជាង1ម៉ោងតែនៅរកមិនឃើញធ្វើអោយមិត្តភក្តិរួមការងារអស់សង្ឃឹម។

នៅវេលាបន្តមានទូកនេសាទត្រីមួយគ្រឿងដែលកំពុងធ្វើដំណើរចូលចតនៅកំពង់ផែបរិវេណនោះបានរាយការណ៍មកថាបានប្រទះឃើញពលករខ្មែរម្នាក់នៅកណ្តាលសមុទ្រមានចំងាយពីកន្លែងបាត់ខ្លួនប្រមាណជាង7គីឡូម៉ែត្រ ហើយត្រូវបានគេជួយសង្គ្រោះស្រង់មកគោកដោយសុវត្ថិភាព។ ពលករខ្មែររូបនោះត្រូវបានគេបញ្ជូនទៅធ្វើការសាកសួរនៅអធិការតម្រួតស្រុកឡែមង៉ុប ដើម្បីសាកសួរពីមូលហេតុដែលឡោតពីលើទូក តាមការបកស្រាយរបស់ពលករខ្មែររូបនោះបានប្រាប់អោយដឹងថាដោយសារតែរូបគេនឹកផ្ទះខ្លាំងពេក រហូតដល់ទ្រាំលែងបានទើបសម្រេចចិត្តឡោតចូលក្នុងទឹកសមុទ្រដើម្បីហែលទឹកវិលត្រឡប់ទៅស្រុកកំណើតវិញ។

## អាជ្ញាធរអន្តោប្រវេសន៍ថៃ ចុះត្រួតពិនិត្យកន្លែងស្នាក់អាស្រ័យ ធ្វើការពលករបរទេស

http://www.pheaktraprak.com December 7, 2017

កាលពីថ្ងៃពុធទី06 ខែធ្នូ ឆ្នាំ2017ម្សិលមិញនេះ កម្លាំងអាជ្ញាធរតម្រួតអន្តោប្រវេសន៍ ខេត្តមុខដាហានប្រទេសថៃ ។ ដឹកនាំកម្លាំងដោយលោកអធិការនិងអធិការរងតម្រួតផ្នែកអន្តោប្រវេសន៍ខេត្ត បើកកិច្ចព្រឹត្តិការណ៍ចុះត្រួតពិនិត្យផ្សារអិនដូរជីន ដើម្បីត្រួតពិនិត្យកន្លែងស្នាក់អាស្រ័យធ្វើការរបស់ពលករបរទេស ព្រមទាំងជួបសំណេះសំណាលជាមួយភ្ញៀវទេសចរនិងអាជីវករលក់ដូរនៅផ្សារនិងប្រជាពលរដ្ឋដែលមកទិញឥវ៉ាន់ផងដែរ។ ក្នុងកិច្ចព្រឹត្តិបត្រការណ៍សមត្ថកិច្ចបានផ្តល់មតិយោបល់ដល់អាជីវករនិងថៅកែថៃដែលកំពុងគ្រប់គ្រងពលករបរទេសអោយប្រញាប់រាយការណ៍កន្លែងស្នាក់អាស្រ័យធ្វើការរបស់ពលករអោយបានត្រឹមត្រូវតាមច្បាប់អន្តោប្រវេសន៍ថៃ ។

## ប្រយ័ត្នអស់2 ម៉ឺនបាត ដោយសារតែវ៉ែវីសារ អត់សុំច្បាប់អនុញ្ញាតធ្វើការ ក្នុងរយៈពេល15ថ្ងៃ

http://www.pheaktraprak.com December 7, 2017

អត្ថបទនេះខ្ញុំសូមដាស់តឿនដល់បងប្អូនពលករកម្ពុជាក្នុងប្រទេសថៃ ដែលបានទទួលលិខិតឆ្លងដែនធ្វើការយ៉ាងត្រឹមត្រូវហើយ តែមិនបានដំណើរការសុំច្បាប់អនុញ្ញាតធ្វើការ បន្ទាប់ពីវ៉ែត្រាវីសារពី( តម៉ )រួចក្នុងរយៈពេល15ថ្ងៃ នៅត្រង់ចំណុចនេះបើបងប្អូនពលករមិនបានដំណើរការទាំងពីរយ៉ាងនេះទេ បងប្អូនអាចនិងក្លាយទៅពលករខុសច្បាប់ដោយមិនដឹងខ្លួន។ ព្រោះបន្ទាប់ពីវ៉ែត្រាវីសារហើយ ទុកឱ្យលើសរយៈពេល15ថ្ងៃ មន្ទីរការងារថៃគេមិនចេញច្បាប់អនុញ្ញាតធ្វើការអោយបងប្អូននោះទេ ។ ដូច្នេះចំពោះបងប្អូនពលករកម្ពុជា ដែលបានយកលិខិតឆ្លងដែនទៅវ៉ែត្រាវីសារហើយ សូមកុំភ្លេចទៅសុំច្បាប់អនុញ្ញាតធ្វើការនៅមន្ទីរការងារថៃ បានមុនរយៈពេល15ថ្ងៃ បើមិនដូច្នេះទេបងប្អូននិងក្លាយទៅពលករខុសច្បាប់ដោយស្វ័យប្រវត្តិ។

## ទោសនេះសាហាវមែន បុរសម្នាក់ជាប់គុក1000ឆ្នាំ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៧ ម៉ោង ០៧:៣០ មុ៉ក សេង

បុរសតិចសាស់ម្នាក់ត្រូវកាត់ក្ដីឱ្យជាប់គុក១០០០ឆ្នាំពីបទល្មើសលើផ្លូវភេទក្មេងស្រី២នាក់ ។ ក្រៅពីជាប់គុករយៈពេល១០០០ឆ្នាំនោះ លោកRobert Benjamin Franks អាយុ៣៩ឆ្នាំ ត្រូវជាប់គុកអស់មួយជីវិតចំនួន២លើក រួមទាំងពិន័យជាប្រាក់១២០.០០០ដុល្លារ ពីបទរំលោភក្មេងស្រី និងប្រព្រឹត្តអសីលធម៌ទៅលើកុមារ ។

អាជ្ញាធរបញ្ជាក់ថា លោកFranks បានល្មើសលើផ្លូវភេទក្មេងស្រី២នាក់អស់រយៈពេលជាច្រើនឆ្នាំ ដោយក្មេងស្រីរងគ្រោះមានអាយុ៩ឆ្នាំ និង១០ឆ្នាំ ។ កាលពីខែមិថុនាឆ្នាំមុន កូនធម៌អាយុ៩ឆ្នាំរបស់លោកFranks បានឆ្លើយថា លោក Franks បានប្រព្រឹត្តបទល្មើសគួរឱ្យស្អប់ខ្ពើម ខណៈពេលរូបនាងនៅផ្ទះ ។ ក្មេងស្រីរូបនោះបញ្ជាក់ប្រាប់ប៉ូលិសថា លោក Franks បានវាយកំប៉េះគូទនិងបង្ខំឱ្យបងស្រីរបស់នាងអាយុ១០ឆ្នាំធ្វើអូ៉ាល់សិច ។ ក្មេងស្រីអាយុ១០ឆ្នាំនោះក្នុងដំណាក់កាលដំបូងបានបដិសេធពីការរួមភេទ ប៉ុន្តែនៅពេលត្រួតពិនិត្យពីអ្នកជំនាញ នាងបានបញ្ជាក់ថា ខ្លួនរងការចាប់រំលោភអស់រយៈពេលជាច្រើនឆ្នាំមក ។

ក្នុងពេលបើកសវនាការថៅក្រមទទួលបានទិន្នន័យបន្ថែមពីប្អូនស្រីរបស់លោក Framks ដែលចោទប្រកាន់ថាធ្លាប់ប្រព្រឹត្តបទល្មើសផ្នែកផ្លូវភេទនៅពេលនាងមានអាយុ១០ឆ្នាំ កាលណោះ Framks មានអាយុ១៤ឆ្នាំ និងបានល្មើសលើផ្លូវភេទម្ដងទៀតក្នុងពេលនាងអាយុ១៦ឆ្នាំ ចំណែក Framks អាយុ២០ឆ្នាំ ៕

## ១៣ ខែធ្នូ ឆ្នាំ២០១៧

## សម្ដេចក្រឡាហោម ស ខេង អញ្ជើញជាអធិបតីក្នុងពិធីបើក «ទិវាជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ លើកទី១១»

http://www.freshnewsasia.com ១២-១២-២០១៧

(ភ្នំពេញ)៖ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅរសៀលថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧នេះ អញ្ជើញជាអធិបតីក្នុងទិវាជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ លើកទី១១។ ក្នុងពិធីនេះ ក៏មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធក្រសួងមហាផ្ទៃ ព្រមទាំងសមាជិក សមាជិកាជាច្រើនទៀតផងដែរ។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានបញ្ជាក់នៅក្នុងរបាយការណ៍របស់ខ្លួនឲ្យដឹងថា រាជរដ្ឋាភិបាលកម្ពុជានៅតែយកចិត្តទុកដាក់កាន់តែខ្លាំងក្លាក្នុងការពារប្រជាពលរដ្ឋ និងប្រទេសជាតិពីភាពរងគ្រោះទាំងឡាយ ដោយឧក្រិដ្ឋកម្មជួញដូរមនុស្ស ដែលបានបង្កឲ្យមានវិនាសកម្ម ជាថ្មីដល់មនុស្សជាតិ ហើយបាននិងកំពុងក្លាយជាទេសភាពសម័យទំនើគួរភ័យខ្លាច និងស្អប់ខ្ពើម។ យុទ្ធនាការនៃការផ្សព្វផ្សាយទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ នឹងបន្តធ្វើយ៉ាងគគ្រឹកគ្រេងបានបណ្ដាខេត្ត និងតាមប្រព័ន្ធផ្សព្វផ្សាយនានា ដើម្បីបញ្ជ្រៀមការយល់ដឹងដល់ ប្រជាពលរដ្ឋនៅទូទាំងប្រទេស៕

## សម្ដេចក្រឡាហោម ស ខេង៖ អំពើជួញដូរមនុស្សជាបទឧក្រិដ្ឋ និងម្ដេជ្ឈាចិត្តទប់ស្កាត់ និងបង្ក្រាប

http://bayontv.com.kh/ 13/12/2017

ភ្នំពេញ៖ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានប្រារព្ធពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅរសៀលថ្ងៃទី ១២ ធ្នូ ឆ្នាំ២០១៧ នេះ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រក្រោមអធិបតីភាពសម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ទិវាប្រយុទ្ធប្រឆាំងអំពើជួ

ញដូរមនុស្ស ក្រោមប្រធានបទ "រួមគ្នាពង្រឹងប្រព័ន្ធសុវត្ថិភាព និងពង្រឹងការអនុវត្តច្បាប់ដើម្បីការពារមនុស្សគ្រប់រូបពីអំពើជួញដូរមនុស្ស"។

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបញ្ជាក់អំពីជំហររបស់រាជរដ្ឋាភិបាលកម្ពុជាថា រាជរដ្ឋាភិបាលបានចាត់ទុកអំពើជួញដូរមនុស្សជាបទឧក្រិដ្ឋ និងប្តេជ្ញាចិត្តទប់ស្កាត់ និងបង្ក្រាបបទល្មើសនេះឱ្យបានខ្លាំងក្លា ដោយមិនអនុញ្ញាតឱ្យជនល្មើសមានឱកាសពង្រីកសកម្មភាព បង្កភាពរងគ្រោះដល់ប្រជាពលរដ្ឋ ដោយមិនបានឆ្លើយតបនោះឡើយ។

បទល្មើសជួញដូរមនុស្ស គឺជាឧក្រិដ្ឋកម្មឆ្លងដែន ដែលកាន់តែស្រួចស្រាល និងគ្រោះថ្នាក់ជាទីបំផុតដល់មនុស្សជាតិ ជាពិសេសក្នុងចំណោមពលករទេសន្តរប្រវេសន៍ ដែលបានចាកចេញទៅធ្វើការងារនៅក្រៅប្រទេស និងជនភៀសខ្លួន ទាំងក្មេង ទាំងចាស់ ប្រុស ស្រី ដោយមិនរើសមុខ៕

## ក្រសួងការងារថៃ ស្នើអោយមន្ត្រីផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជាបន្ថែមកម្លាំងផលិតលិខិតឆ្លងដែនក្នុង1ថ្ងៃ1.000ច្បាប់

http://www.pheaktraprak.com December 11, 2017

កាលពីថ្ងៃសុក្រទី08 ខែធ្នូ ឆ្នាំ2017 កន្លងទៅថ្មីៗនេះក្រសួងការងារថៃ បានបើកកិច្ចប្រជុំពិភាក្សារកដំណោះស្រាយរឿងត្រួតសញ្ជាតិជូនពលករកម្ពុជា ក្នុងប្រទេសថៃ។ កិច្ចប្រជុំនេះដឹកនាំដោយលោក Pichit NilthongKum អគ្គនាយករងនៃក្រសួងការងារថៃ និងលោក Kem Chamroeun មន្ត្រីស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ។ ក្នុងកិច្ចប្រជុំពិភាក្សារកដំណោះស្រាយលើបញ្ហាបញ្ជាក់អត្តសញ្ញាណជូនពលករកម្ពុជាក្នុងប្រទេសថៃលើកនេះ ភាគីថៃបានស្នើសុំអោយខាងភាគីកម្ពុជាអនុវត្តផែនការចំនួន3ចំណុចដូចខាងក្រោម៖

1-ភាគគីថៃបានស្នើអោយមន្ត្រីផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជាបន្ថែមកម្លាំងផលិតលិខិតឆ្លងដែន (TD) ក្នុង1ថ្ងៃចំនួន1.000ក្បាល និងផ្តល់ទិន្នន័យចំនួនពលករកម្ពុជាដែលមកបញ្ជាក់អត្តសញ្ញាណហើយ ព្រមបានទទួលប័ណ្ណពលករកម្ពុជាធ្វើការនៅបរទេសក្នុង1ថ្ងៃ។

2-ភាគីថៃបានស្នើអោយខាងភាគីកម្ពុជា ពិចារណាបន្ថែមទីតាំងបញ្ជាក់អត្តសញ្ញាណនៅតាមខេត្តផ្សេងមួយចំនួនទៀតដោយភាគីថៃ និងកម្ពុជារួមគ្នាចាត់(CarMobil) ភ្នាក់ងារចល័តចុះធ្វើដល់កន្លែងដែលមានពលករធ្វើការរស់នៅច្រើនដូចជា,ខេត្តឈៀងម៉ៃ,ខេត្តតាក,ខេត្តសាមុតសាខន,ខេត្តបាធុមថានី។ល។

3-ភាគីថៃបានស្នើឲ្យភាគីកម្ពុជាកំណត់អត្តលេខសម្គាល់ខ្លួនរបស់ថៅកែថៃ ព្រមទាំងកន្លែងធ្វើការស្នាក់នៅរបស់ពលករ តាមទិន្នន័យរបស់ក្រសួងការងារថៃ។

## ឯកសារសម្រាប់តវីសារ 2ឆ្នាំ ក្រោយពេលផុតកំណត់ 31.03.2018

http://www.pheaktraprak.com December 11, 2017

ចំពោះពលករបងប្អូនពលករកម្ពុជា ដែលបានទទួលវីសារការងារផុតកំណត់នៅថ្ងៃ 31.03.2018 ដើម្បីស្នើសុំវីសារបន្តទៅ2ឆ្នាំខាងមុខទៀតបានបងប្អូនត្រូវរៀបចំឯកសារសម្រាប់ស្នេើសុំវីសារមានដូចខាងក្រោម៖

**1-ពលករត្រូវទៅត្រួតសុខភាពនៅមន្ទីរពេទ្យជាមុនសិន**

1.1-ឯកសារថៅកែ, អត្តសញ្ញាណប័ណ្ណថៅកែច្បាប់ថតចម្លង,បៃកូតា( ចំពោះបៃកូតាបើមិនមានក៏បាន )

1.2-រូបថតរបស់ពលករទំហំ 1នៀវ ចំនួន 3សន្លឹក

1.3-ឯកសារលិខិតឆ្លងដែនធ្វើការរបស់ពលករត្រង់ច្បាប់ថតចម្លងរូបវីសា )

1.4-សៀវភៅ( workpermit )របស់ពលករច្បាប់ថតចម្លង

**2-ឯកសារសម្រាប់វ៉ៃត្រាវីសារ**

2.1-លិខិតឆ្លងដែនធ្វើការច្បាប់ពិតនិងថតចម្លង

2.3-សៀវភៅ( workpermit )ច្បាប់ពិតនិងថតចម្លង

2.3-រូបថត1នៀវចំនួន1សន្លឹក

2.4-ឯកសាររបស់ថៅកែ,អត្តសញ្ញាណ,សៀវភៅគ្រួសារ,កិច្ចសន្យាជួលរបស់ថៅកែឬសន្យាជួល

2.5-ឯកសារបញ្ជាក់ចេញពីមន្ទីរពេទ្យច្បាប់ពិត

**3-ឯកសារតសៀវភៅ( work )ធ្វើការ**

3.1-ឯកសាររបស់ថៅកែ,អត្តសញ្ញាណ,សៀវភៅគ្រួសារ,កិច្ចសន្យាជួល,ផែនទីកន្លែងស្នាក់នៅ

3.2-ឯកសារ( ทร.2 )កិច្ចសន្យាជួលរបស់ពលករ

3.3-លិខិតឆ្លងដែនធ្វើការវ៉ៃត្រាវីសាររួចនិងច្បាប់ថតចម្លង

3.4-សៀវភៅ( workpermit )ច្បាប់ពិតនិងថតចម្លង

3.5-រូបថត 1នៀវចំនួន 3សន្លឹក

3.6-ឯកសារបញ្ជាក់ពិនិត្យសុខភាពពីមន្ទីរពេទ្យច្បាប់ពិត

3.7-ឯកសារបង្កាន់ដៃធ្លាប់ថ្លៃបង់ប្រាក់កាលពីឆ្នាំ2015 ចំនួន1900฿ ច្បាប់ថតចម្លង( ធ្លាប់មាន )

នៅពេលទៅពិនិត្យសុខភាពនៅមន្ទីរពេទ្យ សូមបងប្អូនកុំភ្លេចសុំឯកសារបញ្ជាក់ពីមន្ទីរពេទ្យចំនួន 2ច្បាប់។ បញ្ជាក់:ឯកសារទាំងអស់នេះចំពោះពលករដែលស្នើសុំវីសារធ្វើការនៅក្នុងខេត្តឈុនបុរី ចំពោះខេត្តផ្សេងទៀតឯកសារប្រហាក់ប្រហែលគ្នា ដូច្នេះបងប្អូនអាចយកទៅមើលហើយត្រៀមឯកសារតាមបែបខាងលើនេះបាន។

## ចំពោះពលករកម្ពុជាលុងបៀនថ្មី មិនទាន់ត្រួតសញ្ជាតិ តែចង់បានប៉ាស្ព័រលឿន សូមអានអត្ថបទនេះ

http://www.pheaktraprak.com December 10, 2017

អត្ថបទនេះខ្ញុំសូមណែនាំបងប្អូនពលករខ្មែរដែលលុងបៀនថ្មី ហើយមិនបានត្រួតសញ្ជាតិធ្វើប៉ាស្ព័រនៅក្នុងប្រទេសថៃ ហើយចង់ធ្វើលិខិតឆ្លងដែនធ្វើការដោយមិនចាំបាច់រង់ចាំលេខត្រួតសញ្ជាតិធ្វើប៉ាស្ព័រនៅប្រទេសថៃ។ សូមអានការណែនាំដូចខាងក្រោម៖

បងប្អូនត្រូវអោយថៅកែទៅទំនាក់ទំនងមន្ទីរការងារថៃ ដើម្បីសុំឯកសារបញ្ជាក់ការលុងបៀនច្បាប់ថ្មី (หนังสือรับรองความสัมพันธ์-นายจ้างและลูกจ้างฉบับใหม่)។

១.វិលត្រឡប់ទៅប្រទេសកម្ពុជាវិញដើម្បីធ្វើលិខិតឆ្លងដែនថ្មី។

២.យកលិខិតឆ្លងដែនដែលធ្វើរួចមកវ៉ៃត្រាវីសារនៅស្ថានីយប៉ូលិស( តម៉ )។

៣.ទៅត្រួតពិនិត្យសុខភាពនៅមន្ទីរពេទ្យដែលក្រសួងការងារថៃកំណត់។

៤.យកឯកសារបញ្ជាក់លិទ្ធផលត្រួតពិនិត្យសុខភាពពីមន្ទីរពេទ្យទៅសុំច្បាប់អនុញ្ញាតធ្វើការនៅមន្ទីរការងារ។

បងប្អូននឹងទទួលបានច្បាប់អនុញ្ញាតធ្វើការនៅក្នុងប្រទេសថៃយ៉ាងត្រឹមត្រូវតាមច្បាប់ការងាររបស់ថៃ។ សង្ឃឹមថាវិធីសាស្ត្រនេះនិងជួយឲ្យបងប្អូនពលករខ្មែរ អោយទទួលបានច្បាប់អនុញ្ញាតធ្វើការនៅក្នុងប្រទេសថៃយ៉ាងលឿនជាងរង់ចាំលេខរៀងធ្វើប៉ាស្ព័រនៅប្រទេសថៃ។

បញ្ជាក់:តំលៃធ្វើលិខិតឆ្លងដែននៅឯប្រទេសកម្ពុជានិងក្នុងប្រទេសថៃមានតំលៃខុសគ្នាដូច្នេះសូមបងប្អូនពិចារណាអោយបានច្បាស់មុននឹងសម្រេចចិត្តទៅធ្វើលិខិតឆ្លងដែននៅឯប្រទេសកម្ពុជា។

## តម្រួត(តម៉)ឆ្មក់ត្រួតតាមបេនឡាន ដើម្បីទប់ស្កាត់ពលករខុសច្បាប់

http://www.pheaktraprak.com December 13, 2017

កាលពីថ្ងៃអង្គារ ទី12 ខែធ្នូ ឆ្នាំ2017នេះ កម្លាំងសមត្ថកិច្ចតម្រួតអន្តោប្រវេសន៍ ប្រចាំខេត្តមុខដាហាន ប្រទេសថៃ បានដឹកនាំកម្លាំងតម្រួតអន្តោប្រវេសន៍ខេត្ត ចុះត្រួតពិនិត្យបរិវេណចំណតរថយន្តក្រុងស្ថិតនៅក្នុងខេត្ត ដើម្បីត្រួតពិនិត្យឯកសារដំណើរចេញចូលរបស់ពលករចំណាកស្រុក និងភ្ញៀវទេសចរ ដែលធ្វើដំណើរឆ្លងកាត់តំបន់នេះ។ ក្នុងយុទ្ធនាការត្រួតពិនិត្យចំណតរថយន្តក្រុងខាងលើកនេះ សមត្ថកិច្ចតម្រួតអន្តោប្រវេសន៍ថៃបានធ្វើការសង្កត់ធ្ងន់ទៅលើការត្រួតពិនិត្យទិដ្ឋាការវីសារចេញចូលរបស់ពលករបរទេស ព្រមទាំងធ្វើការណែនាំដល់ភ្ញៀវជាតិនិងអន្តរជាតិក្នុងការស្នាក់នៅក្នុងប្រទេសថៃផងដែរ។

## ថៃអនុញ្ញាតឲ្យពលករខ្មែរ ធ្វើការជាអ្នកបកប្រែភាសាបាន

http://www.pheaktraprak.com December 10, 2017

មតិគណៈរដ្ឋមន្ត្រីថៃសម្រេចអនុញ្ញាតឲ្យពលករខ្មែរអាចធ្វើការជាអ្នកបកប្រែភាសារបស់ខ្លួនបាន ការងារបកប្រែភាសាជាការដ៏សមរម្យចំពោះបងប្អូនពលករកម្ពុជា ហើយការងារនេះត្រូវបាន គណៈរដ្ឋមន្ត្រីថៃ ប្រកាសអនុញ្ញាតឲ្យពលករខ្មែរ,ភូមា, ឡាវ អាចធ្វើការបាន តែត្រូវមានលក្ខខ័ណ្ឌមួយចំនួនដូចតទៅ៖ ចំពោះថៅកែរោងចក្រ,សហគ្រាស,ក្រុមហ៊ុន ក្នុងប្រទេសថៃ អាចជួលពលករខ្មែរ,ភូមា,ឡាវ អោយធ្វើការជាអ្នកបកប្រែភាសានៅក្នុងក្រុមហ៊ុនបាន ដោយក្នុងរោងចក្រ,សហគ្រាសមានពលករបរទេសធ្វើការចាប់ពី100នាក់ ឡើងទៅអនុញ្ញាតឲ្យជួលអ្នកបកប្រែភាសាម្នាក់។ ដូច្នេះការងារនេះជាជំរើសដ៏ល្អមួយ សម្រាប់បងប្អូនពលករខ្មែរដែលកំពុងស្វែងការងារធ្វើនៅប្រទេសថៃ។

## នៅថ្ងៃពុធសប្តាហ៍ខាងមុខនេះនឹងមានដំណឹងល្អរឿងធ្វើប៉ាស្ព័រជូនពលករខ្មែរ

http://www.pheaktraprak.com December 9, 2017

នៅថ្ងៃពុធទី13 ខែធ្នូ ឆ្នាំ2017 ខាងមុខនេះក្រសួងការងារថៃនឹងបើកកិច្ចប្រជុំធំមួយ ដើម្បីពិភាក្សារកដំណោះស្រាយអំពីបញ្ហាផ្តល់លេខរៀងបញ្ជាក់អត្តសញ្ញាណនិងប័ណ្ណស៊ីជម្ពូថ្មី ជូនបងប្អូនពលករខ្មែរ,ភូមា,ឡាវ ។ ក្នុងកិច្ចប្រជុំនេះក្រសួងការងារថៃមានការអញ្ជើញក្រុមហ៊ុននាំចូលពលករបរទេសមួយចំនួនក្នុងប្រទេសថៃ អោយមកចូលរួមពិភាក្សារកដោះស្រាយជាមួយផងដែរ។ ដូច្នេះចំពោះបងប្អូនពលករខ្មែរដែលកំពុងរង់ចាំត្រួតសញ្ជាតិធ្វើប៉ាស្ព័រនិងមានដំណឹងល្អទាំងរឿងផ្តល់លេខរៀងនិងរឿងប័ណ្ណស៊ីជម្ពូថ្មី។ អាស្រ័យហេតុនេះសូមបងប្អូនពលករខ្មែរទាំងអស់រង់ចាំស្តាប់ដំណឹងល្អនៅពេលឆាប់ៗខាងមុខនេះ។

## ពលករខ្មែរម្នាក់ស្លាប់

Royal Embassy of Cambodia in Bangkok added December 10 at 11:04am •

នាថ្ងៃទី០៦រោច ខែមិគសិរ ឆ្នាំរកា ព.ស. ២៥៦១ ទីក្រុងបាងកក ថ្ងៃទី០៩ ខែ ធ្នូ ឆ្នាំ២០១៧ មានពលរដ្ឋខ្មែរម្នាក់ស្លាប់ឈ្មោះ គួង ថង អាយុ ២៨ឆ្នាំ មានស្រុកកំណើត នៅភូមិជើងទឹក ស្រុកកំពង់លាវ ខេត្តព្រៃវែង បានមកធ្វើការក្នុងកន្លែងចិញ្ចឹមបង្គារ ស្ថិតនៅភូមិភ្នំសារ៉ាខាម ឃុំបឹងគោឡ ខេត្តឆាក់ឈើងសាវ ប្រទេសថៃ ។

មូលហេតុនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧ ពេលព្រលប់ គាត់ផឹកស៊ុរ៉ាពីព្រលប់ លុះម៉ោង ៣និង០០ព្រឹក គាត់ឡើងរថយន្តមកខេត្តរ៉ាក់យ៉ង គោលបំណងមកធ្វើលិខិតឆ្លងដែន ប៉ុន្តែនៅវេលាម៉ោង៦និង០០នាទីទើបដឹងថាឈ្មោះ គួង ថងបានស្លាប់នៅលើរថយន្តទៅហើយ។ បន្ទាប់មកសពត្រូវបានបញ្ជូនមកមន្ទីរពេទ្យខេត្តរ៉ាក់យ៉ង រង់ចាំគ្រួសារមកទទួលយកទៅធ្វើបុណ្យនៅស្រុកកំណើត។

នៅវេលាម៉ោង ១៦និង០០នាទី សពត្រូវបានដឹកចេញពីមន្ទីរពេទ្យបញ្ជូនមកតាមច្រកព្រំដែន ប៉ោយប៉ែត នៅវេលាម៉ោង២២និង៤៥នាទីសពបានមកដល់ច្រកព្រំដែនប៉ោយប៉ែត តែដោយនៅច្រកគេបានបិតនៅម៉ោង២២យប់ សពត្រូវយកទៅតំកល់នៅរោងជេ ស្ថិតក្នុងស្រុកអារ៉ាញ់ រួចនៅវេលាព្រឹក ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៧ និងបញ្ជូនសពមកកុងសុលខេត្តស្រះកែវ សម្រួលសពចេញតាមច្រកព្រំដែន។ ទីប្រឹក្សាទទួលបន្ទុកពលករបានពាំនាំថវិកាមួយចំនួន ជូនដល់សាច់ញាតិសព និងទំនាក់ទំនងទៅនយោជក អោយរៀបចំឯកសារសពចេញពីមន្ទីរពេទ្យនិងចេញថ្លៃពេទ្យនិងថ្លៃដឹកសព។

## ក្រុមការងារទទួលបន្ទុកពលករ ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានចុះទៅដោះស្រាយបញ្ហាជូនដល់ពលករកម្ពុជាចំនួនជាង១០០នាក់

Royal Embassy of Cambodia in Bangkok December 8 at 5:23pm •

នាថ្ងៃព្រហស្បតិ៍ ៤រោច ខែមិគសិរ ឆ្នាំរកា ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៧ ក្រុមការងារទទួលបន្ទុកពលករ តំណាងឱ្យឯកឧត្តមឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ បានចុះទៅដោះស្រាយបញ្ហាជូនដល់ពលករកម្ពុជាចំនួនជាង១០០នាក់ ដែលត្រូវបាននិយោជកមិនបើកប្រាក់ឈ្នួលឱ្យ និងមិនមានការងារឱ្យពលករធ្វើ ដែលមានទីតាំងស្ថិតនៅក្នុងស្រុកសាមុទ្រប្រាកាន ខេត្តសាមុទ្រប្រាកានប្រទេសថៃ ដោយនិយោជកយល់ព្រមបើកប្រាក់ឈ្នួលជូនពលករគ្រប់ចំនួន និងអនុវត្តទៅតាមច្បាប់ការងាររបស់ប្រទេសថៃ។

## ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១៧

## នាយករដ្ឋមន្ត្រី មានសុទិដ្ឋិនិយមចំពោះការបញ្ជូនពលករទៅជប៉ុន

http://www.postkhmer.com/ Thu, 14 December 2017 យ៉ន់ ស៊ីនាត and Daphne Chen

ភ្នំពេញៈ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសម្តែងនូវក្តីសង្ឃឹមចំពោះការបញ្ជូនពលករកម្ពុជាទៅប្រទេសជប៉ុន ដើម្បីធ្វើជាអ្នកមើលថែទាំមនុស្សចាស់ដែលជាផ្នែកមួយនៃគម្រោងធំ ដើម្បីបង្កើនចំនួនពលករចំណាកស្រុកកម្ពុជាទៅធ្វើការក្រៅប្រទេស។ ថ្លែងសុន្ទរកថាទៅកាន់ក្រុមកម្មករកាត់ដេរនៅក្នុងខណ្ឌពោធិ៍សែនជ័យកាលពីម្សិលមិញលោកនាយករដ្ឋមន្ត្រីបានលើកឡើងថាលោកបានពិភាក្សាបញ្ហានេះជាមួយលោក ស៊ីនហ្សូ អាបេ នាយករដ្ឋមន្ត្រីជប៉ុននៅឯកិច្ចប្រជុំមួយក្នុងប្រទេសជប៉ុនកាលពីខែសីហា។ សមាជិកសភាជប៉ុន បានធ្វើវិសោធនកម្មច្បាប់អន្តោប្រវេសន៍មួយចំនួនកាលពីឆ្នាំមុនដែលជាកិច្ចខិតខំប្រឹងប្រែងមួយ ដើម្បីបំពេញកង្វះខាតបុគ្គលិកថែទាំមនុស្សមានវ័យចំណាស់ដែលបានកើនឡើងជាលំដាប់នៅក្នុងប្រទេសនេះ។

យោងតាមលោក សុខ ចំរើន អ្នកសម្របសម្រួលមជ្ឈមណ្ឌលបណ្តុះបណ្តាលបានឲ្យដឹងថាក្រុមហ៊ុនជប៉ុនឈ្មោះ Procast Asia Co Ltd បានសាងសង់មជ្ឈមណ្ឌលបណ្តុះបណ្តាលមួយនៅភ្នំពេញរួចហើយដើម្បីរៀបចំពលករចំណាកស្រុកកម្ពុជាឱ្យទៅធ្វើជាអ្នកថែទាំមនុស្សចាស់នៅជប៉ុន។

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារបានថ្លែងថាប្រទេសកម្ពុជាមិនមែនជាប្រទេសតែមួយដែលកំពុងព្យាយាមបណ្តុះបណ្តាលពលករបន្ថែមឱ្យចូលទៅធ្វើការងារថែទាំមនុស្សចាស់របស់ជប៉ុននោះទេ។ លោក សួរ បានបញ្ជាក់ថាៈ «សម្រាប់ខ្ញុំ ខ្ញុំគិតថាវាល្អចំពោះការបញ្ជូនពលករទៅក្រៅប្រទេស។ មិនថាការងារក្នុងស្រុក ឬក្រៅប្រទេសទេសំខាន់គឺការមានការងារធ្វើ»៕ NS

## ពលករ ១១ នាក់ថាពួកគេត្រូវក្រុមហ៊ុនឆបោកអស់រាប់ពាន់ដុល្លារ

http://www.postkhmer.com/ Thu, 14 December 2017 យន់ ស៊ីនាត and Daphne Chen

ភ្នំពេញៈ ពលករចំនួន១១នាក់ដែលសង្ឃឹមថាពួកគេនឹងបានទៅធ្វើការនៅប្រទេសជប៉ុនពេលនេះបានអះអាងថាភ្នាក់ងារជ្រើសរើសពលករបានបោកប្រាស់ពួកគេ បន្ទាប់ពីពួកគេម្នាក់ៗបានចំណាយប្រាក់អស់រាប់ពាន់ដុល្លារកាលពីជិត ២ ឆ្នាំមុនមកនោះ។

ភ្នាក់ងារជ្រើសរើសពលករនេះមានឈ្មោះ APTSE & C (Cambodia) Resources Co. , Ltd បានក្លាយជាកម្មវត្ថុមួយនៃការប្តឹងប្តល់ជាច្រើនករណីមកហើយនៅក្នុងរយៈពេល៧ ឆ្នាំចុងក្រោយនេះដោយការចោទប្រកាន់ទាំងនោះទាក់ទងទៅនឹងរឿងបោកប្រាស់។

កញ្ញា សុខ សូនីកា អាយុ ២៤ ឆ្នាំបានឲ្យដឹងថានាងបានដាក់ពាក្យជាមួយភ្នាក់ងារមួយនេះកាលពីខែមេសាឆ្នាំ ២០១៦ និងទទួលបានការហ្វឹកហ្វឺនរយៈពេល ៦ ខែ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយបន្ទាប់ពីនាងបានចំណាយប្រាក់អស់ចំនួន ២៥០០ ដុល្លារលើថ្លៃការរៀបចំផ្សេងៗមកនោះក្រុមហ៊ុននេះមិនដែលបានធានាថារកការងារឲ្យនាងធ្វើនៅប្រទេសជប៉ុននោះទេ។ បើតាមកញ្ញា សូនីកា ក្រុមហ៊ុននេះបានសន្យាប្រគល់ប្រាក់ឲ្យនាងវិញប្រសិនបើពួកគេមិនអាចរៀបចំការងារឲ្យនាងបាននៅត្រឹមខែតុលាឆ្នាំ ២០១៦ ប៉ុន្តែនៅពេលវេលានោះចូលមកដល់ក្រុមហ៊ុននេះបានប្រគល់ប្រាក់ឱ្យនាងវិញត្រឹមតែ ៤០០ ដុល្លារប៉ុណ្ណោះ។ កញ្ញា សូនីកា បន្តថាៈ «រហូតមកដល់ពេលនេះយើងនៅតែរង់ចាំទទួលប្រាក់ចំនួន ២ ១០០ ដុល្លារទៀតត្រឡប់មកវិញ»។ កញ្ញាបានបន្ថែមថាគ្រួសាររបស់នាងបានខ្ចីប្រាក់ពីស្ថាប័នមីក្រូហិរញ្ញវត្ថុ ហើយឥឡូវនេះកំពុងប្រឈមនឹងអត្រាការប្រាក់កើនឡើង។

ពលករអាយុ ២៣ ឆ្នាំម្នាក់ទៀតឈ្មោះ សៅ ម៉េងលាង បាននិយាយថាកញ្ញាក៏បានចំណាយប្រាក់អស់ចំនួន ២.៥០០ដុល្លារដែរសម្រាប់បានការងារធ្វើនៅប្រទេសជប៉ុន ប៉ុន្តែវាមិនដែលមានភាពច្បាស់លាស់នោះទេហើយក្រោយមក អ្នកតំណាងក្រសួងម្នាក់បានអះអាងថានឹងធ្វើការចរចាជាមួយក្រុមហ៊ុន ប៉ុន្តែមិនឃើញមានលទ្ធផលទេ។ ម៉េងលាង បញ្ជាក់ថាៈ «ខ្ញុំមិនមានគម្រោងទៅធ្វើការនៅប្រទេសជប៉ុនទៀតទេ បើទោះបីជាមានការផ្សព្វផ្សាយថាយើងអាចរកប្រាក់បានច្រើនក៏ដោយ ឥឡូវនេះខ្ញុំខ្លាចណាស់»។ បុរសម្នាក់បានបញ្ជាក់ថាគាត់គឺជាតំណាងភ្នាក់ងារនេះ ប៉ុន្តែបានបដិសេធមិនប្រាប់ឈ្មោះរបស់គាត់ទេ ហើយលោកបានបដិសេធការលើកឡើងរបស់ពលករទាំងនោះ។ លោកបញ្ជាក់ថាៈ «ប្រសិនបើនរណាម្នាក់អះអាងថា ក្រុមហ៊ុននេះបានបោកប្រាស់ពួកគេ ឬកុហកពួកគេយើងត្រូវការឯកសារ និងឈ្មោះរបស់ពួកគេដើម្បីធ្វើឱ្យប្រាកដថាពួកគេបានដាក់ពាក្យមកក្រុមហ៊ុនរបស់យើងមែន»។ លោកបានបង្វែរសំណួរផ្សេងទៀតទៅក្រសួងការងារ ឬតុលាការ។

កញ្ញា សូនីកា បាននិយាយថាកញ្ញា និងពលករ ១០ នាក់ផ្សេងទៀតបានដាក់ពាក្យបណ្តឹងទៅក្រសួងការងារកាលពីខែមុន។ ក្រសួងបានប្តេជ្ញាថានឹងធ្វើការស៊ើបអង្កេតក្រុមហ៊ុន APTSE&C នេះនៅឆ្នាំ ២០១៥ លើពាក្យបណ្តឹងផ្សេងៗគ្នា។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយលោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ បានថ្លែងថាលោកមិនដឹងច្បាស់អំពីក្រុមហ៊ុននេះទេហើយលោក «មិនគិតថា យើងទទួលបានពាក្យបណ្តឹងទេ»។

## ខេត្តកោះកុង ! ប្រារព្ធទិវាជាតិលើកទី១១ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ

http://beta.khtopnews.com/articles/ Khmer top news December 11, 2017

កោះកុងៈ នាព្រឹកថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ នេះ នៅឯទីធ្លាសួនច្បារមាត់សមុទ្រ រដ្ឋបាលខេត្តកោះកុង បានរៀបចំកម្មវិធីទិវាជាតិ លើកទី១១ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៧ ក្រោមអធិបតីភាពលោក ផៃធូន ផ្លាមកេសន អភិបាលស្តីទីខេត្តកោះកុង និងមានការអញ្ជើញចូលរួមពីសំណាក់ប្រធានអនុប្រធានមន្ទីរ អង្គភាពនានាជុំវិញខេត្ត កងកម្លាំងប្រដាប់អាវុធទាំង៣ស្ថាប័ន រួមទាំងក្រុមកាយរិទ្ធជាច្រើននាក់ផងដែរ។

លោក ផៃធូន ផ្លាមកេសន អភិបាលស្តីទីខេត្តកោះកុង បានថ្លែងនៅក្នុងពិធីថា ការជួញដូរមនុស្ស ជាអំពើរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ យើងទាំងអស់គ្នា ត្រូវរួមគ្នាបង្កើនប្រព័ន្ធសុវត្ថិភាព និងពង្រឹងការអនុវត្តន៍ច្បាប់ ដើម្បីការពារប្រជាពលរដ្ឋឲ្យគេចផុតពីអំពើជួញដូរមនុស្ស ពិសេសរាជរដ្ឋាភិបាលកម្ពុជា បច្ចុប្បន្នកំពុងស្អប់ខ្ពើម និងប្រឆាំងដាច់ខាត ចំពោះអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ពិសេសលើស្ត្រី និងកុមារ ដែលជាជនងាយរងគ្រោះ។

ចុងបញ្ចប់នៃពិធីនោះ ក៏មានការដង្ហែក្បួនយុទ្ធនាការជុំវិញផ្សារដងទង់ ដើម្បីជាការបញ្ជៀបនូវការយល់ដឹងមួយចំនួន ដល់បងប្អូនប្រជាពលរដ្ឋដែលពួកគាត់ខ្លះមិនទាន់បានយល់ដឹងអំពីបញ្ហាខាងលើនៅឡើងពិសេសបងប្អូននៅក្នុងខេត្តកោះកុង នេះតែម្តង។ដោយលីវណ្ណឌី

## មេទាហ៊ានវរៈការពារព្រំដែនលេខ៤០៥ហាមចៅហ្វាយស្រុកជាំក្សាន្តមិនឲ្យដឹងពូវឿពលករខ្មែរចូលកាប់ឈើក្នុងដីថៃ

http://pvknweb.com/ បញ្ញវន្តខ្មែរ ចេញផ្សាយ ថ្ងៃទី 09/12/2017

ខេត្តព្រះវិហារ ៖ លោកវរសេនីយ៍ឯក រាម ខេត្ត មេបញ្ជាការវរៈការពារព្រំដែន លេខ៤០៥ នៅតំបន់សមរភូមិមុខទិស ទី០១ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ត្រូវបានគេរាយការណ៍ថាបានបើឲ្យពលករ ឆ្លងដែនចូលទៅកាប់ឈើក្នុងទឹកដីថៃ នៅច្រក របៀងចំនួនបីមានច្រករបៀងដំណក់ទឹក ច្រកកណ្តាល និងច្រករបៀងឈើទាលគង ក្នុងឃុំ ស្រុកជាំក្សាន្ត ខេត្ត ព្រះវិហារ។

ជាក់ស្តែង កាលពីថ្ងៃចន្ទ ១រោច ខែ មិគសិរ ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៧ មានពលករខ្មែរស្រីប្រុសប្រមាណជាង៦០នាក់បាននាំគ្នាឆ្លងដែន ទៅកាប់ឈើគ្រញូងក្នុងទឹកដីថៃតាមច្រកទាំង៣ ខាងលើ ដោយបង់ប្រាក់ឲ្យទៅលោកមេបញ្ជា ការវរៈការពារព្រំដែន៤០៥ ម្តៃពីរម៉ឺន រៀល ហើយក្នុងនោះមានមេការចំនួន២នាក់ ប្តីប្រពន្ធជាអ្នកនាំផ្លូវយកក្នុងមួយគីឡូ ម៉ែត្រ មួយពាន់រៀលផ្សេងទៀត។មេខ្យល់ត្រូវបានគេស្គាល់ ឈ្មោះម៉ឺន ភេទប្រុស និងឈ្មោះអូន ឌីណា ត្រូវជា ប្រពន្ធ។

ករណីយ៍ណលោក ជាំ គឹមសេង អភិបាលស្រុកជាំក្សាន្ត បានទទួលស្គាល់ជាមួយកាសែតថា មានពលករឆ្លងដែន ប្រាកដមែន ក៏ប៉ុន្តែ លោកមិនមានសមត្ថភាពទប់ស្កាត់បានទេពីព្រោះតំបន់ព្រំដែនគ្រប់គ្រង ដោយកង កម្លាំងយោធា។ លោកចៅហ្វាយស្រុកបញ្ជាក់ថា សូម្បីតែរូបលោកចង់ចូលទៅមើលសកម្មភាពភាពទាំងនោះក៏មិនបានផងព្រោះត្រូវរាំងដោយកងកម្លាំងយោធាវរៈការពារព្រំដែនលេខ ៤០៥ របស់លោក រាម ជាមេបញ្ជាការ?។ ជុំវិញករណីខាងលើភ្នាក់ងារកាសែត មិនអាចសុំការបំភ្លឺពីលោក រាម ខេត្តបានទេព្រោះទូរស័ព្ទចូលជាប់រវល់រហូត ។ សង្ឃឹមថាលោកអភិបាលខេត្តព្រះវិហ៊ារនឹងជ្រាបពីពត៍មាននេះហើយអាចមានវិធានការទប់ស្កាត់ជាមិនខាន!៕

## អភិបាលខេត្តព្រះវិហារបញ្ជាសមត្ថកិច្ចចម្រុះចុះទប់ស្កាត់ពលករឆ្លងដែនរឹបអូសឈើក្រញូងបានជាង១០០ដុំជកហ្វតម៉ូតូ១៤គ្រឿងមានតម្លៃជាច្រើនម៉ឺនដុល្លារ

http://ukk-news.com/ ឧត្តមគតិខ្មែរ ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៧

ខេត្តព្រះវិហារ៖ ពលករខ្មែរនៅតែលបលួចឆ្លងដែន ចូលទៅកាប់ និងដឹកជញ្ជូនឈើក្រញូង នៅក្នុងទឹកដីថៃនាំចូលមកកម្ពុជា ដោយខុសច្បាប់ ស្ទើរជារៀងរាល់ថ្ងៃ ក្រោយពីសង្កេតឃើញថា បទល្មើសឆ្លងដែននៅតែបន្តកើតមាននោះ អភិបាលខេត្តព្រះវិហារ លោកអ៊ុន ចាន់ដា បានបញ្ជាទៅអភិបាលស្រុកជាំក្សាន្ត លោកជា គឹមសេង ដឹកនាំសមត្ថកិច្ចចម្រុះ ចុះទៅបង្រ្កាបបទល្មើសឆ្លងដែននោះ ដោយធ្វើឡើងក្នុងរយៈពេល២ថ្ងៃបន្តបន្ទាប់គ្នា គឺចាប់ពីរសៀល

ថ្ងៃទី៩ធ្នូ រហូតមកដល់ល្ងាចថ្ងៃទី១០ធ្នូម្សិលមិញ អនុវត្តទៅលើពីរគោលដៅ នៅច្រកដំណាក់ទឹក នៃចំណុចដំណាក់កណ្តាល និងដំណាក់ផ្តៀក ស្ថិតនៅក្នុងភូមិឈើទាលគង ឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត ។

អភិបាលស្រុកជាំក្សាន្ត លោក ជា គឹមសេង បានប្រាប់ឲ្យដឹងនៅថ្ងៃ១១ធ្នូនេះ ថា ក្រោយទទួលបានព័ត៌មានថា មានពលករខ្មែរមិនតិចជាង១០០នាក់នោះទេ ដែលបាន និងកំពុងធ្វើសកម្មភាពស្លាយឈើក្រញូង ចេញពីក្នុងទឹកដីថៃ ចូលមកខេត្តព្រះវិហារ ប្រទេសកម្ពុជា ដោយពួកគេបាន និងកំពុងចុះតាមច្រកដំណាក់ទឹក ស្ថិតនៅក្នុងតំបន់ភូមិសាស្រ្ត ភូមិឈើទាលគងនោះ លោកបានសុំបទបញ្ជាពី អភិបាលខេត្ត លោក អ៊ុន ចាន់ដា ដើម្បីពិនិត្យពីសកម្មភាពនេះ ។ លោក ជា គឹមសេង បានបន្តទៀតថា បន្ទាប់ពីទទួលបានបទបញ្ជានោះភ្លាម លោកបានដឹកនាំកម្លាំងសមត្ថកិច្ចចម្រុះស្រុកជាំក្សាន្ត ដើម្បីចូលទៅក្នុងព្រៃ ហើយបានប្រដេញស្ទាក់ចាប់យកបទល្មើសឈើឆ្លងដែននោះ ប៉ុន្តែ សមត្ថកិច្ចមិនបានឃាត់ខ្លួនក្រុមពលករទាំងនោះទេ ដោយសារពួកគេបានទម្លាក់ឈើក្រញូង និងទុកម៉ូតូចោលក្នុងព្រៃ រួចរត់គេចខ្លួនចូលក្នុងព្រៃបាត់អស់ ។ លោកថា សមត្ថកិច្ចនៅគ្រានោះ មិនបានធ្វើការប្រដេញស្ទាក់ចាប់ពលករទាំងនោះទេ ដោយសារថ្ងៃជិតលិចទៅហើយ ខ្លាចក្រែងរកភូមិសាស្រ្តចេញមកវិញមិនឃើញ។

លោកអភិបាលស្រុកបានបន្តទៀតថា នៅក្នុងប្រតិបត្តិការចុះបង្រ្កាបបទល្មើសឆ្លងដែន ក្នុងរយៈពេល២ថ្ងៃកន្លងមកនេះ លោកបានបែងចែកកម្លាំងចេញជាពីរក្រុម ១ក្រុមចុះទៅធ្វើរដ្ឋបាលនៅភូមិឈើទាលគង និង១ក្រុមទៀតបានចុះទៅបោសសំអាត និងទប់ស្កាត់ពលករនាំឈើក្រញូងឆ្លងដែន នៅចំណុចដំណាក់កណ្តាល និងដំណាក់ផ្តៀក ហើយបានរកឃើញ ឈើក្រញូង ចំនួន១០៣ដុំ មានទម្ងន់ស្មើនឹង៧២៥គីឡូក្រាម និងម៉ូតូដែលជាមធ្យោបាយបំរើឲ្យការដឹកជញ្ជូនបទល្មើសឈើក្រញូងនោះ ចំនួន១៤គ្រឿងទៀតផងដែរ ។

លោកបានបញ្ជាក់ថា ក្រោយប្រមូលបានវត្ថុតាងបទល្មើសទាំងនោះហើយ ទាំងឈើក្រញូងជិត៨០០គីឡូក្រាម រួមជាមួយម៉ូតូ១៤គ្រឿង ត្រូវបាននាំយកមករក្សាទុក នៅស្នាក់ការកងរាជអាវុធហត្ថជាំក្សាន ឯឈើក្រញូងបានធ្វើការផ្ទេរប្រគល់ ទៅឲ្យផ្នែករដ្ឋបាលព្រៃឈើជាំក្សាន្ត ចាត់ការតាមច្បាប់ ។ លោកបញ្ជាក់ទៀតថា ចំពោះការចុះធ្វើរដ្ឋបាល នៅក្នុងភូមិឈើទាលគងនោះ សមត្ថកិច្ចបានរកឃើញ ប្រជាពលរដ្ឋចំណូលស្រុក១៦នាក់ ស្រី៧នាក់ ហើយនៅក្នុងចំណោមពលរដ្ឋ១៦នាក់នោះ សមត្ថកិច្ចបានឃាត់ខ្លួន២នាក់ ពាក់ព័ន្ធនឹងការរក្សាទុកសារធាតុញៀន១កញ្ចប់តូច ។ លោកថា ជនសង្ស័យទាំងពីរ ដែលរក្សាទុកនូវសារធាតុញៀន ក្រាមពណ៌សថ្លា១កញ្ចប់តូចនោះ កំពុងស្ថិតក្រោមការសាកសួរ ពីមន្រ្តីជំនាញអាវុធហត្ថស្រុកជាំក្សាន្តនៅឡើយ ។ លោក ជា គឹមសេង បានអំពាវនាវដល់ពលរដ្ឋទាំងក្នុងខេត្ត និងមកពីក្រៅខេត្ត ឲ្យបញ្ឈប់ធ្វើចំណាកស្រុក ចូលទៅកាប់ឈើក្រញូងនៅក្នុងទឹកដីថៃដោយខុសច្បាប់ទៀត ជៀសវាងជួបគ្រោះថ្នាក់ជាយថាហេតុផ្សេងៗ ពីការលបលួចចូលទៅកាប់ឈើក្រញូងនោះ ៕

## ដំណឹងល្អ ចំពោះពលករលុងបៀនថ្មី អាចធ្វើប៉ាស្ព័របានដល់ខែ3 ឆ្នាំ2018

http://www.pheaktraprak.com ប្រភពដំណឹងពលករខ្មែរ December 14, 2017

យោងតាមការបញ្ជាក់របស់ម្ចាស់អាខោនហ្វេសប៊ុកឈ្មោះ សុចិន ពឹងប្រសេរិទ្ធ បានអោយដឹងថាចំពោះបងប្អូនពលករខ្មែរដែលលុងបៀនថ្មី មានលិខិតបញ្ជាក់ចេញពីក្រសួងការងារថៃ ហើយផុតកំណត់ថ្ងៃទី31.12.2017 អាចបន្តការត្រួត សញ្ជាតិធ្វើប៉ាស្ព័របានរហូតដល់ថ្ងៃទី31.03.2018 ដោយមិនចាំបាច់ភ័យព្រួយអ្វីទាំងអស់។ ហើយចំពោះពលករដែលកំពុងកាន់ប័ណ្ណស៊ីជម្ពូនិងចាប់ផ្តើមត្រួតសញ្ជាតិចាប់ពីថ្ងៃទី03.01.2018 តទៅ ដោយខាងគណៈកម្មការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជា និងបន្ថែមទីតាំងបញ្ជាក់អត្តសញ្ញាណធ្វើប៉ាស្ព័រចំនួនប្រហែល 5កន្លែងទៀត

ដើម្បីឲ្យដំណើរការត្រួតសញ្ញាតិជូនពលករកម្ពុជាអោយទាន់ពេលកំណត់។ ហើយចំពោះអ្នកត្រួតសញ្ញាតិធ្វើប៉ាស្ព័រ ចាប់ថ្ងៃទីចាប់ពីឆ្នាំ2018 និងទទួលបានវីសារការងាររយៈពេល2ឆ្នាំតែម្តង។ ទាំងនេះដកស្រង់ចេញពីប្រសាសន៍របស់ម្ចាស់អាខោនហ្វេសប៊ុកសុចិន ពឹងប្រសេរិទ្ធ ដែលចូលរួមប្រជុំជាមួយក្រសួងការងារថៃកាលពីថ្ងៃពុធទី13 ខែធ្នូឆ្នាំ2017 ព្រឹកមិញនេះ។

## ក្រុមអភិរក្សសត្វព្រៃថៃ ឃាត់ខ្លួនខ្មែរពីរនាក់ លួចចូលកាប់ឈើគ្រញូង

http://cambodiapolice.com/ 2:33 pm 14 ធ្នូ 2017

ប្រទេសថៃ ៖ ពលករខ្មែរចំនួនពីរនាក់ ក្នុងចំណោមគ្នីគ្នាសរុបប្រមាណជាង២០នាក់ ត្រូវបានកំលាំងចម្រុះថៃធ្វើការចាប់ខ្លួន រួមជាមួយនឹងវត្ថុតាងមួយចំនួនផងដែរ ខណៈដែលពួកគេទាំងអស់គ្នាកំពុងជញ្ជូនឈើគ្រញូងចេញពីក្នុងព្រៃ ដែលជាតំបន់ហាមឃាត់ ហើយត្រូវកំលាំងស្ទាក់ចាប់ខ្លួនតែម្តង ។ យោងតាមរបាយការណ៍ដែលយើងទទួលបានពីភាគីថៃ បានអោយដឹងថា នៅរសៀលថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ ក្រោយពីទទួលបានព័ត៌មានស្តីពីការលបលួចចូលកាប់ឈើគ្រញូងរួចមក កំលាំងចម្រុះដែលមានទាហានឈុតខ្មៅ ក្រុមទី១៣ អង្គភាពរដ្ឋបាលព្រៃឈើ កម្លាំងអភិរក្សសត្វព្រៃ ស្រុកខ្លុងហាត ខេត្តស្រះកែវ បានធ្វើការជាមួយជំនាញស្រុកថាតាក់កៀប ខេត្តឆាក់ឈើងសៅ បានចុះទៅកាន់តំបន់អភិរក្សសត្វព្រៃ ភ្នំអាងឬណៃ ស្ថិតក្នុងចំណុចព្រៃចែក ក្នុងភូមិ២៥ ឃុំខ្លងតាក់ក្រៅ ស្រុកថាតាក់កៀប ដែលនៅក្នុងតំបន់ព្រំប្រទល់ខេត្តស្រះកែវ និងខេត្តឆាក់ឈើងសៅប្រទេសថៃ ។

នៅទីនោះកំលាំងចម្រុះទាំងពីរខេត្ត បានប្រទះឃើញមនុស្សមួយក្រុម ដែលពួកគេកំពុងសម្រាកនៅលើគំនរឈើគ្រញូងជាច្រើនផ្ទាំង ទើបកំលាំងសម្រុកចូលចាប់ពួកគេ ប៉ុន្តែគឺបានតែពីរនាក់ប៉ុណ្ណោះ ដែលជាជនជាតិខ្មែរ ក្រៅពីនេះពួកគេបានរត់គេចខ្លួនចូលព្រៃបាត់ស្រមោលតែម្តង ។ ជនសង្ស័យទាំងពីរនាក់ដែលក្រុមចម្រុះថៃចាប់ខ្លួនបានសារភាពថា ពួកគេនឹងបក្ខពួកសរុបចំនួន២១នាក់ បានលបឆ្លងដែនតាមច្រកមួយចំនួនក្បែរផ្សារពេងក្លឿ ស្រុកអារញ្ញហើយត្រូវបានជនជាតិថៃចំនួនពីរនាក់ ជាអ្នកនាំផ្លូវចូលទៅតាមចំណុច ខ្លងឧត្តម ឃុំវ៉ាំងថង ស្រុកវ៉ាំងសំបូរណ៍ ខេត្តស្រះកែវ ដើម្បីស៊ីឈ្នួលកាប់ឈើគ្រញូង លុះពេលចេញមកវិញក៏ត្រូវថៃចាប់ខ្លួនតែម្តង ។ បច្ចុប្បន្នជនសង្ស័យទាំងពីរនាក់ រួមជាមួយនឹងឈើគ្រញូងចំនួន៣០ផ្ទាំង ត្រូវបានកំលាំងជំនាញនាំយកទៅកាន់ស្នាក់ការរបស់គេដើម្បីធ្វើការសាកសួរបន្ត ៕

## កិច្ចប្រជុំត្រួតពិនិត្យការអនុវត្តគោលការណ៍ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ

http://cambodiapolice.com/ 2:02 pm 14 ធ្នូ 2017

**បាត់ដំបង ៖** លោកជំទាវ នាយឧត្តមសេនីយ៍ឯក យក់ សុខា អគ្គស្នងការរងនគរបាលជាតិ គូសបញ្ជាក់ថា សម្តេច ក្រឡាហោម បានលើកក្នុង អនុសាសន៍ថា ច្រក របៀង តាមបន្ទាត់ព្រំដែនកម្ពុជា ថៃ ត្រូវបានបិទទាំងស្រុង។ នៅឡើយច្រកតំបន់មួយចំនួន ដូចជាច្រកភ្នំដីនៅស្រុកសំពៅលូន ហេតុអ្វី មានប្រជាពលករច្រើនម្ល៉េះជាង១ពាន់នាក់ឆ្លងកាត់ តើប្រជាពលករ ជានាមកពីក្រុមហ៊ុនណា មានអាជ្ញាបណ្ណឬ? ។ ធម្មតា ច្រកតំបន់មួយ ក្រោមការត្រួតពិនិត្យ ពីស្ថាប័នពាក់ព័ន្ធ ពីកម្លាំង ទាហ៊ាន នគរបាល ជាដើម ហេតុអី អគ្គស្នងការមិនដឹង អំពីចំនួនប្រជាកម្មករឆ្លងកាត់ ឬកន្លែងច្រកនោះមិនរាយការណ៍ ? ដូច្នេះ អគ្គស្នងការ ត្រូវតែ ស្វែងយល់ និងដាក់បទបញ្ជាតាមបណ្តាស្នងការមួយចំនួនជាប់ព្រំដែន ពិនិត្យករណីនេះ ឡើងវិញ។

ប្រសាសន៍របស់ លោកជំទាវ អគ្គស្នងការរង លើកឡើងក្នុងកិច្ចប្រជុំត្រួតពិនិត្យការអនុវត្តន៍គោលការណ៍របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៧ នៅក្នុងសាលប្រជុំស្នង

ការដ្ឋាននគរបាលខេត្តបាត់ដំបង កាលពីព្រឹកថ្ងៃទី១៤ ខែធ្នូនេះ ដែលមានវត្តមានចូលរួមពី សំណាក់ លោកនឹងលោកស្រីជាស្នងការរងទទួលផែនជំនាញអធិការ លោកនឹងលោកស្រីជានាយការិយាល័យជំនាញ សរុប២៨នាក់ មកពីបណ្តាខេត្តមាន ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងក្រុងប៉ៃលិន។

ក្នុងអង្គប្រជុំ ឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ ប្រធាននាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្សលើកឡើងផងដែរ ជុំវិញ អំពីជំនាញ ពាក់ព័ន្ធការងារជួញដូរមនុស្ស លោកបានជំរុញជំនាញកំពុងអនុវត្ត បន្តស្រាវជ្រាវ និងអនុវត្តអោយបានបន្ថែមទៀត ឆ្លើយតបនិងតម្រូវរបស់ប្រជាពលរដ្ឋ និងបង្ការទប់ស្កាត់បង្ក្រាបអោយបានឧក្រិដ្ឋជន។

ឆ្លើយតបនិង របាយការណ៍ លោកវរសេនីយ៍ឯក កុយហៀងស្នងការរងទទួលផែនប្រឆាំងបទល្មើស និងលោកស្រី រស់ ជីវី នាយរងការិយាល័យ ជួញដូរមនុស្ស នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង លោកស្រី អគ្គស្នងការរងនគរបាលជាតិ ក៏បានដាក់ចេញផែនការសកម្មភាព អនុវត្តន៍បន្ថែមទៀត ពាក់ព័ន្ធនឹងប្រព័ន្ធច្បាប់ និងរបៀបរបបការងាររដ្ឋបាល ៕

## ថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០១៧

## អាជ្ញាធរខេត្តសៀមរាប រៀបចំទិវាប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ដើម្បីទប់ស្កាត់ការកេងប្រវ័ញ្ច ការជួញដូរមនុស្សដោយខុសច្បាប់

http://www.akp.gov.kh/kh/ AKP ខេត្តសៀមរាប ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧

អាជ្ញាធរខេត្តសៀមរាបបានអះអាងថា ការធ្វើចំណាកស្រុកឆ្លងដែនដោយខុសច្បាប់ របស់ប្រជាពលរដ្ឋជាកត្តាមួយដ៏ធំ ក្នុងការងាយរងគ្រោះពីអំពើកេងប្រវ័ញ្ច និងជួញដូរមនុស្ស។ ថ្លែងនៅក្នុងទិវាប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៧ នៅខេត្តសៀមរាប កាលពីព្រឹក ថ្ងៃព្រហស្បតិ៍១១រោច ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧ លោកស្រី យូ សុភា អភិបាលរងខេត្តសៀមរាប និងជាប្រធានលេខាធិការ ដ្ឋាននៃគណៈកម្មាធិការ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាបបានមាន ប្រសាសន៍ថា គោលនយោបាយរបស់រាជរដ្ឋាភិបាល គឺផ្តល់ឱកាសជូនប្រជាពលរដ្ឋ ធ្វើការងារបង្កើតប្រាក់ចំណូលទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ហើយពលរដ្ឋមួយ ចំនួនធំ បានទទួលកម្រៃល្អ និងអាចលើកកម្ពស់ជីវភាព។

លោកស្រីបានបន្តថា ប៉ុន្តែអ្វីដែលជាការបារម្ភនោះ គឺការធ្វើទេសន្តប្រវេសន៍ ដោយប្រថុយប្រថាន មិនមានការធានាផ្នែកច្បាប់ និងមិនមានការគ្រប់គ្រង ច្បាស់លាស់របស់ប្រជាពលរដ្ឋ បាននាំឱ្យប្រឈម នឹងហានិភ័យដោយអំពើកេងប្រវ័ញ្ច និងជួញដូរមនុស្ស។ លោកស្រីបានបញ្ជាក់ថា បច្ចុប្បន្ននេះប្រជាពលរដ្ឋនៅខេត្តសៀមរាប បានធ្វើ ចំណាកស្រុកទៅធ្វើការ នៅក្រៅប្រទេសមានរហូតដល់ទៅជាង១០.០០០នាក់ ទាំងទៅ ដោយស្រប ច្បាប់ និងមិនស្របច្បាប់ ហើយអ្នកមួយចំនួនកំពុងប្រឈមការ កេងប្រវ័ញ្ច និងជួញដូរមនុស្ស។

លោកជំទាវ ប៉ុន សំខាន់ អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស បានលើកឡើងថា អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គឺជាបរិបទសកល ដែលនៅ តែបន្តកើតមាន ដោយកត្តាបីសំខាន់ គឺការអប់រំ ការអនុវត្តច្បាប់ និងការឆក់ឱកាស ពីជនល្មើស។ លោកជំទាវបានអះអាងថា រូបភាព នៃអំពើជួញដូរមនុស្ស មិនត្រឹមតែជាការជួញដូរ ឬកេងប្រវ័ញ្ចកម្លាំង ពលកម្ម និងផ្លូវភេទ ប៉ុណ្ណោះទេ ថែមទាំងលេច ចេញបាតុភាពមួយចំនួន ដែលមានទំនោរទៅរក អំពើជួញ ដូរសរីរាង្គ និងបទល្មើសរត់ពន្ធ ឬជួញដូរទារកឆ្លងដែន ដែលហៅថា បទអន្តរការីនៃ អំពើពពោះជំនួស។

លោកជំទាវបានបន្តទៀតថា បញ្ហានេះជាកង្វល់ដែលគណៈកម្មាធិការជាតិប្រយុទ្ធ ប្រឆាំងអំពើជួញដូរ មនុស្ស ចាំបាច់ត្រូវដាក់វិធានការសើបអង្កេតស្រាវជ្រាវ និងបង្ក្រាបឱ្យបានទាន់ពេល និងបានកសាង ច្បាប់បទដ្ឋានគតិយុត្តិពាក់ព័ន្ធបន្ថែមទៀត ដើម្បីចៀសវាងការរីកដុះ ដាលនៃបទល្មើស ដែលនាំឱ្យបង្ក គ្រោះថ្នាក់កាន់តែច្រើន ដល់ជីវិតមនុស្ស។លោកជំទាវបានបន្ថែមទៀតថា បញ្ហាអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនេះ រាជរដ្ឋាភិបាល កម្ពុជា បានយកចិត្តទុកដាក់ខ្លាំងណាស់ ក្នុងការការពារ ប្រជាពលរដ្ឋ ព្រោះគ្រោះថ្នាក់ទាំងឡាយ ដោយឧក្រិដ្ឋកម្មជួញដូរមនុស្ស បង្កឱ្យមានវិនាស កម្មដល់មនុស្សជាតិ៕ ដោយ យុត សៅ

## បំពង់ដែកបាញ់បេតុង ធ្លាក់ត្រូវក្បាលពលករខ្មែរម្នាក់ ស្លាប់យ៉ាងអាណោចអាធ័ម

http://www.pheaktraprak.com ដំណឹងពលករខ្មែរ December 15, 2017

ពលករខ្មែរម្នាក់បានស្លាប់បាត់ជីវិតភ្លាមៗ បន្ទាប់ពីមេការសំណង់ថៃព្យាយាមបញ្ជូនទៅសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យក្រុងប៉ាតាយា ដោយសាររងគ្រោះថ្នាក់ត្រូវបំពង់ដែកបាញ់បេតុងធ្លាក់ចំ។ ហេតុការណ៍គ្រោះថ្នាក់បានកើតឡើងកាលពីវេលាម៉ោង10ព្រឹកនាថ្ងៃព្រហស្បតិ៍ទី14 ខែធ្នូ ឆ្នាំ2017 នៅការដ្ឋានសាងសង់ខនដូមួយកន្លែង ស្ថិតនៅ(សយ) ការសេតសិន 5 ខៅព្រះដំណាក់ ឃុំណងព្រី ស្រុកបាងឡាម៉ុង ខេត្តឈុនបុរី ប្រទេសថៃ។

ប្រភពពីកន្លែងកើតហេតុបានឲ្យដឹងថា បំពង់ដែកបាញ់បេតុងឡើងលើអាគារ កំពុងសាងសង់កម្ពស់ 2ជាន់ បានរអិលធ្លាក់មកខាងក្រោមបណ្តាលឱ្យចំបុរសឈ្មោះ (kuok kol) កុក ជន អាយុ 36 ឆ្នាំ សញ្ជាតិខ្មែរ ដែលកំពុងធ្វើការនៅជាន់ខាងក្រោម បណ្តាលរងរបួសធ្ងន់ ក្រោយមកបានស្លាប់បាត់បង់ជីវិតបន្ទាប់ពីមេការសំណង់ថៃបានបញ្ជូនទៅសង្គ្រោះដល់មន្ទីរពេទ្យ។

ក្រោយពីមានហេតុនេះកើតឡើងការដ្ឋានសាងសង់ខនដូខាងលើនេះត្រូវបានគេបិទផ្អាកឈប់សម្រាកភ្លាម ដើម្បីអោយសមត្ថកិច្ចថៃចូលធ្វើការត្រួតពិនិត្យនៅកន្លែងកើតហេតុ។ យ៉ាងណាមិញសាច់ញាតិរបស់ពលកររងគ្រោះបានរិះគន់យ៉ាងខ្លាំងចំពោះករណីធ្វើឲ្យមានមនុស្សស្លាប់បែបនេះ ហើយករណីគឺកើតឡើងដោយសារតែការធ្វេសប្រហែសរបស់អ្នកបើករថយន្តបាញ់បេតុងដៃខ្វះការប្រុងប្រយ័ត្ន។

## ពលករខ្មែរ 3នាក់បានស្លាប់ និង 2នាក់ទៀតរងរបួសធ្ងន់ នៅក្នុងខេត្តស្រះកែវ

http://www.pheaktraprak.com ដំណឹងពលករខ្មែរ December 14, 2017

កាលពីថ្ងៃព្រហស្បតិ៍ទី14 ខែធ្នូ ឆ្នាំ2017 នៅវេលាម៉ោង09:50នាទីព្រឹកមិញនេះ មានករណីគ្រោះថ្នាក់ចរាចរដ៏រន្ធត់មួយបានកើតឡើងបណ្តាលឲ្យមានពលរដ្ឋខ្មែរចំនួន 3នាក់ស្លាប់ និង 2នាក់ទៀតរងរបួសធ្ងន់។ ហេតុការណ៍គ្រោះចរាចរនេះបានកើតឡើងកាលពីវេលា09:50នាទីព្រឹក នៅត្រង់ចំណុចជិតផ្លូវបំបែកស្រះកែវ-វាត់ណានាខន ស្ថិតនៅក្នុងភូមិម៉ុងខនម៉ៃថៃ ឃុំធង់កុម ស្រុកវាត់ណានាខន ខេត្តស្រះកែវ ប្រទេសថៃ ប្រភពពីកន្លែងកើតហេតុបានឲ្យដឹងថា រថយន្តពីកអាប់ ម៉ាកToyota vigos មួយបាំងកន្លះមួយគ្រឿង ផ្ទុកពលករខ្មែរចំនួន 5នាក់ បានជួបគ្រោះថ្នាក់បុកដើមឈើក្បែរផ្លូវ បណ្តាលអោយមនុស្ស 3នាក់គៀបស្លាប់នៅក្នុងរថយន្ត និង 3នាក់រងរបួសធ្ងន់ ដែលមានឈ្មោះ ៖

១.ឈ្មោះ រឿន វុធ ភេទប្រុស អាយុ 37ឆ្នាំ សញ្ជាតិខ្មែរ អ្នកបើកបររថយន្ត

២.ឈ្មោះ អៀង អូន ភេទស្រី អាយុឆ្នាំ សញ្ជាតិខ្មែរ

៣.ឈ្មោះ ហារ៉េ នី ភេទស្រី អាយុ 19ឆ្នាំ សញ្ជាតិខ្មែរ

៤.ឈ្មោះ សារី ភេទប្រុស អាយុ សញ្ជាតិខ្មែរ ( ស្លាប់ )
៥.ឈ្មោះ យុទ្ធណា ភេទប្រុស សញ្ជាតិខ្មែរ ( ស្លាប់ )
៦.ឈ្មោះ ផឹង ណយ ភេទប្រុស សញ្ជាតិខ្មែរ( ស្លាប់ )

យោងតាមប្រភពព័ត៌មានពីថៃបានប្រាប់អោយដឹងថា រថយន្តដឹកពលករខ្មែរដែលជួបគ្រោះថ្នាក់បុកដើមឈើនៅក្នុងខេត្តស្រះកែវនោះ បើកបរដោយបុរសឈ្មោះ រឿន វុធ ជាពលករខ្មែរធ្វើការស្នាក់នៅក្នុង( ม.5 ต.เขาคันทรง อ.ศรีราชา จ. ชลบุรี) ។ តាមការបញ្ជាក់របស់សមត្ថកិច្ច បុរសឈ្មោះ រឿន វុធ បានបើកបរថយន្តម៉ាកToyota vigos ពាក់ស្លាកលេខ( ผผ-1322 ชลบุรี) ដឹកពលករខ្មែរទាំងអស់មកពីខេត្តឈុនបុរីឆ្ពោះទៅព្រំដែន តែដល់ចំណុចកើតហេតុរថយន្តបានរេចង្កូតធ្លាក់ផ្លូវរួចជ្រុលទៅបុកនឹងដើមឈើក្បែរផ្លូវទើបធ្វើឱ្យមានមនុស្សស្លាប់ និងរងរបួសរបួសតែម្តង។

ក្រោយពេលកើតហេតុជនរងគ្រោះ និងអ្នកបើកបររថយន្តកើតហេតុត្រូវភ្នាក់ងារសង្គ្រោះស្រុកវាត់ណានាខនបញ្ជូនយកទៅសង្គ្រោះនៅមន្ទីរពេទ្យខេត្តស្រះកែវ ចំណែកជនរងគ្រោះដែលស្លាប់សម្តកិច្ចថៃកំពុងធ្វើការត្រួតពិនិត្យរួចបញ្ជូនយកទៅរក្សាទុកនៅមន្ទីរពេទ្យដើម្បីរង់ចាំប្រគល់ជូនសាច់ញាតិអោយយកទៅធ្វើបុណ្យតាមប្រពៃណី។

## ILO **ថា ពលករចំណាកស្រុកមានបញ្ហាលើសុខភាព**

http://www.postkhmer.com/ Fri, 15 December 2017 Daphne Chen

**ភ្នំពេញៈ** អង្គការពលកម្មអន្តរជាតិ (ILO) និងអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) បានចេញរបាយការណ៍មួយកាលពីម្សិលមិញដោយបានបង្ហាញថាមានពលករចំណាកស្រុកកម្ពុជា ៨ នាក់ក្នុងចំណោមពលករចំណាកស្រុក ១០ នាក់ បានជួបការរំលោភបំពានសិទ្ធិការងារ ខណៈធ្វើការនៅបរទេសហើយ ៧ នាក់ក្នុងចំណោម ១០ នាក់បានទទួលរងបញ្ហាសុខភាពផ្លូវកាយ និងផ្លូវចិត្តនៅពេលត្រឡប់មកវិញ។ ការសិក្សាដែលមានទ្រង់ទ្រាយធំនេះបង្ហាញថា ពលករចំណាកស្រុកកម្ពុជាបានរាយការណ៍អំពីបទពិសោធន៍អាក្រក់បំផុតក្នុងចំណោមប្រទេសនៅអាស៊ីអាគ្នេយ៍រួមមាន វៀតណាម ឡាវ និងមីយ៉ាន់ម៉ា។ ពលករពីកម្ពុជាគឺទំនងជាទទួលរងគ្រោះច្រើនជាងចំពោះការរំលោភបំពានសិទ្ធិការងារ និងមានបញ្ហាផ្លូវកាយ និងផ្លូវចិត្តខ្លាំងជាងប្រទេសដទៃៗនៅពេលត្រឡប់មកវិញ។ នេះបើតាមការសិក្សា។

Ben Harkins អ្នកនិពន្ធរបាយការណ៍នេះបានថ្លែងថាវា «ពិបាកនិយាយ» ថាតើការចំណាកស្រុកមានផលវិជ្ជមាន ឬផលអវិជ្ជមានលើពលរដ្ឋកម្ពុជា។ បើទោះបីជាមានអត្ថប្រយោជន៍រយៈពេលវែងមួយចំនួនក៏ដោយរួមមានដូចជា ការធ្លាក់ចុះបន្តិចបន្តួចនៃចំណូល «វាក៏មានបញ្ហាជាច្រើនផងដែរ»។ Harkins បានថ្លែងថាពលករចំណាកស្រុកកម្ពុជាងាយរងគ្រោះចំពោះការរំលោភបំពានសិទ្ធិការងារ និងនៅបានរយៈពេលខ្លីបំផុត។ ជាងនេះទៀតពលករចំណាកស្រុកត្រូវតែស៊ូស្វែងរកការងារនៅពេលត្រឡប់មកវិញ។ Harkins បានថ្លែងបន្តថាៈ នៅមានគម្លាត។ «បើទោះបីពួកគេមានភាពប្រសើរឡើងចំពោះជំនាញ ពួកគេតែងតែមិនអាចអនុវត្តជំនាញនោះបាននៅពេលត្រឡប់មកកម្ពុជាវិញ»។ ២ ភាគ ៣ ក៏បានរាយការណ៍ផងដែរអំពីបញ្ហាសង្គម ផ្លូវចិត្ត និងសុខភាពនៅពេលត្រឡប់មកវិញ។

លោក ស្រេន ឡាំងដា ប្រធានគម្រោងសម្រាប់អង្គការប្រឆាំងការជួញដូរមនុស្សឈ្មោះចាប់ដៃបានថ្លែងថាលោកមិនមានការភ្ញាក់ផ្អើលនឹងលទ្ធផលនេះទេ។ លោកបានបន្តថា ដោយសារពលករកម្ពុជាភាគច្រើនបំផុតចំណាកស្រុកតាមរយៈបណ្តាញក្រៅផ្លូវការដែលជាញឹកញាប់មិនមានកិច្ចសន្យាពួកគេបានដាក់ខ្លួនឯងស្ថិតនៅក្នុងហានិភ័យ។ លោកបានបន្តថាៈ «ពួកគេជួបនិយោជកអាក្រក់ជាច្រើនដែលមិនគោរពតាមការសន្យា មិនផ្តល់ប្រាក់ខែដល់ពួកគេ និយោជកទាំងនោះប្រើពួកគេ និយោជកទាំងនោះកេងប្រវ័ញ្ចការងាររបស់ពួកគេ»។

ទោះយ៉ាងណាក្តីលោក ឡាំងដា ស្ទាក់ស្ទើរមិននិយាយថាការចំណាកស្រុកមានបទពិសោធអវិជ្ជមានទាំងស្រុងចំពោះពលករចំណាកស្រុកកម្ពុជាទេ។ លោកបានថ្លែងថាៈ «នៅពេលពួកគេកំពុងនៅជនបទ ពួកគេមិនមានអ្វី

ធ្វើ ពួកគេគ្មានការងារធ្វើ»។ «ពលករចំណាកស្រុកអាចកែលម្អការរស់នៅរបស់ពួកគេ»។ ពលករចំណាកស្រុកកម្ពុជាប្រមាណ ១,៥ លាននាក់កំពុងរស់នៅបរទេស ហើយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងនៅក្នុងសុន្ទរកថាទៅកម្មករកាត់ដេរកាលពីថ្ងៃពុធថាលោកសង្ឃឹមថានឹងបង្កើនចំនួននោះបន្ថែមទៀតនាពេលអនាគត។

ក្រុមអ្នកស្រាវជ្រាវបានចំណាយរយៈពេល១ ឆ្នាំកន្លះដើម្បីស្រាវជ្រាវទៅលើពលករចំណាកស្រុកជាង ១.៨០០ នាក់ដែលបានត្រឡប់មកប្រទេសវិញក្នុងប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម និងបានចងក្រងទិន្នន័យដើម្បីផលិតជារបាយការណ៍។

Harkins បានគូសបង្ហាញថាមានការគូសបង្ហាញមួយចំនួនជិតពាក់កណ្ដាលនៃពលករចំណាកស្រុកកម្ពុជាបាននាំមកវិញនូវជំនាញថ្មីពីការងារនៅបរទេស។ ដើម្បីកែលម្អបទពិសោធសម្រាប់ពលករចំណាកស្រុកអង្គការ ILO និង IOM បានផ្ដល់អនុសាសន៍ថាប្រទេសទិសដៅគួរពង្រឹងការការពារសិទ្ធិការងាររបស់ពួកគេហើយប្រទេសបញ្ជូនពលករគួរកែលម្អឱកាសការងារសម្រាប់ពលករចំណាកស្រុក។ Harkins ក៏បានអំពាវនាវឲ្យអាជ្ញាធរកម្ពុជាមានភាពតឹងរ៉ឹងជាងមុនចំពោះការតាមដានការរំលោភបំពានសិទ្ធិការងារ ជាពិសេសការរំលោភបំពានដែលធ្វើឡើងដោយទីភ្នាក់ងារជ្រើសរើសពលករ។ លោកបានថ្លែងបន្តថា ៖ «អត្ថប្រយោជន៍នៃការចំណាកស្រុកមិនត្រូវបានធ្វើឲ្យឈានដល់កម្រិតអតិបរមាសម្រាប់ពលករកម្ពុជា ប៉ុន្តែយើងទទួលស្គាល់ថា មានលទ្ធផលសម្រាប់ពលករចំណាកស្រុកក្នុងការទទួលបានលទ្ធផលវិជ្ជមាន»៕ PS

## សមត្ថកិច្ចថៃ ជួយរំដោះពលករភូមា 20នាក់ បន្ទាប់ពីត្រូវថៅកែឃុំខ្លួននៅកណ្ដាលសមុទ្រ

http://www.pheaktraprak.com ប្រភពដំណឹងពលករខ្មែរ December 14, 2017

កាលពីពេលថ្មីៗកន្លងកម្លាំងសមត្ថកិច្ចជើងទឹកថៃ បានអន្តរាគមន៍ ជួយរំដោះពលករភូមាធ្វើការលើទូកសាទត្រី ចំនួន20នាក់ បន្ទាប់ពីត្រូវថៅកែទូកឃុំខ្លួននៅកណ្ដាលសមុទ្រ មិនបើកប្រាក់ឈ្នួលអោយ។ ករណីខាងលើនេះបានកើតឡើងកាលពីថ្ងៃពុធទី13 ខែធ្នូ ឆ្នាំ2017 នៅតំបន់សមុទ្រខាងត្បូងស្ថិតនៅក្នុងស្រុកខះហម ខេត្តណាខនស៊ីថាមរាច ប្រទេសថៃ បន្ទាប់ពីមានពលករភូមាធ្វើការនៅលើទូកនេសាទត្រីនោះសូមអោយមូលនិធិក LPN ក្នុងប្រទេសថៃជួយអន្តរាគមន៍ ។

## ថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១៧

## សម្ដេចក្រឡាហោម ស ខេង ស្នើឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ថៃ ជួយសម្របសម្រួលពលករកម្ពុជា ដែលទៅធ្វើការនៅប្រទេសថៃ

http://www.freshnewsasia.com/ 2017-12-15

**(ភ្នំពេញ)៖** សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧នេះ បានស្នើឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ថៃ ជួយសម្របសម្រួលដល់ ពលករកម្ពុជា ដែលទៅស្វែងរកការងារធ្វើនៅក្នុងប្រទេសថៃ ខណៈដែលបច្ចុប្បន្ននេះ មានពលករកម្ពុជារាប់ម៉ឺននាក់ បាននឹងកំពុងធ្វើការនៅប្រទេសថៃ។

ការស្នើសុំបែបនេះ បានធ្វើឡើងក្នុងកិច្ចជំនួបរវាងសម្ដេចក្រឡាហោម ស ខេង ជាមួយលោក ប្រាជីន ជុនទុង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ថៃ នារសៀលថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧នេះ។ កិច្ចជំនួបនេះ បានរៀបចំធ្វើឡើងនាទីស្ដីការក្រសួងមហាផ្ទៃ កម្ពុជា។ សម្ដេចក្រឡាហោម បានឲ្យដឹងថា បញ្ហាពលករកម្ពុជា ធ្វើការនៅ

ប្រទេសថៃនេះ គឺកម្ពុជា-ថៃ បានទទួលផលប្រយោជន៍ទាំងសងខាង។ ពលករកម្ពុជាទទួលបានផលប្រយោជន៍សម្រាប់គាំទ្រជីវភាពរបស់ខ្លួន ដោយឡែកខាងភាគីថៃ ជាពាណិជ្ជករទទួលបានផលប្រយោជន៍ ពីពលកម្មរបស់ពលករកម្ពុជា។ ចំពោះបញ្ហានេះ សម្តេចក្រឡាហោម ស្នើឲ្យស្ថាប័នពាក់ព័ន្ធរវាងកម្ពុជា-ថៃ ត្រូវធ្វើយ៉ាងណាសហការគ្នាសម្របសម្រួលដល់ដំណើរការឆ្លងដែន របស់ពលករកម្ពុជាទៅធ្វើការនៅប្រទេសថៃ អាចប្រព្រឹត្តិទៅក្នុងភាពស្របច្បាប់ នៃប្រទេសទាំងពីរ។

ឆ្លើយតបទៅនឹងបញ្ហានេះ លោក ប្រាជីន ជុនទុង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ថៃ បានទទួលយកនូវសំណើររបស់សម្តេចក្រឡាហោម ដើម្បីយកទៅជជែកពិភាក្សា ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធរបស់ថៃ ដែលក្នុងនោះ គឺមានក្រសួងការងារ និងក្រសួងមហាផ្ទៃ របស់ថៃ ដែលធ្វើការងារពាក់ព័ន្ធនឹងបញ្ហានេះ។

ក្នុងជំនួបនោះដែរ សម្តេចក្រឡាហោម ស ខេង ក៏បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិ ការរវាងរាជរដ្ឋាភិបាលកម្ពុជា និងថៃកន្លងមក ហើយតាមរយៈដំណើរទស្សនកិច្ចរបស់រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ថៃមកកម្ពុជានៅពេលនេះ គឺនឹងជំរុញកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំង ពីរឲ្យកាន់តែខ្លាំងក្លាឡើងបន្ថែមទៀត៕

## ស្វែងយល់សុខទុក្ខពលករចំណាកស្រុក! តំណាងរាស្ត្រ ឈាង វុន និងក្រុមការងារ ចុះសួរសុខទុក្ខពលករខ្មែរ នៅខេត្តស្រះកែវ ប្រទេសថៃ

http://www.freshnewsasia.com/ 2017-12-16

(ភ្នំពេញ)៖ ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាននៃរដ្ឋសភា បានចុះសាកសួរសុខទុក្ខប្រជាពលករខ្មែរ ប្រមាណជាង២៥០នាក់ ដែលកំពុងធ្វើការងារនៅក្នុងចំការអំពៅ នាខេត្តស្រះកែវ ប្រទេសថៃ នៅព្រឹកថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៧។ នៅក្នុងដំណើរស្វែងយល់ពីសុខទុក្ខរបស់ពលករខ្មែរដែលកំពុងធ្វើការងារនៅក្នុងប្រទេសថៃ នាពេលនេះមានការអមដំណើរដោយលោកស្រី ញ៉ឹក សាគន្ធ អភិបាលរងខេត្តបាត់ដំបង, លោក យ៉េម សុរិទ្យ ទីប្រឹក្សាសម្តេចក្រឡាហោម ស ខេង និងក្រុមការងារជាច្រើនរូបទៀត។

លោក ឈាង វុន បាននាំនូវការផ្តាំផ្ញើសាកសួរសុខទុក្ខ ពីសំណាក់សម្តេច ហេង សំរិន ប្រធានរដ្ឋសភា, សម្តេច សាយ ឈុំ ប្រធានព្រឹទ្ធសភា, សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ជូនដល់ពលករទាំងអស់ផងដែរ។ លោកបានលើកឡើងថា ថ្នាក់ដឹកនាំស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ តែងតែគិតគូរពីសុខទុក្ខរបស់ពលករខ្មែរ ដែលបានចេញមកធ្វើនៅប្រទេសគេ ពិសេសពលករខ្មែរ ដែលកំពុងធ្វើការនៅ ប្រទេសថៃនេះ។ លោកបន្ថែមថា រដ្ឋាភិបាលកម្ពុជា បានខិតខំចចារជាមួយភាគីថៃជាប្រចាំដើម្បីការពារផលប្រយោជន៍ពលករខ្មែរ ហើយរដ្ឋាភិបាលថៃ ក៏បានសន្យាថា នឹងការពារថៃរក្សាពលករខ្មែរ ឲ្យទទួលបាននូវអត្ថប្រយោជន៍នានា ស្របទៅតាមច្បាប់របស់ប្រទេសគេ។

ប្រធានគណៈកម្មការកិច្ចការបរទេស បានគូសបញ្ជាក់ថា ដាក់ស្តែងកាលពីពេលថ្មីៗនេះ សម្តេចតេជោនាយករដ្ឋមន្ត្រី បានណែនាំដល់រដ្ឋមន្ត្រីក្រសួងការងារឲ្យជំរុញ និងពិភាក្សាជាមួយប្រទេសថៃ ដើម្បីធ្វើយ៉ាងណាឲ្យពលករខ្មែរដែលកំពុងធ្វើការខុសច្បាប់ បានបំពេញឯកសារ ក្លាយជាពលករស្របច្បាប់។ ជាមួយគ្នានេះ លោកផ្ទាល់ក៏ធ្លាប់បានមកចរចាជាមួយរដ្ឋាភិបាលថៃ និងបានពិភាក្សាជាមួយរដ្ឋសភាថៃ ដើម្បីការពារអត្ថប្រយោជន៍នានា ជូនពលករកម្ពុជានោះផងដែរ។

ជាមួយគ្នានោះ លោក ឈាង វុន បានថ្លែងអំណរគុណដល់រដ្ឋាភិបាលថៃ អង្គការ សមាគមថៃ ដែលជួយការពារ និងសម្រួលដល់ពលករខ្មែរ។ ទន្ទឹមនឹងនោះ លោកមានសង្ឃឹមថា រាល់សំណូមពរ ឬការលំបាកនានារបស់ប្រជាពលរដ្ឋខ្មែរ ដែលនៅសេសសល់ រដ្ឋាភិបាលកម្ពុជា នឹងខិតខំដោះស្រាយ ដោយមិនទុកឲ្យប្រជាពលរដ្ឋមានផលលំបាក មានបញ្ហា នៅក្នុងប្រទេសគេនោះទេ។ នៅក្នុងឱកាសនោះ លោក ឈាង វុន ក៏បានចែកជូននូវថវិកាមួយចំនួនដល់ប្រជាពលរដ្ឋខ្មែរផងដែរ៕

## ពលករខ្មែរនៅបរទេសជាង១លាននាក់ ផ្ញើលុយឲ្យគ្រួសារប្រមាណ ៣.៨០០លានដុល្លារ ក្នុងមួយឆ្នាំៗ

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្តិ៍ ចេញផ្សាយ ថ្ងៃទី 16 December, 2017

ភ្នំពេញ ៖ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ ឯកឧត្តម អ៊ិត សំហេង បានអះអាងថា ក្នុងមួយឆ្នាំៗពលករខ្មែរដែលកំពុងបម្រើការងារនៅក្រៅប្រទេសចំនួន១លាន២សែននាក់ ពួកគេ បានផ្ញើរប្រាក់ដែលធ្វើការបានមកឲ្យក្រុមគ្រួសារនៅក្នុងប្រទេសកម្ពុជាវិញប្រមាណជា ៣.៨០០ លានដុល្លារ អាមេរិក។ ក្នុងឱកាសអញ្ជើញចូលរួមខួប១០ឆ្នាំ របស់សមាគមជ្រើសរើសពលករកម្ពុជា អាក្រា កាលពី ល្ងាចថ្ងៃទី១៥ខែធ្នូ ឆ្នាំ២០១៧ នៅភោជនីយដ្ឋានតារ៉ាន់ដេង ក្នុងរាជធានីភ្នំពេញ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង បានមានប្រសាសន៍ថា សរុបពលករខ្មែរដែលកំពុងធ្វើការនៅក្រៅប្រទេស រហូតមក ដល់ពេលនេះ មានចំនួន ១លាន២សែននាក់ ក្នុងចំនួនពលករទាំងអស់នេះ បានផ្តល់នូវអំណោយ ផលច្រើនមកដល់សង្គមជាតិ ទោះបីទៅដោយស្របច្បាប់ ឬមិនស្របច្បាប់ តែអាចពួកគេរកការងារបានធ្វើនៅឯក្រៅប្រទេស និងបានផ្ញើរប្រាក់មកក្រុមគ្រួសារជារៀងរាល់ឆ្នាំ។

ឯកឧត្តមបណ្ឌិតបានលើកឡើងថា "ពេលខ្ញុំផ្ទាល់បានទៅជួបសំណេះសំណាល ជាមួយ បង ប្អូននៅតាមរោងចក្រមួយចំនួន ខ្ញុំបានសួរមើលទៅថាក្នុងចំណោមទាំងអស់គ្នា អ្នកណាខ្លះផ្ញើប្រាក់ មកផ្ទះវិញមួយខែ២០០ដុល្លារ ឲ្យលើកដៃមើលទៅសឹងតែមួយរយភាគរយ ដោយយ៉ាងតិចណាស់ ក៏១៥០ដុល្លារដែរ"។ ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រីបន្ថែមថា បើសរុបពលករខ្មែរកំពុងធ្វើការនៅថៃ១លាននាក់ ដោយ ក្នុង ម្នាក់ផ្ញើមក១៥០ដុល្លារ ក្នុងមួយខែៗ បូកសរុបទាំងអស់ក្នុងមួយឆ្នាំៗ មានចំនួន១៨០០ លាន ដុល្លារ ហើយសម្រាប់ពលករដែលបម្រើការងារនៅកូរ៉េ ជប៉ុន ម៉ាឡេ យ៉ាងតិចណាស់ក៏២ពាន់លាន ដុល្លារទៀតដែរ ។ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង បានលើកឡើងទៀតថា សម្រាប់ពលករដែលបានទៅ ធ្វើការ នៅក្រៅប្រទេស ទីភ្នាក់ជ្រើសរើសពលករទាំងអស់ គឺមានភារកិច្ចមួយត្រូវប្រើ សម្តីឲ្យឯកភាពគ្នាបានន័យថា ត្រូវតែគោរពនូវពលករដែលធ្វើការនៅក្រៅប្រទេស ដោយពួកគាត់មិនមែនទៅ ធ្វើជា ខ្ញុំគេ ទៅធ្វើ ជាកញ្ជះគេជាច់ថ្លៃ ដូចពួកប្រឆាំងនិយាយនោះទេ ដោយគ្រប់សមាគមភ្នាក់ទាំងអស់ ត្រូវចេះលើកទឹកចិត្តដល់ពលករ ទៅបម្រើការងារដោយសមត្ថភាពនិងមានជំនាញច្បាស់លាស់។

សូមបញ្ជាក់ថា បច្ចុប្បន្នមានក្រុមហ៊ុនចំនួន៨៥ បាននាំពលករខ្មែរទៅធ្វើនៅប្រទេសរួមមាន៖ ប្រទេសថៃ ជប៉ុន ម៉ាឡេស៊ី ហុងកុង សិង្ហបុរីនិងប្រទេសតំបន់អារ៉ាប់មួយចំនួនទៀត។ ដោយឡែកពលករទៅបម្រើការងារនៅប្រទេសកូរ៉េខាងត្បូង មិនមែនទៅតាមរយៈក្រុមហ៊ុននោះទេ គឺកើតឡើងដោយមានកិច្ចព្រមព្រៀងរវាងក្រសួងការងារកម្ពុជានិងកូរ៉េ។

លោកស្រី អ៊ឹង សៀងឫទ្ធី ប្រធានសមាគមជ្រើសរើសពលករកម្ពុជា អាក្រា បានលើកឡើងថា ក្នុងចំណោមក្រុមហ៊ុនទាំង៨៥ ដែលនាំពលករទៅក្រៅប្រទេសនេះ គឺមានចំនួន៤៧ក្រុមហ៊ុន ជា សមាជិករបស់សមាគមអាក្រា៕

## អាជ្ញាធរខេត្តព្រះវិហារ ប្រារព្ធទិវាប្រយុទ្ធប្រឆាំងអំពើរ ជួញដូរមនុស្ស១២ ធ្នូ ឆ្នាំ២០១៧

http://www.akp.gov.kh/kh/ AKP ខេត្តព្រះវិហារ ថ្ងៃទី១៦ ខែ ធ្នូ ឆ្នាំ២០១៧

អាជ្ញាធរខេត្តព្រះវិហារ បានប្រារព្ធពិធីអបអរសាទរទិវា ប្រយុទ្ធប្រឆាំងអំពើរជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៧ ក្រោមប្រធានបទ រួមគ្នាពង្រឹងសុវត្ថិភាព និងពង្រឹង ការអនុវត្តច្បាប់ ដើម្បីការពារមនុស្សពីអំពើរជួញដូរ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម អ៊ុន ចាន់ដា អភិបាលខេត្តព្រះវិហារ នៅបរិវេណសាលាស្រុកជាំក្សាន្ត កាលពីថ្ងៃសុក្រ ១២

ពេច ខែ មិគសិរ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី១៥ ខែ ធ្នូ ឆ្នាំ ២០១៧ ដោយមានការចូលរួមពីអភិបាលរងខេត្ត ប្រធានមន្ទីរអង្គភាព ជុំវិញខេត្តជាច្រើនរូបទៀត ។

ឯកឧត្តម អ៊ុន ចាន់ដា បានមានប្រសាសន៍ថា ការប្រឆាំងអំពើជួញដូរមនុស្ស មិនមែនជារឿងថ្មីនោះឡើយ តែគឺជាកាតព្វកិច្ចរបស់មន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធក្នុងរាជរដ្ឋាភិបាល ក្នុងការពង្រឹងការអនុវត្តច្បាប់ និង គោលនយោបាយជាតិដែលកំពុងតែនៅជាធរមាន រួមទាំងគោនយោបាយ និងច្បាប់ ដែលបានដាក់បញ្ចូល រួចជាស្រេចនូវការទប់ស្កាត់ និងលុបបំបាត់ អំពើជួញដូរមនុស្សនៅតាមបណ្តា ឃុំ-សង្កាត់ ថ្នាក់មូលដ្ឋាន ថែមទៀត។ ឯកឧត្តម បានបន្តថា ជនល្មើសមានវិធីសាស្រ្ត កលល្បិច ល្បួង អន្ទងប្រមូល មនុស្សឱ្យចូលទៅក្នុងប្រព័ន្ធ នៃអំពើជួញដូរមនុស្ស ហេតុធ្វើឱ្យជនរងគ្រោះ មិនដឹងខ្លួន ថាខ្លួនកំពុងតែរងគ្រោះទៀតផង។ ឯកឧត្តម អភិបាលខេត្តបានបន្តទៀតថា រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ក្នុងការ បង្ការទប់ស្កាត់ ការពារថែទាំ ប្រជាពលរដ្ឋ ហើយការជួញដូរមនុស្សគឺជាបញ្ហារំលោភ សិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរបំផុត និងការជាន់ឈ្លី ទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និងជាអំពើឧក្រិដ្ឋកម្ម ដែលមិនអាចមើលរំលង និងមិនអាចអនុគ្រោះបាន។

ឯកឧត្តម បានចាត់ទុកថា បញ្ហាទាំងអស់នេះវាជាការព្រួយបារម្ភរបស់យើងទាំងអស់គ្នា ព្រោះអំពើនេះបានជះឥទ្ធិពលជាអវិជ្ជមានទៅលើការរីកចម្រើននៃសរីរាង្គបុគ្គល គំនិត ស្មារតី ទឹកចិត្ត សីលធម៌ គុណតម្លៃ សេចក្តីថ្លៃថ្នូរ និងធ្វើឱ្យខូចសណ្តាប់ធ្នាប់ក្នុងសង្គម តម្លៃគ្រួសារ ខ្មែរ និងតម្លៃសង្គមជាតិទាំងមូល៕ ដោយ ទិត ស្រ

## កិច្ចប្រជុំត្រួតពិនិត្យការអនុវត្តគោលការណ៍ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៧

http://cambodiapolice.com/ 10:19 am 18 ធ្នូ 2017 បោះពុម្ព អ៊ីម៉ែល

កណ្តាលៈ នៅថ្ងៃច័ន្ទ១កើត ខែបុស្ស ឆ្នាំរកា ព.ស២៥៦១ ត្រូវនឹងថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧ នេះនៅស្នងការដ្ឋាននគរបាលខេត្តកណ្តាល បានបើកកិច្ចប្រជុំត្រួតពិនិត្យការអនុវត្តគោលការណ៍របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៧ ក្រោមអធិបតីភាពលោកជំទាវ ឧត្តមសេនីយ៍ឯក យក់ សុខា អគ្គស្នងការរងនគរបាលជាតិ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ និងឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល ពិជេយ្យ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស , លោកឧត្តមសេនីយ៍ទោ អ៊ាវ ចំរើន ស្នងការនគរបាលខេត្ត ។

កិច្ចប្រជុំនេះដែរ មានការចូលរួមពី លោកស្រីស្នងការរង ទទួលការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ,ក្រុមការងារមកពីស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ,ខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង , ក្រុមការងារមកពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ,នាយ-នាយរងការិយាល័យជំនាញពាក់ព័ន្ធ ចំណុះស្នងការដ្ឋាននគរបាលខេត្តកណ្តាល និងអធិការ-អធិការរងនគរបាលស្រុកស្អាង ,អង្គស្នួល , កណ្តាលស្ទឹង ,ខ្សាច់កណ្តាល ,កៀនស្វាយ ,កោះធំ និងក្រុងតាខ្មៅ ។

ស្នងការនគរបាលខេត្តកណ្តាល លោកឧត្តមសេនីយ៍ទោ អ៊ាវ ចំរើន បានឡើងអានរបាយការណ៍ស្វាគមន៍ក្នុងកិច្ចប្រជុំនេះយ៉ាងដូច្នេះថា ដោយមានការចង្អុលដឹកនាំក្នុងអាណាព្យាបាលភាពរបស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការនគរបាលជាតិ ព្រមទាំងការផ្តល់នូវកិច្ចសហប្រតិបត្តិការ ពីបណ្តានាយកដ្ឋានជំនាញចំណុះក្រសួងមហាផ្ទៃ និងអាស្រ័យដោយមានការយកចិត្តទុកដាក់ ដឹកនាំសម្របសម្រួលនីតិវិធីរបស់ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តផងនោះ បានធ្វើឲ្យឥរិយាបទភាពជាអ្នក

បំរើសេវាសាធារណៈ ក៏ដូចជាការអនុវត្តគោលនយោបាយភូមិ/ឃុំមានសុវត្ថិភាព ទទួលបាននូវផលវិជ្ជមាន នៃវិជ្ជាជីវៈនគរបាលក្នុងឆ្នាំ២០១៧ ។ លោកឧត្តមសេនីយ៍ទោ អ៊ាវ ចំរើន បានបន្តថា ក្នុងឆ្នាំ២០១៧នេះបទល្មើសព្រហ្មទណ្ឌបានកើតឡើងចំនួន ៣៥៨លើ២៩៦ករណី (កើន៦២ករណី) ។ ក្នុងនោះបទឧក្រិដ្ឋមានចំនួន៤៧លើ៤៩ករណី រួមមាន៖ លួចមានស្ថានទម្ងន់១៣ករណី ,ឃាតកម្ម១០ករណី ,រំលោភសម្លាប់១ករណី ,រំលោភសេពសន្ថវៈ២៣ករណី ។ ដោយឡែកបទមជ្ឈឹមបានកើតមានឡើងចំនួន៣១១ករណី បណ្ដាលឲ្យស្លាប់មនុស្សចំនួន១៧នាក់ និងរបួស១៥៣នាក់ ។

ដោយមានការយកចិត្តទុកដាក់ និងលើកទឹកចិត្តពីសំណាក់ថ្នាក់ដឹកនាំអគ្គស្នងការនគរបាលជាតិ ក៏ដូចជាឯកឧត្តមប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត មន្ត្រីប្រតិបត្តិ នៃស្នងការដ្ឋាននគរបាលខេត្តកណ្ដាល បានយកអស់កម្លាំងកាយចិត្ត អនុវត្តតាមសមត្ថកិច្ចជំនាញ ជាលទ្ធផលបង្ក្រាបបានរួមមាន៣២៦ករណី ចាប់ខ្លួនជនសង្ស័យ៤០៥នាក់ ចាប់យកវត្ថុតាងរួមមាន៖ អាវុធខ្លី០១ដើម ,ម៉ូតូ២៦គ្រឿង ,ទូរស័ព្ទ០១គ្រឿង ,ដាវ០២ដើម និងកាំបិតប៉័ងតោចំនួន០១ដើមផងដែរ ។ ចំពោះបទល្មើសគ្រឿងញៀនវិញ សមត្ថកិច្ចនគរបាលខេត្តកណ្ដាល បង្ក្រាបបានចំនួណ៤៩៤ករណី ឃាត់ខ្លួនជនសង្ស័យ៨៣៤នាក់ ចាប់យកវត្ថុតាងថ្នាំញៀនមេតំហ្វេតាមីន០៣ដុំធំ ,០១ដុំមធ្យម ,២.០១២កញ្ចប់តូច ,ថ្នាំញៀនប្រភេទWYចំនួន១៤គ្រាប់ ,MDMA០៩គ្រាប់ និងមធ្យោបាយពាក់ព័ន្ធក្នុងបទល្មើសជាច្រើនទៀត ។ ដោយឡែកបទល្មើសគ្រោះថ្នាក់ចរាចរណ៍ បានកើតមានឡើងចំនួន២៤៣លើក បណ្ដាលឲ្យមានមនុស្សស្លាប់ចំនួន១៥៤នាក់ និងរបួសចំនួន៣៥៨នាក់ ។ ករណីគ្រោះថ្នាក់ចរាចរណ៍ទាំងអស់នេះកើតមានឡើងដោយសារ ការបើកបរមិនយោគយល់គ្នា ,ផ្ទុកលើសចំណុះ/ទម្ងន់ ,យានយន្តមិនត្រឹមត្រូវតាមនិយាមបច្ចេកទេស និងការបើកបរក្នុងស្ថានភាពស្រវឹង....។ល។

ក្រោយពីស្ដាប់របាយការណ៍ស្វាគមន៍របស់ លោកឧត្តមសេនីយ៍ទោ អ៊ាវ ចំរើន រួចមក លោកជំទាវ ឧត្តមសេនីយ៍ឯក យក់ សុខា អគ្គស្នងការរងនគរបាលជាតិ បានធ្វើការកោតសរសើរដល់ការដឹកនាំរបស់ លោកឧត្តមសេនីយ៍ទោ អ៊ាវ ចំរើន និងការខិតខំប្រឹងប្រែងរបស់មន្ត្រីអនុវត្តច្បាប់ ធ្វើឲ្យការអនុវត្តគោលនយោបាយភូមិ/ឃុំមានសុវត្ថិភាពទទួលបាននូវផលវិជ្ជមាន នៃវិជ្ជាជីវៈនគរបាលក្នុងឆ្នាំ២០១៧នេះ ។ លោកជំទាវ ឧត្តមសេនីយ៍ឯក យក់ សុខា ក៏បានធ្វើការណែនាំ និងផ្ដាំផ្ញើដល់មន្ត្រីជំនាញត្រូវខិតខំប្រឹងប្រែង អនុវត្តគោលការណ៍របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឲ្យទទួលបានលទ្ធផលកាន់តែប្រសើរឡើងថែមទៀត ៕ ជី គឹមហុង

## ក្រឡាប់ឡានធ្លាក់ទឹកស្រះ ធ្វើឲ្យពលរដ្ឋខ្មែរចំណាកស្រុកខុសច្បាប់ 4នាក់បានស្លាប់បាត់បង់ជីវិត

http://www.pheaktraprak.com December 15, 2017

កាលពីវេលាម៉ោង01:25នាទី នាយប់ថ្ងៃសុក្រទី15ខែធ្នូ ឆ្នាំ2017 មានករណីក្រឡាប់រថយន្តដឹកពលរដ្ឋចំណាកស្រុកខុសច្បាប់មួយគ្រឿងបណ្ដាលឲ្យមានមនុស្សស្លាប់ 4នាក់ និងរបួសជាច្រើននាក់ករណីខាងលើនេះបានកើតឡើងកាលពីវេលាម៉ោង01:25នាទីយប់ ស្ថិតនៅក្នុងភូមិម៉ូតាឃុប ឃុំហួរសាំរ៉ុង ស្រុកប្លែងយ៉ាវ ខេត្តឆាកឈើងសៅ ប្រទេសថៃ ។

ប្រភពពីកន្លែងកើតហេតុបានឲ្យដឹងថា រថយន្តការ៉ាក់មួយគ្រឿង ពណ៌ទឹកប្រាក់ ពាក់ស្លាកលេខ5816 ខេត្តស្រះកែវ បានធ្វើដំណើរមកព្រំដែនកម្ពុជាថៃ ដោយផ្ទុកពលរដ្ឋខ្មែរចំណាកស្រុកខុសច្បាប់ចំនួន 20នាក់ និងជនជាតិថៃ 3នាក់ ឆ្ពោះទៅដំណើរទៅតំបន់ឧស្សាហកម្មមួយចំនួនក្នុងប្រទេសថៃ តែមកដល់ត្រង់ចំណុចកើតហេតុ រថយន្តកើតគ្រោះថ្នាក់ក្រឡាប់ធ្លាក់ផ្លូវចូលក្នុងទឹកស្រះនៅក្បែរនោះតែម្តង។

ក្រោយពេលកើតហេតុកម្លាំងសមត្ថកិច្ចថៃបានចុះអន្តរាគមន៍ដល់កន្លែងកើតហេតុ តាមការសាកសួររបស់សមត្ថកិច្ច អ្នករងគ្រោះបានប្រាប់សមត្ថកិច្ចថាពួកគេជាជនជាតិខ្មែរដែលចំណាកស្រុកខុសច្បាប់ចូលមកស្វែងរកការងារធ្វើនៅក្នុងប្រទេសថៃ។

## ពលរដ្ឋខ្មែរខុសច្បាប់ 5នាក់ត្រូវតម្រួតថៃចាប់ខ្លួន

http://www.pheaktraprak.com ប្រភពដំណឹងពលករខ្មែរ December 15, 2017

កាលពីវេលាម៉ោង 10ព្រឹកថ្ងៃសុក្រទី15 ខែធ្នូ ឆ្នាំ2017នេះ ពលករដ្ឋខ្មែរខុសច្បាប់ចំនួន 5នាក់ បាននាំគ្នាលួនឆ្លងដែនខុសច្បាប់ចូលមកស្វែងរកការងារធ្វើនៅទីក្រុងបាងកក ប្រទេសថៃ ត្រូវបានកម្លាំងតម្រួតអន្តោប្រវេសន៍ ស្រុកអារញ្ញ ធ្វើការឃាត់ខ្លួន។ ករណីខាងលើនេះបានកើតឡើងកាលពីវេលាម៉ោង10ព្រឹក ស្ថិតត្រង់ចំណុចរបងថ្មជាប់ព្រំដែនកម្ពុជាថៃ ក្បែរចំណតឈប់ចតរថយន្តរបស់ក្រុមហ៊ុនGoldenGate នៅក្នុងផ្សារលុងក្លឿ ស្រុកអារញ្ញ ខេត្តស្រះកែវ តាមការត្រួតពិនិត្យរបស់សមត្ថកិច្ចថៃបានឲ្យដឹងថាពលរដ្ឋខ្មែរប្រុសស្រីទាំង 5នាក់ គ្មានឯកសារស្នាក់នៅឬធ្វើដំណើរចេញចូលប្រទេសថៃឡើយ។

ក្រោយពេលឃាត់ខ្លួនពលរដ្ឋខ្មែរទាំងអស់ត្រូវបានកម្លាំងសមត្ថកិច្ចថៃបញ្ជូនយកទៅធ្វើការសាកសួរនៅស្ថានីប៉ូលិសអន្តោប្រវេសន៍ ស្រុកអារញ្ញ រួចប្រគល់ជូន សមត្ថកិច្ចកម្ពុជាប្រចាំក្រុងប៉ោយប៉ែតអោយយកវិលត្រឡប់ទៅស្រុកកំណើតរបស់ពួកគេវិញរៀងៗខ្លួន។

## ពលករមានប័ត្រស៊ីជម្ពូ ចាប់ផ្តើមទៅយកលេខរៀងត្រួតសញ្ជាតិបាន.!

http://www.pheaktraprak.com ប្រភពដំណឹងពលរខ្មែរ December 17, 2017

ជារាងរាល់ថ្ងៃមានបងប្អូនពលករខ្មែរយើងធ្វើការនៅប្រទេសថៃ ដែលកាន់ប័ណ្ណស៊ីជម្ពូផុតកំណត់31.03.2018 តែមិនទាន់បានត្រួតសញ្ជាតិ តែងតែសួរមកយើងខ្ញុំ"ថាតើអ្នកមានប័ត្រស៊ីជម្ពូគេបើកអោយធ្វើប៉ាស្ព័រថ្ងៃណា.?" ។ តាមការបញ្ជាក់របស់ក្រសួងការងារថៃ និងគណៈកម្មការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជាក្នុងប្រទេសថៃ ធ្លាប់បានប្រកាសថា អ្នកមានប័ត្រស៊ីជម្ពូអាចទៅយកលេខរៀងត្រួតសញ្ជាតិ ធ្វើប៉ាស្ព័របាន ចាប់តាំងពីថ្ងៃពុធទី03 ខែមករា ឆ្នាំ 2018 (03.01.2018)ខាងមុខនេះ ដូច្នេះសូមបងប្អូនពលករខ្មែរទាំងអស់ដែលមានប័ត្រស៊ីជម្ពូផុតកំណត់ខែ03 ឆ្នាំ 2018 ត្រូវចែយ៉េនៗ។ ហើយចំពោះអ្នកមានលិខិតសម្គាសន៍ក៏និងចាប់ផ្តើមទៅយកលេខរៀងធ្វើប៉ាស្ព័របាននៅពេលឆាប់ៗខាងមុខនេះដែរ ដូច្នេះសូមបងប្អូនពលករខ្មែរទាំងអស់ទាំងមានប័ត្រស៊ីជម្ពូ និងលិខិតសម្គាសន៍សូមមេត្តាចែយ៉េនៗ។

## ពលករខ្មែរម្នាក់ សុំអំពាវនាវឲ្យសមត្ថកិច្ចខ្មែរជួយអន្តរាគមន៍ដល់ពលរដ្ឋខ្មែរ ចំនួន 10 នាក់ដែលកំពុងជាប់ឃុំនៅក្នុងពន្ធនាគារថៃ

http://www.pheaktraprak.com December 18, 2017

យោងតាមប្រភពព័ត៌មានពីពលករខ្មែរធ្វើការនៅក្នុងខេត្តឈុនបុរី ប្រទេសថៃ បានប្រាប់អោយដឹងថា កាលពីពេលថ្មីកន្លងទៅនេះ មានករណីពលរដ្ឋខ្មែរចំនួន 10នាក់ បានចំណាកស្រុកចូលមកស្វែងរកការងារធ្វើនៅក្នុងប្រទេសថៃតាមរយៈច្រកព្រំដែន(ឆងចម)ខេត្តសុរិន្ទ ប្រទេសថៃ តែត្រូវបានកម្លាំងសមត្ថកិច្ចថៃប្រចាំច្រកទ្វារព្រំដែន(ឆងចម) ឃាត់ខ្លួន បន្ទាប់ពីពលរដ្ឋខ្មែរទាំងនោះ ត្រូវបានមេខ្យល់បោកធ្វើអោយកាន់លិខិតឆ្លងដែនក្លែងក្លាយចូលប្រទេសថៃ។ ប្រភពពីពលករដដែលបានបន្តទៀតថា ក្រោយពេលឃាត់ខ្លួនពលរដ្ឋខ្មែរទាំងអស់ត្រូវសមត្ថកិច្ចថៃបញ្ជូនទៅអោយតុលាការកាត់ទោស ក្រោយមកតុលាការថៃ បានកាត់ទោសពលរដ្ឋខ្មែរទាំងអស់អោយជាប់ពន្ធនាគារក្នុងម្នាក់ 12ឆ្នាំពីបទប្រើប្រាស់លិខិតឆ្លងដែនក្លែងក្លាយចូលក្នុងប្រទេសថៃ។

បើតាមការបញ្ជាក់របស់ពលករខ្មែររូបនោះ បាននិយាយថា ពលរដ្ឋខ្មែរកំពុងជាប់ឃុំនៅក្នុងពន្ធនាគារថៃនោះ គឺជាអ្នករស់នៅក្នុងខេត្តបាត់ដំបង 6នាក់ និងខេត្តផ្សេងទៀត 4នាក់ បច្ចុប្បន្ននេះពលករខ្មែររូបនោះបានអំពាវអោយភ្នាក់ងារមានសមត្ថកិច្ចនៅក្នុងប្រទេសថៃជួយអន្តរាគមន៍ដល់ពលរដ្ឋខ្មែរទាំងអស់នោះផង។ ប្រភពព័ត៌មានពី:ព័ត៌មានពលករ ឆ្លងដែន

## បែកធ្លាយរឿងតម្រួត(តម៉)យកប្រាក់ពីពលករភូមាថ្លៃតម្រង់ជួរចូលវ៉ៃវីសារ

http://www.pheaktraprak.com ប្រភពដំណឹងពលករខ្មែរ December 16, 2017

ម្ចាស់ហ្វេសប៊ុកឈ្មោះสุชิน พึ่งประเสริฐ បានឡាយហ្វេសប៊ុករិះគន់រឿងតម្រួត(តម៉) ខេត្តឈាងម៉ៃប្រទេសថៃយកប្រាក់ពីពលករភូមាថ្លៃតម្រង់ជួរចូលវ៉ៃត្រាវីសារក្នុងម្នាក់1.500฿-2.000฿ ចំពោះអ្នកចង់ធ្វើលឿនហេតុការណ៍បានកើតឡើងកាលពីពេលថ្មីៗកន្លងទៅនេះ។ បន្ទាប់ពីមានការរិះគន់ទូរទស្សន៍ប៉ុស្តិ៍លេខ7ថៃបានរឿងរ៉ាវនេះទៅធ្វើការផ្សព្វផ្សាយដើម្បីអោយមានការត្រួតពិនិត្យពីភ្នាក់ងាររដ្ឋ។

## ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០១៧

## ខេត្តកំពង់ចាមប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ២០១៧

*http://www.akp.gov.kh/kh/* ប្រភព AKP ខេត្តកំពង់ចាម ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧

នៅព្រឹកថ្ងៃច័ន្ទ ១កើត ខែបុស្ស នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ២០១៧ អាជ្ញាធរខេត្តកំពង់ចាម បានប្រារព្ធទិវាជាតិលើកទី១១ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ២០១៧ ក្រោមអធិបតីភាពលោកជំទាវ ស្រី គឹមឆយ អភិបាលរងខេត្តកំពង់ចាម នៅក្នុងវិទ្យាល័យ ហ៊ុន សែន សង្កើប ស្ថិតនៅក្នុងឃុំសំបូរ ស្រុកបាធាយ។

លោកជំទាវ ស្រី គឹមឆយ មានប្រសាសន៍ថា ការរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ២០១៧នេះគឺជាបុព្វហេតុនៃយុទ្ធនាការដ៏ធំមួយ ដើម្បីផ្សព្វផ្សាយការយល់ដឹងឱ្យកាន់តែទូលំទូលាយ អំពីសុវត្ថិភាព និងសន្តិសុខ ជូនប្រជាពលរដ្ឋយល់ដឹងអំពីការរំលោភបំពាន គ្រប់រូបភាពនៃអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដែលជាបរិបទ សកលលោក។ លោកជំទាវបានបញ្ជាក់ថា រូបភាពនៃការជួញដូរមនុស្ស មានច្រើនរូបភាព ដូចជាការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការបំពានផ្លូវភេទ អំពើជួញដូរសរីរាង្គ និងបទល្មើសរត់ពន្ធ ជួញដូរទារកឆ្លងដែន បទអន្តរកាវី នៃអំពើពរពោះជំនួស សុទ្ធសឹងជាបទល្មើសនៃការជួញដូរមនុស្ស ។ ទាំងអស់នេះជាក្តីកង្វល់ដែលត្រូវដាក់វិធានការស៊ើបអង្កេត ស្រាវជ្រាវ និងបង្ក្រាបឱ្យទាន់ពេលវេលា ។ រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកអំពើជួញដូរចមនុស្ស ជាបទឧក្រិដ្ឋ និងប្តេជ្ញាទប់ស្កាត់ និងបង្ក្រាបបទល្មើសនេះឱ្យបានខ្លាំងក្លា ដោយមិនអនុញ្ញាតឱ្យជនល្មើសមានឱកាសពង្រីកសកម្មភាព បង្កភាពរងគ្រោះដល់ប្រជាពលរដ្ឋ ដោយមិនបានឆ្លើយតបនោះឡើយ ។

លោកជំទាវលើកឡើងថា គោលនយោបាយរបស់រាជរដ្ឋាភិបាល គឺផ្តល់ឱកាសឱ្យប្រជាពលរដ្ឋ ក្នុងការងារបង្កើនប្រាក់ចំណូល ទាំងនៅក្នុងស្រុក និងនៅក្រៅស្រុក ដយ បានទទួលកម្រៃល្អ និងអាចលើកកម្ពស់ជីវភាពតាមការរំពឹងទុក និងទទួលបាននូវជំនាញ បច្ចេក ទេសកាន់តែប្រសើរឡើង។ ប៉ុន្តែ អ្វីដែលជាការបារម្ភនោះគឺការធ្វើទេសន្តរប្រវេសន៍ ដោយប្រថុយប្រថាន មិនមានការធានាផ្នែកច្បាប់ និងការគ្រប់គ្រងច្បាស់លាស់ ។ លោកជំទាវ អភិបាលរងខេត្តបានឱ្យដឹងថា ដើម្បីទប់ស្កាត់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានខិតខំពង្រឹងអនុវត្តន៍ច្បាប់ និងនីតិវិធីសម្របសម្រួល ដល់ការធ្វើទេសន្តរប្រវេសន៍ ។

ចំណែកពលករនៅក្នុងស្រុក រាជរដ្ឋាភិបាលកម្ពុជា ក៏បាននឹងកំពុងលើកកម្ពស់សិទ្ធិ និងអត្ថប្រយោជន៍ស្របច្បាប់ជាច្រើន តាមរយៈនៃការដាក់ចេញនូវគោលនយោបាយជាបន្តបន្ទាប់ ជាអាទិ៍ការដំឡើងប្រាក់បៀវត្សរៀងរាល់ឆ្នាំ ការផ្តល់របបសោធននិវត្តន៍ដល់កម្មករ ការលើកកម្ពស់លក្ខខណ្ឌការងារសមស្រប ការផ្តល់ឱកាសដល់ស្ត្រីមានផ្ទៃពោះ និងស្ត្រីមានទារក ដើម្បីទទួលបាននូវអត្ថប្រយោជន៍ជាដើម ។ ដូច្នេះ យើងរួមគ្នាផ្សព្វផ្សាយ ទៅដល់អ្នកដែលរស់នៅក្នុងសហគមន៍ និងមូលដ្ឋានរបស់ខ្លួន បានយល់ដឹងអំពីអំពើជួញដូរមនុស្ស និងរួមគ្នាទប់ស្កាត់ឱ្យមានប្រសិទ្ធភាព៕
ដោយ ឆាយ ម៉ុត

## រដ្ឋមន្ត្រីក្រសួងការងារជំរុញឱ្យទីភ្នាក់ងារជ្រើសរើសពលករបង្កើនការយក ចិត្តទុកដាក់ការពារពលករធ្វើការនៅក្រៅប្រទេស

http://www.akp.gov.kh/kh/ ប្រភព AKP ភ្នំពេញ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧

ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈបាន ជំរុញឱ្យទីភ្នាក់ងារជ្រើសរើសពលករទាំងអស់ ត្រូវយកចិត្តទុកដាក់ការពារ ពលករធ្វើការ នៅក្រៅប្រទេស ដើម្បីឱ្យពួកគេមានភាពកក់ក្តៅ។ ថ្លែងនៅក្នុងឱកាសអញ្ជើញចូលរួមខួប១០ឆ្នាំ របស់សមាគមជ្រើសរើសពលករ កម្ពុជាកាលពីចុង សប្តាហ៍នេះ ឯកឧត្តម អ៊ិត សំហេង បានបញ្ជាក់ថា ទីភ្នាក់ងារជ្រើស រើសពលករទាំង អស់ត្រូវចេះ លើកទឹក ចិត្តដល់ពលករចេះគោរពដល់ពលករ ដែលធ្វើការនៅក្រៅប្រទេស ព្រោះថាពួកគាត់មិនមែន ទៅធ្វើជាខ្ញុំគេ ទៅធ្វើជាកញ្ជះគេជាច់ ថ្លៃនោះទេគឺពួកគេបានចូលរួម ចំណែកយ៉ាងសំខាន់ក្នុងការជំរុញ ឱ្យសេដ្ឋកិច្ចជាតិមានការរីកចម្រើន។

ឯកឧត្តម រដ្ឋមន្ត្រីបានបន្ថែមថាបច្ចុប្បន្ននេះមានពលករខ្មែរ កំពុងបម្រើការ ងារនៅក្រៅ ប្រទេស ចំនួន១.២លាននាក់ ដោយក្នុងមួយឆ្នាំៗពួកគាត់បានផ្ញើប្រាក់ មកឱ្យក្រុមគ្រួសារនៅ កម្ពុជាវិញប្រមាណ ៣.៨០០លាន ដុល្លារ។ ឯកឧត្តមលើកឡើងថា ចំពោះទំហំទឹកប្រាក់នេះមិនត្រឹមតែជួយ លើកស្ទួយដល់ជីវភាពរស់នៅក្នុងក្រុម គ្រួសារ ពលករប៉ុណ្ណោះទេថែមទាំង ចូលរួមចំណែកធ្វើ ឱ្យសេដ្ឋកិច្ចជាតិមានការរីកចម្រើនផងដែរ។ ឯកឧត្តមបានបន្ថែមថា បើសរុបពលករខ្មែរ កំពុងធ្វើការនៅថៃជាង ១លាននាក់ ដោយផ្ញើក្នុងម្នាក់ ១៥០ដុល្លារ ក្នុងមួយខែៗ បូកសរុបទាំងអស់ក្នុងមួយឆ្នាំៗ មានចំនួន ១.៨០០លានដុល្លារ។ ចំណែក ពលករដែលបម្រើការងារនៅកូរ៉េ ជប៉ុន ម៉ាឡេស៊ី វិញយ៉ាងតិចណាស់ក៏ផ្ញើមកគ្រួសារវិញប្រមាណ ជាង២.០០០លានដុល្លារដែរ។

លោកជំទាវ អ៊ឹង សៀវឫទ្ធី ប្រធានសមាគមជ្រើសរើសពលករកម្ពុជាហៅកាត់ថា (អាក្រា) បានសន្យានឹង ខិតខំបង្កើតនីតិវិធីផ្សេងទៀត ដើម្បីបង្កើនកិច្ចគាំពារ និងការពារ ផលរបស់ពលករក្រៅប្រទេស កុំឱ្យរងការរំលោភបំពាន និងការកេងប្រវ័ញ្ចពលកម្ម និងប្រាក់បៀវត្សរ៍ជាដើម។ លោកជំទាវបានបន្ថែមថា អ្វីដែលសំខាន់ទៀតនេះ សមាគមជ្រើសរើសពលករកម្ពុជា នឹងបន្តចូលរួម ជាមួយរាជរដ្ឋាភិបាលក្នុងការលំបាកបញ្ហាពលករ ចំណាក់ស្រុក ខុសច្បាប់ ហើយណែនាំឱ្យពួកគេវិលមក រកភាពស្របច្បាប់វិញ ដើម្បីបញ្ចៀសការធ្វើបាប ឬធ្វើទុក្ខបុកម្និញពីអាជ្ញាធរនៅក្រៅប្រទេស។

សូមបញ្ជាក់ថា បច្ចុប្បន្ននេះ នៅកម្ពុជាមានទីភ្នាក់ងារជ្រើសរើសពលករទាំងអស់ចំនួន ៨៥អង្គភាព ក្នុងនោះមានតែចំនួន៤៧អង្គភាពប៉ុណ្ណោះ ដែលបានចុះបញ្ជីជាស មាជិកសមាគមទីភ្នាក់ងារជ្រើសរើស ពលករកម្ពុជា៕
ដោយ គង់ សិរីរ័ត្ន

## សាលាឧទ្ធរណ៍ ដម្រះជនជាប់ចោទនាំនារីខ្មែរទៅការនៅចិន

http://www.postkhmer.com ប្រភពភ្នំពេញប៉ុស្តិ៍ Tue, 19 December 2017 គឹម សារុំ

ភ្នំពេញៈ ស្ត្រីជាប់ចោទ ៣ នាក់បានទទួលកំហុសនិងស្ត្រីម្នាក់ទៀតច្រានចោលបទចោទពាក់ព័ន្ធនាំនារីខ្មែរ ២ នាក់ទៅរៀបការប្តីនៅប្រទេសចិន កាលពីឆ្នាំ ២០១៥ ដែលជនជាប់ចោទទាំង ៤ នាក់ត្រូវតុលាការថ្នាក់ក្រោមផ្តន្ទាទោសដាក់ពន្ធនាគារម្នាក់ ៧ ឆ្នាំ។

តាមកំណត់ហេតុរបស់នគរបាលបានបង្ហាញថាកាលពីអំឡុងខែកុម្ភៈ ឆ្នាំ ២០១៥ ស្ត្រីជាប់ចោទឈ្មោះប៊ួយ សាម៉ុនអាយុ៤៦ឆ្នាំបានអះអាងប្រាប់គូកនរបស់ខ្លួនថាគាត់មានប្អូននិងកូនស្រីមានប្តីនៅប្រទេសចិនហើយពួកគេមានជីវភាពធូរជាណាស់។ ក្នុងការឃោសនានោះស្ត្រី ប៊ួយ សាម៉ុន បានណែនាំឲ្យស្ត្រីជាប់ចោទឈ្មោះ ហុង រី អាយុ ៥០ ឆ្នាំ,ឈ្មោះ អ៊ុល យ៉ុង អាយុ ៤៩ ឆ្នាំ,និង ឈ្មោះ កើត ហួន អាយុ ៥៥ ឆ្នាំដើររកនារីខ្មែរដើម្បីទៅរៀបការប្តីនៅប្រទេសចិនហើយពួកគេរើសបាននារីខ្មែរ ២ នាក់ពីខេត្តក្រចេះ មានអាយុ ១៩ ឆ្នាំដូចគ្នា។

អង្គហេតុបន្តថា ក្រុមស្ត្រីជាប់ចោទបានរត់ការឯកសារនិងបានបញ្ជូននារីរងគ្រោះទៅប្រទេសចិន តែត្រូវបុរសចិនធ្វើទារុណកម្មក៏ប្រាប់មកក្រុមគ្រួសារប្តឹងសមត្ថកិច្ចចាប់ពួកមេខ្យល់ទាំងនេះតែម្តង៕

## សាលាឧទ្ធរណ៍ថៃ ច្រានចោលបណ្តឹងពលករនេសាទខ្មែរ ៨ នាក់

http://www.postkhmer.com ប្រភពភ្នំពេញប៉ុស្តិ៍ Tue, 19 December 2017 Leonie Kijewski

ភ្នំពេញៈ សាលាឧទ្ធរណ៍ថៃបានច្រានចោលបណ្តឹងឧទ្ធរណ៍របស់អ្នកនេសាទជនជាតិកម្ពុជា ១១ នាក់ដែលត្រូវបានជួញដូរ និងបង្ខំឲ្យធ្វើការនៅលើទូកនេសាទក្នុងប្រទេសថៃអស់រយៈពេលជាច្រើនខែមុនពេលត្រូវបានជួយសង្គ្រោះកាលពីឆ្នាំមុន។

សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍តំបន់ ៨ របស់ប្រទេសថៃដែលច្រានចោលបណ្តឹងឧទ្ធរណ៍របស់កម្មករនេសាទកម្ពុជាប្រឆាំងនឹងការច្រានចោលរបស់សាលាដំបូងក្នុងរឿងនេះត្រូវបានចេញកាលពីចុងខែតុលា ប៉ុន្តែត្រូវបានអានជាសាធារណៈកាលពីសប្តាហ៍មុន។ នេះបើតាមលោកស្រី Nishkhan Usayapant អ្នកគ្រប់គ្រងគម្រោងប្រឆាំងការជួញដូរនៃមូលនិធិសិទ្ធិមនុស្ស និងការអភិវឌ្ឍ។

ដើមបណ្តឹងជនជាតិកម្ពុជាបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការច្រានចោលចំពោះករណីពួកគេកាលពីចុងខែកក្កដា។ លោកស្រីបានថ្លែងថាតុលាការបានលើកទឡ្ហីករណ៍ថា៖ «ករណីដែលបង្ហាញនោះមិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្ហាញថាកម្មករពួកគេត្រូវបានគំរាម ឬបង្ខំឲ្យធ្វើការប្រឆាំងនឹងឆន្ទៈពួកគេទេ»។ «ជនរងគ្រោះបានអះអាងថា អ្នកគ្រប់គ្រងទូកបានជះទឹកលើពួកគេ ខណៈកំពុងនៅលើទូក។ អ្នកគ្រប់គ្រងទូកក៏បានយកញញួរបុកទូកជាទង្វើធ្វើឲ្យជនរងគ្រោះមានអារម្មណ៍រងការគំរាមកំហែង»។ លោកស្រីបានថ្លែងថាបញ្ហាទាំង ២ នេះគឺជាផ្នែកនៃបណ្តឹងឧទ្ធរណ៍ដោយសារមិនត្រូវបានអើពើដោយសាលាដំបូង។ ប៉ុន្តែសាលាឧទ្ធរណ៍ឥឡូវនេះសម្រេចថាវាជា «ការព្រមាន» ឬ «ការដាក់ទោសវិន័យ» និងមិនមែនជាភ័ស្តុតាងនៃការបំភិតបំភ័យ។

ទន្ទឹមនេះលោកស្រី Usayapant បានថ្លែងថា ករណីប្រឆាំងម្ចាស់ទូកឈ្មោះ Kamneungnuan Wongkajornkitti កំពុងស្ថិតក្នុងការរៀបចំភ័ស្តុតាង។ លោកស្រីថា៖ «ទីភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធកំពុងពិភាក្សាពីរបៀបប្រមូលសក្ខីកម្មពីជនរងគ្រោះដែលបានទៅកម្ពុជា»៕ PS

## លោកនាយករដ្ឋមន្ត្រីថៃ ប្រកាសសាងសង់កន្លែងស្នាក់នៅជូនពលករបរទេស

http://www.pheaktraprak.com ប្រភពដំណឹងពលករខ្មែរ December 18, 2017

យោងតាមបណ្តាញសារព័ត៌របស់កាសែតថៃបានចុះផ្សាយកាលពីថ្ងៃច័ន្ទ ទី18 ខែធ្នូ ឆ្នាំ2017 នេះ បានអោយដឹងថា លោកនាយករដ្ឋមន្ត្រី ប្រយុទ្ធ ចាន់អូចា កំពុងបង្កើតគម្រោងសាងសង់កន្លែងស្នាក់នៅជូនពលករបរទេស ដែលកំពុងធ្វើការស្នាក់នៅក្នុងប្រទេសថៃ។ ដោយគម្រោងនេះនឹងចាប់ផ្តើមសាងសង់កន្លែងស្នាក់នៅ នូវតាមតំបន់ឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេសមួយចំនួនក្នុងប្រទេសថៃ ដើម្បីចាត់របៀបរៀបរយពលករបរទេសតាមនយោបាយ (Zoneing)របស់ថៃនៅក្នុងពេលឆាប់ៗខាងនេះ។ ក្នុងនោះលោកនាយករដ្ឋមន្ត្រីបានស្នើគម្រោងនេះដល់នាយកដ្ឋាន

លើកកម្ពស់មូលនិធិសង្គម(BOI) ក្រសួងមហាផ្ទៃថៃនិងក្រសួងការងារថៃអោយសហការជាមួយក្រុមហ៊ុនឯកជនដើម្បីចាត់ចែងសាងសង់កន្លែងស្នាក់នៅជូនពលករបរទេសព្រមទាំងអភិវឌ្ឍន៍ការងារជូនដល់ពលករទៀតផង។

## ករណីគ្រោះថ្នាក់ចរាចរណ៍ស្ថិតក្នុងស្រុកគ្លៀងយ៉ៃ ខេត្តឆាក់ឈើងសៅ ដែលបណ្ដាលអោយពលរដ្ឋកម្ពុជា០៤នាក់បាត់បង់ជីវិត

https://www.facebook.com/ Royal Embassy of Cambodia in Bangkok

ខេត្តឆាក់ឈើងសាវ ប្រទេសថៃ, នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧ ក្រុមការងារទទួលបន្ទុកពលករ និងមន្ត្រីផ្នែកកុងស៊ុល តំណាងឲឯកឧត្តមឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ បានចុះទៅស្ថានីយ៍ប៉ូលីសស្រុកគ្លៀងយ៉ៃ ស្ថិតក្នុងខេត្តឆាក់ឈើងសៅ ប្រទេសថៃ ដើម្បីពិនិត្យមើលករណីរថយន្តដឹកពលករដ្ឋកម្ពុជាចំនួន២០នាក់ដែលមានបំណងចូលមកធ្វើការនៅក្នុងប្រទេសថៃ ជួបគ្រោះថ្នាក់ចរាចរណ៍ បណ្ដាលអោយពលរដ្ឋកម្ពុជាចំនួន០៤នាក់បានបាត់បង់ជីវិត ដោយក្រុមការងារបានជួយសម្របសម្រួលជាមួយសមត្ថកិច្ចដោះលែងពលរដ្ឋខ្មែរដែលប៉ូលីសឃាត់ខ្លួនចំនួន០៣នាក់ និងបានទំនាក់ទំនងស្វែងរកសាច់ញាត្តិសព ដើម្បីរៀបចំឯកសារបញ្ជូនសាកសពទៅធ្វើបុណ្យតាមប្រពៃណីនៅព្រះរាជាណាចក្រកម្ពុជាវិញ។

ជាមួយគ្នានេះដែរ ក្រុមការងារបានស្នើសុំសមត្ថកិច្ចជួយស្រាវជ្រាវ និងស្វែងរកក្រុមមេខ្យល់ដែលដឹកជញ្ជូនពលរដ្ឋកម្ពុជាមកធ្វើការដោយខុសច្បាប់នៅក្នុងប្រទេសថៃ មកទទួលទោសតាមច្បាប់អោយទាល់តែបាន ដើម្បីជួយកាត់បន្ថយការនាំពលរដ្ឋកម្ពុជាមកប្រទេសថៃដោយខុសច្បាប់។

## ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៧

## សមត្ថកិច្ចតាមមូលដ្ឋានត្រូវណែនាំអប់រំប្រជាពលរដ្ឋបញ្ឈប់ចំណាកស្រុកខុសច្បាប់និងកម្លាំងតាមបន្ទាត់ព្រំដែនត្រូវទប់ស្កាត់

https://cambodiapolice.com/ ប្រភពគេហទំព័រអគ្គស្នងការដ្ឋាននគរបាលជាតិ 10:13 pm 19 ធ្នូ 2017

បន្ទាយមានជ័យ ៖ នៅព្រឹកថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧ នេះ នៅទីលានមាត់ស្ទឹងព្រះពន្លា ក្រុងសិរីសោភ័ណបានប្រារព្ធពិធី ទិវាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ក្នុងពិធីនោះលោក សួន បវរ អភិបាលខេត្តបន្ទាយមានជ័យមានប្រសាសន៍ថា៖ជំហររបស់រដ្ឋបាលសាលាខេត្តដោយចាត់ទុកអំពើជួញដូរមនុស្សជាបទល្មើសឧក្រិដ្ឋកម្ម និងប្ដេជ្ញាចិត្តបង្ក្រាប ទប់ស្កាត់បទល្មើសនេះអោយបានខ្លាំងក្លាដោយមិនអនុញ្ញាតអោយជនល្មើសមានឱកាសពង្រីកសកម្មភាពបង្កភាពរងគ្រោះដល់ប្រជាពលរដ្ឋដោយមិនបានឆ្លើយតបអោយបានទាន់ពេលវេលានោះឡើយ។

លោកបានបញ្ជាក់ថា៖រាជរដ្ឋាភិបាលកម្ពុជាកំពុងសហការជាមួយបណ្ដាប្រទេសអាស៊ាន ក្នុងកិច្ចសហប្រតិបត្តិការលើវិស័យរបបសន្តិសុខសង្គមដោយធានាចំពោះពលករស្របច្បាប់នៅគ្រប់ប្រទេស។ដោយឡែកសម្រាប់ពលករធ្វើការនៅប្រទេសថៃត្រូវបានអនុញ្ញាតអោយប្រើប្រាស់ឯកសារថតចម្លងត្រឹមត្រូវតាមច្បាប់ដើមដើម្បីបំពេញបែបបទស្របច្បាប់ទាំងនេះជាប្រយោជន៍សម្រាប់ពលករទេសន្តរប្រវេស។ លោក សួន បវរ បានបញ្ជាក់ថា៖ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាយុទ្ធនាការដធំមួយគឺត្រូវអាជ្ញាធរនិងសមត្ថកិច្ចតាមមូលដ្ឋានត្រូវចូលរួមអប់រំណែនាំដល់ប្រជាពលរដ្ឋតាមជនបទអោយឈប់ការចាញ់បោកមេខ្យល់និងកងកម្លាំងឈរជើងតាមបន្ទាត់ព្រំដែនត្រូវទប់ស្កាត់អោយបានការសុវត្ថិភាពប្រជាពលរដ្ឋ៕ដោយៈ ចន្ទ្រា

# តំណាងអយ្យការសុំឱ្យតុលាការលើកលែងចោទ លើជនជាតិចិនដែលនាំពលរដ្ឋខ្មែរទៅលក់នៅចិន រាប់សិបនាក់

http://ann.com.kh/site/news/ ថ្ងៃពុធ, 20 ខែធ្នូ 2017 9:08 ព្រឹក

**រាជធានីភ្នំពេញ៖** កាលពីរសៀល ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧ លោកស្រី ថ្លាង ផាណែត ប្រធានក្រុមប្រឹក្សាចៅក្រមជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ បានបើកសវនាការកាត់ទោសបុរសជនជាតិចិនម្នាក់ និងបុរសខ្មែរម្នាក់ មានតួនាទីនាយកវិទ្យាស្ថាន IPAT ពាក់ព័ន្ធ ករណីនាំនិស្សិតខ្មែរទៅលក់ឱ្យធ្វើជាកម្មកររោងចក្រនៅប្រទេសចិន។ លោក រៀល សុភិន ជាតំណាងអយ្យការ បានចោទប្រកាន់លើជនជាប់ចោទ ទី១.ឈ្មោះ អ៊ិន ស៊ីម៉ាណាន់ ភេទប្រុស អាយុ៣៤ឆ្នាំ មុខរបរជានាយកវិទ្យាស្ថាន បណ្តុះបណ្តាលគណនេយ្យ វិជ្ជាជីវៈ (IPAT) និងទី២.ឈ្មោះ Liu Wing Hing ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិចិន ពីបទនាំចេញដោយមិនស្របច្បាប់ សម្រាប់នាំឆ្លងដែន ប្រព្រឹត្តអំឡុងចុងឆ្នាំ២០១៥ យោងតាមមាត្រា១១ នៃច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

ក្នុងសវនាការជនជាប់ចោទឈ្មោះ អ៊ិន ស៊ីម៉ាណាន់ បានសារភាពថា ខ្លួនពិតជាបាន ផ្សព្វផ្សាយជ្រើសរើសនិស្សិត ឱ្យទៅរៀននៅសាកលវិទ្យាល័យ ថ្នៃម៉ូតសម្លៀកបំពាក់ ផ្នែកច្នៃម៉ូតសម្លៀកបំពាក់ ក្នុងប្រទេសចិន ដោយតម្រូវឱ្យនិស្សិតបង់លុយពី ២,៥០០ដុល្លារ ទៅ៤,៥០០ដុល្លារ។ ជនជាប់ចោទបន្តថា នៅពេលទៅដល់ប្រទេសចិន និស្សិតអាចមានការងារធ្វើក្រៅម៉ោង បានប្រាក់ខែចន្លោះពី៥០០ ទៅ៦០០ដុល្លារ ខ្លួនមិនបានបោកប្រាស់និស្សិតយកទៅលក់ឱ្យធ្វើជាកម្មករ នៅរោងចក្រក្នុងប្រទេសចិនឡើយ។ ចំណែកជនជាប់ចោទឈ្មោះ Liu Wing Hing បានបដិសេធថា ខ្លួនមិនបានដឹងរឿងអ្វីទេ គឺគ្រាន់តែជួយរត់ការឯកសារនាំនិស្សិត ទាំងអស់ទៅប្រទេសចិនតែប៉ុណ្ណោះ។

ជនរងគ្រោះដែលបានចូលរួមក្នុងសវនាការ បានអះអាងថា មាននិស្សិតចំនួន២២នាក់ ដែលត្រូវចាញ់បោកជនជាប់ចោទទាំងពីរនាក់ខាងលើ អស់ប្រាក់ពីចន្លោះ ២,៥០០ដុល្លារ ទៅ៤,៥០០ដុល្លារក្នុងម្នាក់ៗ។ ជនជាប់ចោទបានបញ្ជូនពួកគេ ទៅធ្វើជាកម្មកររោងចក្រកាត់ដេរ ដោយធ្វើការពី៨ ទៅ១០ម៉ោងក្នុង១ថ្ងៃ ដោយគ្មានពេលសម្រាក និងទទួលបានប្រាក់ខែតែ ១០០ ទៅ១២០ដុល្លារតែប៉ុណ្ណោះ មិនដូចជាអ្វីដែលជនជាប់ចោទបានសន្យានោះទេ។ ក្រោយពីពួកគេដឹងខ្លួនថា ត្រូវចាញ់បោកគេ ជនជាតិចិនបាន ដកហូតលិខិតឆ្លងដែនរបស់បពួកគេទុក និងបង្ខាំងពួកគេឱ្យធ្វើការ គ្មានពេលសម្រាក។ ក្រោយមកដោយទ្រាំមិនបាន បពួកគេក៏បាននាំគ្នារត់ទៅរកស្ថានទូតខ្មែរឱ្យជួយអន្តរាគមន៍ និងបញ្ជូនមកប្រទេសកម្ពុជាវិញ។

អ្វីដែលគួរឱ្យកត់សម្គាល់នោះ គឺក្រោយពីសាកសួរដេញដោលចប់សព្វគ្រប់ លោក រៀល សុភិន ជាតំណាងអយ្យការ ដែលជាចោទប្រកាន់លើជនជាប់ចោទផ្ទាល់ បែរជាស្នើសុំឱ្យតុលាការលើកលែងការចោទប្រកាន់លើជនជាប់ចោទជាជនជាតិឈ្មោះ Liu Wing Hing ទៅវិញ។

គេរង់ចាំមើលថា តើនៅពេលប្រកាសសាលក្រមព្រឹកថ្ងៃទី៩ ខែមករា ឆ្នាំ២០១៨ ខាងមុខ តុលាការនឹងលើកលែងការចោទប្រកាន់លើជនជាតិចិនដែល នាំពលរដ្ឋខ្មែរទៅលក់នៅប្រទេសចិន តាមសំណូមពរលោកតំណាងអយ្យការដែរឬទេ?៕ **ដោយ៖ ឡុក សំរិត**

# អាជ្ញាធរខេត្តបន្ទាយមានជ័យ ជំរុញគ្រប់ភាគីពាក់ព័ន្ធត្រូវបន្តបង្កើនសកម្មភាព ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទាំងអស់គ្នា

http://www.akp.gov.kh/ AKP ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧

អាជ្ញាធរខេត្តបន្ទាយមានជ័យ បានជំរុញដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់បន្តប្រឹងប្រែងបង្កើនសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព ឱ្យមាន ប្រសិទ្ធភាពស្របទៅ តាមទិសដៅនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល។នៅក្នុងទិវាជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស១២ធ្នូ លើកទី១១ ដែលខេត្តបន្ទាយមានជ័យបាន

ប្រារព្ធធ្វើនៅ ព្រឹកថ្ងៃអង្គារ ២កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹង ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧ នៅមាត់ស្ទឹងក្រុងសិរីសោភ័ណ មានអ្នកចូលរួមជិត២០០០នាក់ នោះឯកឧត្តម សួន បវរ អភិបាលខេត្ត បន្ទាយមានជ័យបានមានប្រសាសន៍ថា ទិវាដ៏មានសារៈសំខាន់នេះ មានការចូលរួមពីគ្រប់សមាសភាព ពាក់ព័ន្ធដែលជាអ្នកមានតួនាទីក្នុងការគាំទ្រ ឱ្យកិច្ចការមួយនេះ ទទួលបានលទ្ធផលគួរកត់សម្គាល់ក្នុង ការអប់រំផ្សព្វផ្សាយការអនុវត្ត ច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ក៏ដូចច្បាប់ផ្សេងៗទៀត ជុំវិញការរំលោភបំពាន ទៅលើសិទ្ធិមនុស្សការរំលោភបំពានទៅលើស្ត្រីនិងកុមារ និងការអនុវត្តវិធានការទាំងឡាយ ក្នុងការបង្ការទប់ស្កាត់និងបង្ក្រាបបទល្មើស។

ឯកឧត្តម សួន បវរ បានគូសបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា នៅតែបន្តយកចិត្ត ទុកដាក់កាន់តែខ្លាំងក្លា ក្នុងការការពារប្រជាពលរដ្ឋ និងប្រទេសជាតិពីភាពរងគ្រោះទាំងឡាយ ដោយឧក្រិដ្ឋកម្មជួញដូរមនុស្ស ដែលបានបង្កឱ្យមានវិនាសកម្មជាថ្មីដល់មនុស្សជាតិ ហើយបាន និងកំពុងក្លាយជាទេសភាពសម័យទំនើបគួរភ័យខ្លាច និងស្អប់ខ្ពើមជាទីបំផុត។អភិបាលខេត្តបន្ទាយមានជ័យបានធ្វើការអះអាងថា ក្នុងនាមរដ្ឋបាលខេត្ត និងក្នុងនាមគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្តេជ្ញាបន្តខិតខំប្រឹងប្រែង ដើម្បីឱ្យប្រជាពលរដ្ឋកម្ពុជា និងមនុស្សជាតិ ក៏ដូចក្នុងខេត្តទទួលបានការគោរពសិទ្ធិសេចក្តីថ្លៃថ្នូរ ផលប្រយោជន៍ស្របច្បាប់ និងភាពសុខដុមរមនា ដោយរួមសហការជាមួយបណ្តាដៃគូពាក់ព័ន្ធនានា ដើម្បីរួមគ្នាបង្ក្រាបអំពើជួញដូរមនុស្សគ្រប់រូបភាពនិងផ្តន្ទាទោសជនល្មើសឱ្យបានម៉ឺងម៉ាត់ដើម្បី កាត់បន្ថយនិងលុបបំបាត់ប្រសិទ្ធភាពបទល្មើស។ឯកឧត្តមបន្តទៀតថា យុទ្ធនាការនេះ នឹងបន្តធ្វើយ៉ាងគគ្រឹកគគ្រេងក្នុងខេត្តបន្ទាយមានជ័យនិងទូទាំងប្រទេស ដោយផ្សព្វផ្សាយតាមប្រព័ន្ធនានាមានវិទ្យុ ទូរទស្សន៍និងបណ្តាញ ព័ត៌មានវិទ្យាដើម្បីបញ្ជ្រាបការ យល់ដឹងទៅដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន និងដើម្បីកុំឱ្យប្រជាពលរដ្ឋពិសេសស្ត្រី និងកុមារក្លាយ ជាឧបករណ៍ជួញដូរនៃជនដែលកេងប្រវ័ញ្ចលើផល ប្រយោជន៍មនុស្សជាតិ៕ ដោយ ឈុន សារ៉ាត

## រដ្ឋបាលខេត្តកំពង់ធំរៀបចំអបអរសាទរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ

http://www.akp.gov.kh/ ប្រភព AKP ខេត្តកំពង់ធំ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧

ឯកឧត្តម សុខ លូ អភិបាលខេត្តកំពង់ធំ និងជាប្រធានគណៈកម្មាធិការ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងកងកម្លាំងទាំងប្រដាប់អាវុធទាំង៣ប្រភេទនិងលោកគ្រូ អ្នកគ្រូគរុសិស្ស ព្រមទាំងសមាជិកសសយកទាំងអស់ បានអញ្ជើញចូលរួមរៀបចំអបអរសាទរ ទិវាជាតិប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ក្រោមប្រធានបទ« រួមគ្នាពង្រឹងប្រព័ន្ធសុវត្ថិភាពនិងពង្រឹងការអនុវត្តច្បាប់ ដើម្បីការពារមនុស្សអំពើជួញ ដូរមនុស្ស»។ ពិធីនេះបានធ្វើឡើងកាលពីព្រឹកថ្ងៃអង្គារ ២កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧។

លោកស្រី យួន យុនឌី អភិបាលរងខេត្តកំពង់ធំ បានបញ្ជាក់នៅក្នុងរបាយ ការណ៍ឱ្យដឹងថា រាជរដ្ឋាភិបាលកម្ពុជានៅតែយកចិត្តទុកដាក់កាន់តែខ្លាំងក្លា ក្នុងការការ ពារប្រជាពលរដ្ឋ និងប្រទេសជាតិពីភាពរងគ្រោះទាំងឡាយ ដោយឧក្រិដ្ឋកម្មជួញដូរមនុស្ស ដែលបានបង្កឱ្យមានវិនាសកម្មជាថ្មីដល់មនុស្សជាតិហើយបាននិង កំពុងក្លាយ ជាទេសភាពសម័យទំនើបគួរភ័យខ្លាច និងស្អប់ខ្ពើមផងដែរ។

ឯកឧត្តម សុខ លូ បានមានប្រសាសន៍ណែនាំដល់សមាជិកអង្គប្រជុំ ជាពិសេសក្មួយៗគរុសិស្ស អំពីល្បិចកលរបស់ជនខិលខូច ដែលបានប្រើប្រាស់គ្រប់រូបភាព ដើម្បីលួងលោមបោកបញ្ឆោត ក្នុងគោលបំណងជួញដូរស្ត្រីភេទ និងកុមារ។ ឯកឧត្តមអភិបាលខេត្តបានកោត សរសើចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ ក្រុង ស្រុក មន្ទីរ-អង្គភាព និងមន្ត្រីរាជការ អង្គការ មិនមែនរដ្ឋាភិបាល ដោយខិតខំធ្វើការងារដោយមិនខ្លាចនឿយហត់។ ឯកឧត្តមអភិបាលខេត្តបានជំរុញដល់ស្ថាប័ន នៃកងកម្លាំងទាំង៣ ធ្វើការសហការគ្នាជាមួយនឹងអាជ្ញាធរដែនដី ប្រើប្រាស់កម្លាំងបង្កប់

ប្រកបដោយ ការយកចិត្តទុកដាក់ខ្ពស់ ពុះពាររួមគ្នាជម្នះការលំបាក គ្រប់ឧបសគ្គ ក្នុងការទប់ស្កាត់បានទាន់ពេលវេលា ជាពិសេសត្រូវធ្វើការតាមដានស្រាវជ្រាវ និងចាប់ខ្លួនមេខ្លោងយក មកផ្តន្ទាទោសទៅតាម ផ្លូវ ច្បាប់ ត្រូវធ្វើជាប្រចាំឱ្យដូចភ្លៀងរលឹមផងដែរ៕ ដោយ ស៊ុម វណ្ណា

## ថៃដោះលែងពលករខ្មែរ១៥នាក់និងម៉ូតូ១២គ្រឿង

http://www.postkhmer.com Tue, 19 December 2017 ឃុត សុភចរិយា

បន្ទាយមានជ័យ : មេបញ្ជាការយោធាវរការពារព្រំដែនលេខ ៥០៣ ដែលឈរជើងនៅតំបន់ព្រំដែនកម្ពុជា-ថៃ នៃស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ បានប្រាប់ភ្នំពេញប៉ុស្តិ៍នៅរសៀលនេះថា អាជ្ញាធរថៃបានយល់ព្រមដោះលែងពលករខ្មែរ ១៥ នាក់ និង ម៉ូតូ ១២គ្រឿង និង អនុញ្ញាតឲ្យចេញចូលទៅធ្វើការងារ (ព្រឹកវិលល្ងាច) ក្នុងប្រទេសថៃដូចដើមវិញ បន្ទាប់ពីពួកគេគ្មានភស្តុតាងដាក់បន្ទុកពលរដ្ឋខ្មែរពីបទ«លួចទ្រព្យសម្បត្តិ» និង ក្រោយពេលអាជ្ញាធរកម្ពុជាបានធ្វើការឃាត់ទុករថយន្តដឹកកសិផលរបស់ជនជាតិថៃ ៥ គ្រឿង មិនឲ្យត្រឡប់ចូលក្នុងប្រទេសថៃវិញ ដើម្បីជុំរុញឲ្យមានការចរចាផ្តល់ដំណោះស្រាយ ប្រកបដោយភាពយុត្តិធម៌ដល់ពលរដ្ឋកម្ពុជាវិញ។

លោក ឃួន ជឿន មេបញ្ជាការយោធា វរការពារព្រំដែន ៥០៣ បានថ្លែងថា នៅព្រឹកថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០១៧ ក្រុមប្រជាការពារថៃ ប្រចាំភូមិសាកសាន់ ឃុំ-ស្រុកគោកធ្យូង ខេត្តសាកែវ(ប្រទេសថៃ) បានធ្វើការចាប់ឃាត់ខ្លួនពលរដ្ឋខ្មែរ ១៥ នាក់ ក្នុងនោះមាន ៥ នាក់ជាស្ត្រី និងរឹបអូសម៉ូតូ ១២ គ្រឿង ដោយចោទថា ពលរដ្ឋខ្មែរទាំងនេះបានលួចយកម៉ាស៊ីនបូមទឹកមួយគ្រឿងរបស់គ្រួសារកសិករថៃម្នាក់នៅក្នុងភូមិខាងលើនេះ កាលពីយប់ថ្ងៃទី១៥ធ្នូ ឆ្នាំ ២០១៧ ប៉ុន្តែត្រូវបានពលករខ្មែរទាំងនោះបដិសេធ។ លោកបានបញ្ជាក់ថា៖«ប្រជាការពារភូមិជនជាតិថៃ ទាំងនោះបានចាប់ពលរដ្ឋយើង និងធ្វើការចោទប្រកាន់ដោយគ្មានភស្តុតាងត្រឹមត្រូវ។ ពលរដ្ឋយើងទាំង ១៥ នាក់ ជាពលករចេញចូលទៅធ្វើការក្នុងប្រទេសថៃវិលល្ងាច ហើយបើពួកគេជាមនុស្សអាក្រក់ ឬ ជាចោរមែននោះ ម្ល៉េះមិនមានពលរដ្ឋថៃជាច្រើននាក់ រួមទាំងម្ចាស់កសិដ្ឋានជនជាតិថៃ ដែលពួកគេទៅបម្រើការជាមួយនោះ ចេញមុខធានាចំពោះពួកគេនោះទេ»។

លោក ឃួន ជឿន បានថ្លែងបន្តថា នៅក្នុងការចរចាកាលពីរសៀលថ្ងៃម្សិលមិញនោះ មុនដំបូងក្រុមប្រជាការពារថៃទាំងនោះ បានសម្រេចដោះលែងតែមនុស្ស ប៉ុន្តែ ម៉ូតូរបស់ពួកគេចំនួន ១២ គ្រឿង មិនត្រូវបានអនុញ្ញាតិឲ្យនាំយកត្រឡប់មកវិញទេ ដោយពួកគេអះអាងថា ត្រូវរង់ចាំឲ្យមន្ត្រីជំនាញមកធ្វើការត្រួតពិនិត្យ។ ដោយយល់ឃើញថាក្រុមប្រជាការពារភូមិជនជាតិថៃទាំងនោះ ប្រើលេសពន្យាពេល សមត្ថកិច្ចយោធារកម្ពុជា ប្រចាំច្រករបៀងតំបន់៥ បានធ្វើការឃាត់ទុករថយន្តដឹកកសិផលរបស់ជនជាតិថៃចំនួន ៥គ្រឿង ដែលបានចូលមកទិញកសិផលពីប្រជាកសិករខ្មែរនៅតាមបណ្តាភូមិ ឃុំមួយចំនួនជាប់ព្រំប្រទល់កម្ពុជា-ថៃ ដើម្បីជាថ្នូរក្នុងការជម្រុញឲ្យអាជ្ញាធរថៃប្រចាំ ស្រុកគោកធ្យូង ខេត្តស្រះកែវ ពិសេសកម្លាំងយោធាព្រំដែនថៃ ចេញមុខជួយអន្តរាគមន៍ ដោះស្រាយផ្តល់ភាពយុត្តិធម៌មកឲ្យភាគីពលករកម្ពុជាវិញ។ លោក ជឿន បានបន្ថែមថា៖«ក្រោយរកភស្តុតាងចោទប្រកាន់ពលរដ្ឋយើងលួចម៉ាស៊ីនបូមទឹកពលរដ្ឋគេមិនបាន គេថាពលរដ្ឋយើងជិះម៉ូតូចូលទៅក្នុងប្រទេសគេខុសច្បាប់ អញ្ចឹងយើងមានតែចាប់ឃាត់រថយន្តពាណិជ្ជកររបស់ពួកគេ៥គ្រឿង ដែលចេញចូលមកទិញនិងដឹកកសិផលពីក្នុងប្រទេសយើងខុសច្បាប់វិញ...ទើបខាងអាជ្ញាធរស្រុកគោកធ្យូង រួមទាំងទាហ៊ានព្រំដែនថៃចេញមុខអន្តរាគមន៍ដោះស្រាយ និង ប្រគល់ម៉ូតូ១២គ្រឿងមកឲ្យពលករយើងវិញ ហើយយើងក៏អនុញ្ញាតិឲ្យរថយន្តដឹកកសិផលរបស់ពាណិជ្ជករថៃ បានត្រឡប់ចូលក្នុងទឹកដីថៃវិញ»។

បើតាមសម្តីរបស់លោក អំ អែម អាយុ ៤៥ ឆ្នាំ ដែលជាមេភូមិប្រាសាទ បានអះអាងថា ពលករខ្មែរ ដែលចូលធ្វើការក្នុងប្រទេសថៃព្រឹកវិលល្ងាចជារឿយៗ បានជួបប្រឈមទៅនឹងបញ្ហាជាច្រើន ដូចជាថៅកែ មិនបើកលុយឲ្យគ្រប់ចំនួន ឬ ត្រូវ ទាហ៊ានព្រំដែន ចាប់ឃាត់ខ្លួន ឬ រារាំងមិនឲ្យចូលទៅធ្វើការងារ ដោយលើកយកមូលហេតុផ្សេងៗ ជាពិ

សេក្រុមប្រជាការពារភូមិរបស់ថៃ មួយចំនួនដើរទារប្រាក់ពីពលករខ្មែរ ក្នុងម្នាក់ ៣០ បាតក្នុងមួយថ្ងៃ បើមិនឲ្យពួកគេនឹងបង្ករឿង ដូចជាចោទថាពលករខ្មែរចូលមកលួចទ្រព្យសម្បត្តិរបស់ពលរដ្ឋគេ ដូចជាករណីខាងលើនេះ ជាដើម៕

## អ្នកជំនាញថាដើម្បីបង្កើនអត្ថប្រយោជន៍ពីការធ្វើចំណាកស្រុកគេត្រូវពង្រឹងការការពារសិទ្ធិការងារ និងបណ្តុះបណ្តាលជំនាញ

https://khmer.voanews.com/ 20 ធ្នូ 2017 នូវ ពៅលក្ខិណា

របាយការណ៍អង្គការ ILO និង IMO បង្ហាញថា ថ្វីបើពលករខ្មែរចំណាកស្រុងផ្ញើលុយច្រើនមកផ្ទះក៏ពិតមែន តែពួកគេនៅតែងាយរងការរំលោភបំពាន។

ភ្នំពេញៈ បើទោះបីជាពលករចំណាកស្រុកកម្ពុជារកប្រាក់បានច្រើន ហើយមានកំណើននៃការផ្ញើប្រាក់បញ្ជូនត្រឡប់មកស្រុកកំណើតវិញក៏ដោយ ក៏ពួកគេនៅតែងាយទទួលរងការរំលោភបំពាននៅបរទេស។ នេះបើយោងតាមរបាយការណ៍ថ្មីមួយអំពី«ហានិភ័យនិងអំណោយផលៈ លទ្ធផលនៃការធ្វើចំណាកស្រុក ពលកម្មនៅអាស៊ីអាគ្នេយ៍»។ របាយការណ៍នេះត្រូវបានបង្កើតឡើងរួមគ្នាដោយអង្គការពលកម្មអន្តរជាតិ (ILO) និងអង្គការទេសន្តប្រវេសក៍អន្តរជាតិ (IMO)។ កញ្ញា នូវ ពៅលក្ខិណា នៃ VOA បានសម្ភាសន៍លោក Benjamin Harkins ជាសហស្ថាបនិកនៃរបាយការណ៍នេះ ហើយលោកក៏ជាមន្ត្រីបច្ចេកទេសអង្គការ ILO ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិកអំពីការធ្វើឱ្យប្រសើរឡើងនូវជីវភាពរបស់ពលករចំណាកស្រុកកម្ពុជា ដោយលើកកម្ពស់ការការពារសិទ្ធិការងារ និងការអភិវឌ្ឍជំនាញ ដើម្បីបង្កើនអត្ថប្រយោជន៍យូរអង្វែងពីការធ្វើចំណាកស្រុក។

**VOA៖ តើអ្វីជាលទ្ធផលសំខាន់ៗនៃរបាយការណ៍នេះ ពាក់ព័ន្ធនឹងពលករចំណាកស្រុករបស់កម្ពុជា?**

Benjamin Harkins៖ តាមរយៈសន្ទស្សន៍នេះ អ្វីដែលយើងរកឃើញគឺថា កម្ពុជាមានទំនោរទៅរកស្ថានភាពអាក្រក់ជាងប្រទេសដទៃទៀតដែលស្ថិតនៅក្នុងការសិក្សាស្ទង់មតិនេះ។ យើងក៏បានពិនិត្យមើលផងដែរទៅលើជនអន្តោប្រវេសន៍ឡាវ ជនអន្តោប្រវេសន៍មីយ៉ាន់ម៉ា និងជនអន្តោប្រវេសន៍វៀតណាម។ មានការកើនឡើងមួយចំនួនទាក់ទងនឹងប្រាក់ចំណូលដែលពលករទទួលបាននៅពេលត្រឡប់មកមាតុប្រទេសខ្លួនវិញ។ រឿងសំខាន់មួយដែលយើងបានរកឃើញគឺថា ប្រជាជនកម្ពុជាងាយទទួលរងការរំលោភបំពាននៅបរទេស។ យើងបានរកឃើញថា មានការរាយការណ៍ប្រហែល៨០ភាគរយថា ពួកគេបានរងការរំលោភបំពានសិទ្ធិការងារនៅក្នុងប្រទេសគោលដៅនៃការងារហើយប្រាកដណាស់ វាមានឥទ្ធិពលអវិជ្ជមានទៅលើផលប្រយោជន៍ក្នុងរយៈពេលវែង ដោយសារការធ្វើចំណាកស្រុកនេះ។ យើងបានពិនិត្យមើលទៅលើការអនុវត្ត និងលក្ខខណ្ឌដែលអាចផ្តល់អត្ថប្រយោជន៍ដល់ជនអន្តោប្រវេសន៍កម្ពុជា។ ហើយអ្វីដែលយើងបានរកឃើញនោះគឺថា ការការពារសិទ្ធិការងារនៅក្នុងប្រទេសគោលដៅទទួលពលករគឺមានសារៈសំខាន់បំផុតក្នុងការជួយសម្រួល ធានាដល់លទ្ធផលវិជ្ជមានសម្រាប់ពលករ។ ហើយដើម្បីសម្របសម្រួលបាននោះ យើងពិតជាត្រូវលើកកម្ពស់ការការពារសិទ្ធិរបស់ជនអន្តោប្រវេសន៍កម្ពុជា ទាំងនៅក្នុងប្រទេសគោលដៅ និងនៅក្នុងដំណាក់កាលដែលពួកគេកំពុងត្រូវបានជ្រើសរើសនៅកម្ពុជា។ ដូច្នេះយើងអាចធានាបានថា ពួកគេមានបទពិសោធន៍ទាក់ទងនឹងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពនិងភាពសុខសាន្តសមប្រកប។

**VOA៖ របាយការណ៍នេះបានអំពាវនាវឲ្យមានការផ្តោតការចាប់អារម្មណ៍ច្រើនទៅលើវិធីសាស្ត្រ អំពីជនអន្តោប្រវេសន៍នៅក្នុងគោលនយោបាយអន្តោប្រវេសន៍នៅក្នុងអាស៊ាន។ តើលោកអាចពន្យល់ពីការស្នើនេះក្នុងបរិបទកម្ពុជាបានទេ?**

Benjamin Harkins៖ អ្វីដែលយើងបានរកឃើញគឺវិធីដែលរដ្ឋាភិបាលមើលទៅលើការធ្វើចំណាកស្រុកនិងឥទ្ធិពលរបស់ការធ្វើចំណាកស្រុកទៅលើការអភិវឌ្ឍ ជារឿយៗផ្តោតលើទំហំនៃការផ្ញើប្រាក់ទៅផ្ទះវិញ។ ហើយអ្វីដែលយើងព្យាយាមធ្វើនោះគឺ ប្រាប់ថា «ក្រឡេកមើលនែ! វាពិតជាមានការផ្លាស់ប្តូរដ៏ស្មុគស្មាញច្រើននេះទៅទៀត ដែលកើតមានទៅជនចំណាកស្រុក»។ វាមិនមែនគ្រាន់តែថា ពួកគេកើនប្រាក់ចំណូលហើយបានផ្ញើទៅស្រុកវិញក្នុងរយៈ

ពេលខ្លីនោះទេ ក៏ប៉ុន្តែពួកគេក៏បានទទួលជំនាញជាច្រើននៅក្រៅប្រទេសដែលពួកគេអាចប្រើប្រាស់បាន ក្រោយពេលធ្វើមាតុភូមិនិវត្តន៍ត្រឡប់មកស្រុកវិញ ប្រសិនបើអ្វីៗដំណើរការទៅយ៉ាងរលូននោះ។ ហើយវាក៏មានការផ្លាស់ប្តូរយ៉ាងទូលំទូលាយផងដែរទៅលើជីវភាពរស់នៅរបស់ពួកគេ នៅពេលពួកគេវិលត្រឡប់មកស្រុកវិញ។ ពួកគេអាចផ្លាស់ប្តូរទៅរកការងារមានជំនាញខ្ពស់ដែលផ្តល់ប្រាក់ឈ្នួលនិងលក្ខខណ្ឌការងារប្រសើរជាងមុន។ ដូច្នេះអ្នកមិនអាចគ្រាន់តែកំណត់បទពិសោធន៍នៃការធ្វើចំណាកស្រុក ដោយគិតចង្អៀតត្រឹមតែទៅលើបរិមាណទឹកប្រាក់ដែលបានផ្ញើទៅផ្ទះនោះទេ។ អ្នកត្រូវមើលឱ្យបានច្រើនជាងមុនអំពីរបៀបដែលការធ្វើចំណាកស្រុកប៉ះពាល់ដល់ពលករនិងសមាជិកគ្រួសាររបស់ពួកគេ។

**VOA៖ របាយការណ៍នេះបានអំពាវនាវឲ្យមានកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល និយោជក និងភ្នាក់ងារជ្រើសរើសពលករ។ តើសំដៅលើរដ្ឋាភិបាលនៃប្រទេសដើមកំណើតរបស់ពលករ ឬប្រទេសគោលដៅនៃការងារ?**

Benjamin Harkins៖ ខ្ញុំគិតថា ទាំងពីរប្រទេស។ យើងពិតជាត្រូវការកិច្ចសន្ទនាសង្គម និងកិច្ចសហប្រតិបត្តិការត្រីភាគី ដើម្បីបង្កើតគោលនយោបាយនៃការធ្វើចំណាកស្រុកនៅប្រទេសបញ្ជូនពលករចេញ ប៉ុន្តែពិតណាស់វាត្រូវការកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលប្រទេសគោលដៅនៃការទទួលពលករផងដែរ។ តាមរយៈរបាយការណ៍នេះជារឿយៗ យើងឃើញពលករកម្ពុជាជំពាក់បំណុលក្នុងការចំណាយប្រាក់ច្រើនដើម្បីធ្វើចំណាកស្រុកតាមរយៈច្រកចេញស្របច្បាប់ដែលពួកគេត្រូវចំណាយពេលយូរដើម្បីចេញទៅបរទេសតាមច្រកចេញស្របច្បាប់ដែលមានភាពស្មុគស្មាញក្នុងការប្រើ ហើយជារឿយៗពួកគេត្រូវឆ្លងកាត់ទីភ្នាក់ងារជ្រើសរើសពលករដើម្បីសម្របសម្រួល។ ដូច្នេះមានភាពចាំបាច់ក្នុងការធ្វើកិច្ចសហប្រតិបត្តិការរវាងបណ្តាប្រទេសគោលដៅ និងប្រទេសបញ្ជូនពលករចេញ ដើម្បីធ្វើឱ្យដំណើរការអន្តោប្រវេសន៍ជាទូទៅមានលក្ខណៈអំណោយផលជាងមុនសម្រាប់ការធ្វើចំណាកស្រុក។ យើងបានឃើញកិច្ចសហប្រតិបត្តិការត្រីភាគីនៅប្រទេសកម្ពុជាមានភាពរឹងមាំរវាងរដ្ឋាភិបាល ទីភ្នាក់ងារជ្រើសរើសពលករ និយោជក និងសហជីព។ អង្គការពលកម្មអន្តរជាតិបានធ្វើការយ៉ាងសកម្មក្នុងការបង្កើតគោលនយោបាយជាតិស្តីពីការធ្វើចំណាកស្រុកនៃកម្លាំងពលកម្មនៅក្នុងប្រទេសកម្ពុជា ដែលយើងគិតថា វាពិតជាគំរូដ៏ល្អសម្រាប់ប្រទេសផ្សេងទៀតដែលបញ្ជូនពលករចេញ។ ពិតណាស់មានការងារជាច្រើនទៀតដែលត្រូវធ្វើដើម្បីធានាថា វិធីដែលយើងអនុវត្តតាមត្រូវបានអនុវត្តដោយមានប្រយោជន៍និងការពារពលករចំណាកស្រុក។

**VOA៖ បន្ទាប់ពីមានរដ្ឋប្រហារនៅក្នុងប្រទេសថៃកាលពីឆ្នាំ២០១៤ មានការបញ្ជូនពលករកម្ពុជាចេញពីប្រទេសថៃយ៉ាងច្រើនត្រឡប់មកកម្ពុជាវិញ។ ដោយសារប្រទេសថៃគឺជាប្រទេសដែលមានពលករកម្ពុជាច្រើន តើកម្ពុជាអាចរៀនអ្វីពីបទពិសោធន៍នេះដើម្បីកែលម្អស្ថានភាពពលករចំណាកស្រុក?**

Benjamin Harkins៖ ខ្ញុំគិតថា ការបញ្ជូនពលករចេញដែលបានកើតឡើងនៅពេលនោះ មិនមែនគ្រប់គ្នាចង់ឲ្យកើតឡើងនោះទេ។ វាបានធ្វើឲ្យមានកង្វះពលកម្មសម្រាប់និយោជកនៅក្នុងប្រទេសថៃ ហើយវាបានធ្វើឲ្យប៉ះពាល់ដល់ជីវភាពរបស់ពលករចំណាកស្រុកកម្ពុជាដែលកំពុងធ្វើការឱ្យនិយោជកទាំងនោះ។ វាក៏មិនបានបម្រើផលប្រយោជន៍ឲ្យរដ្ឋាភិបាលថៃផងដែរ។ ការណ៍នោះក៏ដោយសារពួកគេចង់ធ្វើឲ្យប្រាកដថា ជនអន្តោប្រវេសន៍ទាំងនោះត្រូវបានគេជួលឱ្យធ្វើការងារដោយស្របច្បាប់។ វាជាតម្រូវការឲ្យមានការបង្កើតគោលនយោបាយទេសន្តប្រវេសន៍ការងារនៅខាងភាគីប្រទេសថៃ ដើម្បីធានាថា ជនចំណាកស្រុកអាចមក និងទទួលឱកាសការងារសមរម្យសម្រាប់និយោជកនៅក្នុងប្រទេសថៃ ហើយនិយោជកថៃក៏ទទួលបានពលកម្មតាមតម្រូវការពីពលករកម្ពុជាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការងារទាំងនោះ។ អ្វីដែលយើងអាចរៀនបានពីការបញ្ជូនពលករចេញនាពេលនោះគឺតម្រូវការឲ្យមានគោលនយោបាយរយៈពេលវែងមួយស្តីពីការធ្វើចំណាកស្រុកទៅប្រទេសថៃ។ វិធីសាស្ត្របែបនេះ ជួនកាលបណ្តាលឱ្យមានការលំបាកហើយចាំបាច់ត្រូវពិចារណាពិនិត្យ ពិច័យឡើងវិញ។

**VOA៖ ការងារដែលពលករកម្ពុជាធ្វើនៅប្រទេសថៃ និងម៉ាឡេស៊ីគឺជាការងារជំនាញទាប ដូចជានេសាទ សំណង់ ការងារតាមផ្ទះ។ ការងារទាំងនេះមិនសូវចាំបាច់តម្រូវឲ្យមានការត្រៀមច្រើនលើជំនាញឡើយ។ តើយើងត្រូវធ្វើដូចម្តេចដើម្បីពលករមានការហ្វឹកហាត់ជំនាញត្រៀមបានច្រើន មុននឹងធ្វើចំណាកស្រុកចេញទៅបម្រើការងារនៅក្រៅប្រទេស?**

Benjamin Harkins: អ្វីដែលរបាយការណ៍នេះអំពាវនាវគឺការពង្រីកការបង្វឹកជំនាញសម្រាប់ពលករចំណាកស្រុក ដើម្បីបំពេញតម្រូវការរបស់និយោជក។ ប៉ុន្តែការបង្វឹកនោះក៏មិនត្រូវបន្ថែមបន្ទុក ដូចជាពេលវេលានិងធនធានទៅលើពលករទាំងនោះទេ។ ពលករចំណាកស្រុកមកពីប្រទេសកម្ពុជា ភាគច្រើន ត្រូវបានជ្រើសរើសដោយផ្អែកលើតម្រូវការសម្រាប់ប្រាក់ខែទាប ជាជាងតម្រូវការផ្អែកជំនាញ។ យើងគិតថា ការផ្គូរផ្គងការងារកាន់តែជិតគ្នារវាងជំនាញរបស់ពលករចំណាកស្រុកនិងឱកាសការងារ នឹងផ្តល់ប្រយោជន៍ឲ្យទាំងនិយោជក និងពលករចំណាកស្រុក ដោយសារវាបានរួមចំណែកដល់ផលិតកម្ម ហើយក៏ធ្វើឲ្យប្រាក់បៀវត្ស និងលក្ខខណ្ឌការងារកាន់តែប្រសើរ។ តាមរយៈរបាយការណ៍នេះ គំរូការងារមួយដែលយើងគិតថា មានប្រសិទ្ធភាព និងមិនបន្ថែមការចំណាយនិងពេលវេលារបស់ពលករគឺកម្មវិធីហ្វឹកហ្វឺនលើការងារ និងការហាត់ការដោយមានប្រាក់កម្រៃ។ យើងស្នើឲ្យការកសាងភាពជាដៃគូរវាងនិយោជក និងស្ថាប័នគំរូហ្វឹកហ្វឺនវិជ្ជាជីវៈបច្ចេកទេស ដើម្បីធ្វើការផ្សព្វផ្សាយប្រព័ន្ធបណ្តុះបណ្តាលមួយដែលរួមបញ្ចូលទាំងពលករស្ត្រីនិងបុរសច្រើនជាងមុន ហើយថែមទាំងឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនៃប្រទេសគោលដៅប្រកពការងារ។

**VOA៖ តើលោកអាចនិយាយពីទស្សនៈទូទៅរបស់លោកអំពីលំហូរនៃពលករកម្ពុជាចំណាកស្រុកនៅក្នុងប្រទេសសមាជិកអាស៊ានបានទេ ថាតើផលប៉ះពាល់នោះមានអ្វីខ្លះ? តើវាអាចជាការគំរាមកំហែងដល់ប្រទេសកម្ពុជាដែរ ឬទេ ដែលជាប្រទេសដើមដែលបញ្ជូនពលករយ៉ាងច្រើនចេញទៅក្រៅប្រទេស?**

Benjamin Harkins: អ្វីដែលយើងឃើញជាបឋមអំពីកម្ពុជានោះគឺថា ពលករចំណាកស្រុកទៅក្រៅប្រទេសគឺទៅធ្វើការលើជំនាញទាប។ ហើយអ្វីដែលយើងកំពុងព្យាយាមពន្យល់តាមរយៈរបាយការណ៍នេះគឺថា តាមពិតទៅកម្ពុជាអាចទទួលផលប្រយោជន៍យ៉ាងពិតប្រាកដពីការបញ្ជូនពលករចំណាកស្រុកទៅក្រៅប្រទេសគឺដរាបណាធ្វើឲ្យពួកគេទទួលបានជំនាញថ្មីៗ ដែលពួកគេអាចនាំមកកាន់កម្ពុជាវិញនូវទីផ្សារពលកម្មមួយដែលប្រកបដោយពលករដែលមានជំនាញស្រាប់ ឬថា ពួកគេអាចកើននូវធនធានហិរញ្ញវត្ថុសមរម្យដែលអាចឲ្យគេបង្កើតអាជីវកម្ម និងទ្រទ្រង់ជីវភាពក្រុមគ្រួសាររបស់ពួកគេ ទៅលើការបង់ថ្លៃវេជ្ជសាស្ត្រ ការអប់រំ និងចំណាយនានាសម្រាប់ក្រុមគ្រួសាររបស់ពួកគេ។ នៅក្នុងរបាយការណ៍នេះយើងក៏ចង់បង្ហាញដែរថា យើងត្រូវព្យាយាមចៀសវាងការចំណាកស្រុកដែលធ្វើឲ្យពលករនៅជាប់ជំពាក់បំណុលគេ។ យើងចាំបាច់ត្រូវប្រាកដថា ពួកគេទទួលបានការការពារដោយសិទ្ធិការងារនៅតាមប្រទេសគោលដៅ ហើយប្រាកដថា គេមានឱកាសបង្កើនកម្រិតជំនាញរបស់ពួកគេបន្ថែម ហើយចុងក្រោយបំផុតគឺនៅពេលពួកគេវិលត្រឡប់មកកម្ពុជាវិញ ត្រូវប្រាកដថា ពួកគេមានឱកាសទូលំទូលាយក្នុងការប្រកបការងារនៅក្នុងស្រុក ហើយបើបានដូច្នោះពួកគេមិនត្រូវបានបង្ខំឱ្យធ្វើចំណាកស្រុកម្តងហើយម្តងទៀតដើម្បីត្រឹមតែរកការងារប៉ុណ្ណោះទេ។

**VOA៖ ជាកិច្ចបញ្ចប់នៃការសម្ភាសន៍នេះ តើលោកមានអ្វីចង់បន្ថែម ឬជាសារអ្វីទៀតដែលទាក់ទិននឹងការស្រាវជ្រាវរបស់លោកដែរឬទេ?**

Benjamin Harkins៖ ខ្ញុំគិតថា នៅមានមួយផ្នែកទៀតដែលគួរតែចង្អុលបង្ហាញតាមរបាយការណ៍នេះ។ រឿងមួយសំខាន់ជាងគេគឺថា នៅពេលពលករអន្តោប្រវេសន៍ទទួលរងនូវការរំលោភបំពានដែលផ្ទុយពីសិទ្ធិការងារ វាចាំបាច់ត្រូវមានទណ្ឌកម្មកាន់តែតឹងរ៉ឹងបន្ថែមទៀតទៅកាន់ភ្នាក់ងារជ្រើសរើសពលករណាដែលកំពុងរួមចំណែកប្រព្រឹត្តការរំលោភបំពានទាំងនោះ។ អ្វីដែលយើងបានឃើញគឺថា វាគ្រាន់បើបន្តិចក្នុងការបង្កើតយន្តការដើម្បីដោះស្រាយការរំលោភបំពានទាំងនោះ ការពារជនអន្តោប្រវេសន៍កម្ពុជា ប៉ុន្តែមិនមានការដាក់ទណ្ឌកម្មណាមួយនៅឡើយចំពោះអ្នកដែលពាក់ព័ន្ធ ដើម្បីរារាំងកុំឲ្យពួកគេប្រព្រឹត្តអំពើរំលោភបំពានបាន។ ចំណែករឿងមួយទៀតគឺថា យើងពិតជាចង់

ឃើញការកាត់បន្ថយចំណាយដែលជនចំណាកស្រុកកម្ពុជាចាយសម្រាប់ការធ្វើចំណាកស្រុក។ យើងមានបទដ្ឋានអន្តរជាតិមួយអំពីចំណាកស្រុកនេះគឺថា កម្មករមិនគួររងការទទួលខុសត្រូវលើដំណើរការជ្រើសរើសបុគ្គលិកទេ វាត្រូវតែជានិយោជកដែលត្រូវបង់លើការចំណាយជ្រើសរើសពលករ។ ហើយឥឡូវនេះ វាមិនអញ្ចឹងទេ ពោលគឺយើងបានរកឃើញថា ពលករចំណាកស្រុកកម្ពុជាជាច្រើនត្រូវខ្ចីបុលគេសន្ទឹកដើម្បីចំណាយសម្រាប់ការធ្វើចំណាកស្រុក។ដូច្នេះប្រាកដណាស់ ក្នុងពេលខាងមុខ យើងចង់ឃើញការផ្លាស់ប្តូរនៃបន្ទុកចំណាយលើការធ្វើចំណាកស្រុក គឺឲ្យនិយោជកដែលកំពុងទទួលបានអត្ថប្រយោជន៍ពីសេវាកម្មពលករចំណាកស្រុកទាំងនោះជាអ្នកទទួលបន្ទុកចំណាយវិញ៕

## ស្ត្រី ៣ នាក់សារភាពនៅឧទ្ធរណ៍ ខណៈម្នាក់បដិសេធរឿងនាំមនុស្សយកប្តីចិន

http://www.postkhmer.com/ Wed, 20 December 2017 គីម សារុំ

**ភ្នំពេញៈ** នៅក្នុងអង្គសវនាការសាលាឧទ្ធរណ៍កាលពីម្សិលមិញស្ត្រីជាប់ចោទ ៣នាក់បានទទួលកំហុស ខណៈស្ត្រីម្នាក់ទៀតប្រានចោលបទចោទពាក់ព័ន្ធនឹងការនាំនារីខ្មែរ ២ នាក់ទៅរៀបការប្តីនៅចិនកាលពីឆ្នាំ ២០១៥ ជាសំណុំរឿងដែលត្រូវតុលាការថ្នាក់ក្រោមផ្តន្ទាទោសម្នាក់ៗ ៧ ឆ្នាំ។ នៅក្នុងបន្ទប់សវនាការស្ត្រីជាប់ចោទ ឈ្មោះ ប៊ូយ សាម៉ុន,អ៊ុល យ៉ុង និងឈ្មោះ ហុង រី បានសារភាពទទួលកំហុស ខណៈស្ត្រីឈ្មោះ កើត ហួន បានបដិសេធថាខ្លួនមិនពាក់ព័ន្ធនឹងអំពើនេះទេ ហើយសុំតុលាការដោះលែង។ ស្ត្រីជាប់ចោទ ប៊ូយ សាម៉ុន,អ៊ុល យ៉ុង និង ហុង រី ប្រាប់ចៅក្រមថាៈ «ពួកខ្ញុំទទួលខុសហើយ ប៉ុន្តែសូមតុលាការជួយបន្ធូរបន្ថយទោសដល់ពួកខ្ញុំផង»។

តាមកំណត់ហេតុនគរបាលបង្ហាញថា កាលពីអំឡុងខែកុម្ភៈ ឆ្នាំ ២០១៥ ស្ត្រីឈ្មោះ ប៊ូយ សាម៉ុន អាយុ ៤៦ ឆ្នាំបានប្រាប់គូកនខ្លួនថាគាត់មានប្អូន និងកូនស្រីមានប្តីនៅចិន ហើយពួកគេមានជីវភាពធូរធារណាស់។ ក្នុងការឃោសនានោះ ស្ត្រី ប៊ូយ សាម៉ុន បានណែនាំឲ្យស្ត្រីឈ្មោះ ហុង រី អាយុ ៥០ ឆ្នាំ,ឈ្មោះ អ៊ុល យ៉ុង អាយុ ៤៩ ឆ្នាំ និងឈ្មោះ កើត ហួន អាយុ ៥៥ ឆ្នាំដើររកនារីខ្មែរដើម្បីទៅរៀបការប្តីនៅចិនដែរ ហើយបន្ទាប់មកពួកគេរើសបាននារីខ្មែរ ២ នាក់ពីខេត្តក្រចេះមានអាយុ ១៩ ឆ្នាំដូចគ្នា។ កំណត់ហេតុដដែលបន្តថាក្រុមស្ត្រីជាប់ចោទបានរត់ការ និងបានបញ្ជូននារីរងគ្រោះទៅចិនតែត្រូវបុរសចិនធ្វើទារុណកម្មក៏ប្រាប់មកក្រុមគ្រួសារប្តឹងទើបសមត្ថកិច្ចចាប់ពួកមេខ្យល់ទាំងនេះតែម្តង ។ ឯស្ត្រីឈ្មោះ ប៊ូយ សារុធ និង យ៉ាន សាមាន រត់គេចខ្លួន ។ សំណុំរឿងនេះត្រូវសាលាដំបូងរាជធានីភ្នំពេញផ្តន្ទាទោសឲ្យស្ត្រីទាំង ៤ នាក់ជាប់ពន្ធនាគារម្នាក់ៗ ៧ ឆ្នាំកាលពីថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១៥ ។

លោកព្រះរាជអាជ្ញា ជា ម៉េត តំណាងមហាអយ្យការសន្និដ្ឋានថាៈ «ក្រោយពីបានពិនិត្យអង្គហេតុមកខ្ញុំយល់ឃើញថារឿងនេះមានភ័ស្តុតាងគ្រប់គ្រាន់ក្នុងការចោទប្រកាន់ជនជាប់ចោទ។ ដូច្នេះខ្ញុំសូមតម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញនៅដដែល»។

លោកស្រី ផល គុណកញ្ញា មេធាវីការពារសិទ្ធិស្ត្រីជាប់ចោទទាំង ៤ នាក់សន្និដ្ឋានថារឿងនេះកូនក្តីលោកស្រី ៣ នាក់បានសារភាពចាប់តាំងពីនៅនគរបាលរហូតដល់សវនាការនៅសាលាដំបូងរាជធានីភ្នំពេញទៀត។ លោកស្រីថា ៖ «សូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាបន្ថយទោសដល់កូនក្តីខ្ញុំ ៣ នាក់ផង ឯឈ្មោះ កើត ហួន សូមតុលាការធ្វើការចាត់របៀបស៊ើបអង្កេតឡើងវិញដើម្បីឲ្យគាត់ចាញ់ដោយអស់ចិត្ត។ ក្រោយជំនុំជម្រះលោកចៅក្រម ស៊ិនវិសាល ប្រធានក្រុមប្រឹក្សាជំនុំជម្រះថ្លែងថា សាលដីការឿងនេះប្រកាសនៅថ្ងៃទី ២៨ ខែធ្នូខាងមុខ៕

## លិខិតធ្វើដំណើរចុះទៅផ្ទះ ចំពោះអ្នកមានប័ត្រ និងលុងបៀនថ្មី

http://www.pheaktraprak.com ប្រភពដំណឹងពលករខ្មែរ December 19, 2017

នេះជាលិខិតអនុញ្ញាតសម្រាប់ធ្វើដំណើរចេញពីតំបន់ដែលយើងរស់នៅ ចំពោះបងប្អូនពលករខ្មែរដែលមានប័ត្រស៊ីជម្ពូនិងលុងបៀនថ្មី តែមិនទាន់បានត្រួតសញ្ជាតិ។ លិខិតនេះជួយអោយបងប្អូនពលករខ្មែរដែលមិនទាន់មានប៉ាស្ព័រ អាចធ្វើដំណើរវិលត្រឡប់ទៅប្រទេសកម្ពុជាយើងបានក្នុងរយៈពេល 7ថ្ងៃ-10ថ្ងៃ តាមតែសពុលភាពដែលបាន

កំណត់នៅក្នុងលិខិត។ ចំពោះលិខិតធ្វើដំណើរនេះបងប្អូនអាចអោយថៅកែទៅធ្វើការស្នើសុំនៅអំភើ(អំភេខ)ក្នុងតំបន់ដែលយើងធ្វើការរស់នៅ។ ហើយចំពោះអ្នកស្នាក់នៅទីក្រុងបាងកក អាចទៅសុំលិខិតនេះបាននៅសាំណាក់ងានខេត្ត(សំណាក់ងានខេត)ឬក្រសួងការងារថៃផ្ទាល់តែម្តងក៏បាន។

បញ្ជាក់: លិខិតនេះអាចធ្វើដំណើរចុះឡើងទៅប្រទេសកម្ពុជាយើងបានត្រឹមតែរយៈពេលខ្លីប៉ុណ្ណោះដូច្នេះបងប្អូនត្រូវពិនិត្យនៅក្នុងថ្ងៃ.ខែ កំណត់អោយបានច្បាស់លាស់ប្រយ័ត្នមានបញ្ហានៅពេលធ្វើដំណើរឡើងមកធ្វើការនៅក្នុងប្រទេសថៃវិញ។

## ថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៧

## អាជ្ញាធរខេត្តកំពតប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៧

http://www.akp.gov.kh/ AKP ខេត្តកំពត ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧

កាលពីរសៀលថ្ងៃអង្គារ ២កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹង ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧ អាជ្ញាធរខេត្តកំពត បានប្រារព្ធពិធី អបអរសាទរទិវាជាតិប្រយុទ្ធ ប្រឆាំងអំពើ ជួញដូរមនុស្ស១២ ធ្នូ ២០១៧ នៅក្នុងសាលប្រជុំសាលាខេត្តកំពតដោយមានការ អញ្ជើញចូលរួមពី ឯកឧត្តម ចាន់ ចេស្តា អភិបាល នៃគណៈអភិបាលខេត្តកំពត ថ្នាក់ដឹកនាំខេត្ត និងមន្ទីរអង្គភាពជុំវិញខេត្ត កងកម្លាំងប្រដាប់អាវុធទាំងបីប្រភេទ ព្រមទាំងសិស្សនិស្សិត យុវជនកាយឫទ្ធិ-យុវ ជនកាកបាទក្រហមនិងសហភាព សហព័ន្ធយុវជនកម្ពុជាប្រមាណជិត៣០០នាក់។

លោកស្រី យូ សុគន្ធ អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន ប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្សខេត្តកំពតបានលើកឡើងពីស្ថានភាពបទល្មើសការជួញដូរមនុស្ស និងការធ្វើអាជីវកម្ម ផ្លូវភេទនៅទូទាំងខេត្តកំពត ដោយពុំមាន សកម្មភាពអ្វីកើតឡើង គួរឱ្យកត់សំគាល់នោះឡើយ ដោយបញ្ហាទាំងនេះក៏មានការ គ្រប់គ្រង ទប់ស្កាត់និងបង្រ្កាបទទួលបានលទ្ធផលគួរជាទី មោទនៈផងដែរ។

ឯកឧត្តម ចាន់ ចេស្តា បានបញ្ជាក់ថា ការរៀបចំទិវាប្រយុទ្ធ ប្រឆាំងអំពើជួញ ដូរមនុស្ស គឺជាយុទ្ធនាការ ដ៏ធំមួយដែលរាជរដ្ឋាភិបាលមាន ឱកាសផ្សព្វផ្សាយការ យល់ដឹងឱ្យកាន់តែទូលំ ទូលាយ និងក៏ជាការបង្ហាញយ៉ាងច្បាស់រួមគ្នាទាំងស្ថាប័នរដ្ឋ និងឯកជនក៏ដូចជាសហគមន៍ អំពីការយកចិត្តទុកដាក់ខ្ពស់នូវការប្តេជ្ញាចិត្ត និងកិច្ចខិតខំប្រឹងប្រែងទាំងឡាយក្នុងការ គោរព សិទ្ធិមនុស្ស ការការពារសុវត្ថិភាព និងសន្តិសុខប្រជាពលរដ្ឋពីការរំលោភបំពានគ្រប់រូបភាព។ ឯកឧត្តមបានបន្តថា បទល្មើសជួញដូរមនុស្សគឺជាឧក្រិដ្ឋកម្មឆ្លងដែន និងគ្រោះថ្នាក់បំផុតដល់មនុស្សជាតិ ជាពិសេសក្នុងចំណោមពលករទេសន្តប្រវេសន៍ ដែលបានចាកចេញ ទៅធ្វើការងារនៅក្រៅប្រទេស និងជនភៀសខ្លួនទាំងក្មេងចាស់ ប្រុសស្រីដោយមិនរើសមុខ។ ឯកឧត្តមអភិបាលខេត្តក៏បានអំពាវនាវដល់ក្មួយៗដែលជាយុវជន មន្ត្រីគ្រប់លំដាប់ថ្នាក់ និងដៃគូពាក់ព័ន្ធទាំងអស់ បន្តរួមគ្នាអនុវត្តន៍សកម្មភាពព្រមៗគ្នា ពង្រឹងប្រព័ន្ធ សុវត្ថិភាព ពង្រឹងការអនុវត្តច្បាប់ ដើម្បីការពារមនុស្សគ្រប់រូបភាពពី អំពើជួញដូរមនុស្ស។ ដោយ ប្រាក់ លាង

## ខេត្តឧត្តរមានជ័យផ្សព្វផ្សាយស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការទប់ស្កាត់អំពើជួញដូរមនុស្ស

http://www.akp.gov.kh/ AKP ខេត្តឧត្តរមានជ័យ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧

-នៅសាលាក្រុងសំរោង ខេត្តឧត្តរមានជ័យមានរៀបចំពិធីផ្សព្វផ្សាយ ស្តីពីយន្តការនៃការធ្វើចំណាក់ស្រុកប្រកបដោយសុវត្ថិភាព និង ការទប់ស្កាត់អំពើជួញដូរមនុស្ស ក្រោមអធិបតីភាពឯកឧត្តម ប៊ូ សាខន អភិបាលរងខេត្ត និង ឯកឧត្តម ខាំ វិសាល សមាជិកក្រុមប្រឹក្សាខេត្ត កាលពីថ្ងៃពុធ ៣កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមមេបញ្ជាការ មេបញ្ជាការរងនៃកងកម្លាំង

ប្រជាប់អាវុធអភិបាល អភិបាលរង ក្រុងសំរោង ប្រធាន អនុប្រធានមន្ទីរជុំវិញខេត្ត ចៅសង្កាត់ទាំងអស់ក្នុងក្រុងសំរោង សិស្សានុសិស្ស និងប្រជាពលរដ្ឋ ប្រមាណ ២៣០នាក់ ។

លោក ម៉ូត សុខមេសា អនុប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើបាយការណ៍ស្តីពីយន្តការនៃការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការទប់ស្កាត់អំពើជួញដូរមនុស្ស ។ ដោយអនុលោមតាមកម្មវិធីនយោបាយដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៥ នៃរដ្ឋសភាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បីកំណើនការងារសមធម៌ និងប្រសិទ្ធភាពការងារនៅកម្ពុជា ដែលក្នុងនោះកំណើនការងារថ្មីៗនេះកាន់តែមានច្រើនឡើងៗតម្រូវការកម្លាំងពលកម្មក៏ច្រើនដែរ នេះត្រូវបានចាត់ទុកថាជាយុទ្ធសាស្ត្រ នៃអាទិភាពមួយក្នុងចំណោមគោលដៅយុទ្ធសាស្ត្រទាំង៤ ។ លោកបានបន្តថា ជាមួយការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បីកំណើនការងារ សមធម៌ និង ប្រសិទ្ធភាព កំពុងបាននាំមកនូវវឌ្ឍនភាពជូនជាតិ និងប្រជាជន និងអនុវត្តន៍តាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨ ក៏ដូចជាផែនការយុទ្ធសាស្ត្រ ៣ឆ្នាំរំកិលរបស់រដ្ឋបាលខេត្តឧត្តរមានជ័យ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តឧត្តរមានជ័យ បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រចំនួន៣ សម្រាប់ឆ្នាំ ២០១៤-២០១៨ រួមមាន៖

ទី១- ការអភិវឌ្ឍលក្ខខណ្ឌការងារនិងសុខដុមនីយកម្មក្នុងទំនាក់ទំនងវិជ្ជាជីវៈ។ ទី២- ការអភិវឌ្ឍ ការអប់របណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ។ ទី៣- ការពង្រឹងអភិបាលកិច្ចល្អ ដើម្បីទទួលបានសមិទ្ធផលថ្មីៗជាច្រើនទៀត ។

ឯកឧត្តម ប៊ូ សាខន អភិបាលរងខេត្តមានប្រសាសន៍ថា ដើម្បីចូលរួមកាត់បន្ថយនូវការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងអំពើជួញដូរមនុស្សគ្រប់រូបភាព យើងត្រូវចូលរួមទប់ស្កាត់ទាំងអស់គ្នាដោយធ្វើការពន្យល់ដល់បងប្អូនប្រជាពលរដ្ឋរបស់យើងឱ្យដឹងអំពីការគ្រោះថ្នាក់ទាំងអស់នេះ ហើយចំណុចពិសេសមួយទៀត គឺត្រូវបង្កើនការងារឱ្យបានច្រើន និងតម្លៃសមរម្យសម្រាប់ពួកគាត់ និងការជួយអន្តរាគមន៍ ការរៀបចំឯកសារនានាដែលចាំបាច់ និងការជួយពន្យល់ដល់ពួកគាត់អំពីការចាញ់បោកមេខ្យល់ ដែលតែងតែអះអាងពីការនាំទៅធ្វើការនៅប្រទេសនោះ នៅប្រទេសនេះ ដែលកន្លងមកបងប្អូនយើងឧស្សាហ៍ចាញ់បោកគេជារឿយៗ ។ ចំណុចមួយទៀត គឺអាជ្ញាធរភូមិ ឃុំត្រូវយកចិត្តទុកដាក់ខ្ពស់ចំពោះពួកគាត់ពីព្រោះអស់លោកនៅជាប់ជាប្រចាំជាមួយពួកគាត់តែម្តង ។សូមបញ្ជាក់ផងដែរថា នៅក្នុងពិធីនេះក៏មានការបង្ហាញជូនពីសៀវភៅណែនាំ សម្រាប់ប្រជាជនកម្ពុជាដែលមានបំណងស្វែងរកការងារធ្វើនៅបរទេសផងដែរ ៕ដោយ ទិត ស្រ៊

## រដ្ឋបាលខេត្តព្រះសីហនុ រៀបចំពិធីអបអរសាទរខួបលើកទី១១ នៃទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

http://ann.com.kh/site/news/ ថ្ងៃព្រហស្បតិ៍, 21 ខែធ្នូ 2017 11:27 ព្រឹក

**ខេត្តព្រះសីហនុ៖** នាព្រឹក ថ្ងៃទី២១ ធ្នូ នេះ នៅឯសាលាខេត្តព្រះសីហនុ បានរៀបចំពិធីអបអរសាទរខួបលើកទី១១ នៃទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព ឯកឧត្តម ជាម ហ៊ីម ប្រធានក្រុមប្រឹក្សាខេត្តព្រះសីហនុ ឯកឧត្តម យន្ត មីន អភិបាលខេត្តព្រះសីហនុ និងដោយមានការអញ្ជើញចូលរួមពីសំណាក់មន្ត្រីរាជការមន្ទីរ នៅជុំវិញខេត្តជាច្រើនរូបទៀតផងដែរ៕

## ក្រសួងការងារត្រៀមស្នើច្បាប់មាត្រា44 បន្ថែមរយៈពេលធ្វើប៉ាស្ព័រជូនពលករ6ខែ តទៅមុខទៀត

កាលពីព្រឹកថ្ងៃពុធ ទី20 ខែធ្នូ ឆ្នាំ2017នេះ ឯកឧត្តម សែង សិងកែវ រដ្ឋមន្រ្តីក្រសួងការងារថៃ បានមានប្រសាសន៍ឆ្លើយតបទៅនឹងសំណួររបស់អ្នកកាសែត នៅក្នុងការិយាល័យត្រួតសញ្ជាតិជូនពលករភូមានៅក្នុងហាងទំនើប (អ៊ីមកូលៀមសំរោង)ខេត្តសាមុតប្រាកាន ប្រទេសថៃ ។ ក្នុងករណីជូនពលករខ្មែរ,ភូមា,ឡាវក្នុងរយៈពេល 3ខែខាងមុខនេះមិនទាន់ពេលកំណត់ ក្រសួងការងារនិងធ្វើរបាយការណ៍ស្នើទៅលោកនាយករដ្ឋមន្ត្រី ប្រយុទ្ធចាន់អូចា (ក.ស.ធ) យកច្បាប់មាត្រា.44 មកពិចារណា ដើម្បីបន្តការស្នាក់នៅជូនពលករបរទេសទាំងបីសញ្ជាតិ រយៈពេល6ខែបន្ថែមទៀត ដើម្បីអោយពលករទាំងអស់នោះអាចត្រួតសញ្ជាតិធ្វើប៉ាស្ព័របានរហូតដល់ចប់សព្វគ្រប់ទាំងអស់គ្នា។ កិច្ចសម្ភាសន៍នេះបានធ្វើឡើងកាលពីថ្ងៃពុធទី20 ខែធ្នូ ឆ្នាំ2017 នៅក្នុងការទស្សនកិច្ចចុះត្រួតពិនិត្យកន្លែងបញ្ជាក់អត្តសញ្ញាណជូនពលករភូមានៅក្នុងហាងទំនើបអ៊ីមកូលៀមសំរោង ខេត្តសាមុតប្រាកាន ។ ប្រទេសថៃ

## ថ្ងៃច័ន្ទ ៨កើត ខែបុស្ស នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០១៧

## ព្រះរាជអាជ្ញា បញ្ជាឲ្យសមត្ថកិច្ចចុះបង្រ្កាបទីតាំងជួញដូរផ្លូវភេទនៅខណ្ឌចំការមន ចាប់ខ្លួនថៅកែហាង និងមេកា, រំដោះជនរងគ្រោះ៥នាក់

http://www.freshnewsasia.com/ 2017-12-23

**(ភ្នំពេញ)៖** កម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដឹកនាំដោយលោកឧត្តមសេនីយ៍ត្រី ចាន់ កិត្តិខុម ស្នងការរងទទួលដឹកនាំការងារការិយាល័យជំនាញ សហការជាមួយអាជ្ញាធរមូលដ្ឋានក្រោមការសម្របសម្រួលពីលោក គុជ គីមឡុង ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ បានចុះអនុវត្តចំណារអនុញ្ញាតឲ្យបង្រ្កាបដាក់ស្លែងលេខ ១០៣អ.យ.ភ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើការឆែកឆេរលំនៅដ្ឋានលេខ279B យីហោម៉ាស្សាពេញចិត្ត ផ្លូវលេខ២៧១ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលរកស៊ីសេវាផ្លូវភេទ ដោយចាប់ខ្លួមថៅកែហាង និងមេកា ព្រមទាំងរំដោះបានជនរងគ្រោះ៥នាក់ផងដែរ។

មន្ត្រីនគរបាលជំនាញបានប្រាប់អង្គភាព Fresh News នៅរសៀលថ្ងៃទី២៣ ខែធ្នូ នេះថា ជនសង្ស័យចំនួន ០២នាក់ ១.ឈ្មោះ គឹម វណ្ណា ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ (ថៅកែហាង) ២.ឈ្មោះ ហុង ម៉េងហួរ ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ (មេកា) និងរំដោះជនរងគ្រោះចំនួន ០៥នាក់ (ស្រី ០២នាក់, ភេទទីបី ០៣នាក់ ប្រុស) មកកាន់ការិយាល័យ ដើម្បីធ្វើការសាកសួរ និង ស្រាវជ្រាវតាមនីតិវិធី ។ បើតាមមន្រ្តីនគរបាល ក្រោយការបង្រ្កាបកម្លាំងបានដកហូត វត្ថុតាងដកហូតមាន ស្រោមអនាម័យប្រើប្រាស់រួច និងមិនទាន់ប្រើប្រាស់មួយចំនួន, សៀវភៅកត់ត្រាភ្ញៀវចេញចូលចំនួន ០២ក្បាល៕

## រដ្ឋបាលខេត្តព្រះសីហនុ ប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ២០១៧

http://www.akp.gov.kh/ AKP ខេត្តព្រះសីហនុ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧

កាលថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ រដ្ឋបាលខេត្ត ព្រះសីហនុប្រារព្ធទិវាជាតិប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ២០១៧ ខួបលើកទី១១ ក្រោមប្រធានបទ រួមគ្នាពង្រឹង ប្រព័ន្ធសុវត្ថិភាព និងពង្រឹងការអនុវត្តច្បាប់ ដើម្បីការពារមនុស្ស ពីការជួញដូរ ក្រោមអធិបតី ភាពឯកឧត្តម ជាម ហ៊ីម ប្រធានក្រុមប្រឹក្សាខេត្ត ឯកឧត្តម យន្ត មីន អភិបាលនៃគណៈ អភិបាលខេត្តព្រះសីហនុ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្ស (គ.ខ.ប.ជ) ។

លោកស្រី ហៀក ហ៊ីមុល្លី អភិបាលរងខេត្តព្រះសីហនុ និងជាប្រធានលេខាធិការដ្ឋានប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស គ.ខ.ប.ជបានថ្លែងឱ្យដឹងថា ការប្រារព្ធទិវាជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ២០១៧ ក្រោមប្រធានបទ រួមគ្នាពង្រឹង ប្រព័ន្ធសុវត្ថិភាព និងពង្រឹងការអនុវត្តច្បាប់ ដើម្បីការពារ មនុស្សគ្រប់រូប ពីអំពើជួញដូរ

មនុស្ស ក្នុងគោលបំណងយកចិត្តទុកដាក់ក្នុងការការពារប្រជាពលរដ្ឋ ពីភាពរងគ្រោះ ដោយឧក្រិដ្ឋកម្មជួញដូរមនុស្ស បង្កឱ្យមានវិនាសសកម្មជាថ្មីដល់មនុស្សជាតិ គួរឱ្យខ្លាច និងគួរឱ្យស្អប់ខ្ពើម។ លោកស្រីក៏បានរម្លឹកថា ការធ្វើទេសន្ត ប្រវេសន៍ត្រូវហាមឃាត់ ហើយក៏មិនមែន សុទ្ធតែជាហានិភ័យ ដែលគួរឱ្យចៀសវាងដែរ។ ប៉ុន្តែពលករមួយចំនួនធំបាន ទទួលកម្រៃល្អ និងអាចលើកកម្ពស់ជីវភាពបានប្រសើរជាងមុនរួមទាំងទទួល បាន ជំនាញបច្ចេក ទេសកាន់តែប្រសើរ គួរឱ្យមោទនភាព ប៉ុន្តែអ្វីដែលជាការព្រួយបារម្ភណ៍នោះ គឺការធ្វើទេសន្តប្រវេសន៍ដោយប្រថុយ ប្រថានមិនមានការ ជានាផ្នែកច្បាប់ និងមិនមានការគ្រប់គ្រង ច្បាស់លាស់ ដែលនាំឱ្យប្រឈមនឹងហានិភ័យដោយអំពើកេងប្រវ័ញ្ច ទាញ យកផលប្រយោជន៍ លើកម្លាំងពលកម្មផ្លូវភេទ នឹងរហូតដល់អាយុជីវិតរបស់មនុស្សគ្រប់ប្រភេទ គ្រប់វ័យ បង្កនូវទុក្ខ វេទនា បណ្តាលឱ្យខូចសុខភាព រាងកាយ ផ្លូវចិត្ត ស្មារតី និងសេដ្ឋកិច្ចយ៉ាង ធ្ងន់ធ្ងរ ហើយនេះជាសោក នាដកម្មថ្មីមួយ ទៀត ចំពោះមនុស្សជាតិដែលបង្ក ដោយមនុស្សដូចគ្នា។

ឯកឧត្តម យន្ត មីន អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ក៏បានថ្លែងនូវការកោតសរសើរថ្នាក់ ដឹកនាំ ក្រុង ស្រុក មន្ទីរ-អង្គភាព មន្ត្រីរាជការ អង្គការមិនមែនរដ្ឋាភិបាល និងអន្តរជាតិ ដែលបានរួម គ្នាដោះស្រាយប្រឆាំង នឹងសកម្មភាពរបស់ឧក្រិដ្ឋជន ស្របតាមទិសដៅនឹងគោលនយោបាយរបស់ រាជរដ្ឋាភិបាល ដើម្បីរួមគ្នាប្រឆាំងទៅនឹង អំពើជួញដូរ មនុស្សទទួលបានជោគជ័យ គឺទាមទារមានការ ចូលរួមពីគ្រប់ផ្នែកពាក់ព័ន្ធរួមសហការគ្នា ក្នុងឆន្ទៈនិងការ ប្តេជ្ញាខ្ពស់ ដើម្បីអនុវត្តន៍ភារកិច្ចប្រកបដោយ ការទទួលខុសត្រូវខ្ពស់ ឆ្ពោះទៅកាន់គោល ដៅរួមគ្នាតែមួយ ធ្វើអ្វីដើម្បី សេចក្តីសុខ និងភាពរីកចម្រើន របស់មនុស្សជាតិ។ ឯកឧត្តមក៏បានសំណូមពរឱ្យសមត្ថកិច្ច និងភាគីពាក់ព័ន្ធនៅក្នុង ខេត្ត សហការួមគ្នា ដើម្បីទប់ស្កាត់ និងលុបបំបាត់អំពើជួយដូរមនុស្ស ការជួញដូរផ្លូវភេទតាមគ្រប់ រូបភាពឱ្យទទួល បានលទ្ធផលល្អ បន្ថែមទៀត៕ ដោយ ងួ សុមុនី

## តុលាការកំពូលជំនុំជម្រះក្តី ស្ត្រីម្នាក់ជួញដូរនារីខ្មែរ ២ នាក់ទៅចិន

http://www.postkhmer.com/ Mon, 25 December 2017 គឹម សារុំ

**ភ្នំពេញៈ** តុលាការកំពូលនៅថ្ងៃទី ២៥ ខែធ្នូ ព្រឹកមិញនេះបានបើកសវនាការជំនុំជម្រះស្ត្រីជាប់ចោទម្នាក់ក្នុង រឿងនាំនារីខ្មែរ ២ នាក់ទៅរៀបការប្តីនៅប្រទេសចិន ប្រព្រឹត្តកាលពីឆ្នាំ ២០១៤ ។

លោកចៅក្រម គង់ ស្រ៊ីម ប្រធានក្រុមប្រឹក្សាជំនុំជម្រះថ្លែងថា ស្ត្រីជាប់ចោទឈ្មោះអ៊ុក វ៉ាន់នីអាយុ៦២ឆ្នាំត្រូវ តុលាការថ្នាក់ក្រោមផ្តន្ទាទោស៩ឆ្នាំចោទពីបទ «ប៉ុនប៉ងនាំចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន»។ តាមកំណត់ ហេតុនគរបាលបង្ហាញថា ស្ត្រីជាប់ចោទបានលួងលោមនារីឈ្មោះសំស្រីទូចនិងឈ្មោះវ៉ាត់លីដោយប្រាប់ថាទៅធ្វើការ នៅប្រទេសចិនបានប្រាក់ខែក្នុង ១ ខែ ៨០០ ដុល្លារ។ បន្ទាប់ពីត្រូវរ៉ូវគ្នារួចហើយពួកគេបានរត់ការធ្វើលិខិតឆ្លងដែន ហើយ ស្ត្រីជាប់ចោទបាននាំនារីរងគ្រោះមកស្នាក់ នៅផ្ទះខ្លួនរង់ចាំចេញដំណើរតែត្រូវនគរបាលប្រឆាំងការជួញដូរ មនុស្សនិងការពារអនីតិជនឃាត់ខ្លួនតែម្តង៕

## ខែធ្នូៈ ពលករ៣០នាក់នៅម៉ាឡេស៊ី និងចិន ត្រូវស្ថានទូតជួយឲ្យត្រឡប់មកកម្ពុជាវិញ

https://thmeythmey.com/ 23, Dec 2017 , 10:00 pm ដោយ: ថាន រស្មី

យ៉ាងហោចណាស់ពលករចំណាកស្រុកចំនួន៣០នាក់ ត្រូវបានស្ថានទូតកម្ពុជាជួយឲ្យត្រឡប់មកមាតុភូមិវិញ បន្ទាប់ពីចាញ់បោកមេខ្យល់យកទៅលក់នៅប្រទេសម៉ាឡេស៊ី និងចិន។ ក្នុងចំណោមពលករ ៣០នាក់នេះ មាន២៧ នេះជាពលករចំណាកស្រុកទៅកាន់ប្រទេសម៉ាឡេស៊ី និង ៣នាក់ជាស្ត្រី ដែលរៀបការជាមួយបុរសជនជាតិចិន។

ពលករចំនួន ៣០នាក់បានត្រឡប់មកប្រទេសកម្ពុជាវិញ ក្នុងដំណាច់ខែធ្នូ ឆ្នាំ២០១៧នេះ ដោយក្រសួងការ បរទេសកម្ពុជាបានជួយសង្គ្រោះ ក្នុងនោះមានពលករខ្មែរធ្វើការនៅប្រទេសម៉ាឡេស៊ី និងស្ត្រីខ្មែរដែលរៀបការជាមួយ ជនជាតិចិន ។ បើតាមសេចក្តីប្រកាសរបស់ក្រសួងព័ត៌មានបានឲ្យដឹងថា ស្ត្រីខ្មែរ ៣រូបដែលរៀបការជាមួយជនជាតិ

ចិន បានមកដល់ប្រទេសកម្ពុជាវិញកាលពីថ្ងៃទី៨ និងទី១៤ ខែធ្នូ។ ដោយមានការអន្តរាគមន៍ពីស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំនៅទីក្រុងក្វាងចូវ និង ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំនៅទីក្រុងសៀងហៃ សហការណ៍ជាមួយសមត្ថកិច្ចចិន។

ចំណែកឯពលករចំនួន២៧នាក់ផ្សេងទៀតដែលចាញ់បោកមេខ្យល់ យកទៅលក់នៅប្រទេសម៉ាឡេស៊ី បានជួយអន្តរាគមន៍ពីប្រទេសម៉ាឡេស៊ីវិញនៅថ្ងៃទី៨ ដល់ថ្ងៃទី២៥ ខែធ្នូ នេះ។ ដោយបានស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសម៉ាឡេស៊ី សហការណ៍ជាមន្ត្រីមានសមត្ថកិច្ចម៉ាឡេស៊ី ជួយសង្គ្រោះ។ លិខិតដដែលបានឲ្យដឹងទៀតថា ចំពោះការហូបចុក ស្នាក់នៅ និងធ្វើដំណើររបស់ពលករចំណាកស្រុកទាំង៣០នាក់នេះ គឺជាបន្ទុករបស់ស្ថានទូតកម្ពុជាទាំងអស់។

ជាការកត់សម្គាល់ស្ទើរតែរៀងរាល់ខែ ស្ថានទូតកម្ពុជាតែងតែជួយអន្តរាគមន៍ឲ្យមានមាតុភូមិនិវត្តន៍របស់ពលករខ្មែរដែលចំណាកស្រុកទៅធ្វើការក្រៅប្រទេសទាំងស្របច្បាប់និងមិនស្របច្បាប់ជានិច្ច។ ការជួយអន្តរាគមន៍នេះ គេសង្កេតឃើញថាភាគច្រើនជាពលករដែលចំណាកស្រុកតាមមេខ្យល់ទៅប្រទេសម៉ាឡេស៊ី និងរៀបការជាមួយជនជាតិចិនជាដើម។ យ៉ាងនាពេលកន្លងទៅប្រមុខរដ្ឋាភិបាលកម្ពុជាតែងតែអំពាវនាវឲ្យពលករចំណាកស្រុកទាំងអស់ត្រូវទៅធ្វើការតាមក្រុមហ៊ុនដែលស្របច្បាប់ ចៀសវាងការកេងចំណេញកម្លាំងពលកម្ម និងការជួញដូរមនុស្សជាដើម៕

## មន្ត្រីសង្គមស៊ីវិលស្នើឲ្យរដ្ឋាភិបាលបង្កើតគណៈកម្មការតាមដានពលករចំណាកស្រុក

http://www.rfa.org/khmer/news/ ដោយ ទីន ហ្សាការីយ៉ា 2017-12-24

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា បានប្រកាសថា ស្ថានទូតនៅប្រទេសម៉ាឡេស៊ី និងស្ថានកុងស៊ុលខ្មែរ នៅប្រទេសចិន បានរៀបចំបញ្ជូនពលករមកកម្ពុជា វិញនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧។ ប៉ុន្តែ មន្ត្រីអង្គការសង្គមស៊ីវិលដែលធ្វើការទាក់ទងនឹងពលករចំណាកស្រុកទៅក្រៅប្រទេសនេះ បានទទូចឲ្យអាជ្ញាធរពាក់ព័ន្ធរបស់រដ្ឋាភិបាលកម្ពុជា បង្កើនការយកចិត្តទុកដាក់ និងបង្កើតប្រព័ន្ធតាមដានសុវត្ថិភាពរបស់ពលករទាំងនោះនៅក្រៅប្រទេស ដើម្បីងាយជួយសង្គ្រោះទាន់ពេលវេលា។

មន្ត្រីអង្គការសង្គមស៊ីវិល ដែលធ្វើការទាក់ទងនឹងពលករចំណាកស្រុកបានថ្លែងឲ្យដឹងថា រដ្ឋាភិបាលកម្ពុជា គួរបង្កើតប្រព័ន្ធតាមដាន ឬមានគណៈកម្មការចម្រុះ ដើម្បីត្រួតពិនិត្យ និងតាមដានពលករកម្ពុជា ដែលចេញទៅបំពេញការងារនៅក្រៅប្រទេស ដើម្បីជៀសផុតពីគ្រោះថ្នាក់ផ្សេងៗ។ លោក ឌី ថេហូយ៉ា មន្ត្រីកម្មវិធីផ្នែកសិទ្ធិពលករចំណាកស្រុក នៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថា សង់ត្រាល់ (CENTRAL) បានថ្លែងឲ្យដឹងនៅថ្ងៃទី២៣ ធ្នូ ថា ប្រព័ន្ធការពារសុវត្ថិភាពជូនដល់ពលករដែលធ្វើចំណាកស្រុក ទាំងទៅប្រទេសចិន ឬប្រទេសម៉ាឡេស៊ីជាដើមនោះ គឺនៅមានភាពចន្លោះប្រហោង ដែលធ្វើឲ្យពលករធ្វើចំណាកស្រុកទាំងនោះប្រឈមនឹងហានិភ័យខ្ពស់លើកការកេងប្រវ័ញ្ច និងការជួញដូរ៖ «នៅពេលដែលមានការកេងប្រវ័ញ្ច ការជួញដូរហើយហានិភ័យ ឬបញ្ហាប្រឈមដ៏ធំធេងមួយទៀតនោះគឺថា យន្តការនៃការជួយសង្គ្រោះពួកគាត់នោះពិបាក ហើយមិនងាយបានចូលទៅដល់ជួបជនរងគ្រោះ មិនដឹងថា គាត់នៅទីតាំងណា មានទំនាក់ទំនងយ៉ាងណាអ៊ីចឹង ដែលនេះជាបញ្ហាដែលយើងមើលឃើញថាមិនទាន់បានប្រសើរនៅឡើយទេ»។

អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា លោក ជុំ សុន្ទរី បានប្រកាសពីថ្ងៃទី២២ ខែធ្នូ ថ្មីៗនេះថា ស្ថានទូតកម្ពុជា នៅពីរប្រទេសបានអន្តរាគមន៍ជួយធ្វើមាតុភូមិនិវត្តន៍ដល់ស្ត្រីខ្មែរ ៣នាក់នៅប្រទេសចិន និងពលករខ្មែរ ២៧នាក់នៅប្រទេសម៉ាឡេស៊ី។ ក្រសួងការបរទេសបញ្ជាក់ថា ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ម៉ាឡេស៊ី ដោះស្រាយបញ្ហា និងរៀបចំបញ្ជូនរបស់ពលករ-ពលការិនីខ្មែរ ចំនួន ២៧នាក់ដែលមកដល់កម្ពុជា ក្នុងចន្លោះថ្ងៃទី០៨ ដល់ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧។ ចំណែកឯ ស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំទីក្រុងក្វាងចូវ និងប្រចាំទីក្រុងសៀងហៃ ប្រទេសចិន បានសហការជាមួយ

អាជ្ញាធរមានសមត្ថកិច្ចចិន ជួយសង្គ្រោះស្ត្រីខ្មែរ ៣នាក់ ដែលចាញ់បោកមេខ្យល់នាំទៅរៀបការជាមួយបុរសជនជាតិចិន ហើយបានរៀបចំមាតុភូមិនិវត្តន៍មកដល់កម្ពុជា វិញនៅថ្ងៃទី០៨ និងទី១៤ ខែធ្នូ ឆ្នាំ២០១៧។

ពលការិនីម្នាក់ដែលបានធ្វើមាតុភូមិនិវត្តន៍កាលពីឆ្នាំ២០១៦ កញ្ញា ថុនា មានស្រុកកំណើតនៅខេត្តកំពង់ចាម បានថ្លែងឲ្យដឹងថា នាងបានទៅធ្វើការជាអ្នកបម្រើតាមផ្ទះតាមរយៈក្រុមហ៊ុនឯកជនមួយអស់រយៈពេលប្រមាណ ១ឆ្នាំកន្លះ ប៉ុន្តែនាងមិនទទួលបានកម្រៃ ឬប្រាក់ខែត្រឡប់មកវិញឡើយ។ នាងបានរត់មករកអង្គការ និងស្ថានទូតខ្មែរ នៅទីនោះបានត្រឡប់មកវិញដោយខ្លួនទទេនេះ៖ «ការងារនៅតាមផ្ទះលំបាកដោយសារតែប្រើប្រាស់កម្លាំងយើងខ្លាំង យើងក្រោកម៉ោង៥ ហើយយកទៅធ្វើការចាប់ពីម៉ោង ៦ព្រឹក រហូតដល់ម៉ោង៩យប់ ពេលខ្លះដល់ម៉ោង ១២យប់ក៏មាន។ ការងារនាងខ្ញុំធ្វើ គឺការងារផ្ទះ បោកខោអាវ អ៊ុតខោអាវ បោសជូតផ្ទះ និងលាងបន្ទប់ទឹកជាដើមហ្នឹង»។ នាងបានថ្លែងថា នាងរាងចាល និងទទួលបានបទពិសោធន៍យ៉ាងជូរចត់ធ្វើចំណាកស្រុកទៅធ្វើការងារនៅក្រៅប្រទេស ដោយសារតែចាញ់បោកក្រុមហ៊ុនឯកជនឃោសនាថា ទទួលបានប្រាក់ខែ ៣រយដុល្លារក្នុងមួយខែ ប៉ុន្តែក្រៅពីក្រុមហ៊ុនកាត់ប្រាក់ខែនាងអស់ ៥ខែ គឺនាងមិនបានទទួលមួយរៀលត្រឡប់មកវិញឡើយ។

លោក ឱ ថេហួយ៉ា បានថ្លែងឲ្យដឹងដែរថា រដ្ឋាភិបាលគួរតែផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់ពលរដ្ឋកម្ពុជាអំពីសុវត្ថិភាពនៃការធ្វើចំណាកស្រុកដូចនៅប្រទេសចិន ជាដើមថា រដ្ឋាភិបាលប្រទេសទាំងពីរមិនទាន់បានចុះអនុស្សរណៈយោគយល់គ្នាពីការបញ្ជូនពលករនៅឡើយទេ។ ដូច្នេះហើយតើពលរដ្ឋគួរសម្រេចចិត្តថា គួរចំណាកស្រុកទៅប្រទេសនោះ ឬមិនគួរ ឬត្រៀមលក្ខណៈសម្បត្តិអ្វីខ្លះដើម្បីធ្វើចំណាកស្រុក។ លោកកត់សម្គាល់ឃើញថា ពលករចំណាកស្រុក ឬរៀបការទៅប្រទេសចិន បានធ្វើឡើង ឬឆ្លងកាត់តាមប្រទេសវៀតណាម ចំណែកឯពលករដែលទៅប្រទេសម៉ាឡេស៊ី វិញគឺឆ្លងកាត់តាមប្រទេសថៃ ទាំងពលករធ្វើការនៅផ្ទះ ឬពលករផ្សេងៗទៀត ហើយបញ្ហានេះសមត្ថកិច្ចពាក់ព័ន្ធគួរមានវិធានការតឹងរ៉ឹង៖ «ស្ថាប័នរដ្ឋគួរតែចាត់វិធានការចំពោះមេខ្យល់ក្តី ឬក្រុមហ៊ុនទុច្ចរិតទាំងឡាយណាដែលបញ្ជូនពលករទៅក្រៅប្រទេសដោយមិនបានគោរពសិទ្ធិការងារ ឬមិនបានគោរពសិទ្ធិមនុស្សជាដើម ត្រូវតាមដាន ហើយចាត់វិធានការឲ្យបានម៉ឺងម៉ាត់ ហើយកុំបណ្តោយឲ្យមេខ្យល់ ឬជនទុច្ចរិត ក៏ដូចជាក្រុមហ៊ុនមួយចំនួននោះចេះតែបញ្ជូនទៅដោយមិនបានធានាដល់សុវត្ថិភាពដល់ពលករ ពលការិនីកម្ពុជាយើងនោះ»។

លោកថ្លែងទៀតថា អាជ្ញាធរពាក់ព័ន្ធគួរតែធ្វើប្រព័ន្ធទិន្នន័យដើម្បីគ្រប់គ្រងពលករចំណាកស្រុក ហើយមានប្រព័ន្ធ ឬរបៀបការងារដើម្បីតាមដានមើលស្ថានភាពពលករ និងជួយសង្គ្រោះពេលពលករត្រូវការជំនួយសង្គ្រោះបន្ទាន់ណាមួយនោះ ហើយពលករមិនគួរត្រូវបានម្ចាស់ឈ្នួល ឬក្រុមហ៊ុនដកហូតឯកសារផ្ទាល់ខ្លួនណាមួយទេ។ លោកអង្កេតឃើញដែរថា ពលករដែលធ្វើចំណាកស្រុករកការងារនៅក្រៅប្រទេសគួរទទួលការបណ្តុះបណ្តាលជាមុនសិន ដូចជាភាសាប្រទេសដែលគ្រោងធ្វើចំណាកស្រុកទៅ វប្បធម៌របៀប ប្រពៃណី រស់នៅរបស់ប្រទេសនោះជាដើម ព្រោះថា ស្ត្រីដែលរងការធ្វើបាប ឬរំលោភបំពានពីថៅកែ ភាគច្រើនមិនចេះភាសារបស់ប្រទេសនោះទេ។

សេចក្តីជូនដំណឹងរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចេញផ្សាយកាលដើមឆ្នាំ២០១៧ បានបង្ហាញថា គិតពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ក្នុងឆ្នាំ២០១៦ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានស្ថានទូត និងស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំនៅក្រៅប្រទេសបានជួយដោះស្រាយបញ្ហាជូនពលរដ្ឋ ពលករ-ពលការិនី និងស្ត្រីខ្មែរ ដែលរងគ្រោះដោយការធ្វើបាបពីថៅកែ ការជួញដូរ និងផលលំបាកក្នុងការងារ ឲ្យបានត្រលប់មកកាន់គេហដ្ឋានពួកគេវិញ បានចំនួន ៨១៦នាក់៕

## អាជ្ញាធរស្រុកជាំក្សាន្ត ជួបជាមួយអាជ្ញាធរស្រុកណាំយឺនរបស់ថៃ ស្តីពីកិច្ចសហការតាមព្រំដែន

http://ann.com.kh/site/news/ ថ្ងៃចន្ទ, 25 ខែធ្នូ 2017 8:27 ព្រឹក

**(ព្រះវិហារ)៖** កាលពីថ្ងៃម្សិលមិញនេះ អាជ្ញាធរស្រុកជាំក្សាន្ត នៃខេត្តព្រះវិហាររបស់កម្ពុជា និងអាជ្ញាធរស្រុកណាំយឺន របស់ថៃ បានបើកកិច្ចប្រជុំពិភាក្សាគ្នាពីកិច្ចសហប្រតិបត្តិការរវាងស្រុកជាប់ព្រំប្រទល់គ្នានេះ។

កិច្ចពិភាក្សាគ្នានេះ បានធ្វើឡើងនៅច្រក អានសេះ ដោយខាងកម្ពុជាដឹកនាំដោយ លោក ជា គឹមសេង អភិបាលស្រុកជាំក្សាន្ត និងភាគីថៃដឹកនាំដោយលោក ស៊ុម ឆៃបូរណៈ អភិបាលស្រុកណាំយឺន។ ក្នុងនោះ ភាគីកម្ពុជា បានដាក់នូវរបៀបវារៈសំខាន់៤ សម្រាប់ធ្វើការពិភាក្សា ដោយៈ

ទី១.សូមឲ្យភាគីទាំងពីរបង្កើនកិច្ចសហប្រតិបត្តិកាល្អរវាងថ្នាក់ស្រុក និងស្រុកដែលជាប់ព្រំដែន ជាពិសេសស្រុកជាំក្សាន្តនិងស្រុកណាំយឺន។

ទី២.សូមឲ្យខាងភាគីថៃសហការជួយទប់ស្កាតរាល់បទល្មើសឆ្លងដែននានា ដែលធ្វើឲ្យបាត់បង់នូវផលប្រយោជន៍ជាតិរៀងៗខ្លួន, ជាពិសេសករណីគ្រឿងញៀននៅតាមបន្ទាត់ព្រំដែននៃស្រុកទាំងពីរ។

ទី៣.ខាងភាគីកម្ពុជាសុំស្នើរឲ្យភាគីថៃ ធ្វើយ៉ាងណាបើកច្រកអានសេះនេះឲ្យក្លាយទៅជាច្រកអន្តរជាតិមួយ ដើម្បីបង្ករភាពងាយស្រួលដល់ប្រជាពលរដ្ឋទាំងសងខាងងាយស្រួលដោះដូរទំនិញគ្នាទៅវិញទៅមក ដោយបច្ចុប្បន្នច្រកនេះវាជាច្រកតំបន់មួយដែលក្នុងមួយអាទិត្យ គឺបើកឲ្យបានដំណើរការតែពីរថ្ងៃប៉ុណ្ណោះ ដោយមិនសមនិងតម្រូវការរបស់បងប្អូនអាជីវករទាំសងខាងនោះឡើយ។

ទី៤.សុំឲ្យមានការសម្របសម្រួលគ្នាក្នុងនាមប្រទេសជិតខាង និងកាន់សាសនាព្រះពុទ្ធដូចគ្នា ធ្វើយ៉ាងណាបង្កើតឲ្យមានកាធ្វើបុណ្យឆ្លងឆ្នាំជុំគ្នានៅនឹងច្រកផ្សារអានសេះនេះផ្ទាល់តែម្តង។

ឆ្លើយតបនឹងរបៀបវារៈទាំង៤នេះ ភាគីទាំងពីរបានឯកភាពគ្នា ដោយសម្រេចឲ្យមានកាធ្វើបុណ្យរួមគ្នាមួយប្រព្រឹត្តទៅនៅចុងឆ្នាំ2017 និងនិមន្តព្រះសង្ឃចំនួន45អង្គរ ក្នុងស្រុកជាំក្សាន្ត និង45អង្គនិមន្តមកពីស្រុកណាំយឺផងដែរ។ ជាមួយគ្នានេះ ថៃក៏បានសន្យាជួយផ្តល់ជើងសិប្បនិម្មិតចំនួន80ជើងដល់ជនពិកាក្នុងស្រុកជាំក្សាន្ត ដោយឥតគិតថ្លៃថែមទៀត។

ជាចុងក្រោយលោក ជា គឹមសេង អភិបាលស្រុកជាំក្សាន្ត ក៏បានស្នើរឲ្យភាគីថៃធ្វើយ៉ាងណាមេត្តាជួយទប់ស្កាត់រាល់ពលរដ្ឋឆ្លងដែនខុសច្បាប់ ដោយធ្វើយ៉ាងណា សូមកុំបាញ់សម្លាប់ពួកគាត់ ដោយគ្រាន់តែចាប់ហើយបញ្ជូនមកខាងកម្ពុជាវិញតាមរយៈស្ថានទូត ឬអគ្គកុងស៊ុលខ្មែរដែលមាននៅជិតនោះទៅបានហើយ ព្រោះមួយរយៈកន្លងមកមានបងប្អូនប្រជាពលរដ្ឋខ្មែរមួយចំនួនបានធ្វើការចំណាកស្រុក ដោយជឿតាមមេខ្យល់អូសទាញប៉ុណ្ណោះ៕ ដោយៈ សួន ក្រែង

## ខ្មែរ២នាក់ត្រូវសមត្ថកិច្ចថៃចាប់ខ្លួនរួមនិងឈើគ្រញូងជិត២០០ដុំ នៅជិតព្រំដែនកម្ពុជា

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្តិ៍ ចេញផ្សាយ ថ្ងៃទី 24 December, 2017

បន្ទាយមានជ័យ ៖ ពលករខ្មែរ២ត្រូវបានសកម្លាំងសមត្ថកិច្ចថៃចាប់ខ្លួនបន្ទាប់ពីពួនសំងំ ជ្រៀកឈើគ្រញូង កាលពីរសៀលថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០១៧ នៅចំណុចក្នុងចំការអំពៅមួយ កន្លែង ស្ថិតនៅជាយភូមិ២ ត្រង់ចំណុចណូនស្វារ ស្ថិតក្នុងឃុំសៃថង ស្រុកខ្លងហាតខេត្តស្រះកែវ ប្រទេស ថៃ ។ ពលរដ្ឋខ្មែរទាំង២នាក់ដែលសមត្ថកិច្ចថៃឃាត់ខ្លួននោះមានឈ្មោះ ប្រាក់យ៉ូន ហាមថង និងឈ្មោះ រិទ្ធិផុង សំរោងផល រឹងវត្ថុតាងឈើគ្រញូងដែលជ្រៀករួចប្រមាណជិត២០០ដុំ ត្រូវបាន កំលាំង ជំនាញ និងតម្រួតថៃ ក្រសោបបាននៅក្នុងចំការអំពៅ ក្បែរខ្សែបន្ទាត់ព្រំដែនថៃជាប់ព្រំដែន កម្ពុជា ខណៈដែលឈើទាំងនេះត្រៀមបម្រុងនាំឆ្លងដែនចូលមកកម្ពុជា ។

យោងតាមរបាយការណ៍ពីប្រទេសថៃ បានបញ្ជាក់ថា កិច្ចប្រតិបត្តិការដែលធ្វើឡើងដោយ កំលាំងតម្រួត កំលាំងរដ្ឋបាលព្រៃឈើ និងទាហានឈុតខ្មៅលេខ១៣ បានប្រមូលផ្តុំគ្នា ធ្វើការ ឡោម ព័ទ្ធចំការអំពៅខាងលើនេះ បន្ទាប់ពីទទួលបាននូវព័ត៌មាន ស្តីពីការលបលួចកែច្នៃឈើ គ្រញូង ដើម្បីឆ្លងដែនចេញទៅក្រៅប្រទេស ដែលនៅទីនោះមានមុខសញ្ញាចំនួន៤ នាក់ ដែលកំពុង ធ្វើសកម្មភាពជៀកដុំឈើគ្រញូង នេះ។ ប៉ុន្តែពេលកំលាំងបង្ហាញខ្លួន គឺពួកគេចំនួនពីរនាក់ បានរត់ គេចខ្លួនបាត់ ដោយឡែកពីរនាក់ទៀត ត្រូវបានឃាត់ខ្លួនដើម្បីសាកសួរ ។

នៅក្នុងប្រតិបត្តការនោះដែរ កំលាំងបានធ្វើការដកហូតនូវវត្ថុតាងមួយចំនួនដូចជា រណារយន្ត ចំនួន៣គ្រឿង ឈើគ្រញូងចំនួន១៩០ដុំ សម្ភារៈសម្រាប់ជៀកមួយចំនួន ព្រមទាំងថ្នាំញៀនប្រភេទ យ៉ាម៉ាចំនួន១២គ្រាប់/ ម៉ូតូម៉ាក យ៉ាម៉ាហា ចំនួន ១គ្រឿងផងដែរ ។បច្ចុប្បន្នវត្ថុតាង និងពលករ២ នាក់ ត្រូវបានកំលាំងសមត្ថកិច្ចជំនាញ នាំយកទៅកាន់ខេត្តស្រះកែវ ដើម្បីសាកសួរបន្ត បន្ទាប់ពីពួក គេបានសារភាពថា ឈើទាំងនេះគឺជៀកជាដុំៗ ដើម្បីនាំចេញឆ្លងដែនចូលមកកម្ពុជា៕

## រថយន្តដឹកពលករខ្មែរទៅវ៉ៃVisa ជួបគ្រោះថ្នាក់ចរាចរ បណ្តាលពលករ11នាក់រងរបួសធ្ងន់

http://www.pheaktraprak.com December 21, 2017

កាលពីវេលាម៉ោង05:31នាទីព្រឹកលឹមនាថ្ងៃព្រហស្បតិ៍ទី21 ខែធ្នូ ឆ្នាំ2017 មានករណីរថយន្តដឹកពលករខ្មែរទៅវ៉ៃវីសារជួបឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរក្រឡាប់ធ្លាក់ផ្លូវបណ្តាលឲ្យមានមនុស្សរងរបួសជាច្រើននាក់ ហេតុការណ៍នេះបានកើតឡើងនៅត្រង់ចំណុចផ្លូវជាតិលេខ359 (ខៅសិនសន-ស្រះកែវ) ស្ថិតនៅភូមិ10 ឃុំខៅម៉ៃកែវ ស្រុកការបឹនបុរី ខេត្តប្រាជីនបុរី ប្រទេសថៃ។

ប្រភពពីកន្លែងកើតហេតុបានឲ្យដឹងថា រថយន្តខាងលើ ម៉ាក Izuzu mu7 ពាក់ស្លាកលេខ6780 ឆាកឈើងសៅ បានដឹកពលករខ្មែរចំនួន16នាក់មកពីតំបន់ប្រាមកោ(param9)ទីក្រុងបាងកក ដើម្បីទៅវ៉ៃវីសារនៅព្រំដែនប៉ោយប៉ែតដោយចេញដំណើរមកតាំងពីវេលាម៉ោង02:00យប់ លុះមកដល់ត្រង់ចំណុចកើតហេតុ ប្រហែលជាអ្នកបើកបរងងុយដេក ធ្វើរថយន្តរេ ចង្កូតធ្លាក់ប្រឡាយក្បែរផ្លូវបណ្តាលឲ្យរថយន្តក្រឡាប់ជាច្រើនត្រឡប់ ធ្វើឲ្យពលករជិះនៅក្នុងរថយន្តចំនួន11នាក់រងរបួសធ្ងន់។ ក្រោយពេលកើតហេតុជនរងគ្រោះទាំងអស់ត្រូវភ្នាក់ងារសង្គ្រោះស្រុកការបើនបុរី បញ្ជូនយកទៅសង្គ្រោះនៅមន្ទីរពេទ្យកាប៊ីនបុរី ចំណែកឯមូលហេតុដែលធ្វើឲ្យកើតគ្រោះថ្នាក់ចរាចរនេះសមត្ថកិច្ចថៃកំពុងធ្វើការត្រួតពិនិត្យ។

## លោករដ្ឋមន្ត្រីក្រសួងការងារថៃ អំពាវនាវឲ្យថៅកែថៃផ្តល់ថ្ងៃឈប់សម្រាកបន្ថែមចំនួន4ថ្ងៃ ដល់ពលករនៅក្នុងឱកាសបុណ្យចូលឆ្នាំសកលខាងមុខនេះ

http://www.pheaktraprak.com December 25, 2017

លោកស្រី(Pacharavasin) អនុលេខាអចិន្ត្រៃយ៍នៃក្រសួងការងារថៃ ក្នុងនាមជាអ្នកនាំពាក្យក្រសួងការងារប្រាប់ឲ្យដឹងថា យោងទៅតាមសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី 7 ខែវិច្ឆិកាឆ្នាំ 2560 ចាប់ពីថ្ងៃទី 30 ខែធ្នូឆ្នាំ 2017 ដល់ថ្ងៃទី 2 ខែមករាឆ្នាំ 2018 គឺជាថ្ងៃបុណ្យចូលឆ្នាំថ្មីឆ្នាំសកល ដូច្នេះលោកអាឌុលសេងសូវកែវ (Adul Saengsiew Kaew) រដ្ឋមន្ត្រីក្រសួងការងារថៃ បានអំពាវនាវដល់និយោជិតថៃទាំងអស់ត្រូវផ្តល់ថ្ងៃឈប់សម្រាកបន្ថែដល់បងប្អូនពលករទាំងអស់ ដើម្បីឲ្យពួកគាត់បានវិលត្រឡប់ទៅជួបជុំគ្រួសារនៅឯស្រុកកំណើតក្នុងអំឡុងពេលថ្ងៃបុណ្យចូលឆ្នាំថ្មីនេះ។ ក្នុងនោះលោករដ្ឋមន្ត្រីស្នើដល់និយោជិកត្រូវចាប់ផ្តើមអោយពលករឈប់សម្រាកធ្វើការការងារចាប់ពីថ្ងៃទី 30 ខែធ្នូឆ្នាំ 2017 រហូតដល់ថ្ងៃទី 2 ខែមករាឆ្នាំ 2018 ដើម្បីអោយពួកគេបានត្រឡប់ទៅជួបគ្រួសាររបស់ពួកគេវិញនិងបានចូលរួមនូវសកម្មភាពបុណ្យទានប្រពៃណីរបស់គេ។ ហើយបន្ថែមពីលើនេះលោករដ្ឋមន្ត្រីបានយកចិត្តទុកដាក់ចំពោះបងប្អូនពលករនិងសុំកុំអោយបងប្អូនពិសាគ្រឿងស្រវឹងឬភេសជ្ជៈដែលមានជាតិអាល់កុលនៅពេលធ្វើដំណើរនិងបើកបរយន្តជំនិះព្រមជូនពរឲ្យបងប្អូនពលករទាំងអស់វិលត្រឡប់មកធ្វើការវិញដោយសុវត្ថិភាពគ្រប់គ្នា។

## ប្រទះឃើញសាកសពមនុស្សស្លាប់អណ្តែតទឹកម្នាក់ គេសង្ស័យថាជាកម្មករខ្មែរ

http://www.pheaktraprak.com December 24, 2017

កាលពីវេលាម៉ោង០៦:៣០នាទីល្ងាចថ្ងៃសៅរ៍ទី២៣ ខែធ្នូ ឆ្នាំ២០១៧ កម្មករខ្មែរម្នាក់ឈ្មោះ ង៉ក អាយុ ៤០ឆ្នាំ ធ្វើការនេសាទត្រីនៅក្នុងស្រុកសាត់ហ៊ីប ខេត្តឈុនបុរី បានប្រទះឃើញសាកសពមនុស្សប្រុសម្នាក់ស្លាប់អណ្តែតទឹក នៅក្បែរកំពុងផែរចតទូកមួយស្ថិតនៅភូមិ១ ឃុំសាត់ហ៊ីប ស្រុកសាត់ហ៊ីប ខេត្តឈុនបុរី ប្រទេសថៃ។

យោងតាមប្រភពរបស់សមត្ថកិច្ចថៃដែលចុះទៅពិនិត្យសាកសពនៅកន្លែងកើតហេតុបានអោយដឹងថា អ្នកស្លាប់មានអាយុប្រហែល៣០-៣៥ ឆ្នាំតាមការពិនិត្យនៅលើសាកសពមានស្នាមសាក់រូបបីសាចនៅលើដើមទ្រូង និងនៅលើដៃមានស្នាមសាក់អក្សរជាភាសាអង់គ្លេសថា"My HeartWillGooD" តាមការសាកសួរអ្នកនៅធ្វើការក្បែរទីនោះមិនមានអ្នកណាស្គាល់ឡើយ។ តាមការសន្និដ្ឋានរបស់សមត្ថកិច្ចថៃបានបញ្ជាក់ថាអ្នកស្លាប់ប្រហែលជាកម្មករចំណាកស្រុកធ្វើការលើទូកនេសាទត្រី ដែលមកឈប់ចតនៅកំពង់ផែនេះ អ្នកស្លាប់ឡើងមកអង្គុយផឹកស្រានៅលើកំពុងផែខាងលើ ហើយគណៈពេលស្រវឹងប្រហែលធ្លាក់ទឹកលង់ស្លាប់តែម្តង។ក្រោយពេលត្រួតពិនិត្យសាកសពរួចសម្ថកិច្ចថៃបាន បញ្ជូនសាកសពអ្នកស្លាប់យកទៅរក្សាទុកនៅមន្ទីរពេទ្យដើម្បីប្រកាសស្វែងរកសាចញាតិអោយមកទទួលយកទៅធ្វើបុណ្យតាមប្រពៃណី។

## ថៃ ពន្យារពេលពី ៣ ទៅ ៦ខែទៀត ដើម្បីឲ្យកម្ពុជា ផ្តល់នាពស្របច្បាប់ដល់កម្មករខ្មែរ

http://www.pheaktraprak.com December 23, 2017

រាជរដ្ឋាភិបាលថៃរាជរដ្ឋាភិបាលថៃ សម្រេចផ្អាកអនុវត្តន៍ច្បាប់គ្រប់គ្រងពលករបរទេសថ្មីនៅដើមឆ្នាំ2018ខាងមុខនេះបន្ទាប់ពីបញ្ហាកអត្តសញ្ញាណជូនពលករបរទេសមានភាពយឺតយ៉ាវ។ លោករដ្ឋមន្រ្តីក្រសួងការងារថៃ បានផ្តល់បទសម្ភាសន៍ប្រាប់អ្នកយកព័ត៌មានក្នុងស្រុកថៃ អោយបានដឹងថា រាជរដ្ឋាភិបាលថៃគ្រោងផ្អាកអនុវត្តន៍ច្បាប់គ្រប់គ្រងពលករបរទេសថ្មី ដែលត្រៀមនឹងអនុវត្តនៅដើមឆ្នាំថ្មីខាងមុខនេះ។ តែដោយសារបញ្ហាពលករបរទេសមួយចំនួនធំមិនបានត្រួតសញ្ជាតិរួចដូច្នេះ ធ្វើឲ្យការអនុវត្តច្បាប់នេះមិនអាចដំណើរការបានទាំងស្រុងនៅដើមឆ្នាំ2018ខាងមុខនេះ។

## ឯកសារសម្រាប់ទៅយកលេខរៀង ត្រួតសញ្ជាតិធ្វើប៉ាស្ព័រ

http://www.pheaktraprak.com December 23, 2017

នៅថ្ងៃនេះមានបងប្អូនពលករកម្ពុជាធ្វើការនៅប្រទេសថៃមួយចំនួនធំបាន (Chat) មកសួរខ្ញុំជាច្រើននាក់អំពីរឿងឯកសារសម្រាប់ត្រៀមទៅយកលេខរៀងនៅមន្ទីការងារថៃ នៅថ្ងៃច័ន្ទទី25 ខែធ្នូ ឆ្នាំ2017ខាងមុខនេះ ដើម្បីយកទៅធ្វើប៉ាស្ព័រ។ ជាធម្មតារឿងទៅយកលេខរៀងដើម្បីបញ្ជាក់អត្តសញ្ញាណធ្វើប៉ាស្ព័រភាគច្រើនថៅកែថៃជាអ្នកទៅយកអោយពលករដោយខ្លួនឯង តែនៅម្តងនេះបងប្អូនពលករចង់ទៅយកដោយខ្លួនឯង ដូច្នេះខ្ញុំនិងសរសេររាប់រៀបបញ្ជាក់ប្រាប់អំពីឯកសារទាំងអស់នោះជូនបងប្អូនអានដូចខាងក្រោម៖

**ឯកសារចំពោះអ្នកលុងបៀនថ្មី**

1-ឯកសារសម្ភាសន៍លុងបៀនថ្មី(បៃចាប់គូ)ច្បាប់ថតចម្លងនិងច្បាប់ដើម ចំនួន1ឈុត

2-ឯកសារថៅកែ(អត្តសញ្ញាណប័ណ្ណសញ្ជាតិថៃ) ច្បាប់ថតចម្លងឬឯកសារបញ្ជាក់របស់ក្រុមហ៊ុន ត្រូវយកទំព័រមុខ ត្រូវវ៉ៃត្រា និងចុះហត្ថលេខាបញ្ជាក់អោយបានត្រឹមត្រូវបញ្ជាក់អោយច្បាស់លាសចំពោះ(នីតិបុគ្គល)។

3-ឯកសារផ្ទេរសិទ្ធិ ករណីអោយអ្នកដទៃទៅយកជំនួសព្រមទាំងចុះហត្ថលេខាបញ្ជាក់អ្នកទៅយកជនួស/អត្តសញ្ញាណប័ណ្ណសញ្ជាតិថៃរបស់ថៅកែច្បាប់ថតចម្លង

**ឯកសារចំពោះអ្នកកាន់ប័ត្រស៊ីជម្ពូ**

1-ប័ត្រស៊ីជម្ពូ (31.03.2018) ច្បាប់ថតចម្លងនិងច្បាប់ដើមចំនួន 1ឈុត។

2-ឯកសារថៅកែ (អត្តសញ្ញាណប័ណ្ណសញ្ជាតិថៃ) ច្បាប់ថតចម្លង,ឬឯកសារបញ្ជាក់របស់ក្រុមហ៊ុនត្រូវ យកទំព័រមុខ ត្រូវវ៉ែត្រា និងចុះហត្ថលេខាអោយបានត្រឹមត្រូវចំពោះ(នីតិបុគ្គល)។

3-ឯកសារផ្ទេរសិទ្ធិ ករណីអោយអ្នកដទៃទៅយកជំនួសព្រមទាំងចុះហត្ថលេខាបញ្ជាក់អ្នកទៅយកជនួស/អត្តសញ្ញាណប័ណ្ណសញ្ជាតិថៃរបស់ថៅកែច្បាប់ថតចម្លង។

*ទាំងអស់នេះជាឯកសារដែលខាងមន្ទីរការងារថៃបានកំណត់អោយថៅកែត្រៀមដើម្បីងាយស្រួលក្នុងការយកលេខរៀងត្រួតសញ្ជាតិរបស់ពលករ។ ដូច្នេះបើសិនជាបងប្អូនមានចម្ងល់ក្នុងរឿងឯកសារទៅយកលេខរៀងសូមបងប្អូនទំនាក់ទំនងទៅកាន់លេខទូរស័ព្ទ1694ឬ1111ចាប់ពីថ្ងៃច័ន្ទដល់ថ្ងៃចាប់ម៉ោង08:30ព្រឹក-ម៉ោង05:00ល្ងាច។

## ដំណឹងប្រកាសចែកលេខរៀងធ្វើប៉ាស្ព័រជូនពលករកម្ពុជា

http://www.pheaktraprak.com December 23, 2017

ចាប់ផ្តើមចែកលេខបន្តទៀត សម្រាប់បងប្អូនពលករកម្ពុជាដែលកាន់ប័ណ្ណស៊ីជម្ពូ និងពលករកាន់លិខិតបញ្ជាក់ទំនាក់ទំនងពលករនិងនិយោជក ចាប់ពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ នេះតទៅ គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមជម្រាបជូនដំណឹងដល់ សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើនៅប្រទេសថៃ ជ្រាបថា ភាគីថៃនឹងចាប់ផ្តើមចែកលេខណាត់សម្រាប់ការបញ្ជាក់អត្តសញ្ញាណ ទាំងចំពោះពលករកាន់ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណស៊ីជម្ពូ) និងពលករកាន់លិខិតបញ្ជាក់ទំនាក់ទំនងពលករនិងនិយោជក ចាប់ពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ នេះតទៅ។ អាស្រ័យហេតុនេះ សូមបងប្អូនពលករកាន់ឯកសារទាំងពីរប្រភេទខាងលើនេះ ប្រញាប់ទៅទំនាក់ទំនងជាមួយការិយាល័យ និងមន្ទីរការងារថៃនៅតាមខេត្តដែលបងប្អូនស្នាក់នៅ និងធ្វើការ ដើម្បីទទួលបានលេខណាត់នេះ។ អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជា ជ្រាបជាព័ត៌មាន។

## ដំណឹងល្អ ចំពោះពលករកម្ពុជាអាចធ្វើប៉ាស្ព័របានរហូតដល់ចិតឆ្នាំ

http://www.pheaktraprak.com December 22, 2017

រដ្ឋមន្ត្រីក្រសួងការងារថៃត្រៀមស្នើទៅលោនាយករដ្ឋមន្ត្រីថៃ ដើម្បីបន្តការត្រួតសញ្ជាតិជូនពលករកម្ពុជាដល់ខែមិថុនា ឆ្នាំ2018។ នៅក្នុងឱកាសចុះទស្សនកិច្ចការិយាល័យត្រួតសញ្ជាតិជូនពលករកម្ពុជានៅក្នុងហាងទំនើបអ៊ីមកូលៀម, BigC ឡាតប្លាវ ទីក្រុងបាងកកប្រទេសថៃ របស់លោករដ្ឋមន្ត្រីក្រសួងការងារកម្ពុជា ឯកឧត្តម អ៊ិត សំហេង និងលោករដ្ឋមន្ត្រីក្រសួងការងារថៃ អាប់ឌុន សែងសិងកែវ កាលពីថ្ងៃសុក្រ ទី21 ខែធ្នូ ឆ្នាំ2017 ម្សិលមិញនេះ។ បានឲ្យដឹងថា រដ្ឋមន្ត្រីក្រសួងការងារថៃត្រៀមធ្វើស្នើទៅកាន់លោកនាយករដ្ឋមន្ត្រី ប្រយុទ្ធ ចាន់អូចា នៅក្នុងកិច្ចប្រជុំកំពូលគណៈរដ្ឋមន្ត្រីថៃនៅពេលឆាប់ៗខាងមុខនេះ ដើម្បីអោយគណៈរដ្ឋមន្ត្រីពិចារណាពន្យារការស្នាក់នៅជូនពលករកម្ពុជាដែលមិនបានបញ្ជាក់អត្តសញ្ញាណ អោយអោយពួកគេអាចធ្វើការបញ្ជាក់អត្តសញ្ញាណ(ត្រួតសញ្ជាតិ)បានរហូតដល់ថ្ងៃទី31 ខែ06 ឆ្នាំ2018 នេះបើយោងតាមខ្លឹមរបស់កាសែត MatichonOnline ថៃបានចុះផ្សាយកាលពីល្ងាចថ្ងៃសុក្រទី 22 ខែធ្នូ ឆ្នាំ2017នេះ។

## ពាក្យថាពលករខុសច្បាប់"បកស្រាយដោយបង,HengHoeurn, ហៅកម្មករឆ្លងដែន

http://www.pheaktraprak.com December 21, 2017

សូមតាមដានអត្ថន័យការបកស្រាយរបស់បង (Heng Hoeurn) ហៅបងកម្មករឆ្លងដែនដូចតទៅបច្ចុប្បន្ននេះមាន3ប្រភេទគឺ៖

1-អ្នកប័ត្រស៊ីជម្ពូរ គឺជាពលករដែលលួចឆ្លងដែនចូលមកធ្វើការដោយខុសច្បាប់ តែត្រូវបានរាជរដ្ឋាភិបាលថៃអនុគ្រោះ បើកអោយចុះបញ្ជីឬចុះស្ថិតិចេញប័ណ្ណអនុញ្ញាតធ្វើការនិងស្នាក់នៅបណ្តោះអាសន្ន ដើម្បីរង់ចាំការបញ្ជាក់

អត្តសញ្ញាណឬត្រួតសញ្ជាតិ រួចហើយក៏ទៅស្នើសុំទិដ្ឋាការស្នាក់នៅនិងលិខិតអនុញ្ញាតធ្វើការនោះទើបបានស្របច្បាប់ 100%(ក្រុមប័ត្រស៊ីជម្ពូគឺហៅថាក្រុមមាត្រា13)។

2-ក្រុមមាត្រា44 គឺពលករដែលលួចឆ្លងដែនចូលមកធ្វើការដោយខុសច្បាប់ប៉ុន្តែក៏ត្រូវបានរាជរដ្ឋាភិបាលថៃអនុគ្រោះបើកអោយចុះបញ្ជីរឬចុះស្ថិតិចាប់ពីថ្ងៃទី24 កក្កដា 2017 ដល់ថ្ងៃទី07 សីហា 2017 មានរយៈពេល15ថ្ងៃ រួចក៏ចេញលិខិតបញ្ជាក់ទំនាក់ទំនងរវាងថៅកែនិងពលករ ដើម្បីរង់ចាំការបញ្ជាក់អត្តសញ្ញាណឬត្រួតសញ្ជាតិ រួចហើយក៏ទៅសុំទិដ្ឋាការស្នាក់នៅនិងលិខិតអនុញ្ញាតធ្វើការទើបបានស្របច្បាប់100%។

3-ពលករដែលលួចឆ្លងដែនចូលមកធ្វើការដោយខុសច្បាប់ ហើយគ្មានឯកសារអ្វីទាំងអស់នោះ គឺមិនអាចបញ្ជាក់អត្តសញ្ញាណឬត្រួតសញ្ជាតិនៅក្នុងប្រទេសថៃបានទេ ត្រូវត្រឡប់ទៅស្រុកវិញហើយដំណើរការចូលមកវិញដោយស្របច្បាប់គឺតាមប្រព័ន្ធ MOU

-ចំណែកពលករដែលហៅថា ពលករស្របច្បាប់ពេញលេញ100%នោះ គឺពលករដែលចូលមកធ្វើការតាមប្រព័ន្ធMOU។ ដកស្រង់ពីហ្វេសប៊ុក :Heng Hoeurn ហៅកម្មករឆ្លងដែន

## ថៃទុកពេល៣ទៅ៦ខែទៀត ឲ្យកម្ពុជា ផ្តល់ភាពស្របច្បាប់ ដល់ពលករខ្មែរ គ្រប់ៗគ្នា

https://www.dap-news.com ថ្ងៃច័ន្ទ, ២៥ ធ្នូ ២០១៧ 10:40 ដោយ: អេង ប៊ូឆេង ID:013

ភ្នំពេញ ៖ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក អ៊ិត សំហេង បានឲ្យដឹងថា ថៃនឹងពន្យាពេល ៣ខែទៅ ៦ខែទៀត រហូតដល់កម្ពុជា បានផ្តល់ភាពស្របច្បាប់ ដល់ពលករកម្ពុជាគ្រប់ៗគ្នា និងអនុញ្ញាតឲ្យពលករកម្ពុជា ដែលកាន់ប័ណ្ណស៊ីជម្ពូ និងលិខិតបញ្ជាក់ទំនាក់ទំនង រវាងនិយោជក និងពលករ។

សូមរំលឹកថា លោក អ៊ិត សំហេង នាពេលថ្មីៗនេះ បានដឹកនាំប្រតិភូកម្ពុជា ទៅបំពេញទស្សនកិច្ចផ្លូវការ នៅប្រទេសថៃ ដើម្បីជួបប្រជុំជាមួយ លោក អាឌុប សាំងស៊ីងកែវ រដ្ឋមន្ត្រីក្រសួងការងារថៃ និងបានចុះទៅពិនិត្យមណ្ឌលផ្តល់សេវារបស់ក្រុមការងារកម្ពុជា នៅទីក្រុងបាងកក និងខេត្តរ៉ាក់យ៉ង ។

យោងតាមសេចក្តីប្រកាសព័ត៌មាន របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានឲ្យដឹងថា ភាគីថៃនឹងពន្យាពេលពី ៣ខែ ទៅ៦ខែទៀត រហូតដល់ភាគីកម្ពុជា បានផ្តល់ភាពស្របច្បាប់ ដល់ពលករកម្ពុជាគ្រប់ៗគ្នា និងអនុញ្ញាតឲ្យពលករកម្ពុជា ដែលកាន់ប័ណ្ណស៊ីជម្ពូ និងលិខិតបញ្ជាក់ទំនាក់ទំនង រវាងនិយោជក និងពលករ ធ្វើការស្នើសុំលិខិតអនុញ្ញាត ធ្វើដំណើរទៅមក កម្ពុជា-ថៃ ពីមន្ទីរការងារនៅតាមបណ្តាថៃ ដោយមិនមានបង់កម្រៃសេវាដើម្បីទៅធ្វើ លិខិតឆ្លងដែន លិខិតធ្វើដំណើរ(TD) និងប័ណ្ណពលករកម្ពុជា ធ្វើការនៅបរទេស(OCWC) ឬឯកសារពាក់ព័ន្ធពីអាជ្ញាធរកម្ពុជា។

កម្ពុជា-ថៃ បង្កើតក្រុមការងារផ្តល់ទិដ្ឋាការស្នាក់នៅ និងប័ណ្ណការងារ នៅជិតក្រុមការងារកម្ពុជា និងបង្កើនក្រុមការងារអន្តរក្រសួង បន្ថែមទៀត និងបង្កើតឲ្យមានក្រុមចល័ត តាមសំណើររបស់ភាគីថៃ ដើម្បីធ្វើ TD និងOCWC បានកាន់តែលឿន។ កម្ពុជា-ថៃ បានវាយតម្លៃ កិច្ចសហប្រតិបត្តិការកាន់តែល្អប្រសើរ ក្នុងការដោះស្រាយបញ្ហាពលករ កម្ពុជាបានធ្វើលិខិតធ្វើដំណើរ TD ប័ណ្ណ OCWC ដែលបានផ្តល់ជូនពលកររួចហើយ ចំនួនជាង១៧ម៉ឺននាក់។ នៅសល់ប្រហែល ៤២ម៉ឺននាក់ទៀត ក្នុងនោះ ១៤ម៉ឺននាក់ បានធ្វើរួចហើយត្រូវបន្តចែកជូន និងពលករ ដែលមានប័ណ្ណស៊ីជម្ពូ និង លិខិតចុះបញ្ជីថ្មី ២៨ម៉ឺននាក់។ កម្ពុជា-ថៃ ខិតខំបន្ថែមទៀត ដោយបន្តកិច្ចសហប្រតិបត្តិការ និងទាមទារពេលវេលា បន្ថែមទៀត៣ខែទៅ៦ខែ។ ភាគីទាំង២ ធានាសុវត្ថិភាពជូនពលករកម្ពុជា គ្រប់ប្រភេទ ដែលកំពុងធ្វើការនៅប្រទេសថៃ។ កម្ពុជា-ថៃ បន្តអនុវត្តMOU បង្កើតក្រុមការងារបច្ចេកទេស នៃក្រសួងទាំងពីរ ដើម្បីបង្កើតប្រព័ន្ធ(IT) បញ្ជូនពលករកម្ពុជា មកធ្វើការនៅប្រទេសថៃ តាមMOU ដើម្បីកាត់បន្ថយពេលវេលា និងការចំណាយ។ បន្តកិច្ចសហការ ទទួលស្គាល់ជំនាញវិស័យសំណង់ និងវិស័យផ្សេងៗទៀត ដែលពលករកំពុងធ្វើការ និងមានជំនាញស្រាប់។

កម្ពុជា-ថៃបន្តផ្តល់កិច្ចគាំពារសង្គម របបសន្តិសុខសង្គម ផ្នែកគ្រោះថ្នាក់ការងារ ផ្នែកថែទាំសុខភាព ធានារ៉ាប់រងជីវិត និងបន្តសហការ អនុវត្តរបបសោធននិវត្តន៍ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចពលករខុសច្បាប់, ការទប់ស្កាត់មេខ្យល់ជួញដូមនុស្សខុសច្បាប់ , ការអនុវត្តMOU ទាំង២ ដែលមានស្រាប់។ ជាមួយគ្នានេះដែរ លោក អ៊ិត សំហេង ក៏បានអញ្ជើញ រដ្ឋមន្ត្រីក្រសួងការងារថៃ និងក្រុមការងារ បច្ចេកទេសមកទស្សនកិច្ចនៅកម្ពុជា នៅខែមិនា ឆ្នាំ២០១៨ ខាងមុខ៕

## ពលករខ្មែរនៅប្រទេសកូរ៉េ ផ្ញើលុយមកស្រុកកំណើតមិនតិចជាង៣០០លានដុល្លារក្នុងមួយឆ្នាំៗ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៧ ម៉ោង ១៥:០២ ចន ណារិទ្ធ

រាជធានីភ្នំពេញ ៖ មន្ត្រីស្ថានទូតកម្ពុជាប្រចាំនៅប្រទេសកូរ៉េខាងត្បូង បានអះអាងថា ពលករខ្មែរដែលទៅធ្វើការងារនៅសាធារណរដ្ឋកូរ៉េប្រមាណ៥ម៉ឺននាក់ ដែលបានផ្ញើលុយមកស្រុកកំណើត មិនតិចជាង៣០០លានដុល្លារក្នុងមួយឆ្នាំៗ ។

លោក ឡុង ឌីម៉ង់ ឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសកូរ៉េខាងត្បូង បានឲ្យដឹងថា ពលករខ្មែរដែលទៅធ្វើការងារស្របច្បាប់នៅសាធារណរដ្ឋកូរ៉េ មានប្រមាណជាង៥ម៉ឺននាក់ និងពលករខ្មែរដែលទៅធ្វើការងារមិនស្របច្បាប់មានប្រមាណ៥ភាគរយ ហើយចំនួនពលករខ្មែរមិនស្របច្បាប់នេះបាននឹងកំពុងថយចុះជាបន្តបន្ទាប់ផងដែរ ។ លោកបន្តថា ទាំងពលករខ្មែរស្របច្បាប់ និងមិនស្របច្បាប់ ពួកគាត់ទទួលបានប្រាក់ខែយ៉ាងតិច ១,២០០ដុល្លារ ក្នុង១ខែ ហើយពួកគាត់តែងតែផ្ញើប្រាក់ទាំងនេះមកស្រុកកំណើតវិញ ក្នុងម្នាក់ៗមិនតិចជាង៨០០ទៅ១,០០០ដុល្លារឡើយ ហើយបើគិតពីទូរលេខនេះ ចំនួនទឹកប្រាក់ដែលពលករខ្មែរត្រូវផ្ញើមកស្រុកកំណើត មានប្រមាណជាង៣០០លានដុល្លារក្នុងមួយឆ្នាំ ។

គួរកត់សម្គាល់ថា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គេបានសង្កេតឃើញទាំងមន្ត្រីស្ថានទូតកម្ពុជាប្រចាំនៅប្រទេសកូរ៉េខាងត្បូង និងពលករខ្មែរដែលបម្រើការងារទីនោះហាក់មានការរាក់ទាក់ស្និទ្ធស្នាលជាមួយគ្នាយ៉ាងខ្លាំង តាមរយៈការយកចិត្តទុកដាក់ពីលោក ឡុង ឌីម៉ង់ ជាអគ្គរាជទូត ដូចជាការដោះស្រាយបញ្ហាផ្សេងៗជូនពលករពេលដែលពួកគាត់ជួបបញ្ហា ការបង្កើតឲ្យមានការពិនិត្យសុខភាពពលករ ការចុះសួរសុខទុក្ខការជួបជុំគ្នាហូបបាយសាមគ្គី រួមទាំងការប្រារព្ធពិធីជាប្រពៃណីជាតិជាដើម ៕

## ជប៉ុនត្រូវការ កម្មសិក្សាកម្ពុជា ទៅរៀនបន្តនៅជប៉ុន និងអនុញ្ញាតឲ្យ ធ្វើការងារបណ្តើរៗ

https://www.dap-news.com/kh/ ថ្ងៃច័ន្ទ, ២៥ ធ្នូ ២០១៧ 13:37 ដោយ: ស សំណាង ID:014

ភ្នំពេញ៖សភាពាណិជ្ជកម្មជប៉ុន ត្រូវការកម្មសិក្សាពីកម្ពុជា ទៅបន្តការសិក្សា នៅប្រទេសជប៉ុន ក្នុងខេត្តហ៊ីរ៉ូស៊ីម៉ា ក្នុងនោះក៏មានការអនុញ្ញាត ឲ្យធ្វើការងារជាបណ្តើរៗផងដែរ។ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក អ៊ិត សំហេង បានឲ្យដឹងក្រោយជំនួប ពិភាក្សាជាមួយលោក Hibino Ryotaro ប្រធានសភាពាណិជ្ជកម្ម ក្នុងក្រុងហ៊ីណូយ៉ាម៉ា ខេត្តហ៊ីរ៉ូស៊ីម៉ា នៅព្រឹកថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ថា គោលបំណងនៃជំនួប ចង់លើកទឹកចិត្តដល់កម្ពុជា ក្នុងការបញ្ជូននិស្សិតកម្ពុជា ទៅធ្វើការសិក្សានៅក្នុងទីក្រុងហ៊ីណូយ៉ាម៉ា ថ្នាក់ឧត្តមសិក្សា និងកម្រិតខ្ពស់ជាងនេះ។ និស្សិតដែលទៅរៀន មានឱកាសធ្វើការងារ ពេលសម្រាក់ពីការសិក្សា ដោយក្នុងមួយខែអាចធ្វើបាន២៨ម៉ោង ដោយទទួលបានថវិកា ជិត១ពាន់ដុល្លារ សម្រាប់ធ្វើការផ្គត់ផ្គង់ការសិក្សា។ លោកថា ក្នុងនោះ សភាពាណិជ្ជកម្ម ជប៉ុនចង់បានកម្លាំង ធ្វើការនៅតាមបណ្តារោងចក្រនានា ។ កម្មសិក្សាដែលត្រូវបញ្ជូន ទៅសិក្សានៅជប៉ុនត្រូវឆ្លងកាត់ ការសិក្សា ភាសាជប៉ុន ទើបអាចដាក់ពាក្យបន្តការសិក្សាបាន។ ការសិក្សានៅទីនោះ មានជំនាញច្រើន ដូចជាឧស្សាហកម្ម កសិកម្ម ....។

យ៉ាងណាក្ដីលោករដ្ឋមន្ត្រី មិនបានឲ្យដឹងថា ចំនួនកម្មសិក្សាដែលជប៉ុនចង់បាននោះ មានចំនួនប៉ុន្មាននោះទេ។ ប៉ុន្តែបើតាមលោក Hibino Ryotaro ខាងលោក ជ្រើសរើស យកកម្មសិក្សាទៅជប៉ុន នឹងចាប់ផ្ដើមនៅឆ្នាំ២០១៨ ខាងមុខ ហើយការជ្រើ សរើសមាន២ដងក្នុង១ឆ្នាំ គឺនៅខែមេសា និង មិថុនា ។ លោកបន្តទៀតថា ការជ្រើសរើសកម្មសិក្សាម្ដង ប្រមាណ៣០រូបប៉ុណ្ណោះ ដែលសរុប ទាំង២ លើក៦០រូប ដែលអ្នកទាំងនោះ នឹត្រូវសិក្សាតាមជំនាញ ដែលខ្លួនចូលចិត្ត និងសប្បាយពីការសិក្សា អាចធ្វើការនៅតាមក្រុមហ៊ុននានា ដើម្បីយកប្រាក់សម្រាប់ ផ្គត់ផ្គង់ការសិក្សា៕

## ថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៧

## អង្គការ ILO និង IOM ៖ ពលករចំណាកស្រុកកម្ពុជារងការរំលោភសិទ្ធិនិងបញ្ហាជំងឺផ្លូវចិត្ត

http://wmc.org.kh/ ថ្ងៃចន្ទ ទី២៥ ខែធ្នូ ឆ្នាំ២០១៧ ធូ វីរៈ

ភ្នំពេញ៖អង្គការពលកម្មអន្តរជាតិ(ILO)និងអង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM) បានចេញរបាយការណ៍មួយបង្ហាញថាពលករចំណាកស្រុកខ្មែរត្រូវបានរំលោភបំពានសិទ្ធិការងារនិងទទួលរងបញ្ហាជំងឺផ្លូវចិត្តនៅពេលត្រឡប់មកស្រុកកំណើតវិញ។

ក្នុងរបាយការណ៍រួមគ្នារបស់អង្គការពលកម្មអន្តរជាតិ(ILO )និងអង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM)រកឃើញថាពលករចំណាកស្រុកខ្មែរ៨នាក់ក្នុងចំណោម១០នាក់ ត្រូវបានរំលោភបំពានសិទ្ធិការងារឬស្មើនឹង៨០ភាគរយ និង៧នាក់ក្នុងចំណោម១០នាក់មានបញ្ហាជំងឺផ្លូវចិត្តឬស្មើនឹង៦៦ភាគរយ។ ពលករខ្មែរចំណាកស្រុកទៅក្រៅប្រទេស ១,១៥លាននាក់ក្នុងនោះពលករចំណាកស្រុកទៅប្រទេសថៃមានជាង១លាននាក់។ នេះបើតាមរបាយការណ៍របស់ក្រសួងការងារបណ្ដុះបណ្ដាល វិជ្ជាជីវៈក្នុងឆ្នាំ២០១៦។ ពលករខ្មែរទៅធ្វើនៅប្រទេសក្រៅប្រទេសភាគច្រើនលើវិស័យសំណង់ កសិកម្ម នេសាទនិងជំនួយការមេផ្ទះ។

បើយោងតាមរបាយការអង្គការរួមគ្នានេះបង្ហាញថាពលករខ្មែរភាគច្រើនធ្វើការលើវិស័យសំណង់និងនេសាទទទួលរងការរំលោភសិទ្ធិការងារនិងប្រឈមនឹងបញ្ហាសុខាភាព។រីឯពលការិនីបម្រើការងារតាមផ្ទះក៏ត្រូវបានរំលោភសិទ្ធិការងារនិងជួបប្រទះបញ្ហាជំងឺផ្លូវចិត្តធ្ងន់ធ្ងរ។ ជាក់ស្ដែងកាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៧ ពលករខ្មែរម្នាក់ធ្វើការនៅលើទូកនេសាទថៃ បានលូតពីលើទូកនេសាហែលឆ្ពោះមកឆ្នេរត្រូវបានកងទ័ពជើងទឹកប្រទេសព្រុយណេជួយសង្គ្រោះនិងអន្តរាគមពីអាជ្ញាធរខ្មែរឲ្យត្រឡប់មកភូមិកំណើតវិញស្ថិតនៅខេត្តសៀមរាប។

ករណីមួយទៀត កញ្ញា សូស ទ័រ ពលការិនីបម្រើការងារជាស្ត្រីជាមេផ្ទះនៅប្រទេសអារ៉ាប៊ីសាអូឌីត(Saudi Arabia)ត្រូវបានបង្ខំឲ្យធ្វើការដោយមិនទទួលបានប្រាក់កម្រៃអស់រយៈពេល១២ឆ្នាំចាប់តាំងពីឆ្នាំ២០០៥។នាងត្រូវបានជួយសង្គ្រោះនៅអំឡុងខែកញ្ញាឆ្នាំ២០១៧នេះ។

លោកស្រី ធន សុគន្ធា ប្រធានផ្នែកស្ត្រីនិងកុមាររបស់សមាគមអាដហុកយល់ស្រប់ជាមួយរបាយការណ៍អង្គការពលកម្មអន្តរជាតិ(ILO)និងអង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM)ថាពលករចំណាកស្រុកខ្មែរត្រូវបានរំលោភបំពានសិទ្ធិការងារនិងទទួលរងបញ្ហាជំងឺផ្លូវចិត្ត។ លោកស្រី ធន សុគន្ធា ឲ្យដឹងថាតាមរយៈពាក្យបណ្ដឹងពីសាច់ញាត្តិជនរងគ្រោះឬជនរងគ្រោះផ្ទាល់បង្ហាញថាស្ត្រីបម្រើការងារជាមេផ្ទះនៅប្រទេសម៉ាឡេស៊ីភាគច្រើនទទួលរងធ្ងន់ធ្ងរបញ្ហាជំងឺផ្លូវចិត្ត។ លោកស្រីបញ្ជាក់ថាមូលហេតុនាំឲ្យមានបញ្ហាផ្លូវចិត្តដោយសារពលការិនីត្រូវបានថៅកែបង្ខំឲ្យធ្វើការហួសកម្លាំង របបអាហារមិនគ្រប់គ្រាន់ និងការមិនផ្ដល់ប្រាក់កម្រៃឬបិទសិទ្ធិមិនឲ្យទាក់ទងមកសាច់ញាត្តិជាដើម។*«ចំពោះបញ្ហាផ្លូវចិត្តដោយសារគាត់ធ្វើការច្រើនហួសកម្លាំង របបអាហាររបស់គាត់មិនគ្រប់ហើយអ្នកខ្លះរហូតដល់ការធ្វើការច្រើនមិនបានទទួលប្រាក់បៀវត្សដូចអ្វីដែលមានចុះក្នុងកិច្ចសន្យា ហើយថែមទាំងបិទសិទ្ធិសេរីភាពមិនគាត់ទំនាក់*

*ទំនងជាមួយក្រុមគ្រួសាររបស់គាត់ធ្វើឲ្យបញ្ហាផ្លូវចិត្តបានន័យជាជំងឺបាក់ទឹកចិត្ត។»* លោកស្រី សុគន្ធា បញ្ជាក់ថា ករណីថ្មីៗនេះពលការិនីបានជួយសង្គ្រោះពីតំបន់អារ៉ាមមានរងស្នាមរបួសលើរូបរាងកាយនិងជំងឺសើស្បែកកន្ទួលរមាស់និងករណីខ្លះទៀតពលការិនីបង្ខំឲ្យធ្វើការហួសកម្លាំងរហូតធ្លាក់ខ្លួនឈឺជាដើម។

ជាមួយគ្នានេះ លោក ឌីថេហូយ៉ា មន្ត្រីកម្មវិធីផ្នែកសិទ្ធិពលករចំណាកស្រុកនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្សហៅកាត់ថាសង់ត្រាល់ទទួលស្គាល់ថាពលករខ្មែរភាគច្រើនធ្វើការលើវិស័យសំណង់ និងនេសាទរងការរំលោភសិទ្ធិការងារដោយការកេងប្រវ័ញ្ចកម្លាំងពលកម្មនិងរំលោភកិច្ចសន្យាការងារជាដើម។ ប៉ុន្តែលោកសង្កេតឃើញថាពលករបម្រើការងារលើវិស័យសំណង់ និងទូកនេសាទភាគច្រើនចំណាកស្រុកដោយខុសច្បាប់តាមរយៈពលមេខ្យល់។*«ទីមួយអ្នកធ្វើការនៅផ្នែកនេសាទគាត់ប្រឈមពីការជួញដូរនិងការកេងប្រវ័ញ្ចការងារ។ទីពីរវិស័យសំណង់ភាគច្រើនមិនមានពលករណាដែលគាត់ទៅតាមរយៈក្រុមហ៊ុនស្របច្បាប់ទេ ច្រើនតែពលករឆ្លងដែនមិនមានឯកសារគេចូលចិត្តជួលពួកគាត់ធ្វើការផ្នែកហ្នឹង។បើអ្នកទៅតាមស្រប់ច្បាប់ពួកគេមិនធ្វើទេ។»*

លោកស្រី ធន សុគន្ធា ប្រធានផ្នែកស្ត្រីនិងកុមាររបស់សមាគមអាដហុកបានអំពាវនាវដល់ទីភ្នាក់ងារឬក្រុមហ៊ុននាំពលករធ្វើការងារនៅក្រៅប្រទេសត្រូវចិត្តទុកដាក់តាមដានចំពោះពលករដែលបមពេញការងារនៅបរទេសដើម្បីទប់ស្កាត់ការរំលោភបំពានសិទ្ធិនិងអំពើហិង្សា។

លោក ឌីថេហូយ៉ា មន្ត្រីកម្មវិធីផ្នែកសិទ្ធិពលករចំណាកស្រុករបស់អង្គការសង់ត្រាល់ក៏អំពាវដល់អាជ្ញាធរកម្ពុជាជួយពន្លឿនភាពស្របច្បាប់ចំពោះពលករខ្មែរមិនទាន់ស្រប់ច្បាប់ឲ្យបានឆាប់ក្នុងការទប់ស្កាត់ការកេងប្រវ័ញ្ចកម្លាំងពលកម្មនិងរំលោភសិទ្ធិការងារ។

បើតាមរបាយការណ៍អង្គការ ILO និងអង្គកា IOM រកឃើញថាប្រហែល១ភាគ៣នៃពលករអន្តោប្រវេសន៍ជិត ២០០០នាក់ ដែលបានស្ទង់មតិមាន៣២ភាគរយបានជួបប្រទះបញ្ហាផ្លូវចិត្ត បញ្ហាសង្គមនិងបញ្ហាសុខភាពនៅពេលពួកគេត្រឡប់មកស្រុកកំណើតវិញ និងពលករចំណាកស្រុកក្នុងចំណោមបណ្ដាប្រទេសជាសមាជិកអាស៊ាន មានអារម្មណ៍ធុនទ្រាន់ខ្លាំង២៣ភាគរយនិងការថប់អារម្មណ៍ ធ្លាក់ទឹកចិត្តមាន១៨ភាគរយនិងម្នាក់ក្នុងចំណោម១០នាក់ត្រូវបានគេមាក់ងាយ៕

## ថៃពិចារណាពន្យារពេលធ្វើលិខិតបញ្ជាក់សម្រាប់ពលករចំណាកស្រុកខុសច្បាប់

http://www.rfa.org/khmer/ ដោយ មាន ឫទ្ធិ 2017-12-25

រដ្ឋមន្ត្រីក្រសួងការងារថៃ គ្រោងនឹងស្នើគណៈរដ្ឋមន្ត្រីរបស់ខ្លួន ឲ្យពន្យារពេលកាលបរិច្ឆេទបិទបញ្ចប់ ការធ្វើលិខិតបញ្ជាក់សញ្ជាតិ រួមមានលិខិតឆ្លងដែន ឬលិខិតធ្វើដំណើរ និងប័ណ្ណពលករ ដល់ពលករចំណាកស្រុកខុសច្បាប់ទាំងអស់ សម្រាប់រយៈពេល ៦ខែបន្ថែមទៀត ដើម្បីអនុញ្ញាតឲ្យពួកគេមានពេលវេលាគ្រប់គ្រាន់ធ្វើឯកសារទាំងនេះ។ កាសែតបាងកកប៉ុស្តិ៍ កាលពីថ្ងៃទី២៤ ធ្នូ បានស្រង់ប្រសាសន៍រដ្ឋមន្ត្រីការងារថៃ ឧត្តមសេនីយ៍ អាឌុល សាំងសឹងកែវ (Adul Sangsingkeo) ថា រយៈពេលនៃការផ្ដល់លិខិតបញ្ជាក់សញ្ជាតិ ចាំបាច់ត្រូវតែមានការប្រែប្រួល។ ក្រសួងការងារថៃ រំពឹងថា បច្ចុប្បន្នមានពលករខុសច្បាប់ជាង ១លាននាក់ទៀត កំពុងនៅរង់ចាំដំណើរការចេញលិខិតបញ្ជាក់សញ្ជាតិនេះ។ ក្នុងចំណោមពលករទាំងនេះ មានពលករចំណាកស្រុកខ្មែរ ចំនួន៤សែន ៥ម៉ឺននាក់ (៤៥០.០០០) ពលករចំណាកស្រុកមីយ៉ាន់ម៉ា ឬភូមាចំនួន ៣សែន ៦ម៉ឺននាក់ (៣៦០.០០០) និង ពលករចំណាកស្រុកឡាវចំនួន ១សែន៤ម៉ឺននាក់ (១៤០.០០០)។

ឯកសារបញ្ជាក់សញ្ជាតិ គឺជាឯកសារចាំបាច់ អនុញ្ញាតឲ្យពលករចំណាកស្រុក យកទៅប្រើប្រាស់ដើម្បីដាក់ពាក្យសុំទិដ្ឋាការធ្វើការ ឬលិខិតអនុញ្ញាតឲ្យធ្វើការក្នុងប្រទេសថៃ ដែលជាផ្នែកមួយនៃគោលនយោបាយរបស់ប្រទេស

ថៃ ក្នុងការកាត់បន្ថយចំនួនពលករចំណាកស្រុកខុសច្បាប់ និងធ្វើឲ្យមានប្រសិទ្ធភាពឡើងវិញ ចំពោះប្រព័ន្ធផ្ដល់ឯកសារដល់ពលករចំណាកស្រុក ក៏ដូចជាបង្ការអំពើជួញដូរមនុស្សខុសច្បាប់ ដែលអាចប៉ះពាល់ដល់រូបភាពរបស់ប្រទេសនេះ។

ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈកម្ពុជា កាលពីថ្ងៃទី២២ ធ្នូ ឲ្យដឹងថា កម្ពុជាបានធ្វើលិខិតឆ្លងដែន ឬលិខិតធ្វើដំណើរ និងប័ណ្ណពលករកម្ពុជាធ្វើការនៅបរទេស ដល់ពលករខ្មែរនៅប្រទេសថៃ បានជាង ១៧ម៉ឺននាក់រួចរាល់ហើយ ហើយនៅសល់ ៤២ម៉ឺននាក់ទៀត មិនទាន់ធ្វើរួច។ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ឲ្យដឹងទៀតថា ភាគីថៃនឹងពន្យារពេល ពី៣ ទៅ៦ខែទៀត រហូតដល់ភាគីកម្ពុជា បានផ្ដល់ភាពស្របច្បាប់ដល់ពលករចំណាកស្រុកកម្ពុជា គ្រប់ៗគ្នា៕

## ពលករខ្មែរប្រមាណជាង៤០ម៉ឺននាក់នឹងទទួលបានភាពស្របច្បាប់រស់នៅនិងធ្វើការនៅថៃ

http://bayontv.com.kh/ ប្រភព BTV 25/12/2017

ភ្នំពេញ៖ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈនៅព្រឹកថ្ងៃច័ន្ទនេះបានបញ្ជាក់ថា ពលករខ្មែរដែលកំពុងធ្វើការនៅប្រទេសថៃបច្ចុប្បន្នមានជាង៤០ម៉ឺននាក់ នឹងទទួលបានភាពស្របច្បាប់ក្នុងការរស់នៅ និងធ្វើការនៅក្នុងប្រទេសថៃ។

មានប្រសាសន៍ប្រាប់ក្រុមអ្នកសារព័ត៌មានក្រោយជំនួបពិភាក្សាការងារជាមួយភាគីជប៉ុន នៅព្រឹកថ្ងៃ ទី២៥ ខែធ្នូ ឆ្នាំ២០១៧នេះ ឯកឧត្ដមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួង ការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានបញ្ជាក់ថា យើងនៅត្រូវការពេលវេលាប្រមាណពី៣ ទៅ៦ខែទៀត ដើម្បីធ្វើយ៉ាងណាឲ្យពលករខ្មែរ ទាំងនោះមានលិខិតត្រឹមត្រូវទៅតាមច្បាប់កំណត់ ប៉ុន្តែទោះបីជាយ៉ាងណាភាគីប្រទេសទាំងពីរបានសន្យា ថានឹងធានាសុវត្ថិភាពជូនបងប្អូនខ្មែរនៅទីនោះ។ ឯកឧត្ដមរដ្ឋមន្ត្រីលើកឡើងបន្តថា អ្វីដែលបានធ្វើនាពេលកន្លងមកគឺជាជោគជ័យក្នុងមួយជំហ៊ានដំបូង ហើយអ្វីដែលសំខាន់ និងជោគជ័យទីមួយគឺទាក់ទងនឹងគុណភាពនៃសេវាបានន័យថា ផ្ដល់តែក្នុងរយៈពេលមួយថ្ងៃទាំងលិខិតធ្វើដំណើរ ប័ណ្ណការងារ ទិដ្ឋការស្នាក់នៅ។ ទិដ្ឋការធ្វើការងារពលករចំណាយ ពេលតែមួយថ្ងៃគឺទទួលបានទាំងអស់ ដែលក្លាយពីមិនស្របច្បាប់ទៅស្របច្បាប់ ប៉ុន្តែល្បឿនក្រុមការងារ ក្នុងបីមណ្ឌលនៅថៃ រួមមាននៅបាងកក រ៉ាក់យ៉ង និងខេត្តសុងក្លា អាចធ្វើបានប្រមាណ១.៨០០នាក់ប៉ុណ្ណោះ។ ទាក់ទិននឹងបញ្ហានេះភាគីកម្ពុជាបានស្នើសុំឲ្យភាគីថៃជួយជំរុញផ្សព្វផ្សាយបន្ថែមទៀតដល់ពលករកម្ពុជា ដើម្បីឲ្យពួកគេមកបញ្ជាក់អត្តសញ្ញាណជាមួយភាគីកម្ពុជា ដើម្បីទទួលបានភាពស្របច្បាប់នេះផងដែរ៕

## សេចក្ដីជូនដំណឹងស្ដីពីការឈប់សម្រាករបស់ក្រុមការងារបញ្ជាក់អត្តសញ្ញាណ (ផ្ទៀងផ្ទាត់សញ្ជាតិ) ក្នុងឱកាសបុណ្យចូលឆ្នាំសាកលខាងមុខនេះ

Royal Embassy of Cambodia in Bangkok December/ 22/ 2017 at 1:45pm •

គណៈកម្មការផ្ដល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមជម្រាបជូនដំណឹងដល់សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ឱ្យបានជ្រាបថា នាឱកាសបុណ្យចូលឆ្នាំសាកល ក្រុមការងារបើកផ្ដល់លិខិតឆ្លងដែន(PP) លិខិតធ្វើដំណើរ(TD) និងប័ណ្ណពលករទៅធ្វើការនៅបរទេស(OCWC) នៃលេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រចាំស្ថានទូតកម្ពុជានៅទីក្រុងបាងកក និងក្រុម

ការងារអន្តរក្រសួងចល័តនៅទីក្រុងបាងកក និងខេត្តរ៉ាក់យ៉ង នឹងឈប់សម្រាកចំនួន ៤ថ្ងៃ គឺចាប់ពីថ្ងៃទី១៣កើត ខែបុស្ស ឆ្នាំរកា នព្វស័កព.ស២៥៦១ ដល់ថ្ងៃ១រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី៣០ ខែធ្នូ គ.ស២០១៧ ដល់ថ្ងៃទី២ ខែមករា គ.ស ២០១៨ ។

ដោយឡែក ក្រុមការងារអន្តរក្រសួងចល័តនៅខេត្តសុងក្លា នឹងឈប់សម្រាកចំនួន ៥ថ្ងៃ រហូតដល់ថ្ងៃទី៣ ខែមករា គ.ស ២០១៨ ។ សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ជ្រាបជាព័ត៌មាន។

## ដំណឹងល្អសម្រាប់បងប្អូនពលករកម្ពុជាដែលបញ្ជាក់អត្តសញ្ញាណរួចហើយ នៅការិយាល័យ Big C Ladphrao

Royal Embassy of Cambodia in Bangkok December/ 21/12/ at 5:28pm •

គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមជម្រាបជូនដំណឹងដល់សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ឱ្យបានជ្រាបថា បងប្អូនពលករកម្ពុជាដែលបានមកបញ្ជាក់អត្តសញ្ញាណ ជាមួយក្រុមការងារអន្តរក្រសួងចល័តនៅការិយាល័យទីក្រុងបាងកក អាចទៅស្នើសុំបន្តទិដ្ឋាការស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃ នៅការិយាល័យប៉ូលីសអន្តោសប្រវេសន៍ថៃ នៅក្នុងផ្សារប៊ីកស៊ីឡាតប្រាវ (Big C Ladphrao) ជាន់ទី៥ នៅទីក្រុងបាងកក ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។ អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ពិសេសបងប្អូនពលករ ជ្រាបជាព័ត៌មាន។

## ការស្នើសុំឯកសាររបស់ពលករនៅថៃ អាចត្រូវពន្យារពេល

http://www.postkhmer.com/ Tue, 26 December 2017 យន់ ស៊ីនាត

**ភ្នំពេញៈ** កាលបរិច្ឆេទផុតកំណត់សម្រាប់ពលករចំណាកស្រុកគ្មានឯកសារ ក្នុងប្រទេសថៃក្នុងការស្នើសុំភាពស្របច្បាប់នឹងទំនងជាត្រូវពន្យារពេលពី ៣ ទៅ ៦ ខែទៀត ខណៈវានឹងផុតកំណត់ក្នុងរយៈពេល ៥ ថ្ងៃទៀត។ នេះបើយោងតាមរដ្ឋមន្ត្រីក្រសួងការងារកម្ពុជា លោក អ៊ិត សំហេង។ បន្ទាប់ពីកិច្ចប្រជុំមួយរវាងរដ្ឋមន្ត្រីក្រសួងការងារ និងលោក Hibino Ryotaro ប្រធានសភាពាណិជ្ជកម្ម និងឧស្សាហកម្ម ក្រុងហ៊ីណូយ៉ាម៉ា ប្រទេសជប៉ុន លោក អ៊ិត សំហេង បានប្រាប់អ្នកសារព័ត៌មានថាលោកបានជួបជាមួយក្រសួងការងារថៃកាលពីចុងសប្តាហ៍មុនដែលបានឯកភាពគ្នាថាការពន្យារពេលនេះគឺមានលក្ខណៈចាំបាច់ដើម្បីសម្រួលដល់ដំណើរការធ្វើឲ្យមានលក្ខណៈស្របច្បាប់។

កាលពីខែមិថុនាព្រះរាជក្រឹត្យរបស់ថៃបានដាក់ការផាកពិន័យរហូតដល់ ៣០០០ ដុល្លារចំពោះកម្មករគ្មានឯកសារ និងការផាកពិន័យធ្ងន់ធ្ងរ ចំពោះមេខ្យល់ និងនិយោជក។ ពលករចំណាកស្រុកក៏អាចប្រឈមមុខនឹងការជាប់ពន្ធនាគាររហូតដល់ ៥ ឆ្នាំផងដែរទើបធ្វើឲ្យពលកររាប់ពាន់នាក់ត្រឡប់ទៅប្រទេសរបស់ពួកគេវិញ។ បន្ទាប់ពីមានការរិះគន់ពីភាគីពាក់ព័ន្ធរដ្ឋាភិបាលថៃបានអនុវត្តរហូតដល់ថ្ងៃទី ៣១ ខែធ្នូហើយឥឡូវនេះទំនងជានឹងពន្យារពេលបន្តទៀតបន្ទាប់ពីនេះ។

លោក អ៊ិត សំហេង បានថ្លែងថា ក្រសួងការងារកម្ពុជាបានចាប់ផ្តើមសម្របសម្រួលការងារធ្វើឲ្យស្របច្បាប់ក្នុងប្រទេសថៃនៅ «ចុងត្រីមាសទី ៣» នៃឆ្នាំនេះ ហើយប្រជាពលរដ្ឋកម្ពុជាជាង ៤២ ម៉ឺននាក់នៅកំពុងរង់ចាំការធ្វើឲ្យមានលក្ខណៈស្របច្បាប់។ លោកបន្តថាៈ «មីយ៉ាន់ម៉ា និងឡាវកំពុងមានបញ្ហា»។ «[រដ្ឋាភិបាលថៃ] នឹងពិភាក្សា... ដើម្បីពន្យារពេល ៣ ខែទៅ ៦ ខែរហូតទាល់តែយើងបានធ្វើឲ្យពលករទាំងអស់របស់យើងមានលក្ខណៈស្របច្បាប់»។

មន្ត្រីម្នាក់នៃរដ្ឋបាលពលករបរទេសរបស់ក្រសួងការងារថៃ ដែលសុំមិនបញ្ចេញឈ្មោះដោយសារមិនត្រូវបានអនុញ្ញាតឲ្យនិយាយជាមួយសារព័ត៌មានបានថ្លែងថា ទីស្ដីការគណៈរដ្ឋមន្ត្រីរបស់ថៃនឹងជួបប្រជុំនៅថ្ងៃនេះដើម្បីពិភាក្សាអំពីការពន្យារពេលនេះហើយការប្រកាសជាផ្លូវការនឹងធ្វើឡើងបន្ទាប់ពីនោះ។ មន្ត្រីរូបនេះបន្តថា៖ «ការប្រកាសនេះនឹងមិនយឺតជាងចុងឆ្នាំនេះទេ»។ កាសែតបាងកកប៉ុស្ដិ៍បានរាយការណ៍ថារដ្ឋមន្ត្រីក្រសួងការងារថៃលោក Adul Sang-singkeo នឹងសុំឲ្យទីស្ដីការគណៈរដ្ឋមន្ត្រីពន្យារពេលកាលបរិច្ឆេទផុតកំណត់រហូតដល់ចុងខែមិថុនាឆ្នាំក្រោយ។

លោក វុធ វុយ អាយុ ២៤ ឆ្នាំជាពលករចំណាកស្រុកកម្ពុជាថ្លែងថាលោកមានតែលិខិតឆ្លងដែនមួយហើយមិនទាន់ត្រូវបានធ្វើឲ្យស្របច្បាប់ទាំងស្រុងនៅឡើយទេ។ «ប៉ុន្តែខ្ញុំមិនបារម្ភខ្លាំងអំពីឯកសារច្បាប់នោះទេព្រោះខ្ញុំរស់នៅថៃអស់រយៈពេលជាច្រើនឆ្នាំមកហើយ ដូច្នេះវាងាយស្រួលសម្រាប់ខ្ញុំក្នុងការគេចខ្លួននៅពេលមានការដាក់ទោសទណ្ឌចូលជាធរមាន»។ លោកបន្ថែមថាវាស្មុគស្មាញចំណាយច្រើន និងចំណាយពេលយូរដើម្បីទទួលបានភាពស្របច្បាប់។

បើតាមប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកបានឲ្យដឹងថារដ្ឋាភិបាលថៃក៏កំពុងពិចារណាកាត់បន្ថយការដាក់ទោសទណ្ឌផងដែរ ដែលក្រសួងការងារថៃមិនទាន់បានបញ្ជាក់នៅឡើយ៕ PS **រាយការណ៍បន្ថែមដោយ** Leonie Kijewski

## ដំណើរឆ្ពោះទៅរកសុវត្ថិភាព និងភាពស្របច្បាប់សម្រាប់ការធ្វើចំណាកស្រុក

http://www.postkhmer.com/ Wed, 20 December 2017

នៅក្នុងឆ្នាំ ២០១៧ តំបន់អាស៊ី និងប៉ាស៊ីហ្វិកក្លាយជាកន្លែងមួយសម្រាប់ជនអន្តោប្រវេសន៍អន្តរជាតិប្រមាណ ៦២ លាននាក់ដោយចំនួននេះគឺច្រើនជាងចំនួនប្រជាជនរបស់ប្រទេសកូរ៉េខាងត្បូងទាំងមូលទៅទៀតហើយលើសពីនេះទៀតមនុស្សច្រើនជាង ១០០ លាននាក់កំពុងរស់នៅក្រៅប្រទេសកំណើតរបស់ពួកគេ។

នៅឯកិច្ចប្រជុំគណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក យើងមើលឃើញថា នេះគឺជាឱកាសមួយដែលយើងគួរតែចាប់យកដើម្បីកំណត់អនាគតឲ្យបានប្រសើរសម្រាប់ពលករចំណាកស្រុកនៅក្នុងតំបន់របស់យើងនេះ។ មានមូលហេតុជាច្រើនដែលធ្វើឲ្យពលរដ្ឋទាំងនោះសម្រេចចិត្តធ្វើចំណាកស្រុក។

សម្រាប់និស្សិតក៏ដូចគ្នាដែរ ពួកគេធ្វើចំណាកស្រុកដោយសារតែកម្រិតសិក្សាអប់រំនៅក្នុងប្រទេសរបស់ពួកគេមិនសមស្របតាមការចង់បានរបស់ពួកគេ ដើម្បីពង្រីកការយល់ដឹង និងសម្រេចភាពជោគជ័យនាពេលអនាគតរបស់ពួកគេ ហើយជនអន្តោប្រវេសន៍មួយចំនួនទៀតគឺពួកគាត់ជាជនភៀសខ្លួន ដោយសារតែការរត់គេចចេញពីអំពើហិង្សា និងការធ្វើទុក្ខបុកម្នេញជាដើម។

នៅក្នុងតំបន់របស់យើងនេះ យើងមើលឃើញថាមានជនស៊ីវិលរាប់សិបពាន់នាក់ដែលភាគច្រើនគឺជាជនជាតិភាគតិចរ៉ូហ៊ីងយ៉ាដែលពួកគេបានរត់ភៀសខ្លួនចេញពីលំនៅឋានរបស់ពួកគេនៅក្នុងប្រទេសមីយ៉ាន់ម៉ា ដើម្បីស្វែងរកសុវត្ថិភាពនៅប្រទេសបង់ក្លាដែសជាអ្វីដែលអគ្គលេខាធិការអង្គការសហប្រជាជាតិបានពិពណ៌នាថា ជាជនភៀសខ្លួនដែលរត់ចេញក្នុងពេលដ៏ប្រថុចញ៉ុចជាការរំលោភសិទ្ធិមនុស្សដែលយើងមិនអាចទទួលយកបានឡើយ ហើយករណីដ៏អាក្រក់បែបនេះគឺត្រូវតែបញ្ចប់។

ប៉ុន្តែចំពោះពលករចំណាកស្រុកភាគច្រើនពួកគេធ្វើចំណាកស្រុក ដើម្បីស្វែងរកការងារធ្វើស្វែងរកប្រាក់ឈ្នួលដែលមានតម្លៃខ្ពស់ និងមានជីវភាពល្អប្រសើរជាងមុនសម្រាប់ខ្លួនឯង និងក្រុមគ្រួសាររបស់ពួកគេ។ គ្រាន់តែការផ្ញើរប្រាក់របស់ពួកគេទៅប្រទេសកំណើតរបស់ខ្លួនគឺមានចំនួន ២៧៦ លានដុល្លារទៅហើយនៅក្នុងតំបន់អាស៊ី និងប៉ាស៊ី

ហ្វិកក្នុងឆ្នាំ ២០១៧ នេះហើយប្រាក់ទាំងអស់នេះវាបានជួយដល់សហគមន៍នៅក្នុងប្រទេសកំណើតរបស់ពួកគេយ៉ាងច្រើន។

និយាយឱ្យស្រួលស្តាប់ប្រាក់ដែលផ្ញើមកនោះគឺយកទៅចិញ្ចឹមកុមារបង់ថ្លៃការសិក្សាថែទាំសុខភាព និងជួយឱ្យពួកគេគេចផុតពីភាពក្រីក្រ។ ប៉ុន្តែទោះបីជាពលករចំណាកស្រុកទាំងនោះផ្លាស់ប្តូរទៅធ្វើការនៅក្រៅប្រទេស ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនក្តី ក៏ពួកគេបានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រទេសដែលពួកគេកំពុងធ្វើការឲ្យនោះដែរ។ តាមរយៈការផ្លាស់ប្តូរទីកន្លែងទៅកន្លែងណាដែលមានការងារធ្វើពលករចំណាកស្រុកទាំងនោះបានជួយដល់ការបង្កើតផលិតផលថ្មី បង្កើនកំណើនផលិតភាពជាដើម។

ការចូលរួមចំណែករបស់ពលករចំណាកស្រុកគឺជាចំណុចដ៏សំខាន់ ប៉ុន្តែបញ្ហាប្រឈមដែលពួកគេជួបប្រទះក្នុងការធ្វើដំណើរទៅកាន់ប្រទេសគោលដៅ គឺជាបញ្ហាដ៏គួរឲ្យកត់សម្គាល់ដែលរួមមានការធ្វើដំណើរផ្លូវឆ្ងាយត្រូវចំណាយច្រើន និងប្រឈមនឹងគ្រោះថ្នាក់ជាដើម។ ជារឿយៗ ពលករចំណាកស្រុក ទទួលបានប្រាក់ឈ្នួលទាប ហើយមានលទ្ធភាពតិចតួចក្នុងការទទួលបានសេវាសាធារណៈ។ ជាទូទៅពួកគេមានទំនោរធ្វើការងារណាដែលមានជំនាញតិចតួចនៅក្នុងវិស័យក្រៅផ្លូវការ។ ការជំពាក់បំណុលគេដើម្បីបង់ថ្លៃសេវាខុសច្បាប់ដើម្បីទទួលបានការងារធ្វើមានន័យថាពួកគេមានជម្រើសតិចតួច ប៉ុន្តែត្រូវទទួលយកការងារប្រើកម្លាំងពលកម្មដែលប្រឈមគ្រោះថ្នាក់ខ្ពស់។

ជនចំណាកស្រុកជាស្ត្រីគឺងាយរងគ្រោះថ្នាក់ខ្លាំងណាស់។ ជាញឹកញាប់ពួកគេធ្វើការជាអ្នកបម្រើតាមផ្ទះ ហើយពួកគេងាយរងការកេងប្រវ័ញ្ច និងការរំលោភបំពាន។ បញ្ហាលាយឡំគ្នាច្រើនបែបនេះជារឿយៗបានធ្វើឲ្យពលករចំណាកស្រុកទាំងនោះក្លាយជាអ្នករងកំហុសអ្នកដ៏ទៃ និងទទួលការរើសអើងដែលវាជំរុញឱ្យមានកង្វល់យ៉ាងខ្លាំង។

ដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងអស់នេះ គឺយើងត្រូវលើកកម្ពស់សក្តានុពលរបស់ពលករចំណាកស្រុកទាំងនោះដែលវាជាកម្លាំងចលករសម្រាប់ការផ្លាស់ប្តូរជាវិជ្ជមានមួយ។ ភាពរឹងមាំនៃសេដ្ឋកិច្ចក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក និងប្រជាជនមានវ័យចំណាស់កើនឡើង គឺមានន័យថាពលករចំណាកស្រុកអាចដើរតួនាទីកាន់តែច្រើននៅក្នុងវិស័យសេដ្ឋកិច្ច និងសង្គមរបស់យើងដែលកំពុងពុះពារជាមួយនឹងកង្វះកម្លាំងពលកម្ម និងជំនាញ។ ប៉ុន្តែដើម្បីធ្វើឲ្យវាសម្រេចបានយើងត្រូវការនូវគោលនយោបាយច្បាស់លាស់ ដើម្បីការពារសិទ្ធិរបស់ពលករចំណាកស្រុកនៅកន្លែងធ្វើការរបស់ពួកគេ ដោយត្រូវបង្កើនលទ្ធភាពឲ្យពួកគេអាចទទួលបានសេវាកម្មសំខាន់ៗ ហើយជួយសម្រួលពួកគេ ឲ្យអាចជួយដល់ក្រុមគ្រួសារដែលនៅឯប្រទេសកំណើតរបស់គេបានងាយស្រួល។ ចំណុចនេះត្រូវបានទទួលស្គាល់ដោយរដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិ បន្ទាប់ពីមានវិបត្តិជនភៀសខ្លួនហូរចូលទៅកាន់តំបន់អឺរ៉ុប ហើយនៅពេលដែលមានគំនិតផ្តួចផ្តើមធ្វើការពិភាក្សាគ្នា ដើម្បីសុវត្ថិភាពរបស់ជនអន្តោប្រវេសន៍ជាសកលដោយត្រូវរៀបចំឲ្យមានសុវត្ថិភាព និងភាពស្របច្បាប់សម្រាប់ពួកគេនៅត្រឹមឆ្នាំ ២០១៨ ខាងមុខនេះ។

មហិច្ឆតានេះគឺដើម្បីការពារសិទ្ធិរបស់ជនចំណាកស្រុកដោយផ្អែកលើច្បាប់ និងការអនុវត្តដែលមានស្រាប់ និងដោយការគោរពយ៉ាងពេញលេញចំពោះអធិបតេយ្យភាពរបស់រដ្ឋសមាជិក ហើយការរួមគ្នានេះគួរតែដាក់ជាមូលដ្ឋានគ្រឹះសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីជាផលប្រយោជន៍របស់ប្រទេសដើមប្រទេសទិសដៅ និងជនចំណាកស្រុកខ្លួនឯងផ្ទាល់ផងដែរ។ ដើម្បីរៀបចំរបៀបវារៈនេះឲ្យចេញជារូបរាង គណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិកបានរៀបចំការពិគ្រោះយោបល់មួយក្នុងតំបន់ក្នុងខែវិច្ឆិកា។ រដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងវិស័យឯកជនបានជួបប្រជុំគ្នាដើម្បីកំណត់និន្នាការក្នុងតំបន់ ដើម្បីចែករំលែកនូវការអនុវត្តល្អបំផុត និងការយល់ស្របលើអាទិភាពនានាដើម្បីបញ្ចូលទៅក្នុងការចរចាជាសកល។

អាទិភាពសំខាន់ៗជាច្រើនត្រូវបានលើកឡើង ដូចជាការការពារជនអន្តោប្រវេសន៍ប្រឆាំងនឹងការកេងប្រវ័ញ្ចពីនិយោជកដែលមិនគោរពច្បាប់ ជួយសម្រួលដល់ការធ្វើចំណាកស្រុកឲ្យស្របច្បាប់ដើម្បីធានាដល់ជនចំណាកស្រុកទាំងនោះថាពួកគេអាចផ្ញើប្រាក់មកប្រទេសកំណើតរបស់ពួកគេបានឆាប់រហ័សមានសុវត្ថិភាព និងចំណាយទាបក៏ដូចជាការបង្ក្រាបករណីជួញដូរមនុស្ស និងជួយដល់ជនទាំងឡាយណាដែលត្រូវបានបង្ខំឱ្យចាកចេញដោយសារតែគ្រោះមហន្តរាយធម្មជាតិធ្ងន់ធ្ងរដែលបណ្តាលមកពីបម្រែបម្រួលអាកាសធាតុ។

មានការប្តេជ្ញាចិត្តយ៉ាងមុតមាំពីភាគីទាំងអស់ក្នុងការធ្វើកិច្ចសហប្រតិបត្តិការ ដើម្បីជំរុញរបៀបវារៈនេះឲ្យលឿនទៅមុខ។ ខ្ញុំសង្ឃឹមថាទិវាជនអន្តោប្រវេសន៍អន្តរជាតិអាចជួយបង្កើនកម្លាំងជំរុញលើកកម្ពស់ការចូលរួមចំណែកជាវិជ្ជមានដល់ពលករចំណាកស្រុកនៅក្នុងតំបន់របស់យើង និងជួយឱ្យពួកគេមានសុវត្ថិភាព និងភាពស្របច្បាប់ចំពោះពលករចំណាកស្រុកនៅទូទាំងតំបន់អាស៊ី និងប៉ាស៊ីហ្វិករបស់យើងនេះ៕ NS

## ពលករឡាវ ចំនួន 3នាក់ និងម្ចាស់ហាងថៃ 1នាក់ ត្រូវតម្រួត (តម) ថៃឃាត់ខ្លួន

http://www.pheaktraprak.com December 26, 2017

កាលពីថ្ងៃច័ន្ទទី២៥ ខែធ្នូ ឆ្នាំ២០១៧ កម្លាំងអាជ្ញាធរសមត្ថកិច្ចតម្រួតថៃ(តម៉) ប្រចាំច្រកទ្វារព្រំដែនអន្តរជាតិថៃ-ឡាវ ស្ថិតនៅក្នុងខេត្តណងខាយ ប្រទេសថៃ បានធ្វើការឃាត់ខ្លួនបុរសមេការជនជាតិថៃ១នាក់ និងពលករឡាវចំនួន៣នាក់ បន្ទាប់ពីមេការរូបកំពុងនាំពលករឡាវទាំង៣នាក់ឆ្លងដែនទៅខាងប្រទេសឡាវ។ បើយោងតាមប្រភពពីសមត្ថកិច្ចតម្រួត (តម៉) ថៃបានឲ្យដឹងថា ពលករឡាវទាំងបីនាក់បានឆ្លងដែនចូលមកស្នាក់នៅធ្វើការជាជំរកៅស៊ូជាមួយមេការជនជាតិថៃ ខាងលើអស់រយៈពេលជាង៥១ថ្ងៃមកហើយ តែនៅក្នុងឱកាសបុណ្យចូលឆ្នាំសកលនេះ ពលករឡាវទាំងអស់ចង់វិលត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនវិញ ដើម្បីធ្វើឯកសារចូលមកធ្វើការម្តងទៀតអោយបានត្រឹមត្រូវតែក៏ត្រូវសម្ថកិច្ច(តម៉)ឃាត់ខ្លួនតែម្តង។

បច្ចុប្បន្នពលករឡាវ និងមេការថៃទាំងបួននាក់ត្រូវសមត្ថកិច្ចថៃធ្វើការចោទប្រកាន់ពីបទស្នាក់នៅក្នុងប្រទេសថៃដោយគ្មានច្បាប់អនុញ្ញាតនិងកសាងសំណុំរឿងបញ្ជូនទៅតុលាការដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## ថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១៧

## នាយករដ្ឋមន្ត្រី ដាក់ចេញសារសំខាន់ៗ ៨ចំណុចឲ្យក្រសួង ពាក់ព័ន្ធអនុវត្ត ទៅលើកម្មករមានប្រសិទ្ធភាព

https://www.dap-news.com/kh/ ថ្ងៃពុធ, ២៧ ធ្នូ ២០១៧ 11:25 ដោយ: ដើមអម្ពិល ID:012

ភ្នំពេញ ៖ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានដាក់ចេញនូវសារសំខាន់ៗ ៨ចំណុចដើម្បីឲ្យក្រសួងពាក់ពន្ធ័អនុវត្តន៍ មានប្រសិទ្ធភាព ចំពោះកម្មករ-កម្មការិនី ដែល កំពុងបំរើការងារនៅក្នុងរោងចក្រ នៅទូទាំងប្រទេស ខណៈជិតដាច់ឆ្នាំចាស់ ផ្លាស់ចូលឆ្នាំថ្មី។ លក្ខខណ្ឌទាំង៨ចំណុចដែលសម្តេចដាក់ចេញក្នុងឱកាសជួបសំណេះសំណាលជាមួយកម្មករជាង ១ម៉ឺននាក់ នៅរោងចក្រតំបន់តាមបណ្តោយផ្លូវជាតិលេខ៣ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ រួមមាន៖

១- ត្រូវអនុវត្តប្រាក់ខែអប្បបរិមា ១៧០ ដុល្លារ ចាប់ពីថ្ងៃ១ ខែមករា ឆ្នាំ២០១៨ តទៅ។

២-ត្រូវអនុវត្តន៍ការចុះពិនិត្យនៅតាមមន្ទីរពេទ្យរដ្ឋ ចំពោះការពិនិត្យសុខភាព និងការព្យាបាល កម្មករ-កម្មការិនី រោងចក្រ រួមទាំងកីឡាករ- កីឡាការិនី ក្រុមប្រឹក្សាភូមិ ឃុំ ក៏ត្រូវបានអនុវត្តន៍ ដូចគ្នាជាពិសេសរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងក្រសួងការងារត្រូវធ្វើឲ្យ បានម៉ត់ចត់។

៣-ត្រូវអនុវត្តន៍ចំពោះស្ត្រីមានផ្ទៃពោះសំរាលកូននឹងទទួលបានពេលវេលាឈប់សម្រាក ពីការងាររយៈពេល៣ខែហើយ ហើយនៅទទួលបានប្រាក់ខែ ១២០% (៥០% ដោយក្រុមហ៊ុន និង៧០%ដោយបេឡាជាតិ) ក្រសួងពាក់ព័ន្ធត្រូវតាមដានការងារឲ្យបានជិតដល់។

៤-ត្រូវអនុវត្តន៍ ចំពោះកម្មការិនីសម្រាលបានកូន១ ទទួលថវិកា៤០ម៉ឺនរៀល និងពិនិត្យ ផ្ទៃពោះដោយឥតគិតថ្លៃ។ បើសម្រាលបានកូនភ្លោះ២ ទទួលបានថវិកា៨០ម៉ឺនរៀល។ បើសម្រាលបានកូន៣ ទទួលបានថវិកា១លាន២សែន រៀល ហើយបូកប្រាក់ ឧបត្ថម្ភចំនួន ៥លានរៀលទៀតពីសម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត។

៥-ត្រូវអនុវត្តន៍ ចំពោះរបប សន្តិសុខសង្គម ដោយចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ កម្មករ-កម្មការិនីមិនចាំបាច់បង់ទៀតទេ គឺម្ចាស់ក្រុមហ៊ុនជាអ្នកបង់ជំនួស ១០០%។

៦-អនុវត្តន៍តាមដានមើលបញ្ហា ទឹក ភ្លើង ត្រូវខិតខំបន្ត តទឹកតភ្លើងដល់ផ្ទះរបស់កម្មករ ដែលនៅឆ្ងាយដែលមិនទាន់ទៅដល់ឲ្យបានគ្រប់គ្រាន់ និងតំលៃផ្ទះជួល កុំឲ្យមានការ ឡើងថ្លៃក្នុងឆ្នាំ២០១៨ ពីព្រោះកន្លងមកមានកំណត់រួចរាល់ហើយ។

៧-អនុវត្តន៍ប្រាក់សោធននិវត្តន៍ចាប់ពីឆ្នាំ ២០១៩ កម្មករ នឹងទទួលបានប្រាក់ចូលនិវត្តន៍ (ប្រាក់រ៉ឺត្រែត) ដូច្នេះក្នុងរយៈពេល១ឆ្នាំ (២០១៨) ត្រូវត្រៀមរៀបចំឲ្យហើយ ដើម្បីដំណើរ ការបានល្អនៅឆ្នាំ២០១៩។

៨-អនុវត្តន៍ចូលរួមបន្តយកចិត្តទុកដាក់ និងដោះស្រាយបញ្ហាផ្សេងៗ ដែលពលករទៅក្រៅ ប្រទេស ជួយសម្រួលបែបបទលិខិតបទដ្ឋានផ្លូវច្បាប់នានា ដើម្បីទទួលបានលក្ខខណ្ឌការងារ ល្អប្រសើរ៕

## ប្រាក់ចំណូលពលករនៅក្រៅប្រទេស ២ពាន់លានដុល្លារ ចាក់ចូលសេដ្ឋកិច្ចជាតិ

https://www.dap-news.com/kh/ ថ្ងៃពុធ, ២៧ ធ្នូ ២០១៧ 12:03 ដោយ: អេង ប៊ូធេង ID:013

ភ្នំពេញ ៖ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានបញ្ជាក់ថា ពលករខ្មែរ ដែលកំពុងធ្វើការងារនៅក្រៅប្រទេស បានបញ្ជូនប្រាក់ចាក់ចូលសេដ្ឋកិច្ចកម្ពុជា ប្រមាណជាង ២ពាន់លានដុល្លារ ក្នុង១ឆ្នាំៗ ។ សម្តេចតេជោបានថ្លែង ក្នុងឱកាស អញ្ជើញជួបសួរសុខទុក្ខ កម្មករ-កម្មការិនី ចំនួន១៤,០៩៩នាក់ មកពីរោងចក្រចំនួន១៥ ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៣ ក្នុងខណ្ឌពោធិ៍សែនជ័យ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ថា កម្មករ-កម្មការិនីកម្ពុជា ដែលទៅធ្វើការងារនៅប្រទេសកូរ៉េ បានបញ្ជូនប្រាក់មកឲ្យឪពុក-ម្តាយ ពី៥០០ដុល្លារ ទៅ១០០០ដុល្លារ ក្នុង១ខែៗ ។ សម្តេចតេជោបន្តថា "ការពង្រឹងទីផ្សារការងាររបស់យើង ក្នុងមួយឆ្នាំៗកម្មករ-កម្មការិនី ដែលនៅក្រៅប្រទេស បានបញ្ជូនប្រាក់ចូលមកប្រមាណ ជាង២ពាន់លាន។ ២ពាន់លានដុល្លារ សម្រាប់សេដ្ឋកិច្ច ចាក់បញ្ចូលក្នុងសេដ្ឋកិច្ចកម្ពុជា"។ សម្តេចអះអាងថា កម្មករ-កម្មការិនី ដែលធ្វើការងារនៅប្រទេសថៃ និងប្រទេសមួយចំនួនទៀត ក៏បានផ្ញើប្រាក់មកឲ្យឪពុក-ម្តាយ នៅកម្ពុជាផងដែរ ។

ក្នុងឱកាសជួបកម្មករ-កម្មការិនី នេះផងដែរ សម្តេចតេជោ ហ៊ុន សែន បានបន្ថែមថា គេមិនត្រូវចោទសម្តេចថា "ដឹកនាំប្រទេសឲ្យប្រជាពលរដ្ឋ ទៅធ្វើខ្ញុំគេនោះទេ" ។ សម្តេចថា អ្នកដែលចោទប្រកាន់សម្តេចត្រូវយល់ដឹង អំពីបញ្ហានេះ ដែលពលករបានទៅធ្វើការនៅក្រៅប្រទេស ហើយទទួលបានចំណូលខ្ពស់។ សូមបញ្ជាក់ថា ពលករខ្មែរដែលទៅបំរើការងារ នៅក្រៅប្រទេស គិតមកទល់បច្ចុប្បន្ន មានចំនួន១លាន២សែននាក់៕

## ថ្ងៃស្អែក កម្ពុជាបញ្ជូនពលការិនី១ពាន់នាក់ ទៅបម្រើការងារ ជាជំនួយការមេផ្ទះ នៅហុងកុងលើកដំបូង

http://www.freshnewsasia.com/ 2017-12-26

(ភ្នំពេញ)៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឲ្យដឹងថា នាថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ស្អែកនេះ កម្ពុជានឹងបញ្ជូនពលការិនីប្រមាណ១ពាន់នាក់ ទៅបម្រើការងារជាជំនួយការមេផ្ទះ នៅតំបន់រដ្ឋបាលស្វយ័តហុងកុង ជាលើកដំបូង ដែលនឹងទទួលបានប្រាក់ឈ្នួលចាប់ពី៥៥០ដុល្លារអាមេរិកឡើងទៅ។ ការចាប់ផ្តើមប្រតិបត្តិការលើកដំបូងនេះ ត្រូវបានធ្វើឡើងក្រោយពេលភាគីកម្ពុជា-ហុងកុង បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនពលការិនីកម្ពុជា ទៅធ្វើការនៅហុងកុង នាថ្ងៃទី១០ ខែសីហា ឆ្នាំ ២០១៧ កន្លងទៅ។

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្លាប់បានថ្លែងយ៉ាងដូច្នេះថា «យើងគ្រោងថា នឹងជ្រើសរើសឲ្យបាន១ពាន់នាក់ នៅក្នុងគម្រោងសាកល្បងដំបូង ហើយយើងសង្ឃឹមថា អាចនឹងជ្រើសរើសបាន ដោយសារនៅហុងកុង ប្រាក់ឈ្នួលអប្បបរមាល្អបង្គួរចាប់ពី ៥៥០ដុល្លារ ឡើងទៅ ហើយលក្ខខណ្ឌការងារ និងការធានារ៉ាប់រងផ្សេងៗ ទាំងផ្នែកសុខភាព ការឈប់សម្រាក និងការការពារសិទ្ធិប្រយោជន៍ផ្សេងៗរបស់ពលករ នៅហុងកុងគឺល្អ»។ លោកបន្តថា រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណឲ្យក្រុមហ៊ុនចំនួន៦ ប្រតិបត្តិការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលការិនីខ្មែរ ទៅបម្រើការងារជំនួយការមេផ្ទះនៅហុងកុង ក្នុងនោះរួមមាន៖ ក្រុមហ៊ុន ថប មេនផៅវ័រ, ក្រុមហ៊ុន អានីតា បេសមេនផៅវ័រ, ក្រុមហ៊ុន សុខលាភ មេត្រី, ក្រុមហ៊ុន អ៊ឹង រិទ្ធីគ្រុប, ក្រុមហ៊ុន អេលីត មេនផៅវ័រ អេនជេនស៊ី និងក្រុមហ៊ុន វីនវីន មេនផៅវ័រ។

លោកថា ដំណាក់កាលដំបូង ក្រុមហ៊ុនចាមផ្តើមប្រកាសជ្រើសរើសពលការិនី ជ្រើសរើសបានហើយ មានការបណ្តុះបណ្តាល ចំណែកការបញ្ជូននោះ គឺនឹងបញ្ជូននៅចុងឆ្នាំ២០១៧ ខាងមុខ។ អាណត្តិការងារជំនួយការមេផ្ទះនៅហុងកុងនេះ មានរយៈពេល២ឆ្នាំ លុះដល់ពេលបញ្ចប់អាណត្តិ និងមានការព្រមព្រៀងពីនិយោជកផងនោះ ពលការិនីអាចបន្តអាណត្តិការងារទៀតបាន។ មិនតែប៉ុណ្ណោះ នៅពេលទៅដល់ទឹកដីហុងកុងភ្លាម ពលការិនីកម្ពុជានឹងទទួលបានការណែនាំពាក់ព័ន្ធនឹងការរស់នៅ និងការពន្យល់ពីសិទ្ធិ និងកាតព្វកិច្ចរបស់ពលករនៅហុងកុង និងការគាំពារជាច្រើនផ្សេងទៀត ពីអគ្គកុងស៊ុលកម្ពុជាប្រចាំនៅហុងកុង និងការទំនុកបម្រុងគាំពារដល់ពួកគេផងដែរ ក្នុងពេលដែលធ្វើការនៅទីនោះ។

លោក Law Chi Kwong រដ្ឋលេខាធិការនៃការិយាល័យទទួលបន្ទុកវិស័យការងារ និងសុខុមាលភាពហុងកុង បានបញ្ជាក់ថា នៅតំបន់រដ្ឋបាលពិសេសហុងកុង ពលការិនីកម្ពុជានឹងទទួលបានសិទ្ធិ និងលក្ខខណ្ឌការងារដូចទៅនឹងពលករជនជាតិហុងកុងដែរ ដូចជា ការឈប់សម្រាកមួយថ្ងៃក្នុងមួយសប្តាហ៍ ឈប់សម្រាកដោយទទួលបានប្រាក់

ឈ្នួលចំនួន ៧ថ្ងៃទៅ១៤ថ្ងៃ ក្នុងមួយឆ្នាំ ការគាំពារពេលមានផ្ទៃពោះ (ការឈប់សម្រាកលំហែមាតុភាព) ចំនួន១០សប្តាហ៍ ការធានារ៉ាប់រងពេលមានជំងឺ និងបន្ថែមប្រាក់លើកទឹកចិត្តសម្រាប់ពលករដែលបម្រើការងារយូរឆ្នាំ។

សូមជម្រាបថា បច្ចុប្បន្ន ពលករ-ពលការិនីកម្ពុជា ដែលកំពុងស្នាក់នៅ និងបម្រើការងារនៅក្រៅប្រទេសមានចំនួន១,១៥០,០០០នាក់ ក្នុងនោះ មាននៅប្រទេសថៃមានជាង១លាននាក់ ក្រៅពីនេះមាននៅកូរ៉េខាងត្បូង ម៉ាឡេស៊ី ជប៉ុន និងសិង្ហបុរីជាដើម៕

## ពលការិនីកម្ពុជា ១៤នាក់ ត្រូវបានបញ្ជូន ទៅធ្វើការ តាមផ្ទះ នៅហុងកុង ជាលើកដំបូង

https://www.dap-news.com/kh/ ថ្ងៃពុធ, ២៧ ធ្នូ ២០១៧ 14:20 ដោយ: ហង្ស ទេព ID:012

ភ្នំពេញ ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧នេះ បានបញ្ជូនពលការិនីចំនួន១៤នាក់ ដែលបានទទួល ការបណ្តុះបណ្តាល ជំនាញជំនួយ ការ ផ្ទះទៅបំរើការងារ នៅហុងកុងរយៈពេល២ឆ្នាំ តាមកិច្ចព្រមព្រៀង រវាងភាគីហុងកុង និង កម្ពុជា។

បើតាមលោក ងុយ រិទ្ធ នាយខុទ្ទកាល័យ និងជាអគ្គនាយករង អគ្គនាយកដ្ឋាន ការងារ បាន ប្រាប់ឲ្យដឹង នៅមុនពេលចេញដំណើរ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញថា នេះជា ជំហានដំបូង បន្ទាប់ពីបានចុះMOU រវាងកម្ពុជានិងហុងកុង ក្នុងការទទួលពលការិនីកម្ពុជា ទៅបំរើការ។ នៅថ្ងៃនេះមានក្រុមហ៊ុន២ ជាអ្នកទទួលបញ្ជូនទៅគឺក្រុមហ៊ុន អ៊ុង រិទ្ធី គ្រុប និង Elite manpower agency។ លោកបន្តថា ការបញ្ជូនទៅនេះ ស្ថិតនៅក្រោមការតាមដាន ពិនិត្យជាប្រចាំទាំងការធ្វើដំណើរ ការរស់នៅ រហូតដល់ពេលត្រឡប់មកវិញតាមកុងត្រា របស់ក្រសួងការងារ ដើម្បីកុំអោយមានហានិភ័យកើតឡើងសម្រាប់ប្អូនយើង។ លោកបញ្ជាក់ថា ពលការិនីទាំងអស់ត្រូវបានបណ្តុះបណ្តាលត្រឹមត្រូវ មានជំនាញច្បាស់លាស់ផ្នែកជំនួយការមេផ្ទះដែលពួកគាត់នឹងទទួលបានប្រាក់ខែចំនួន៥៧០ដុល្លារអាមេរិកក្នុងមួយខែរួម នឹងប្រាក់អត្ថប្រយោជន៍ផ្សេងជាច្រើនទៀត ពិសេសមានយន្តការ គ្រប់គ្រងពេលវេលា និងមានទំនាក់ទំនងផ្ទាល់ជាមួយក្រុមគ្រួសារជាប្រចាំថែមទៀតផង។

លោកស្រី ហុង លី អាយុ ៣៩ឆ្នាំ រស់នៅខេត្តកណ្តាល បានបង្ហាញអារម្មណ៍ សប្បាយរីករាយ ពេលបានទៅបំរើការនៅប្រទេសរីកចំរើន។ អ្នកស្រីពឹងថា ក្រៅពីទទួលបានប្រាក់ខែខ្ពស់ និងទទួលបានចំណេះដឹងជាច្រើនទៀត ក្រោយពេលត្រឡប់មកស្រុកវិញ។ អ្នកស្រីមានជំនឿ លើក្រសួងនិងក្រុមហ៊ុន ដោយគ្មានព្រួយបារម្ភអ្វីនោះទេ ។

សូមបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាត ឲ្យទីភ្នាក់ងារជ្រើសរើសពលករចំនួន៦ ដើម្បីបញ្ជូនពលការិនី ជំនួយការមេផ្ទះ ទៅធ្វើការនៅតំបន់រដ្ឋបាលពិសេសហុងកុង ក្នុងនោះ មានទីភ្នាក់ងារខ្លះមានបទពិសោធន៍ក្នុងការជ្រើសរើសបណ្តុះបណ្តាលបញ្ជូន និងគ្រប់គ្រង ពលការិនី ជំនួយការមេផ្ទះ នៅប្រទេសសិង្ហបុរី នាពេលកន្លងមកនិងមាន មួយចំនួន ទៀតជាទីភ្នាក់ងារមានការគ្រប់គ្រងបានល្អ និងពុំសូវមានវិវាទជាមួយពលករ៕

## ឧទ្ធរណ៍ជម្រះជនប៉ាគីស្ថាន២នាក់និងស្ត្រីខ្មែរម្នាក់រឿងនាំមនុស្សទៅធ្វើការនៅអារ៉ាប៊ី សាអ៊ូឌីត

http://www.postkhmer.com/ Tue, 26 December 2017 គីម សារុំ

**ភ្នំពេញៈ** សាលាឧទ្ធរណ៍កាលពីម្សិលមិញ បានបើកសវនាការជំនុំជម្រះ ជនជាប់ចោទជាតិប៉ាគីស្ថាន ២ នាក់ឪពុកកូន និងស្ត្រីខ្មែរម្នាក់ ពាក់ព័ន្ធនាំមនុស្ស៤នាក់ ទៅធ្វើការនៅប្រទេសអារ៉ាប៊ី សាអ៊ូឌីតកាលពីឆ្នាំ ២០១៦។ តាមកំណត់ហេតុនគរបាល បានបង្ហាញថា សំណុំរឿងនេះ មានជនជាប់ចោទឈ្មោះ NIAZ AHMED អាយុ៥៥ ឆ្នាំនិងកូន

ប្រុសរបស់គាត់ឈ្មោះ YAZEO AHMED អាយុ ២៤ ឆ្នាំ ឯស្ត្រីខ្មែរឈ្មោះ ប៊ិន ញ៉ អាយុ ៦៥ឆ្នាំ បាននាំនារីខ្មែរ ៣ នាក់ និងបុរសម្នាក់ មកជួបជនជាប់ចោទ NIAZ AHMED កាលពីថ្ងៃទី២១ ខែសីហា ឆ្នាំ ២០១៦ នៅផ្សាររាត្រី (ផ្សារចាស់) ប៉ុន្តែត្រូវសមត្ថកិច្ចឃាត់ខ្លួន ពេលកំពុងធ្វើដំណើរតាមម៉ូតូកង់បី។

សំណុំរឿងនេះ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ខែមេសាឆ្នាំ ២០១៧ បានសម្រេចផ្តន្ទាទោសជនទាំង ៣ នាក់ ឲ្យជាប់ពន្ធនាគារក្នុងម្នាក់ៗ ៧ ឆ្នាំ ចោទពីបទ«ការនាំចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន» តាមបញ្ញត្តមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរ និងធ្វើអាជីវកម្មផ្លូវភេទ។

បុរសជាប់ចោទ NIAZ AHMED បានឆ្លើយក្នុងសវនាការថា គាត់បានជិះម៉ូតូកង់បីមានគ្នា ៦ នាក់បំណងជូនកូនគាត់ជិះរថយន្តក្រុងទៅប្រទេសថៃ ប៉ុន្តែត្រូវសមត្ថកិច្ចចាប់ខ្លួនពេលកំពុងធ្វើដំណើរ ឯកូនរបស់គាត់ត្រូវសមត្ថកិច្ចបំបែកពីគាត់។ ឯមនុស្ស ៤ នាក់ ដែលធ្វើដំណើរជាមួយគាត់នោះ គាត់មិនដែលស្គាល់ពីមុនមកទេ ហើយពួកគេចង់ដើរលេង ពួកគេក៏ទៅជាមួយគាត់ទៅ។

ទោះយ៉ាងណា លោកចៅក្រម ចាយ ច័ន្ទរាតាវណ្ណ បង្ហាញកំណត់ហេតុឆ្លើយសារភាព ទៅជនជាប់ចោទ ប៉ុន្តែ NIAZ AHMED បាននិយាយថា៖«រាល់ចម្លើយសារភាពក្នុងកំណត់ហេតុប៉ូលិស ខ្ញុំបដិសេធព្រោះកាលណោះ គេឲ្យក្រដាសសខ្ញុំ ហើយឲ្យខ្ញុំផ្តិតមេដៃ។ ខ្ញុំសូមតុលាការដោះលែងខ្ញុំវិញ»។

ស្ត្រីឈ្មោះ ប៊ិន ញ៉ បានឆ្លើយក្នុងសវនាការដែរថា គាត់មានកូន ៣ នាក់ ទៅធ្វើការនៅប្រទេសអារ៉ាប៊ី សាអ៊ូឌីត ដូច្នេះអ្នកក្នុងភូមិបានផ្ញើសាច់ញាតិគេ ឲ្យគាត់ជូនមកភ្នំពេញ ហើយគាត់បានជួបនឹងឈ្មោះ NIAZ AHMEDនិងប្រគល់មនុស្សនោះទៅឲ្យគាត់។ «ខ្ញុំមិនបានជួញដូរអីទេ ខ្ញុំជូនគេមកទេ សូមតុលាការដោះលែងខ្ញុំឲ្យមានសេរីភាពវិញផង ហើយឈ្មោះ NIAZ AHMED ឲ្យខ្ញុំ ៤០ ដុល្លារ»។

លោកព្រះរាជអាជ្ញា លី លន់ តំណាងមហាអយ្យការ សន្និដ្ឋានថា ជនទាំង ២ នាក់ បានសារភាពហើយស៊ីសង្វាក់នឹងចម្លើយស្ត្រីជាប់ចោទដែរ។ ដូច្នេះលោកសូមតម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការ។

លោកមេធាវី យ៉ុង ផានិត បានសន្និដ្ឋានថា សាលាដំបូងរាជធានីភ្នំពេញ បានចោទកូនក្តីលោក តាមតែកំណត់ហេតុរបស់នគរបាលមិនបានពិចារណាឲ្យបានច្បាស់លាស់ទេ។ គ្មានភ័ស្តុតាងដាក់បន្ទុកនិងគ្មានធាតុផ្សំនៃបទល្មើស។ លោកថ្លែងថា៖ បើពិនិត្យមាត្រា១១ គឺមិនអាចដាក់ទោសកូនក្តីខ្ញុំបានទេ។ កូនក្តីខ្ញុំជួយគេក្នុងលក្ខណៈមនុស្សធម៌ប៉ុណ្ណោះ ហើយការជួយរបៀបនេះ មានច្រើនណាស់។ ការចាប់គ្រាន់តែធ្វើទៅតាមការស្រមើស្រមៃប៉ុណ្ណោះ។ សូមតុលាការពិនិត្យភ័ស្តុតាងឡើងវិញ និងឲ្យកូនក្តីខ្ញុំរួចបទចោទ»។ ក្រោយជំនុំជម្រះលោកចៅក្រម ស៊ិន វិសាល ថ្លែងថា សាលដីកានេះ នឹងត្រូវប្រកាសនៅថ្ងៃទី ១១ ខែមករា៕

## ទីតាំងម៉ាស្សាកោសជប់ បង្កប់សេវាបម្រើផ្លូវភេទមួយកន្លែង ត្រូវបាន សមត្ថកិច្ច ចុះបង្ក្រាប និង ឃាត់ខ្លួនបាន៨នាក់

**http://peoplenews.asia/ ថ្ងៃទី27 ខែ12 ឆ្នាំ2017 ម៉ោង 1:33 PM ដោយ ៖ រិទ្ធី**

**ភ្នំពេញ ៖** សមត្ថកិច្ច ចុះបង្ក្រាប ទីតាំងម៉ាស្សាកោសជប់មួយកន្លែង ដែលសង្ស័យថា មានបង្កប់សេវាបម្រើផ្លូវភេទ និង ឃាត់ខ្លួនមនុស្ស៨នាក់។ ប្រតិបត្តិការនេះ ធ្វើឡើងកាលពីវេលាម៉ោង៨យប់ ថ្ងៃអង្គារ៍ ទី៩កើត ខែបុស្ស ឆ្នាំរកា ព.ស២៥៦១ ត្រូវនឹងថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ស្ថិតនៅផ្ទះលេខ៥៩៤ តាមបណ្តោយផ្លូវលេខជាតិលេខ២ ក្រុមទី១២ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

មនុស្សដែលឃាត់ខ្លួនទាំង៨នាក់ ក្នុងនោះមានស្ត្រីម្នាក់ឈ្មោះ ឡុង ស្រី អាយុ៤៥ឆ្នាំ ជាម្ចាស់ហាង ចំណែកស្ត្រីវ័យក្មេងចំនួន៧នាក់ទៀត ដែលមានអាយុចាប់ពី១៨ឆ្នាំដល់៣៥ឆ្នាំ ជាស្ត្រីបម្រើនៅក្នុងហាងម៉ាស្សាកោសជប់មួយនោះ ក្រៅពីនេះក៏មានការដកហូតវត្ថុតាងមួយចំនួនទៀតផងដែរ ដូចជា ស្រោមអនាម័យប្រើរួច នឹងមិនទាន់ប្រើ សៀវភៅកត់ត្រាបញ្ជីភ្ញៀវចេញចូល នឹងទឹកប្រាក់រៀលនឹងដុល្លារ មួយចំនួនផងដែរ។ ចំណែកទីតាំង ដែលបើកម៉ាស្សាកោសជប់ខាងលើនេះ ត្រូវអាជ្ញាធរសម្រេចបិទទ្វារជាបណ្ដោះអាសន្ន។

បច្ចុប្បន្នស្ត្រីម្ចាស់ទីតាំង និងស្ត្រីរងគ្រោះចំនួន៧នាក់ ដែលជាអ្នកបម្រើការនៅទីនោះ ត្រូវបាននាំទៅកាន់នាយកដ្ឋានប្រឆាំងការជួញដូរ មនុស្សនិងការពារអនិតិជន ដើម្បីសួរនាំនិងចាត់ការតាមនិតិវិធីច្បាប់៕

## បងប្អូនពលរដ្ឋខ្មែរនៅកូរ៉េ បង្ហាញបញ្ហាកង្វល់ និងសំណូមពរ ដើម្បីរួមគ្នាដោះស្រាយ ចំពោះមុខឯកអគ្គរាជទូត

https://www.dap-news.com/kh/ ថ្ងៃអង្គារ, ២៦ ធ្នូ ២០១៧ 14:24 ដោយ: ស៊ាន កុសល ID:014

ភ្នំពេញ៖ ស្ថានទូតកម្ពុជា ប្រចាំសាធារណរដ្ឋកូរ៉េ បានអញ្ជើញ ថ្នាក់ដឹកនាំ សមាគម សហគមន៍ មូលនិធិ ក្រុមសិល្បៈ នានា និងបណ្ដាញស្ត្រីខ្មែរ នៅសាធារណរដ្ឋកូរ៉េសរុបជាង ៣០ ដើម្បីជួបពិភាក្សាដកពិសោធន៍ សិក្សាពីចំនុចខ្លាំង និងចំនុចខ្សោយជម្រះមន្ទិលសង្ស័យ និងកែលម្អនូវចំនុចខ្វះខាតក្នុងការបំពេញយុទ្ធនាការរួមគ្នាជួយដោះស្រាយបញ្ហារបស់ប្រជាជនខ្មែរនៅកូរ៉េ និងការចូលរួមលើកស្ទួយ អភិរក្សមរតកវប្បធម៌ ប្រពៃណីទំនៀមទម្លាប់ជាតិខ្មែរ ក្នុងរយៈពេលពេញមួយឆ្នាំកន្លងទៅ។ កិច្ចប្រជុំលើកទី៤ បានប្រព្រឹត្តិទៅនៅល្ងាចថ្ងៃអាទិត្យ ទី២៤ ខែធ្នូ ឆ្នាំ២០១៧ នាទីក្រុងស៊ូវ៉ុន ក្រោមវត្តមាន ដឹកនាំដោយ លោក ឡុង ឌីម៉ង់ ឯកអគ្គរាជទូតកម្ពុជា និងសហការី ជាមួយនឹងថ្នាក់ដឹកនាំសមាគម សហគមន៍ មូលនិធិ ក្រុមសិល្បៈ នានា និងបណ្ដាញស្ត្រីខ្មែរ នៅសាធារណរដ្ឋកូរ៉េប្រមាណ ៥០នាក់។

ជាការឆ្លើយតបនឹងសំណូមពរ របស់ថ្នាក់ដឹកនាំសមាគម លោកឯកអគ្គរាជទូតកម្ពុជា បានសម្រេច បន្តយុទ្ធនាការចុះផ្ដល់សេវាបន្តលិខិតឆ្លងដែន ប្រឹក្សាយោបល់ និងបើកវេទិកាសាធារណៈនៅមូលដ្ឋានឲ្យបានច្រើននិងទៅឲ្យដល់សហគមន៍មូលដ្ឋានដែលនៅឆ្ងាយ។បន្តយុទ្ធនាការជាមួយសមាគមគ្រូពេទ្យស្ម័គ្រចិត្តចុះផ្ដល់សេវាពិនិត្យព្យាបាលសុខភាពទូទៅ ពិនិត្យបេះដូង ចាក់វ៉ាក់សាំង ការពារផ្ដាសាយ និងថតX-Ray ជូនដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋ ឲ្យបានច្រើនឡើងបន្ថែមទៀត។ រៀបចំកម្មវិធីអប់រំសីលធម៌ អប់រំផ្លូវចិត្ត តាមបែបព្រះពុទ្ធសាសនា ដើម្បីបំពេញតម្រូវការរបស់សហគមន៍ខ្មែរនៅកូរ៉េ ឲ្យបាន២ដងក្នុងមួយឆ្នាំ ដោយនិមន្តព្រះសង្ឃ ដែលប៉ិនប្រសព្វមកពីខ្មែរ។ បន្តយុទ្ធនាការជួយដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅ ធ្វើការ និងសិក្សានៅសាធារណរដ្ឋកូរ៉េ ឲ្យបានកាន់តែទូលំទូលាយ និងប្រសើរឡើងបន្ថែមទៀត។ល។

ទន្ទឹមនេះតំណាងស្ថានទូត លោក ឡុង ឌីម៉ង់ ក៏បានស្នើត្រឡប់ ទៅថ្នាក់ដឹកនាំសមាគម សហគមន៍ មូលនិធិ ឲ្យរៀបចំបង្កើតកម្មវិធីជួបជុំធំ-តូច តាមលទ្ធភាព ដើម្បីអប់រំផ្សព្វផ្សាយ ពីច្បាប់ការងារ ការថែទាំសុខភាព ការវិនិយោគខុសច្បាប់ ឬការស្វែងរកសេវារត់ការខុសច្បាប់ផ្សេងៗ និងការជំរុញលើកទឹកចិត្តដល់ពលករខ្មែរឲ្យត្រឡប់ទៅកម្ពុជាវិញដោយស្របច្បាប់ពេលចប់អាណត្តិការងារ ដើម្បីចូលរួមរក្សាកូតា ជ្រើសរើសពលករកម្ពុជាថ្មីបន្ថែមទៀត ហើយក្រុមការងារស្ថានទូត សន្យានឹងចូលរួមតាមគ្រប់រូបភាព។

អង្គប្រជុំទាំងអស់ ក៏បានចូលរួមយ៉ាងសស្រាក់សស្រាំពិភាក្សាលើការងាររៀបចំមហាសង្ក្រាន្តខ្មែរ នៅកូរ៉េលើកទីពីរ ដែលជា ព្រឹត្តិការណ៍វប្បធម៌ ប្រពៃណីធំជាងគេប្រចាំឆ្នាំ ដើម្បីអបអរសាទរ ពិធិបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ៕

## ដេកប្រកាច់ក្នុងបន្ទប់ គ្រប់គ្នាផ្អើលនាំគ្នាជួយ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៧ម៉ោង ១៤:៥០ម៉ឺត សារុន

ខេត្តបន្ទាយមានជ័យ ៖ ភាគីថៃបានធ្វើការបញ្ជូនសពពលករខ្មែរម្នាក់ប្រគល់ឲ្យសាច់ញាតិត្រឹមព្រំដែនច្រកទ្វារអន្តរជាតិប៉ោយប៉ែត-ខ្លងលឹកនាព្រឹកថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ បន្ទាប់ពីដេកស្លាប់សង្ស័យខ្យល់គលើទឹកដីថៃ នៅខេត្តសាមុទ្រប្រាកាន ។ ជនរងគ្រោះឈ្មោះ សាំង យ៉ុម ភេទប្រុស អាយុ៤០ឆ្នាំ ជាកម្មកររោងចក្រ elictronic នៅក្នុងខេត្តកើតហេតុខាងលើ និងមានទីលំនៅភូមិទំពសៀម ឃុំ-ស្រុកជីក្រែង ខេត្តសៀមរាប ។

សាច់ញាតិសពប្រាប់ថា ជនរងគ្រោះមុនស្លាប់បានប្រកាច់នៅក្នុងបន្ទប់ ហើយអ្នកដេកជាមួយម្នាក់បានព្យាយាមរឹតទ្រូង និងធ្វើចលនា ប៉ុន្តែមិនអាចជួយបានគឺជនរងគ្រោះបានដាច់ខ្យល់ស្លាប់ភ្លាមៗនៅម៉ោង១១យប់ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៧ ។ សពត្រូវបានសាច់ញាតិជួលរថយន្តដឹកទៅលំនៅដ្ឋានដើម្បីធ្វើបុណ្យតាមប្រពៃណី ៕

## សមត្ថកិច្ចថៃកំពុងបើកការស៊ើបអង្កេតលើករណី តម្រួតថៃជំរិតទារប្រាក់ពីពលករខ្មែរ នៅខេត្តស្រះកែវ

http://www.pheaktraprak.com December 26, 2017

កាលពីថ្ងៃអង្គារទី២៦ ខែធ្នូ ឆ្នាំ២០១៧នេះ លោកអគ្គស្នងការមេតម្រួតប្រទេសថៃ បានដាកបញ្ជាអោយលោកស្នងការតម្រួតខេត្តស្រះកែវ ប្រទេសថៃ អោយបើកការសើបអង្កេតស្រាវជ្រាវលើករណីវីដេអូឃ្លីបហេតុការណ៍តម្រួតថៃមួយរូបគណៈពេលកំពុងជំរិតទាប្រាក់ពីរពលករខ្មែរក្នុងមនុស្សម្នាក់១០០បាត ទាំងមានលិខិតឆ្លងដែនធ្វើដំណើរត្រឹមត្រូវ ខណៈពេលដែលពលករខ្មែរទាំងអស់នោះជិះរថយន្តតូរីសធ្វើដំណើរដើម្បីវិលត្រឡប់ទៅជួបគ្រួសារនៅឯប្រទេសកម្ពុជា។

តាមការបញ្ជាក់របស់អ្នកនាំពាក្យអគ្គស្នងការតម្រួតថៃ បានប្រាប់ឲ្យដឹងថា ក្នុងករណីវីដេអូឃ្លីបជំរិតទារប្រាក់ពីពលករខ្មែរខាងលើនេះ លោកអគ្គស្នងការមេតម្រួតថៃបានបញ្ជាឲ្យលោកស្នងការតម្រួតខេត្តស្រះកែវតាមស្រាវជ្រាវរកតម្រួតនៅក្នុងឃ្លីបវីដេអូនេះអោយឃើញនៅក្នុងរយះពេល៧ថ្ងៃ ព្រមទាំងប្រកាសចាត់វិធានការយ៉ាងដាច់ខាតចំពោះមន្ត្រីតម្រួតថៃ ដែលជំរិតទារប្រាក់ពីពលករកម្ពុជាដែលស្របច្បាប់។

## ថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១៧

## ខេត្តឧត្តរមានជ័យប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ២០១៧

http://www.akp.gov.kh/kh/ AKP ខេត្តឧត្តរមានជ័យ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧

ខេត្តឧត្តរមានជ័យប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្ស ១២ ធ្នូ ២០១៧ ក្រោមប្រធានបទ រួមគ្នាពង្រឹងប្រព័ន្ធ សុវត្ថិភាព និងពង្រឹងការអនុវត្ត ច្បាប់ដើម្បីការពារមនុស្ស ពីអំពើជួញដូរ កាលពីថ្ងៃអង្គារ ០៩កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ក្រោមអធិបតីភាពឯកឧត្តម ស ថាវី អភិបាលនៃ គណៈអភិបាលខេត្ត និង ឯកឧត្តម យឹម ធិន ប្រធានក្រុមប្រឹក្សាខេត្ត។

លោកស្រី ឯក សុវណ្ណភារៈ អភិបាលរងខេត្តឧត្តរមានជ័យ និងជាប្រធានលេខាធិការ ដ្ឋានប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស គ.ខ.ប.ជ បានថ្លែងឱ្យដឹងថា ការប្រារព្ធទិវាជាតិប្រយុទ្ធ ប្រឆាំងអំពើជួញដូរ មនុស្ស ១២ធ្នូ ២០១៧ ក្រោមប្រធានបទរួមគ្នាពង្រឹងប្រព័ន្ធសុវត្ថិភាព និង ពង្រឹងការអនុវត្តច្បាប់ ដើម្បីការពារមនុស្សគ្រប់រូបពីអំពើជួញដូរមនុស្ស មានគោលបំណង បន្តយកចិត្តទុកដាក់ ក្នុងការការពារ ប្រជាពលរដ្ឋពីភាពរងគ្រោះដោយឧក្រិដ្ឋកម្មជួញដូរមនុស្ស ដែលបង្កឱ្យមានវិនាសកម្មជាថ្មីដល់មនុស្ស ជាតិ ហើយបាន និងកំពុងក្លាយ ជាទាសភាពសម័យទំនើបគួរឱ្យភ័យខ្លាច និងគួរឱ្យស្អប់ខ្ពើមបំផុត។ ដើម្បីជាយុទ្ធនាការរួមគ្នាបង្កើតនូវប្រព័ន្ធសុវត្ថិភាព និងពង្រឹងការអនុវត្តច្បាប់ឱ្យកាន់ តែរឹងមាំសម្រាប់ ការពារប្រជាពលរដ្ឋ ឱ្យរួចផុតពីភាពរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលជាធនធានដ៏

មានសក្តានុពល ក្នុងការពង្រឹង និង ពង្រីកល្បឿនសេដ្ឋកិច្ចដ៏ល្អប្រសើរបោះ ជំហានទៅមុខឆ្ពោះទៅកាន់ចក្ខុវិស័យរួមគឺ "កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ" ។

ក្រុមការងារទាំង៦របស់លេខាធិការដ្ឋានអនុវត្តន៍ការងារសកម្មភាពរបស់ខ្លួនឱ្យកាន់តែប្រសើរ។ យល់ដឹងកាន់តែស៊ីជម្រៅបន្ថែមទៀតលើការទប់ស្កាត់អំពើជួញដូរមនុស្ស និងការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស។ រួមគ្នាបង្កើតនូវប្រព័ន្ធសុ វត្ថិភាព និងពង្រឹងការអនុវត្តច្បាប់ឱ្យកាន់តែរឹងមាំសម្រាប់ការពារប្រជាពលរដ្ឋ ឱ្យរួចផុតពីភាពងគ្រោះដោយអំពើជួញដូរមនុស្ស បញ្ហាផ្សេងៗត្រូវបានដោះស្រាយ ប្រកបដោយប្រសិទ្ធភាព ។

ឯកឧត្តម ស ថាវី ក៏បានមានប្រសាសន៍ ដោយរំលេចនូវការកោតសរសើរ ចំពោះគ្រប់កិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំក្រុង ស្រុក មន្ទីរ អង្គភាព មន្ត្រីរាជការ អង្គការមិនមែនរដ្ឋាភិបាល ក្នុងខេត្ត និងអន្តរជាតិ ដែលបានរួមគ្នាដោះស្រាយ ប្រឆាំងដាច់ខាតទៅនឹងសកម្មភាពរបស់ឧក្រិដ្ឋជន ស្របទៅតាមទិសដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល៕ ដោយ ទិត ស្រ៊

## រដ្ឋមន្រ្តីក្រសួងការងារ ប្តេជ្ញាអនុវត្តន៍តាម អនុសាសន៍ទាំង៨ ចំណុចសំខាន់ៗ របស់រាជរដ្ឋាភិបាល

https://www.dap-news.com/kh/ ថ្ងៃពុធ, ២៧ ធ្នូ ២០១៧ 20:40 ដោយ: ដើមអម្ពិល ID:030

ភ្នំពេញ៖ លោក អ៊ិត សំហេង រដ្ឋមន្រ្តីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្តេជ្ញាអនុវត្ត តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់ របស់សម្តេចតេជោ ហ៊ុន សែន ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ទាំង៨ចំណុច សំខាន់ៗ។

**អនុសាសន៍ទាំង៨ចំណុចនោះរួមមាន៖**

១៖ ការអនុវត្តប្រាក់ឈ្នួលអប្បបរមា១៧០ដុល្លារនៅឆ្នាំ២០១៨

២៖ ការពិនិត្យព្យាបាលជំងឺនៅតាមមន្ទីរពេទ្យរដ្ឋទាំងអស់ដោយមិនបង់ថ្លៃ។

៣៖ ការទទួលប្រាក់ឈ្នួល១២០ភាគរយ រយៈពេល៣ខែ សម្រាប់កម្មការិនីក្នុងពេលសម្រាលកូន

៤៖ តាមដានកម្មវិធីឧបត្ថម្ភប្រាក់ដល់កម្មការិនីទាំងក្នុង និងក្រៅប្រព័ន្ធពេលសម្រាលកូន

៥៖ ការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ដោយនិយោជក១០០%

៦៖ ត្រូវត្រួតពិនិត្យជាប្រចាំនូវថ្លៃឈ្នួលផ្ទះ ថ្លៃទឹក និងថ្លៃអគ្គិសនី

៧៖ បន្តខិតខំរៀបចំដាក់ឲ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកសោធននិវត្តន៍ឆ្នាំ២០១៩

ទី៨៖ បន្តដោះស្រាយបញ្ហាពលករដែលកំពុងបម្រើការងារនៅក្រៅប្រទេស៕

## ស្ត្រីម្នាក់ដែលជាប់ពាក់ព័ន្ធករណីការយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ ត្រូវនគរបាលបញ្ជូនទៅពន្ធនាគារ

http://cambodiapolice.com/ 5:17 pm 27 ធ្នូ 2017 29

**កំពង់ចាម ៖** កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយកម្លាំងអធិការដ្ឋាននគរបាលស្រុកស្រីសន្ធរ បានបង្ក្រាបកាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៧ ត្រូវបានលោក ប៉ុក សុវណ្ណមុន្នី ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តកំពង់ចាម ចេញដីកាបង្គាប់ឲ្យឃុំខ្លួន លេខ ០៧ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ពីបទការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ ប្រព្រឹត្តនៅភូមិស្វាយតានាន់(ខ) ឃុំព្រែករំដេង ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧។

សូមរម្លឹកថា: កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង១២ថ្ងៃត្រង់ មានករណីការយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ នៅចំណុចភូមិស្វាយតានាន់(ខ) ឃុំព្រែករំដេង ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ក្រោយពីទទួលបានពាក្យបណ្តឹងភ្លាម នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៧ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយកម្លាំងអធិការដ្ឋាននគរបាលស្រុកស្រីសន្ធរ បានចុះធ្វើការស្រាវជ្រាវបង្ក្រាបឃាត់ខ្លួនជន

សង្ស័យ បានម្នាក់ ឈ្មោះ ហ៊ឹម នោរី ភេទស្រី អាយុ២៥ឆ្នាំ ជនជាតិខ្មែរឥស្លាម នៅភូមិស្វាយតានាន់(ខ) ឃុំព្រែករំដេង ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម និងបានសង្គ្រោះជនរងគ្រោះ ប្រគល់ជូនឪពុកម្តាយវិញ។

បច្ចុប្បន្ន ជនជាប់ចោទ ត្រូវបានសមត្ថកិច្ចបញ្ជូនទៅឃុំខ្លួននៅពន្ធនាគារខេត្តកំពង់ចាម រួចរាល់ហើយ តាមបញ្ញត្តិច្បាប់ មាត្រា៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ៕ ការិយាល័យផ្សព្វផ្សាយអប់រំ

## ស្ត្រីជាប់ចោទ អូស្ត្រាលី សារភាពកំហុស តែសុំឲ្យឧទ្ធរណ៍បន្ថយទោស ករណីជួលមនុស្សពពោះជំនួស

http://www.postkhmer.com/ ភ្នំពេញប៉ុស្តិ៍ Wed, 27 December 2017 គឹម សារុំ

ភ្នំពេញៈ ស្ត្រីជនជាតិអូស្ត្រាលី ដែលជាប់ពាក់ព័ន្ធនឹងករណីជួលស្ត្រីខ្មែរឲ្យពពោះជំនួស នៅព្រឹកមិញនេះ បានទទួចសុំឲ្យចៅក្រមសាលាឧទ្ធរណ៍ បន្ថយទោសដល់ខ្លួន ខណៈត្រូវតុលាការថ្នាក់ក្រោមផ្តន្ទាទោស ១ ឆ្នាំ ៦ ខែ។ ឆ្លើយតាមរយៈអ្នកបកប្រែប្រាប់លោកស្រីចៅក្រម គឹម ដានី ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ក្នុងបន្ទប់សវនាការស្ត្រីជាប់ចោទឈ្មោះ TAMMY ALAYNE CHALES អាយុ ៤៩ ឆ្នាំ ថាគាត់ព្រមទទួលកំហុស ប៉ុន្តែក៏ស្នើដល់ក្រុមប្រឹក្សាជំនុំជម្រះផងដែរ ដើម្បីសម្រាលទោស។

តាមអង្គហេតុ ស្ត្រីជាប់ចោទបានទាក់ទងជនជាតិខ្មែរ ២ នាក់ ម្នាក់ឈ្មោះ ពេជ្រ រិទ្ធី ភេទប្រុសអាយុ ២៨ ឆ្នាំ មុខរបរមិនពិតប្រាកដស្នាក់នៅសង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក និង សំរិទ្ធ ចាន់ចរិយ៉ា ភេទ ស្រី អាយុ៣០ ឆ្នាំ មុខរបរធ្មបស្នាក់នៅសង្កាត់វាលវង់ ខណ្ឌ ៧ មករា ដើម្បីពពោះនិងបញ្ជូនក្មេងដែលកើតនោះទៅបរទេសព្រោះអតិថិជនជាជនបរទេស ។

បើតាមរបាយការណ៍ស្ត្រីអូស្ត្រាលីរូបនេះត្រូវបានសមត្ថកិច្ចចាប់ខ្លួនកាលពីចុងឆ្នាំមុនជាមួយខ្មែរ២នាក់ ដែលជាប់ពាក់ព័ន្ធករណីនេះ៕

## រាជរដ្ឋាភិបាលនឹងជំរុញដាក់រោងចក្រនៅតាមបណ្តាខេត្តដើម្បីកាត់បន្ថយការធ្វើចំណាកស្រុក

http://www.rasmeinews.com/ December 28, 2017

(ភ្នំពេញ)៖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាមានប្រសាសន៍ឲ្យដឹងថា រាជរដ្ឋាភិបាលនឹងជំរុញដាក់រោងចក្រនៅតាមបណ្តាខេត្ត ដើម្បីកាត់បន្ថយនូវការធ្វើចំណាកស្រុករបស់យុវជន យុវនារីដែលតែងស្វែងរកការងារធ្វើនៅរាជធានីភ្នំពេញ ។ តាមរយៈផែនការនេះប្រមុខរដ្ឋាភិបាលក៏បានអំពាវនាវឲ្យកម្មកររោងចក្រទាំងអស់ចូលរួមការពារឲ្យបាននូវសន្តិភាព ចូលរួមរក្សាស្ថិរភាពនយោ បាយដើម្បីជានាការអភិវឌ្ឍ ជានាការងារធ្វើសម្រាប់ក្មួយៗ និង ពង្រឹងសុវត្ថិភាពនៅក្នុងរោងចក្រ ។

ប្រមុខរាជរដ្ឋាភិបាលបានថ្លែងបែបនេះទៅកាន់ក្រុមកម្មករ កម្មការិនីប្រមាណជាង១,៤ ម៉ឺននាក់នៅតំបន់ផ្លូវជាតិលេខ ៣ ក្នុងខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី ២៧ ខែ ធ្នូ ។ សម្តេចតេជោនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា៖«ក្មួយៗត្រូវចាំបើចង់រក្សាការងារធ្វើ ចង់រក្សានូវប្រាក់ចំណូលដែលក្មួយមាន ត្រូវខិតខំរួមចំណែកការពារនូវសន្តិភាពឲ្យខានតែបាន មិនត្រូវផ្តល់ឱកាសឲ្យអ្នកណាមួយទាំងជនជាតិខ្មែរ និង ជនជាតិបរទេស បំផ្លិចបំផ្លាញសន្តិភាពដូចពីអតីតកាលនោះទេ កុំផ្តល់ឱកាសឲ្យពួកគេ ដោយតម្លៃណាក៏ដោយយើងត្រូវហានងើបឈរឡើងដើម្បីការពារនូវ ឯករាជ្យ អធិបតេយ្យជាតិ ការពារនូវសន្តិភាព ដើម្បីបន្តការអភិវឌ្ឍសម្រាប់យើងទាំងអស់គ្នា ។ ព្រោះនេះវាជាជីវិតរបស់យើង វាជាឆ្នាំងបាយរបស់យើង អតីតកាលបានបង្រៀនយើងគ្រប់សព្វហើយ...» ។

សម្តេចតេជោនាយករដ្ឋមន្ត្រីបានបន្តទៀតថា៖ក្រឡេកមើលមកក្រោយបន្តិច ដើម្បីមានឱកាសថ្ងៃនេះ យើងបានធ្វើកិច្ចការច្រើនណាស់។ គណបក្សប្រជាជនបានលះបង់ធំធេងណាស់៖ទី ១ ផ្តួលរំលំរបប ប៉ុល ពត ដើម្បីសង្គ្រោះជីវិតជីដូនជីតា ឪពុកម្តាយរបស់ក្មួយៗអោយរស់រានមានជីវិត ។ទី ២ ការទប់ស្កាត់ការវិលត្រឡប់នៃរបបប្រល័យពូជសាសន៍ ប៉ុល ពត។ ទី៣. ការស្វែងរកសន្តិភាព ដើម្បីដំណើរការបង្រួបបង្រួមជាតិ តាមរយៈកិច្ចព្រមព្រៀងទីក្រុងប៉ារីស ហើយបន្ទាប់ទៅយើងដាក់ចេញនូវការអនុវត្តនយោបាយឈ្នះឈ្នះដែលនាំមកនូវការឯកភាពទឹកដីជាលើកដំបូង ជាប្រវត្តិសាស្ត្រជាតិរបស់យើង ដែលមុននេះទឹកដីនៃប្រទេសកម្ពុជា ជាប្រទេសមួយមានតំបន់ត្រួតត្រាច្រើនកម្លាំងប្រដាប់អាវុធច្រើន ប្រខាំគ្នាមិនចេះចប់ ។ ប៉ុន្តែយើងបានខិតខំដើម្បីស្វែងរកធ្វើឲ្យមានឯកភាពជាតិជាលើកដំបូងនៅក្នុងប្រវត្តិសាស្ត្រ បើមិនរាប់រយឆ្នាំទេ ក៏រាប់សិបឆ្នាំហើយដែរ ។ ឱកាសមាស ឱកាសពេជ្រ បានមកដល់សម្រាប់កម្ពុជារបស់យើង យើងបានខិតខំដើម្បីប្រើប្រាស់ឱកាសដែលអនុគ្រោះចេញមកពីសន្តិភាព និងការបង្រួបបង្រួមជាតិនេះ ដើម្បីអភិវឌ្ឍប្រទេសជាតិឡើងវិញ ។

សម្តេចតេជោនាយករដ្ឋមន្ត្រីបានបន្តថា៖ជោគជ័យនៃគោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជា គឺបានមកពីការចូលរួមចំណែករបស់ប្រជាពលរដ្ឋ ។ ប្រសិនគ្មានការគាំទ្រពីប្រជាពលរដ្ឋទេ ក៏គ្មានជោគជ័យដែរ ។ ដូចនេះមិនមែនជាបញ្ហាដាច់ដោយឡែករបស់គណបក្សប្រជាជន មិនមែនជាបញ្ហាដាច់ដោយឡែករបស់មេដឹកនាំរបស់គណបក្សប្រជាជននោះទេ។ ក៏ប៉ុន្តែជាមោទនភាពដែលក្មួយទាំងឡាយគប្បីត្រូវមានចំពោះជីដូនជីតាឪពុកម្តាយរបស់ក្មួយៗដែលបានខិត ខំធ្វើនូវកិច្ចការងារនេះ ។ គ្មានជោគជ័យណាមួយដែលយើងដណ្តើមបានដោយខ្វះការចូលរួមនោះទេ ។ ឯអ្នកចូលរួមជំនាន់មុនគឺជីដូនជីតា ឪពុកម្តាយរបស់ក្មួយៗនោះហើយ ដែលជាអ្នកបានចូលរួមគាំទ្រគណបក្សប្រជាជនបានចូលរួមគាំទ្រមេដឹកនាំគណបក្សប្រជាជន។ ដោយហេតុនេះហើយបានជាក្មួយៗត្រូវចងចាំថា ដើម្បីមានការងារធ្វើនៅថ្ងៃនេះ យើងបានលះបង់ច្រើនណាស់យើងបានធ្វើកិច្ចការច្រើនណាស់ដើម្បីឲ្យក្មួយ ៗមានការងារធ្វើ និងមានប្រាក់ចំណូលកាន់តែច្រើនទៅៗ ។ នេះជាប្រសាសន៍របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ។

ជាទីបញ្ចប់សម្តេចតេជោ ហ៊ុន សែន ក៏បានផ្តាំផ្ញើតាមរយៈក្មួយៗជាកម្មករ កម្មការិនីទៅកាន់ក្រុមគ្រួសារជាមាតាបិតា ជាជីដូនជីតា និង ក្រុមគ្រួសារ នូវការសាកសួរសុខទុក្ខហើយសង្ឃឹមថា ពួកគាត់នឹងផ្តល់នូវការគាំទ្រសម្រាប់គណបក្សប្រជាជនសម្រាប់សម្តេចបន្តការដឹកនាំប្រទេសមួយនេះ ក្នុង រយៈពេលមិនតិចជាង ១០ ឆ្នាំទៀត ។ សម្តេចបានបន្តថាសម្តេចពិតជាមានការហត់នឿយណាស់ទៅហើយ ក៏ប៉ុន្តែដើម្បីអមដំណើរជាមួយបងប្អូនកម្មករ កម្មការិនី ពង្រីកនូវការលូតលាស់ និង ធានាឲ្យបាននូវសន្តិភាពសម្តេចមានតែខិតខំបន្តទៀតតែប៉ុណ្ណោះ ដើម្បីនាំប្រទេសនេះទៅកាន់ប្រទេសមួយដែលមានប្រាក់ចំណូលកម្រិតខ្ពស់ និង អត្រានៃភាពក្រីក្រធ្លាក់ចុះមកនៅត្រឹម១ ភាគរយ ឬសូន្យភាគរយ ៕ដោយ៖*តារារិទ្ធ/sn*

## ពលការិនីកម្ពុជា១៤នាក់ ត្រូវបានបញ្ជូនទៅបម្រើការជាជំនួយការមេផ្ទះ នៅហុងកុងលើកដំបូង

https://www.mlvt.gov.kh/ ពុធ, 27 ធ្នូ 2017 17:41

(ភ្នំពេញ)៖ បន្ទាប់ពីចុះអនុស្សរណៈបញ្ជូន និងទទួលពលករកម្ពុជាទៅបម្រើការងារជាជំនួយការមេផ្ទះ នៅតំបន់រដ្ឋបាលពិសេសហុងកុង ឲ្យបាន១ពាន់នាក់ នៅឆ្នាំ២០១៨ កាលពីពេលកន្លងទៅរួចមក ភាគីកម្ពុជាបានបញ្ជូនពលការិនីចំនួន ១៤នាក់ ជាជំហានដំបូងសិន។ នេះបើតាមលោក ងុយ រិទ្ធ អគ្គនាយករង នៃអគ្គនាយកដ្ឋានការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

មុនពេលឡើងយន្តហោះចាកចេញពីកម្ពុជាឆ្ពោះទៅហុងកុង លោក ង៉ុយ រិទ្ធ បានឲ្យដឹងថា ពលការិនីទាំង១៤ នាក់ខាងលើ ត្រូវចេញដំណើរពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នារសៀលថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ជាមួយការ អមដំណើរពីមន្ត្រីរាជការ នៃក្រសួងការងារផងដែរ។ លោកបន្តថា មុនការចេញដំណើរនេះ ពលការិនីកម្ពុជាខាងលើ បានទទួលការបណ្តុះបណ្តាលពីជំនាញការងារ ផ្នែកជំនួយការមេផ្ទះ ភាសា និងរបៀបរបបមួយចំនួន រយៈពេល៣ខែ ដើម្បីតម្រង់ទិសបណ្តើរៗពីជីវភាពរស់នៅ នៅតំបន់រដ្ឋបាលពិសេសហុងកុងនោះ។ លោកបន្ថែមថា អាណត្តិការងារ ជំនួយការមេផ្ទះនៅហុងកុង មានរយៈពេល២ឆ្នាំ ប៉ុន្តែដល់ពេលបញ្ចប់អាណត្តិការងារ បើសិនមានការព្រមព្រៀងពី និយោជកទៀត ពលការិនីអាចបន្តអាណត្តិការងារទៀតបាន។ ប្រាក់ឈ្នួលអប្បបរមាដែលទទួលបានចាប់ពី ៥៧០ ដុល្លារឡើងទៅ រួមទាំងអត្ថប្រយោជន៍មួយចំនួនទៀត ដូចជា លក្ខខណ្ឌការងារ និងការធានារ៉ាប់រងផ្សេងៗល្អប្រសើរ ទាំងផ្នែកសុខភាព ការឈប់សម្រាក និងការការពារសិទ្ធិប្រយោជន៍ ពោលដូចទៅនឹងកម្មករ-កម្មការិនីហុងកុង និង ពលករ-ពលការិនីជនជាតិដទៃផងដែរ។

សម្រាប់ការបញ្ជូនពលការិនីបន្ត ត្រូវបានលោក ង៉ុយ រិទ្ធ បញ្ជាក់ថា នឹងធ្វើឡើងជាបន្តបន្ទាប់ទៀត ដោយ អាស្រ័យលើការជ្រើសរើស ការបណ្តុះបណ្តាល និងតម្រូវការជាក់ស្តែងរបស់និយោជកនៅហុងកុង។ លោកបានគូស បញ្ជាក់ថា បើតាមការគ្រោងទុកនៅឆ្នាំ២០១៨ កម្ពុជាបានព្រមព្រៀងជាមួយហុងកុង បញ្ជូនពលការិនីកម្ពុជាទៅហុង កុង ឲ្យបាន១៣ន់នាក់ ខណៈតម្រូវការទីផ្សារការងារនៅហុងកុងមានច្រើនជាងនេះ ប៉ុន្តែកម្ពុជាមិនអាចផ្តល់កម្លាំង ពលកម្មទៅបានច្រើនជាងនេះទេ ព្រោះត្រូវការចំណាយពេលវេលា ក្នុងការជ្រើសរើស បណ្តុះបណ្តាលទៅតាមស្តង់ ដារ និងការងារពាក់ព័ន្ធនានា។ លោកបន្តទៀតថា មុនចេញដំណើរទៅហុងកុងនេះ ក្រុមមន្ត្រីនៃក្រសួងការងារ និង ក្រុមការងាររបស់ក្រុមហ៊ុនបញ្ជូន និងទទួល បានជួបសំណេះសំណាលជាមួយពលការិនីខាងលើ និងក្រុមគ្រួសាររបស់ ពួកគេ ដោយពួកគេបានបង្ហាញពីការសប្បាយរីករាយ ក្នុងការទៅបម្រើការងារនៅទឹកដីនាគសេដ្ឋកិច្ចហុងកុងនេះ ព្រោះមិនត្រឹមតែទទួលបានប្រាក់ឈ្នួលខ្ពស់ប៉ុណ្ណោះទេ ពួកគេក៏សង្ឃឹមថា នឹងទទួលបានជំនាញ បទពិសោធន៍ ចំណេះដឹងភាសា ការមើលឃើញពីការអភិវឌ្ឍនៅទីនោះផងដែរ។ សូមជម្រាបថា លោក Law Chi Kwong រដ្ឋ លេខាធិការនៃការិយាល័យទទួលបន្ទុកវិស័យការងារ និងសុខុមាលភាពហុងកុង ធ្លាប់បានបញ្ជាក់ថា នៅតំបន់រដ្ឋបាល ពិសេសហុងកុង ពលការិនីកម្ពុជានឹងទទួលបានសិទ្ធិ និងលក្ខខណ្ឌការងារដូចទៅនឹងពលករជនជាតិហុងកុងដែរ ដូច ជា ការឈប់សម្រាកមួយថ្ងៃក្នុងមួយសប្តាហ៍ ឈប់សម្រាកដោយទទួលបានប្រាក់ឈ្នួលចំនួន ៧ថ្ងៃទៅ១៤ថ្ងៃ ក្នុង មួយឆ្នាំ ការគាំពារពេលមានផ្ទៃពោះ (ការឈប់សម្រាកលំហែមាតុភាព) ចំនួន១០សប្តាហ៍ ការធានារ៉ាប់រងពេលមាន ជំងឺ និងបន្ថែមប្រាក់លើកទឹកចិត្តសម្រាប់ពលករដែលបម្រើការងារយូរឆ្នាំ៕

## ពលករខ្មែរបម្រើការងារនៅប្រទេសថៃផឹកស៊ីស្រវឹងកាប់គ្នាស្លាប់ម្នាក់

http://cambodiapolice.com 12:11 pm 28 ធ្នូ 2017

ប្រទេសថៃ ៖ ជនរងគ្រោះម្នាក់ ដែលជាពលករបម្រើការងារនៅឯប្រទេសថៃបានស្លាប់នៅក្នុងថ្លុកឈាម ខាង មុខអគារស្នាក់នៅរបស់ខ្លួន បន្ទាប់ពីជនរងគ្រោះរូបនេះបានផឹកស៊ីជាមួយមិត្តភ័ក្រ្ត ដែលជាពលករខ្មែរដូចគ្នា ហើយ ទំនងជាស្រវឹងរៀងខ្លួននិងបានទាស់សម្តីគ្នា ទើបត្រូវភាគីម្ខាងទៀតទាញប៉័ងតោកាប់យកតែម្តង ហើយគេចខ្លួនបាត់។

យោងតាមរបាយការណ៍ពីសមត្ថកិច្ចថៃបានឲ្យដឹងថា ករណីឃាតកម្មនេះ បានកើតឡើងកាលពីវេលាម៉ោង៧ និង៣០ នាទីយប់ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ត្រង់ចំណុចខាងមុខអគារស្នាក់នៅរបស់កម្មករមួយកន្លែងដែលស្ថិតក្នុង ក្រុមហ៊ុនអ៊ីតាលៀនថៃ ឌីវើលុបភើមេន ប្រកចូលសណ្ឋាគារប៉ាធុមផាឡាស់ ក្នុងឃុំបានម៉ៃ ស្រុកមឿង ខេត្តប៉ាធុមថានី ប្រទេសថៃ។ នៅកន្លែងកើតហេតុគេសង្កេតឃើញមានកម្មករកសាងជាច្រើននាក់ បានឈរចោមរោមមើលសពពលករ ខ្មែរម្នាក់ដែលបានដេកស្លាប់ស្តូកស្តឹងក្នុងថ្លុកឈាម ដែលក្រោយពីសមត្ថកិច្ចថៃបានចុះទៅពិនិត្យសពគឺសង្កេតឃើញ

ថា មានស្នាមកាប់នឹងវត្ថុមុតស្រួចចំនួន២កន្លែង គឺក្បាលផ្នែកខាងក្រោយមួយកន្លែង និងដៃស្តាំមួយកន្លែង។ សពនេះមានឈ្មោះ ធុច ចង្រិត ភេទប្រុស អាយុ៣៧ឆ្នាំ ជាពលករខ្មែរ ដែលប្រភពមួយចំនួនបានឲ្យដឹងថា នៅមុនពេលកើតហេតុគេឃើញជនរងគ្រោះរូបនេះបានផឹកស៊ីជាមួយមិត្តភ័ក្ត្ររបស់គេម្នាក់ ដែលជាពលករមកពីប្រទេសកម្ពុជាដូចគ្នា លុះពេលស្រវឹងទំនងជាមានការទាស់សម្តីគ្នា ទើបត្រូវភាគីម្ខាងប្រើកាំបិតប៉័ងតោកាប់ស្លាប់ដោយគ្មានអ្នកណាដឹងសោះ។

ស្ត្រីឈ្មោះ សិរីផាន់ សែនផាប អាយុ៤៩ឆ្នាំ បាននិយាយថាខណៈដែលខ្លួនកំពុងឈរជជែកគ្នាលេងជាមួយនឹងអ្នកគ្រប់គ្រងអគារស្នាក់នៅរបស់កម្មករ នៅឯប៉ុស្តិ៍យាមខាងមុខគឺបានឃើញពលករខ្មែរម្នាក់(ជនសង្ស័យ) ស្លៀកខោជើងវែង ពាក់អាវដៃវែង ពណ៌ខៀវ គ្មានពាក់ស្បែកជើង បានដើរចេញទៅក្រៅដោយបានប្រាប់ថា សុំទៅទិញសាច់ក្លែមខាងក្រៅមួយភ្លែត ហើយក៏បាត់រហូត រួចទើបដឹងថា មានករណីនេះកើតឡើង។

បច្ចុប្បន្នសពត្រូវបានកម្លាំងសមត្ថកិច្ចជំនាញធ្វើការស្រាវជ្រាវរកអត្តសញ្ញាណដើម្បីរៀបចំបញ្ជូនមកអោយក្រុមគ្រួសារ សាច់ញាតិ នៅឯប្រទេសកម្ពុជាវិញ ដោយឡែកជនសង្ស័យដែលគេបានស្គាល់សាវតាច្បាស់ហើយនោះ គឺតម្រួតថៃ កំពុងតាមរកក្នុងការចាប់ខ្លួនយកទៅផ្តន្ទាទោសតាមផ្លូវច្បាប់ ៕ ដោយៈ ពាយ័ព្យ

## ឧទ្ធរណ៍ជម្រះក្តីស្ត្រីអូស្ត្រាលី ករណីជួលស្ត្រីខ្មែរពពោះ

http://www.postkhmer.com/ Thu, 28 December 2017 គីម សារុំ

**ភ្នំពេញៈ** ស្ត្រីជនជាតិអូស្ត្រាលីម្នាក់ឈ្មោះ Tammy Alayne Chales អាយុ ៤៩ ឆ្នាំដែលជាជនជាប់ចោទពាក់ព័ន្ធក្នុងសំណុំរឿងជួលស្ត្រីខ្មែរពពោះយកក្មេងទៅបរទេសកាលពីម្សិលមិញបានទទួលកំហុស និងសុំឲ្យបន្ធូរទោសនៅចំពោះមុខសវនាការជម្រះក្តីនៃសាលាឧទ្ធរណ៍ ដែលបានធ្វើឡើងក្រោយពីតុលាការថ្នាក់ក្រោមផ្តន្ទាទោសដាក់ពន្ធនាគារ ១ ឆ្នាំ ៦ ខែ។

មុនសវនាការចាប់ផ្តើម បើទោះបីជាមានការណែនាំពីលោកស្រី គឹម ដានី ប្រធានក្រុមប្រឹក្សាជំនុំជម្រះថាជនជាប់ចោទមានសិទ្ធិដឹងពីការចោទប្រកាន់ អាចសុំផ្លាស់ប្តូរសមាសភាពចៅក្រមប្រឹក្សាមានសិទ្ធិជ្រើសរើសមេធាវី និងមានសិទ្ធិឆ្លើយ ឬមិនឆ្លើយនៅពេលចៅក្រមសួរ តែជនជាប់ចោទមិនយកចិត្តទុកដាក់លើការណែនាំនោះទេ ដោយទុកឲ្យតុលាការបន្តនីតិវិធីតាមធម្មតា។ ជនជាប់ចោទថ្លែងថាៈ «សំណូមពររបស់ខ្ញុំទៅតុលាការគឺដោយសារគ្រូពេទ្យបានធ្វើលិខិតបញ្ជាក់អំពីបញ្ហាជំងឺមហារីកកោសិកាដល់ខ្ញុំ ដូច្នេះខ្ញុំសូមដល់តុលាការជួយកាត់បន្ថយទោសដល់ខ្ញុំផងដើម្បីឲ្យខ្ញុំឆាប់បានចេញពីមន្ទីរឃុំឃាំងទៅព្យាបាលជំងឺ»។

លោកព្រះរាជអាជ្ញា ជា ម៉េត តំណាងមហាអយ្យការបានសន្និដ្ឋានថាក្រោយពីបានស្តាប់ការសួរដេញដោលរបស់ក្រុមប្រឹក្សាជំនុំជម្រះ និងក្រោយពីពិនិត្យលើអង្គហេតុបានឲ្យដឹងថាជនជាប់ចោទបានសារភាពហើយឆ្លងតាមកំណត់ហេតុរបស់នគរបាលគឺជាបទល្មើសជាក់ស្តែង។ លោកព្រះរាជអាជ្ញាថ្លែងថាៈ «ការចោទប្រកាន់របស់សាលាដំបូងរាជធានីភ្នំពេញលើជនជាប់ចោទ និងបក្ខពួកគឺជាការសម្រេចត្រឹមត្រូវតាមច្បាប់ហើយ។ ដូច្នេះខ្ញុំសូមតម្កល់សាលក្រមទុកជាបានការដដែល»។

លោកស្រីចៅក្រម គឹម ដានី បានឲ្យដឹងតាមអង្គហេតុថាកាលពីអំឡុងឆ្នាំ ២០១៥-២០១៦ ស្ត្រីជាប់ចោទ Tammy- Alayne Chales បានមកប្រទេសកម្ពុជាហើយស្វែងរកស្ត្រីខ្មែរដើម្បីពពោះយកទារក និងបានទាក់ទងបុរសឈ្មោះ ពេជ្រ ឫទ្ធី និង ស្ត្រីឈ្មោះ សំរិទ្ធ ចរិយ៉ា ដើម្បីរកស្ត្រីខ្មែរឲ្យពពោះ។ អង្គហេតុបង្ហាញបន្តថាបន្ទាប់ពីជនទាំង ២ នាក់រកស្ត្រីខ្មែរបានក៏នាំទៅមន្ទីរសម្ភពដើម្បីចាក់មេជីវិតដែលស្ត្រីជាប់ចោទផ្តល់ប្រាក់ឲ្យថ្លៃសេវាចំនួន ៣០០ ដុល្លារ។ រីឯស្ត្រីជាអ្នកពពោះនោះគឺស្ត្រីជាប់ចោទផ្តល់ប្រាក់ឲ្យ ១ ម៉ឺនដុល្លារពេលទារកកើតមក។ ប៉ុន្តែត្រូវធ្វើសំបុត្រកំណើតហើយយកឯកសារពីបុរសបរទេសមកធ្វើជាឪពុក និងបញ្ជូនទារកនោះចេញទៅបរទេសតែម្តង។ ប៉ុន្តែរឿងនេះត្រូវ

នគរបាលប្រឆាំងការជួញដូរមនុស្សឃាត់ខ្លួនបុរសឈ្មោះ ពេជ្រ ឫទ្ធី ស្នាក់នៅសង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក និង ស្ត្រីឈ្មោះ សំរិទ្ធ ចរិយ៉ា អាយុ ៣០ ឆ្នាំ មុខរបរធ្មេបស្នាក់នៅសង្កាត់វាលវង់ ខណ្ឌ ៧ មករានៅថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០១៦។

សំណុំរឿងនេះត្រូវសាលាដំបូងរាជធានីភ្នំពេញប្រកាសសាលក្រមនៅថ្ងៃទី ៣ ខែសីហាឆ្នាំ ២០១៧ សម្រេចផ្ដន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារ ១ ឆ្នាំ ៦ ខែចោទបទ «អន្តរកាលរវាងអ្នកសុំកូន និងស្ត្រីពពោះ និងបទសុំឲ្យផ្ដល់ឯកសារទុច្ចរិត» និងពិន័យប្រាក់ ៤ លានរៀលចូលថវិការដ្ឋ។ ដោយឡែកជនជាប់ចោទខ្មែរ ២ នាក់ទៀតក៏ជាប់ដូចគ្នាជាចារីសមគំនិត។

មុនបញ្ចប់ជំនុំជម្រះលោកស្រីចៅក្រម គឹម ដានី បានថ្លែងថា សាលដីកានេះនឹងប្រកាសនៅថ្ងៃទី ៨ ខែមករាខាងមុខ។ បើតាមរបាយការណ៍នគរបាលបង្ហាញថា ករណីនេះមានស្ត្រីខ្មែរ ២៣ នាក់ហើយដែលត្រូវបានសមត្ថកិច្ចស្រាវជ្រាវរកឃើញទាក់ទងនឹងករណីគេឲ្យពពោះជំនួសក្នុងអាជីវកម្មខុសច្បាប់។ ក្នុងចំណោមស្ត្រីខ្មែរទាំង ២៣ នាក់នោះគេបង្កើតបានទារក ៥ នាក់ខណៈស្ត្រី ១៨ នាក់ទៀតកំពុងពពោះនៅឡើយ៕

## ថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៧
## អាជ្ញាធរខេត្តផ្សព្វផ្សាយច្បាប់អំពើជួញដូរមនុស្សដល់មន្ត្រី និងប្រជាពលរដ្ឋក្នុងខេត្ត

http://knv-info.com/ Kampuchea News and Views Thursday, December ថ្ងៃទី 28,ឆ្នាំ 2017, 8:34 am

ត្បូងឃ្មុំ៖ លោក ជំទាវ អភិបាលរងខេត្ត ជំរុញឱ្យមន្ត្រីក្រោមឱវាទ ត្រូវបង្កើនការយល់ដឹង បន្តការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងខេត្ត ពិសេសនៅមូលដ្ឋាន ដើម្បីបង្ការទប់ស្កាត់ ការធ្វើចំណាកស្រុក ដោយប្រថុយប្រថាន នាំឱ្យមានការជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ ដែលនាំឱ្យបង្កគ្រោះថ្នាក់កាន់តែច្រើនឡើងដល់ជីវិតមនុស្ស ដូច្នេះយើងទាំងអស់គ្នាត្រូវប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះឱ្យបានដាច់ខាត ថ្លែងនៅក្នុងសាលប្រជុំសាលាខេត្តត្បូងឃ្មុំនាព្រឹកថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ នេះ ។ លោក ជំទាវ ឡេង សុខា អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប. ជ បានថ្លែងថា ថ្ងៃនេះដែរ គណៈកម្មាធិការខេត្ត បានរៀបចំទិវាប្រយុទ្ធប្រឆាំងអំពើជួញដូរ នាឱកាសនេះគឺ ដើម្បីបង្កើនការយល់ដឹង នប្តការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋមូលដ្ឋាន ការបង្ការទប់ស្កាត់ ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន តាមរយៈមេខ្យល់ នាំឱ្យមានការជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ ។

អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គឺជាបរិបទសាកល ដែលនៅតែបន្តកើតមានអស្រ័យ កត្តាសំខាន់បី គឺការអប់រំសង្គម ការអនុវត្តច្បាប់ និងការធេក់ឱកាសពីជនល្មើស ។ រូបភាពនៃអំពើជួញដូរមនុស្ស មិនត្រឹមតែការជួញដូរ ឬការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងផ្លូវភេទប៉ុណ្ណោះទេ តែក្នុងឆ្នាំកន្លងទៅ ក៏មានលេចចេញ នូវបាតុភូតមួយចំនួន ដែលមានទមនោរទៅរកអំពើជួញដូរសរីរាង្គ និងបទល្មើសរត់ព័ន្ធ ឬជួញដូរទារកឆ្លងដែន ដែលហៅថា បទអន្តរការីនៃអំពើពពោះជំនួយ ។ នេះជាកង្វល់ដែលគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សចាំបាច់ត្រូវដាក់វិធានការស៊ើបអង្កេត ស្រាវជ្រាវ និងបង្ក្រាបឱ្យបានទាន់ពេល និងបានកសាងច្បាប់ បទដ្ឋានគតិយុត្តិពាក់ព័ន្ធបន្ថែមទៀតដើម្បីជៀសវាងការរីកដុះដាលនៃបទល្មើស ដែលនាំឱ្យបង្កគ្រោះថ្នាក់កាន់តែច្រើនឡើងដល់ជីវិតមនុស្ស ។

លោកជំទាវបានបន្តបញ្ជាក់ទៀតថា ការធ្វើទេសន្តប្រវេសន៍ដោយប្រថុយប្រថាន មិនមានការធានាផ្នែកច្បាប់ និងមិនមានការគ្រប់គ្រងច្បាស់លាស់ ដែលនាំឱ្យប្រឈមនឹងហានិភ័យដោយអំពើកេងប្រវ័ញ្ច និងជួញដូរមនុស្ស ។ ពលករទាំងនោះ ជារឿយៗ ត្រូវទទួលរងនឹងការកេងប្រវ័ញ្ចគ្រប់រូបភាពនៅគ្រប់ដំណាក់កាលក្នុងវដ្តនៃទេសន្តប្រវេសន៍ តាំងពីពេលចេញដំណើរ ការឆ្លងដែន រហូតដល់កន្លែងការងារ ដូច្នេះចាំបាច់ត្រូវពង្រឹងការគ្រង ដើម្បីលើកកម្ពស់សក្តានុពលនៃកម្លាំងពលកម្មទេសន្តប្រវេសន៍ដ៏ច្រើននេះ។ គណៈកម្មាធិការជាតិដាក់ចេញនូវប្រធានបទគោលដ៏សំខាន់មួយគឺ(រួមគ្នាពង្រឹងប្រព័ន្ធសុវត្ថិភាពនិងពង្រឹងការអនុវត្តច្បាប់ ដើម្បីការពារមនុស្សគ្រប់រូបភាពអំពើជួញដូរមនុស្ស) ដើម្បីជាយុទ្ធនាការដ៏ទូលាយផ្សព្វផ្សាយការយល់ដឹង និងអំពាវនាវចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ និងជនរួមជាតិគ្រប់ទិសទី ក្នុងសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទាំងអស់គ្នា៕

## នគរបាលឃាត់ខ្លួន បុរសជនជាតិអូស្ត្រាលីម្នាក់ដោយ បង្ខាំងស្ត្រីខ្មែរ៥នាក់ឲ្យរួមភេទ

http://peoplenews.asia/ ដោយ ៖ រិទ្ធី ថ្ងៃទី29 ខែ12 ឆ្នាំ2017 ម៉ោង 8:03 AM

**ព្រះសីហនុ៖** នៅយប់ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧ បុរសជនជាតិអូស្ត្រាលីម្នាក់ បង្ខាំងស្ត្រីជនជាតិខ្មែរ៥នាក់នៅក្នុងផ្ទះ ដោយបង្ខំឲ្យរួមភេទជាមួយទើបដោះលែង តែមិនបានសម្រេចក៏ត្រូវកម្លាំងនគរបាលខេត្តព្រះសីហនុ បង្ក្រាបបានទាន់ពេលនៅផ្ទះជួលស្ថិតក្នុងភូមិ២ សង្កាត់៣ ក្រុងព្រះសីហនុ។

ស្នងការនគរបាលខេត្តព្រះសីហនុ លោកឧត្តមសេនីយ៍ទោ ជួន ណារិន្ទ បានឲ្យដឹងថា នៅវេលាម៉ោង៩យប់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ កម្លាំងនគរបាលជំនាញរបស់លោក បានទទួលព័ត៌មានថា នៅផ្ទះជួលខាងលើមានករណីបង្ខាំងមនុស្ស។ បើតាមលោកឧត្តមសេនីយ៍ស្នងការ ក្រោយទទួលព័ត៌មានភ្លាមកម្លាំងការិយាល័យជំនាញ សហការជាមួយកម្លាំងមូលដ្ឋាន ចុះទៅដល់ផ្ទះកើតហេតុ ដោយធ្វើការសម្របសម្រួល ដោយឲ្យជនសង្ស័យជាជនជាតិអូស្ត្រាលី ឲ្យចាក់សោរបើកទ្វារផ្ទះ តែជនសង្ស័យពុំព្រមតាមការស្នើសុំរបស់សមត្ថកិច្ចឡើយ។ រហូតដល់ម៉ោង០១៖៣០នាទីឈានចូលថ្ងៃទី២៨ ខែធ្នូ ដោយមានការអនុញ្ញាតពីលោកស្រី ព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត ទើបកម្លាំងជំនាញបានសម្រេចកាត់សោរផ្ទះ នាំខ្លួនជនសង្ស័យម្នាក់ និងជនរងគ្រោះ៥នាក់ ស្រី៤នាក់ ក្នុងនោះក្មេង២នាក់ ស្រីម្នាក់ ប្រុសម្នាក់ ទៅកាន់ស្នងការដ្ឋាននគរបាលខេត្ត។ លោកឧត្តមសេនីយ៍ ជួន ណារិន្ទ បញ្ជាក់ទៀតថា ជនរងគ្រោះឈ្មោះ យូ គា អាយុ៣៨ឆ្នាំ បានអះអាងថា មិត្តប្រុសរបស់ខ្លួនជាជនជាតិអូស្ត្រាលី បានចាក់សោទ្វារផ្ទះបង្ខាំងរូបនាង ប្អូនស្រី កូន២នាក់ និងក្មួយស្រីរបស់នាងមិនឲ្យចេញពីផ្ទះ លុះត្រាតែប្អូនស្រី និងក្មួយស្រីរបស់នាងយល់ព្រមរួមភេទជាមួយជនសង្ស័យ ទើបបានចាក់សោរទ្វារផ្ទះបើកឲ្យចេញក្រៅ។

ដោយឡែកជនសង្ស័យឈ្មោះ KING JAMES BERNARD បានសារភាពថា ពិតជាបានចាក់សោរទ្វារផ្ទះមិនឲ្យជនរងគ្រោះខាងលើចេញពីផ្ទះ ដូចការចោទប្រកាន់ពីជនរងគ្រោះប្រាកដមែន។ បច្ចុប្បន្នជនសង្ស័យត្រូវបានកម្លាំងជំនាញឃាត់ខ្លួនបណ្ដោះអាសន្ន ដើម្បីបន្តតាមនីតិវិធី បញ្ជូនទៅសាលាដំបូងខេត្តចាត់ការតាមច្បាប់៕

## ពលករខ្មែររាប់រយនាក់ ចាប់ផ្តើមធ្វើដំណើរទៅលេងផ្ទះ តាមរយៈច្រកព្រំដែនបានឡែម

http://www.pheaktraprak.com December 28, 2017

កាលពីថ្ងៃព្រហស្បតិ៍ ទី២៨ ខែធ្នូ ឆ្នាំ២០១៧នេះ របាយការណ៍ពីរច្រកព្រំដែនអន្តរជាតិបានឡែម ស្រុកពោងណាមរ៉ន ខេត្តចាន់បុរី ប្រទេសថៃ បានអោយដឹងថា ពលករកម្ពុជាធ្វើការនៅក្នុងប្រទេសថៃ ចំនួនរាប់រយបានចាប់ផ្តើមធ្វើដំណើរវិលត្រឡប់ទៅលេងស្រុកកំណើត ដើម្បីជួបជុំបងប្អូននៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ឆ្នាំសកល២០១៨ខាងមុខនេះយ៉ាងច្រើនកុះករ។ តាមការបញ្ជាក់របស់អាជ្ញាធរថៃប្រចាំច្រកទ្វារព្រំដែនអន្តរជាតិឡែមអោយដងថា ចាប់តាំងពីម្សិលមិញដល់រហូតមកដល់ថ្ងៃនេះ គេសង្កេតឃើញមានពលករខ្មែរចំនួនរាប់រយនាក់ដែលធ្វើការនៅខេត្តផ្សេងនៅក្នុងប្រទេសថៃ បាននាំគ្នាធ្វើដំណើរចុះទៅលេងស្រុកកំណើតតាមរយៈច្រកព្រំដែនអន្តរជាតិបានឡែមនេះយ៉ាងច្រើនសន្ធឹកសន្ធាប់។

## ពលករខ្មែរ1នាក់ បើកជួលម៉ូតូបោកក្បាលស្លាប់ យ៉ាងអាណោចអាធ័ម

http://www.pheaktraprak.com December 29, 2017

ករណីពលករខ្មែរធ្វើការនៅក្នុងខេត្តសារ៉ាកបុរី ប្រទេសថៃ បើកម៉ូតូជួលបោកក្បាលស្លាប់ភ្លាមនៅកន្លែងកើតហេតុ យ៉ាងអាណោចអាធ័ម កាលពីវេលាម៉ោង១០:៣០យប់ ថ្ងៃពុធ ទី២៧ ខែធ្នូ ឆ្នាំ២០១៧ មានករណីពលករខ្មែរ១នាក់ ឈ្មោះ គ្រុយសុខហ៊ីង ភេទប្រុសអាយុ១៨ ឆ្នាំ រស់នៅភូមិកំពុងឈើទាល ឃុំក្រាំងការសៅ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ បានរងគ្រោះថ្នាក់ដោយឧបទ្ទវហេតុដោយសារបើកម៉ូតូជួលបុករបងបណ្ដាលអោយបោកក្បាលស្លាប់ភ្លាមនៅនឹងកន្លែងកើតហេតុ ករណីនេះបានកើតឡើងនៅភូមិ៥ ឃុំណងប៉ាឡៃ ស្រុកមឿង ខេត្តសារ៉ាកបុរី ប្រទេសថៃ ។ បច្ចុប្បន្នសាកសពជនរងគ្រោះត្រូវសមត្ថកិច្ចថៃបញ្ជូនយកទៅរក្សាទុកនៅមន្ទីរពេទ្យ ស្រុកមឿង ខេត្តសារ៉ាកបុរី ដើម្បីរង់ចាំប្រគល់ជូនសាច់ញាតិអោយយកទៅធ្វើបុណ្យតាមប្រពៃណី។